2831

BIBLIOTHÈQUE NATIONALE DU CAMBODGE 1818

២

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

ពុទ្ធសាសនបណ្ឌិត្យ
INSTITUT BOUDDHIQUE

ឆ្នាំទី ៣៩ ខែ កុម្ភៈ

ព.ស. ២៥០៩ គ.ស. ១៩៦៧

– ភ្នំពេញ –

215

BIBLIOTHEQUE NATIONALE DU CAMBODGE
P.K. 1
1967 - ៤
BIBLIOTHEQUE NATIONALE DU CAMBODGE

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ
ចេញរាល់ខែ ពីពុទ្ធសាសនបណ្ឌិត្យ

## បញ្ជីរឿង

ផ្នែកសាសនា — ទំព័រ

១- បញ្ហាព្យាករណ៍ពីពុទ្ធសាសនា លោក សម-ថាំង ប្រែ-រៀបរៀង (ត) . . . ១០៩
២- អានិសង្សសីល លោក ប៊ូ-ប៊ូ ដកស្រង់-រៀបរៀង . . . . . . . . . . ១១៩
៣- ព្រះត្រៃលក្ខណ៍ លោក ព្រួច-ភុម ស្រាវជ្រាវ-ដកស្រង់ . . . . . . ១២៦

ផ្នែកអក្សរសាស្ត្រ

៤- ប្រវត្តិសម្ដេចព្រះធម្មលិខិត ល្វី-ឯម សាស្ត្រាចារ្យ ឈឹម-ស៊ុម រៀបរៀង (ត-ចប់) . ១៣៤
៥- វចនានុក្រម សំស្ក្រឹត-ខ្មែរ ព្រះមហា ជាំង-ខាត់ រៀបរៀង (ត) . . . . . ១៤៧
៦- ពិចារណាដើម្បីយល់តក្កវិជ្ជា លោក ហ៊ុន-គឹមសៀ រៀបរៀង (ត) . . . ១៥១
៧- ព្រះរាជនិពន្ធរាមកេរ្តិ៍ លោក ឌ. គាម ស្រាវជ្រាវ (ត) . . . . . . ១៥៩
៨- ឯកសារ សាស្ត្រាស្លឹករឹតនិងក្រាំង លោក ញ៉ុក-ថែម រៀបរៀង (ត) . . . . . ១៧៤
៩- រឿងសាមកុក អ្នកឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង (ត) . . . . . ១៧៨
១០ ឯកសារកម្ពុជសុរិយា លោក ឌ.គាម ប្រមូលរៀបរៀង (ត) . . . . . . . ១៨៦
១១- អត្ថបទផ្នែកទំនៀមទម្លាប់ រឿងព្រេងនៅក្នុងឃុំស៊ីធរ លោក គឹម-ហ៊ុយ រៀបរៀង . ១៩៤
១២- ជីវប្រវត្តិរបស់ខ្ញុំ ឈ្មោះ អៀង-សាយ (ត) . . . . . . . . . . . ២០៣

ផ្នែកកំណត់និងប្រវត្តិការណ៍

១៣- សេចក្ដីរាយការណ៍ អំពីសកម្មភាពពុទ្ធសាសនបណ្ឌិត្យ ៣ត្រីមាស (ត-ចប់) . . ២១១

មួយឆ្នាំមាន ១២ សៀវភៅ តម្លៃជាវ ២៣០រ០០ ។

## ផ្នែកសាសនា

ពាក្យឃាត់មិនឲ្យ ធ្វើការអាក្រក់
ជាការលាមក, ឲ្យធ្វើល្អទៅ,
ឲ្យជុំរសាតចិត្ត កុំឲ្យហ្មងសៅ,
បីនេះលោកហៅ ពុទ្ធសាសនា ។

ក.ត.

# បញ្ហាព្យាករណ៍ពីពុទ្ធសាសនា

( ត )

លោក សម-ថាំង ប្រែ - រៀបរៀង

បុ. ទេវទូតទាំង៤នេះ គឺអ្វីខ្លះ ?

វិ. គឺមនុស្សចាស់, មនុស្សឈឺ, មនុស្សស្លាប់ និងអ្នកបួស ។

បុ. ទ្រង់បានឃើញទេវទូតទាំង៤នេះ តែមួយព្រះអង្គឯងទេឬអ្វី ?

វិ. ទេ, នាយឆន្នអាមាត្យបានឃើញដែរ ។

បុ. បើទ្រង់គ្រាន់តែឃើញហេតុជាធម្មតាយ៉ាងនេះទេ ម្ដេចឡើយក៏បណ្ដាលឲ្យព្រះអង្គ ស្ដេចចេញចាកព្រះនគរ ចូលទៅគង់នៅក្នុងអរញ្ញប្រទេសកើត ?

វិ. យើងរាល់គ្នា ធ្លាប់បានឃើញរឿយ ៗ ពិតមែនហើយ ប៉ុន្តែចំណែកខាងព្រះអង្គ ទ្រង់ពុំធ្លាប់បានឃើញដូចយើងទេ ព្រោះហេតុនេះហើយបានជា ព្រះអង្គមានព្រះទ័យតក់ស្លុតជាពន្លឹកយ៉ាងនោះឯង ។

បុ. ហេតុដូចម្ដេចបានជា ក្នុងពេលមុន ទ្រង់ពុំបានជួបប្រទះជ្រាបហេតុដូច្នេះសោះ ?

វិ. ព្រាហ្មណ៍ជាហោរា បានទាយតាំងពីកាលដែលព្រះអង្គទើបនឹងប្រសូតមកថា ទ្រង់មុខជានឹងលះបង់រាជសម្បត្តិ ហើយនឹងបានត្រាស់ជាព្រះពុទ្ធ មួយព្រះអង្គនោះ ព្រះវររាជបិតា ទ្រង់ពុំមានព្រះរាជបំណងចង់ឲ្យព្រះរាជបុត្រឃ្លាតឆ្ងាយចាកព្រះអង្គ ទើបទ្រង់ហាមប្រាមយ៉ាងដាច់ខាតមិនឲ្យនរណាមួយធ្វើឲ្យព្រះរាជទរស ជ្រាបអំពីទុក្ខលំបាករបស់មនុស្ស និងសេចក្ដីស្លាប់ឡើយ ។ នរណាមួយ ក៏មិនត្រូវនាំរឿងហេតុទាំងនេះមកថ្វាយទូល ឲ្យល្អក់ព្រះហឫទ័យបន្តិចបន្តួចឡើយ ។ ព្រះពោធិសត្វក៏ហាក់ដូចជាត្រូវគេឃុំឃាំង ឲ្យគង់នៅក្នុងប្រាសាទដ៏ល្អវិចិត្រ ដែលមានសួនឧទ្យានដ៏ដេរដាស ដោយបុប្ផជាតិផ្កាយក្លិនពិដោរឈ្ងុយឈ្ងប់ សឹងដ៏ពន្លេដោយកំពែងខ្ពស់ស្កឹមស្កៃ ផ្ទៃខាងក្នុងសោតសឹងប្រដាប់ដោយគ្រឿងលំអគ្រប់យ៉ាង ព្រោះគ្រាតែព្រះអង្គពុំមានឱកាសទតមើលយល់ នូវទុក្ខលំបាកក្នុងលោកនេះបានសោះឡើយ ។

បុ. បើដូច្នេះ មកពីទ្រង់មានព្រះហឫទ័យ ប្រកបដោយករុណាទិគុណយ៉ាងនេះហើយឬ ទើបព្រះវររាជបិតាទ្រង់ព្រួយបារម្ភខ្លាំងណាស់?

វិ. យ៉ាងហ្នឹងមែនហើយ, ព្រះបរមពោធិសត្វ ហាក់ដូចជាមានព្រះហឫទ័យប្រកបដោយមេត្តា និង ករុណា ចំពោះសត្វលោកយ៉ាងទូលំទូលាយណាស់ ។

ប្រ. ដោយហេតុដូចម្តេចបានជា ព្រះអង្គសង្ឃឹមថា នឹងរកឃើញនូវហេតុនៃសេចក្តីទុក្ខក្នុងអារញ្ញប្រទេសនោះ ?

វិ. ដោយហេតុថា ទ្រង់បានចេញឆ្ងាយ អំពីរបស់ដែលជាទំនាស់ក្នុងការរំពឹងពិចារណារកហេតុនៃទុក្ខ និងដើមកំណើតសង្ខារ ។

ប្រ. ទ្រង់យាងចេញអំពីព្រះបរមរាជវាំងទៅដោយប្រការដូចម្តេច ?

វិ. រាត្រីមួយ នៅពេលដែលអ្នកទាំងពួងកំពុងនិទ្រាលក់ស្កប់ស្កល់ ព្រះបរមពោធិសត្វទ្រង់តើនចាកទីសយនាគ្រឡាព្រះបន្ទំ ហើយទៀងព្រះនេត្រទតព្រះរាជទេពី និងព្រះរាជឱរសដែលកំពុងផ្ទំលក់ ក៏ត្រាស់ហៅនាយឆន្នអាមាត្យ ឲ្យនាំយកសេះសេតសញ្ជាតិឈ្មោះកណ្ឋកៈ ហើយទ្រង់យាងចេញតាមទ្វារព្រះរាជវាំង; កាលនោះ ពួកទេវតាបានសណ្តំអស់ទាំងអ្នកយាមទ្វារ ឲ្យនៅលក់ស៊ប់ មិនឲ្យដឹងស្មារតី ទាល់តែគ្មាននរណាមួយឮស្នូរសព្ទជើងសេះ បន្តិចបន្តួចឡើយ ។

ប្រ. ចុះទ្វារព្រះរាជវាំងក្នុងពេលនោះ មិនបានបិទចាក់សោទេ ឬ ?

វិ. ទ្វារបិទជិត ប៉ុន្តែទេវតាបើកមិនឲ្យឮសូរសន្ធឹកសោះ រួចហើយ ព្រះអង្គក៏យាងផុតចេញទៅ ក្នុងរាត្រីនោះ ។

ប្រ. ទ្រង់យាងទៅកាន់ទីណា ?

វិ. ទៅកាន់ស្ទឹងអនោមា ឆ្ងាយដាច់ស្រយាលពីក្រុងកបិលពស្តុ

ប្រ. ដល់ហើយ ទ្រង់ធ្វើដូចម្តេច ?

វិ. ទ្រង់យាងចុះពីលើខ្នងនៃកណ្ឋកៈអស្សតរ កាត់ព្រះកេសា ដោយព្រះខាន់ពេជ្រ ហើយព្រះរាជទានគ្រឿងអលង្ការ ព្រមទាំងព្រះទីនាំង ទៅនាយឆន្ន ឲ្យនាំយកទៅថ្វាយព្រះវររាជបិតាវិញ ។

បុ. ក្រោយមក ទ្រង់ធ្វើដូចម្តេចទៀត ?

វិ. ទ្រង់យាងដោយព្រះបាទទទេ ទៅកាន់នគររាជគ្រឹះ ដែលជារាជធានីរបស់ព្រះបាទពិម្ពិសារ ព្រះចៅដែនមគធៈ ។

បុ. ទ្រង់យាងទៅជួបនឹងនរណា ?

វិ. ទ្រង់បានជួបនឹងព្រះបាទពិម្ពិសារ ដែលកំពុងគង់នៅក្នុងទីប្រជុំនៃនាម៉ឺនសព្វមុខមន្ត្រី ។

បុ. ហេតុដូចម្តេច ក៏ទ្រង់យាងមកកាន់ទីនេះ ?

វិ. ព្រោះនៅក្នុងព្រៃជិតនេះ មានតាបសឫសី ជាអ្នកចេះដឹងច្រើន ទ្រង់ធ្វើជាសិស្សសាវ័ក ដោយមានព្រះរាជបំណងថា មុខជានឹងបានប្រទះឃើញនូវសម្មាសម្ពោធិញ្ញាណ ដែលព្រះអង្គស្វែងរកពុំបាន ។

បុ. ពួកតាបសទាំងនេះ កាន់សាសនាអ្វី ?

វិ. កាន់សាសនាវិស្ណុ ( សាសនាព្រាហ្មណ៍ ) ព្រោះសុទ្ធតែជាពួកព្រាហ្មណ៍ ។

បុ. ពួកអាចារ្យទាំងនេះ បានបង្រៀនអ្វីខ្លះ ?

វិ. បានបង្រៀនប្រដៅព្រះអង្គ ឲ្យកាន់ក្រឹត្យវិន័យយ៉ាងតឹងរ៉ឹង

ឲ្យព្យាយាមធ្វើបាបខ្លួនឯង ឲ្យបានសេចក្ដីលំបាក ដែលជាអត្តកិលមថា-នុយោគ ដែលគេយល់ថាជាផ្លូវនាំឲ្យបានសំរេចមគ្គផល ។

ប្រ. ចុះទ្រង់យល់ឃើញផ្លូវនេះដែរឬអ្វី ?

វិ. ទេ, ទ្រង់ខំប្រឹងរៀនអំពីសំណាក់តាបសទាំងនោះ បានសព្វគ្រប់ ទ្រង់ខំប្រឹងបំពេញវត្តចេះចាំចប់ ដោយសេចក្ដីព្យាយាមយ៉ាងលំបាកហើយ ក៏ពុំឃើញហេតុនៃសេចក្ដីទុក្ខនិងផ្លូវទៅកាន់ទីរំលត់ទុក្ខសោះឡើយ ។

ប្រ. បើយ៉ាងនេះ តើទ្រង់ត្រឡប់ធ្វើដូចម្ដេចវិញ ?

វិ. ទ្រង់យាងចេញទៅគង់ក្នុងព្រៃទៀបកន្លែងមួយ ឈ្មោះឧរុវេលា គឺត្រង់កន្លែងដែលសព្វថ្ងៃហៅថា "មហាពោធិ" ក្នុងដែនពុទ្ធគយា ហើយទ្រង់គង់ស្ងៀមស្ងាត់ បំពេញទុក្ករកិរិយាយ៉ាងតឹងតែង ទៀយលំបាកព្រះកាយពល នៅទីនោះ អស់ ៦ វស្សា ។

ប្រ. ទ្រង់គង់នៅទីនោះ តែមួយព្រះអង្គឯងទេឬ ?

វិ. ទេ, មានព្រាហ្មណ៍ ៥ នាក់ បានតាមទៅនៅកំដរដែរ ។

ប្រ. ព្រាហ្មណ៍ ៥ នាក់នោះ មាននាមដូចម្ដេចខ្លះ ?

វិ. កោណ្ឌញ្ញ ភទ្ទិយ វប្ប មហានាម អស្សជិ ។

ប្រ. ទ្រង់ប្រព្រឹត្តដូចម្ដេចខ្លះ ដែលនាំឲ្យព្រះហឫទ័យរបស់ព្រះអង្គបានដល់នូវមោក្ខធម៌ ?

វិ. ទ្រង់គង់ពត់ព្រះភ្នែនពែនព្រះបាទតម្រង់ព្រះទ័យ នឹករឭកដល់

ជីវិតសង្ខារ ហើយទ្រង់ធ្មេចព្រះនេត្រ និងសង្រួមព្រះស្រោត មិនឲ្យអារម្មណ៍ដទៃ មកប៉ះពាល់រំជួលព្រះហឫទ័យព្រះអង្គឡើយ ។

ប្ុ. ព្រះអង្គទ្រង់អត់អាហារបិណ្ឌបាតឬទេ ?

វិ. មែន, គ្រប់ៗ ពេល ទ្រង់ចេះតែបន្ថយចង្ហាន់និងទឹក ដរាបដល់នៅត្រឹមតែបាយឬល្ងមួយគ្រាប់ប៉ុណ្ណោះ ក្នុងមួយថ្ងៃ ។

ប្ុ. ដែលប្រតិបត្តិដូច្នេះ តើទ្រង់បានសម្រេចគុណធម៌ដ៏វិសេស ដូចបំណងឬទេ ?

វិ. ទេ, មានតែថយព្រះកាយពលចុះទៅដរាបជាលំដាប់ ទាល់តែថ្ងៃមួយ នៅពេលដែលទ្រង់កំពុងចង្ក្រមចំរើនមេត្តាភាវនា ទ្រង់អស់កំឡាំងដួលលើពសុធា បាត់ព្រះស្មារតី ។

ប្ុ. ចុះពួកព្រាហ្មណ៍ទាំងនោះ យល់ឃើញដូចម្ដេចទៅ ?

វិ. យល់ឃើញថា ទ្រង់ទិវង្គតហើយ ប៉ុន្តែលុះយូរបន្តិចទៅ ទ្រង់ក៏ស្រាប់តែមានព្រះស្មារតីឡើងវិញ ។

ប្ុ. ក្នុងខណៈនោះ មានហេតុអ្វីទៅទៀត ?

វិ. ទ្រង់រំពឹងពិចារណាទៅឃើញថា សម្មាសម្ពោធិញ្ញាណ ពុំមែនកើតឡើងដោយការបង្អត់អាហារ និងការធ្វើបាបខ្លួនប្រាណឲ្យនឿយលំបាកនោះឡើយ ។ គុណធម៌នេះ នឹងសំរេចបានមកតែអំពីមនោទ្វារ, ដោយទ្រង់ស្ទើរតែនឹងដល់នូវមរណកាល ព្រោះខ្សោយព្រះកាយពល

ហើយនៅតែពុំបានសំរេចមគ្គផលអ្វីនោះ ទើបទ្រង់បែរមកទទួលអាហារបិណ្ឌបាតវិញ ដើម្បីឲ្យមានព្រះជន្មាយុនៅបានយូរ ប្រយោជន៍ឲ្យបានដល់ផ្លូវត្រាស់ដឹង ។

បុ. ឈ្មោះណាដែលបានថ្វាយចង្ហាន់ទ្រង់ ?

វិ. ព្រះអង្គបានទទួលចង្ហាន់ ពីនាងសុជាតាជាកូនគហបតី ដោយនាងនេះឃើញទ្រង់ផ្ទុំសន្ធឹង នៅក្រោមនិគ្រោធមួយដើម លុះទ្រង់បានឆាន់ចង្ហាន់ហើយ ក៏មានព្រះកាយពលដូចប្រក្រតី ទ្រង់ក្រោកចាកទីនោះកាន់យកបាត្រ ចុះស្រង់គង្គាក្នុងស្ទឹងនេរញ្ជរា ទើបឆាន់ចង្ហាន់រួចហើយចូលទៅក្នុងព្រៃ ។

បុ. ទ្រង់ធ្វើអ្វី នៅទីនោះ ?

វិ. ក្រោយដែលទ្រង់បានពិចារណា និងប្តេជ្ញាហើយ ពេលល្ងាចទ្រង់យាងតម្រង់ទៅកាន់ដើមពោធិ៍ ឬ អស្សត្ថព្រឹក្ស ត្រង់កន្លែងដែលជាទីតាំងនៃមហាពោធិវិហារ ក្នុងកាលឥឡូវនេះ ។

បុ. ហើយតទៅទៀត ?

វិ. ទ្រង់ប្តេជ្ញាថា បើពុំបានត្រាស់ដឹងជាព្រះពុទ្ធទេ ក៏ទ្រង់ពុំព្រមយាងចេញចាកទីនោះដែរ ។

បុ. ទ្រង់គង់នៅនាគល់ឈើនោះ បែរព្រះភក្ត្រទៅទិសណា ?

វិ. ឆ្ពោះព្រះភក្ត្រទៅទិសបូព៌ា ។

ប្រ. រាត្រីជាដំបូងទ្រង់បានអ្វីខ្លះ ?

ឆ្លើយ. ទ្រង់រឭកឃើញជាតិកំណើតរបស់ព្រះអង្គក្នុងអតីតជាតិ ដែលអន្ទោលទៅមកក្នុងវដ្តសង្សារ (បុព្វេនិវាសានុស្សតិញាណ) ហេតុដែលនាំសត្វឲ្យប្រែទៅចាប់បដិសន្ធិ ( ចុតូបបាតញាណ ) និងផ្លូវជាទីរំលត់នូវសេចក្តីប្រាថ្នា ( អាសវក្ខយញាណ ) នៅពេលទៀបភ្លឺ ប្រាជ្ញាញាណរបស់ទ្រង់សឹងបើកចំហពេញបន្ទុក ប៉ីដូចជាផ្កាបុណ្ឌរីក ដែលរីក ។ ពន្លឺរស្មីរបស់ផ្កាជាន់ខ្ពស់ ឬ អរិយសច្ចទាំង ៤ សឹងមានដល់ព្រះអង្គ ។ ទ្រង់បានជាព្រះពុទ្ធ ១ ព្រះអង្គ ត្រាស់ដឹងក្នុងលោក មានព្រះនាមថា សព្វញ្ញូ ឬ សពិជ្ញ ។

ប្រ. ទ្រង់រកឃើញហេតុនៃកងទុក្ខ របស់សត្វលោកឬទេ ?

ឆ្លើយ. រកឃើញហើយ ប៉ីដូចពន្លឺព្រះអាទិត្យ ដែលទើបនឹងរះកំចាត់បង់នូវងងឹតឲ្យថយឆ្ងាយ ។ បណ្តាលឲ្យមើលឃើញ ដើមឈើ ស្រែចម្ការ ថ្ម សិលា សមុទ្រ ស្ទឹង សត្វពាហនៈ មនុស្ស និង វត្ថុផ្សេងៗ យ៉ាងណា ប្រាជ្ញាកើតមានក្នុងហឫទ័យរបស់ព្រះអង្គ នាំឲ្យទ្រង់ឃើញកងទុក្ខរបស់មនុស្សសត្វ និងឧបាយ ដែលនាំចេញចាកទុក្ខបាន ក៏យ៉ាងនោះដែរ ។

ប្រ. ដើម្បីបានដល់នូវសព្វញ្ញុតញ្ញាណនោះ ត្រូវប្រកបដោយសេចក្តីប្រឹងប្រែងព្យាយាមយ៉ាងដូចម្តេច ?

វិ. យ៉ាងហ្នឹងហើយ, គ្រូប្រកបដោយការប្រឹងប្រែង និងព្យា-
យាមយ៉ាងអស្ចារ្យ, ទ្រង់បានផ្ចាញ់នូវអំពើដ៏លាមកទាំងឡាយ ដែល
មានក្នុងព្រះអង្គ កំចាត់បង់នូវតម្រេកនិងសេចក្តីប្រាថ្នា គឺអវិជ្ជាដែល
ជាគ្រឿងរាំងមិនឲ្យឃើញនូវសច្ចធម៌ ។ ព្រះអង្គផ្ចាញ់ហេតុទាំងឡាយ
ដ៏លាមក ដែលបិទបាំងធម៌នេះ ដូចកលសេនាទាហាន ដែលតយុទ្ធ
ដោយអស់សង្ឃឹម ក្នុងចំណោមពួកខ្មាំងជាច្រើន ។ ទ្រង់ខំប្រឹងច្បាំង
និងសត្រូវដោយមុតមាំ ដូចជាអ្នកចម្បាំងមានថ្វីដៃ ហើយបានសំរេច
ដូចបំណង ដោយទ្រង់បានជួបប្រទះ ជ្រាបច្បាស់ នូវទុក្ខវេទនារបស់
មនុស្សជាតិ ក្នុងព្រះហឫទ័យ ។

បុ. វិជ្ជាដែលបានមកយ៉ាងនេះហើយព្រះអង្គយកទៅប្រើដូចម្តេចខ្លះ?

វិ. មុនដំបូងព្រះអង្គអត់ទ្រាំពុំទាន់សំដែងប្រាប់មនុស្សណាឡើយ ។

បុ. ហេតុដូចម្តេច ?

វិ. ព្រោះព្រះធម៌មានអត្ថដ៏ធំទូលាយ និងគម្ពីរភាពជ្រាលជ្រៅ
ណាស់ ទ្រង់ខ្លាចក្រែងមនុស្សជាច្រើន មិនយល់ច្បាស់ ហើយការ
សំដែងនោះ នឹងទៅជានាំបណ្តាលឲ្យខូចសតិញ្ញាណ របស់មនុស្ស
ទៅវិញ ។

បុ. ចុះនរណាដែលនាំឲ្យទ្រង់ប្រែព្រះយោបល់នេះទៅវិញ ?

វិ. ព្រះអង្គទ្រង់ជ្រាបច្បាស់ថាជាករណីយកិច្ចរបស់ទ្រង់ត្រូវសំដែង

ប្រដៅធម៌ដែលទ្រង់បានជ្រាបហើយ ដោយគ្រោះក្បាយឆាយ ៗ ល្មមឲ្យសត្វលោកស្តាប់យល់បាន ឥតមានសេចក្តីសន្ទិះសង្ស័យតាមនិស្ស័យរបស់សត្វនីមួយ ៗ ព្រះធម៌នេះជាគន្លងមួយ នាំឲ្យរលាស់ខ្លួនចេញចាកទុក្ខ ដែលសត្វនីមួយ ៗ គប្បីឃើញច្បាស់ដោយខ្លួនឯងបាន ។ ហេតុដូច្នេះ បានជាព្រះអង្គទ្រង់ព្រះយោបល់ថា ត្រូវសំដែងធម៌ដល់ពួកបញ្ចវគ្គិយ ដែលតែងបោលព្រះអង្គ កាលដែលលះបង់វិធីបង្អត់អាហារបិណ្ឌបាតនោះ ។

ប្ញ. ព្រះអង្គជួបនឹងពួកបញ្ចវគ្គិយនៅទីណា ?

វិ. ជួបក្នុងព្រៃម្រឹគ ឈ្មោះឥសិបតនៈ ជិតក្រុងពារាណសី ។

ប្ញ. កន្លែងនេះ សព្វថ្ងៃគេស្គាល់ឬទេ ?

វិ. ស្គាល់, មានស្តូបបាក់បែកមួយនៅទីនោះ ។

ប្ញ. ចុះពួកបញ្ចវគ្គិយទាំងនោះ ប្រុងស្តាប់ព្រះអង្គ ដោយពេញចិត្តឬទេ ?

វិ. មុនដំបូង មិនបានប្រុងស្តាប់ដោយពេញចិត្តទេ ក៏ប៉ុន្តែដោយអំណាចទឹកព្រះហឫទ័យរបស់ព្រះអង្គដ៏ល្អស្អាត ព្រមទាំងព្រះសទ្ធម្មទេសនា ដែលទ្រង់សំដែងចេញទៅ ក៏ពីរោះគ្រោះក្បាយគួរប្រតិបត្តិតាមផងនោះ ពួកបញ្ចវគ្គិយ ក៏ត្រឡប់ជាលះបង់មានះក្អាម ហើយទំប្រុងស្តាប់ដោយគោរពយ៉ាងក្រៃលែង ។ (នៅមានត)

# អានិសង្សសីល

( សុត្តន្តបិដក អង្គុត្តរនិកាយ ឯកាទសកនិបាត និស្សយវគ្គទី ១
ព្រះត្រៃបិដកបាលី–ខ្មែរ លេខ ៥១ ទំព័រ ២២៣... )

លោក ប៊ូ-ប៉ូ ដកស្រង់–រៀបរៀង

សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពនរបស់ អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះ ព្រះអានន្ទមានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ ក្រាបថ្វាយបង្គំហើយទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន សីលទាំងឡាយជាកុសល មានអ្វីជាប្រយោជន៍ ជាអានិសង្ស ?

ព្រះអង្គទ្រង់ត្រាស់ថា ម្នាលអានន្ទ សីលទាំងឡាយជាកុសល មានអវិប្បដិសារៈ គឺសេចក្តីមិនក្តៅក្រហាយ ជាប្រយោជន៍ ជាអានិសង្ស ។

អា.– ចុះអវិប្បដិសារៈនោះ តើមានអ្វីជាប្រយោជន៍ ជាអានិសង្ស?

ព្រះ.– អវិប្បដិសារៈនោះ មានបាមុជ្ជៈ គឺសេចក្តីរីករាយទន់ ជាប្រយោជន៍ ជាអានិសង្ស ។

អា. – ចុះបាមុជ្ជៈនោះ តើមានអ្វីជាប្រយោជន៍ ជាអានិសង្ស ?

ព្រះ. - បាមុជ្ជៈ មានបីតិ គឺសេចក្តីរីករាយខ្លាំង ជាប្រយោជន៍ ជាអានិសង្ស ។

អា.- ចុះបីតិនោះ តើមានអ្វីជាប្រយោជន៍ ជាអានិសង្ស ?

ព្រះ.- បីតិ មានបស្សទ្ធិ គឺសេចក្ដីស្ងប់រម្ងាប់ ជាប្រយោជន៍ ជាអានិសង្ស ។

អា.- ចុះបស្សទ្ធិនោះ តើមានអ្វីជាប្រយោជន៍ ជាអានិសង្ស ?

ព្រះ.- បស្សទ្ធិ មានសុខៈ គឺសេចក្ដីសុខ ជាប្រយោជន៍ ជាអានិសង្ស ។

អា.- ចុះសុខៈនោះ តើមានអ្វីជាប្រយោជន៍ ជាអានិសង្ស ?

ព្រះ.- សុខៈ មានសមាធិ គឺការតាំងចិត្តមាំ ជាប្រយោជន៍ ជាអានិសង្ស ។

អា.- ចុះសមាធិនោះ តើមានអ្វីជាប្រយោជន៍ ជាអានិសង្ស ?

ព្រះ.- សមាធិ មានយថាភូតញ្ញាណទស្សនៈ គឺការឃើញនូវសច្ចៈ ៤ ដោយញាណតាមពិត ជាប្រយោជន៍ ជាអានិសង្ស ។

អា.- ចុះយថាភូតញ្ញាណទស្សនៈនោះ តើមានអ្វីជាប្រយោជន៍ ជាអានិសង្ស ?

ព្រះ.- យថាភូតញ្ញាណទស្សនៈ មាននិព្វិទា គឺសេចក្ដីនឿយណាយ ជាប្រយោជន៍ ជាអានិសង្ស ។

អា.- ចុះនិព្វិទានោះ តើមានអ្វីជាប្រយោជន៍ ជាអានិសង្ស ?

ព្រះ.- និព្វិទា មានវិរាគៈ គឺការប្រាសចាកតម្រេក ឬ

ជាការគ្មានសេចក្ដីត្រេកអរ ជាប្រយោជន៍ ជាអានិសង្ស ។

អា.– ចុះវិរាគៈនោះ តើមានអ្វីជាប្រយោជន៍ ជាអានិសង្ស ?

ព្រះ.– វិរាគៈ មានវិមុត្តិញ្ញាណទស្សនៈ គឺបច្ចវេក្ខណញ្ញាណ ការពិចារណាឡើងវិញច្បាស់ នូវទីកើតនិងទីរលត់សង្ខារ ជាប្រយោជន៍ ជាអានិសង្ស ។

ម្នាលអានន្ទ ! សីលទាំងឡាយជាកុសល តែងកើតមានបរិបូណ៌ ដើម្បីឲ្យបានសម្រេចព្រះអរហត្តតាមលំដាប់ ដោយប្រការដូច្នេះឯង ។

កាលព្រះពុទ្ធជាម្ចាស់ ទ្រង់ត្រាស់ដោះស្រាយប្រស្នា របស់ព្រះអានន្ទត្ថេរចប់ហើយ ព្រះអង្គទ្រង់ត្រាស់ពន្យល់តទៅទៀតថា ៖

ម្នាលភិក្ខុទាំងឡាយ ! បុគ្គលអ្នកមានសីលពេញបរិបូណ៌ហើយ មិនចាំបាច់នឹកឲ្យនឹងចង់បានអវិប្បដិសារៈទេ ទៀងតែបានអវិប្បដិសារៈជាមិនខាន ។

អ្នកដែលបានអវិប្បដិសារៈហើយ មិនបាច់នឹកឲ្យនឹងចង់បានបាមុជ្ជៈទេ ទៀងតែបានបាមុជ្ជៈជាមិនខាន ។

អ្នកដែលបានបាមុជ្ជៈហើយ មិនចាំបាច់នឹកឲ្យនឹងចង់បានបីតិទេ ទៀងតែបានបីតិជាមិនខាន ។

អ្នកបានបីតិហើយ . . . ទៀងតែបានបស្សទ្ធិជាមិនខាន ។

អ្នកបានបស្សទ្ធិហើយ . . . ទៀតតែបានសុខៈជាមិនខាន ។

អ្នកបានសុខៈហើយ . . . ទៀតតែបានសមាធិជាមិនខាន ។

អ្នកបានសមាធិហើយ . . . ទៀតតែបានយថាភូតញាណទស្សនៈ ជាមិនខាន ។

អ្នកបានយថាភូតញាណទស្សនៈហើយ . . . ទៀតតែបាន និព្វិទាជាមិនខាន ។

អ្នកបាននិព្វិទាហើយ . . . ទៀតតែបានវិរាគៈជាមិនខាន ។

អ្នកបានវិរាគៈហើយ . . . ទៀតតែបានវិមុត្តិញាណទស្សនៈ ជាមិនខាន ។

កាលព្រះបរមគ្រូ ទ្រង់ពន្យល់អំពីអានិសង្សសីលបណ្តាយគ្នាតាមលំដាប់ ចាប់តាំងពីអវិប្បដិសារៈជាខាងដើម រហូតទល់វិមុត្តិញាណទស្សនៈជាទីបំផុត ចប់ហើយ ទើបទ្រង់ពន្យល់ អំពីអានិសង្សសីល ចាប់ពីខាងចុងត្រាសឡើងទៅខាងដើមវិញថា :

ម្នាលភិក្ខុទាំងឡាយ ! វិរាគៈ មានវិមុត្តិញាណទស្សនៈ ជាប្រយោជន៍ ជាអានិសង្ស ។

និព្វិទា មានវិរាគៈ ជាប្រយោជន៍ ជាអានិសង្ស ។

យថាភូតញាណទស្សនៈ មាននិព្វិទា ជាប្រយោជន៍ ជាអានិសង្ស ។

សមាធិ មានយថាភូតញាណទស្សនៈ ជា -ដ-

បស្សទ្ធិ មានសុខៈ ជា -ដ-

បីតិ មានបស្សទ្ធិ ជា -ដ-

បាមុជ្ជៈ មានបីតិ ជា -ដ-

អវិប្បដិសារៈ មានបាមុជ្ជៈ ជាប្រយោជន៍ ជាអានិសង្ស ។

ម្នាលភិក្ខុទាំងឡាយ ! សីលទាំងឡាយជាកុសល មានអវិប្បដិសារៈ ជាប្រយោជន៍ ជាអានិសង្ស តាមលំដាប់ ដរាបដល់វិមុត្តិញាណទស្សនៈ ដោយប្រការដូច្នេះឯង ។

ម្នាលភិក្ខុទាំងឡាយ ! ធម៌ទាំងឡាយ តែងញុំាងធម៌ទាំងឡាយ ឲ្យប្រព្រឹត្តទៅ ធម៌ទាំងឡាយ តែងញុំាងធម៌ទាំងឡាយឲ្យបរិបូណ៌ ដើម្បីចេញអំពីទីមិនមែនជាត្រើយ ទៅកាន់ត្រើយ គឺព្រះនិព្វាន ដោយប្រការដូច្នេះ ។

កាលព្រះពុទ្ធអង្គទ្រង់ពន្យល់ អំពីអានិសង្សសីលចប់ហើយ ទើបទ្រង់ពន្យល់ អំពីទោសរបស់អ្នកគ្មានសីលតទៅទៀតថា ៖

ម្នាលភិក្ខុទាំងឡាយ ! មនុស្សគ្មានសីល តែងមិនបានអវិប្បដិសារៈ, កាលបើ គ្មានអវិប្បដិសារៈហើយ បាមុជ្ជៈក៏គ្មាន, កាលបើ គ្មានបាមុជ្ជៈហើយ បីតិក៏គ្មាន, កាលបើ គ្មានបីតិហើយ បស្សទ្ធិក៏គ្មាន, កាលបើ គ្មានបស្សទ្ធិហើយ សុខៈក៏គ្មាន, កាលបើ

គ្មានសុខៈហើយ សម្មាសមាធិក៏គ្មាន, កាលបើ គ្មានសម្មាសមាធិហើយ យថាភូតញាណទស្សនៈក៏គ្មាន, កាលបើ គ្មានយថាភូតញាណទស្សនៈហើយ និព្វិទាក៏គ្មាន. កាលបើ គ្មាននិព្វិទាហើយ វិរាគៈ ក៏គ្មាន. កាលបើ គ្មានវិរាគៈហើយ វិមុត្តិញាណទស្សនៈក៏គ្មាន ។ ម្នាលភិក្ខុទាំងឡាយ ! ប្រៀបដូចដើមឈើដែលគ្មានមែកនិងស្លឹក, កាលបើ គ្មានមែកនិងស្លឹកហើយ ក្រមរក្តី សំបកក្តី ស្រាយក្តី ខ្លឹមក្តី របស់ដើមឈើនោះ ក៏មិនពេញលេញដែរ ។

អានិសង្សសីល ចប់ប៉ុណ្ណេះ ។

## អានិសង្សសីល ១០ យ៉ាង

ដែលត្រូវទន្ទេញឲ្យចាំជាប់ក្នុងចិត្ត គឺ៖

អានិសង្ស

ទី ១– អវិប្បដិសារៈ សេចក្តីមិនក្តៅក្រហាយ

២– បាមុជ្ជៈ សេចក្តីរីករាយទន់

៣– បីតិ សេចក្តីរីករាយខ្លាំង

៤– បស្សទ្ធិ សេចក្តីស្ងប់ល្ងាប់

៥– សុខៈ សេចក្តីសុខ

៦– សមាធិ ការតាំងចិត្តមាំ

៧– យថាភូតញាណទស្សនៈ ការឃើញនូវសច្ចៈ ៤

ដោយញាណតាមពិត ។

៨- និព្វិទា សេចក្តីនឿយណាយ

៩- វិរាគៈ ការប្រាសចាកតម្រេក

១៩- វិមុត្តិញាណទស្សនៈ បច្ចវេក្ខណញាណ ។

អានិសង្សសីលទាំង ១០ យ៉ាងនេះ មានសេចក្តីអធិប្បាយដោយពិស្តារ នៅក្នុងគម្ពីរច្បាប់ផ្សេង ៗ ស្រាប់ហើយ បើអស់លោក-អ្នកចង់ជ្រាប សូមរកមើលក្នុងគម្ពីរច្បាប់នោះ ៗ ចុះ ។

---

# ព្រះត្រៃលក្ខណ៍[១]

រូបំទុក្ខ ទុក្ខអើយទុក្ខខ្លាំង ខ្លាំងពន់ប្រមាណ
ពីតូចដល់ធំ ទុក្ខរំកន្ត្រាណ ទុក្ខឥតស្រាកស្រាន្ត
ទុក្ខដល់ខ្ទមក្ស័យ ។

អនិច្ចំពុំថិត ពុំថេរនៅនិត្យ យើនយូរឡើយនៃ
ស្លាប់នៅជាខ្មោច អសោចិ៍ពេកក្រៃ ឆ្អឹងសាច់សរសៃ
ជាព្រះធរណី ។

អនត្តាសូន្យសោះ សូន្យរូបសូន្យឈ្មោះ សូន្យសព្វសញ្ញី
សូន្យយសសក្កា- ធិការសោភី សូន្យអស់ឥន្ទ្រិយ
មាសប្រាក់អន្តរាយ ។

ដួងបេះគួរគិត គួរក្រោចិត្ត ខឹងឆាប់រសាយ
ចិត្តស្អប់លំពោន ដូចកូនជិងម្តាយ ខឹងឆាប់រសាយ
ខឹងបាត់ទៅហោង ។

---

១ ជាស្នាដៃរបស់ការីបុក្គណា ។ តែគួរឲ្យស្តាយណាស់ ដោយស្រាវជ្រាវរកកាលបរិច្ឆេទ ពីងនាមអ្នកនិពន្ធពុំទាន់ឃើញ ។ យើងយល់ឃើញថា : ក្នុងថ្លៃនៃធម៌ព្រះត្រៃលក្ខណ៍នេះ ប្រសិនបើ មានសេចក្តីខ្វះឃ្លាងឃ្លៀងឃ្លាត ចាកគម្ពីរដីការនៃពុទ្ធសាសនា ក៏គួរលើកទុកមួយអន្លើទៅចុះ, គង់នៅមានអក្សរសិល្ប៍ថ្លៃថ្លាជាច្រើនអន្លើ ដែលពុទ្ធមាមកជនអាចលើកយកមកពិចារណា ឲ្យបានជាសារៈប្រយោជន៍ដល់ផ្លូវចិត្ត ។ មួយវិញទៀត ដោយយល់ឃើញថាគួរតែរក្សាស្នាដៃនេះ ទុកឲ្យបានគង់វង្សតទៅផង, ទើបយើងស្រាវជ្រាវចម្លង យកមកចុះផ្សាយក្នុងទស្សនាវដ្តីនេះ ។ ( ព្រួច–ភុម )

សត្វក្នុងត្រៃកេត្រ កោណកើតហេតុ ត្រៃភូមិភពជន
ពុំបានជិនបុណ្យ ជិនគុណតបស្នង លុះដោយគន្ធន
សុញ្ញកាលនៅឆ្ងាយ ។

កើតកាលកើតឯក ព្រះពុទ្ធព្រះបច្ចេក ព្រះសង្ឃពណ្ណកយ
ព្រះត្រាស់មួយអង្គ ស្រង់សត្វទាំងឡាយ សុញ្ញកាលនៅឆ្ងាយ
ព្រះត្រាស់ពីអង្គ ។

ធរណីកាលនោះ ព្រះត្រាស់ចំពោះ ត្រឹមត្រៃបីអង្គ
ត្រចះរង្សី រស្មីត្រចង់ ព្រះទ័យមកស្រង់
សព្វសត្វសប្បាយ ។

សាសនាកាលនោះ ពិសេសឥតមោះ ប្រសើរពណ្ណរាយ
ព្រះត្រាស់ ៤ អង្គ គ្រប់ងាឆាយ ប្រោសសត្វទាំងឡាយ
ដោយពុទ្ធសាសនា ។

ភទ្ទកល្បនោះមាន ព្រះពុទ្ធទ្រង់ញាណ ៥ អង្គសោភណា
ព្រះនាមថាថ្ងៃ ប្រពៃសោភា ទុកព្រះសាសនា
ទីទៃពល់អង្គ ។

ព្រះកកុសន្ធោ ដើមប្រសើរពោ- ធិព្រឹក្សខ្ពស់ខ្ពង់
ឆព្វណ្ណរង្សី រស្មីត្រចង់ ព្រះជន្មស្ថិតគង់
បួនហ្មឺនព្រះវស្សា ។

ព្រះកោនាគមនោ　ដើមល្វាជាពោ-　ធិព្រឹក្សសាខា
ឆព្វណ្ណរង្សី　រស្មីថ្លៃថ្លា　ព្រះជន្មសាស្តា
　　　បីម៉ឺនឆ្នាំគត់ ។

ព្រះកស្សបោ　ដើមជ្រៃជាពោ-　ធិព្រឹក្សបវិសុទ្ធ
ឆព្វណ្ណរង្សី　រស្មីព្រះពុទ្ធ　ព្រះជន្មកំណត់
　　　ពីរម៉ឺនព្រះវស្សា ។

ព្រះសមណគោតម　ត្រាស់ជាប្រថម　បរមសាស្តា
ផុសរតនបល្ល័ង្ក　ទីនាំងពេជ្រថ្លា　ស្តេចគង់ផ្ចាញ់មារ
　　　ព្រះអង្គឥតភ្លឹក ។

ថ្កើងទសបារមី　ឆព្វណ្ណរង្សី　ក្រោមពោធិព្រឹក្ស
នាងគង្ហីងព្រះធរណី　ទេវីសាចទឹក　ពលមារបីអធិក
　　　ផ្ចាញ់ព្រះសាស្តា ។

ព្រះជន្មប៉ែតសិប-　ឆ្នាំទើបរៀបចប់　ប្រាំពាន់ព្រះវស្សា
ព្រះចូលនិព្វាន　ទុកតែសាសនា　ប្រោសអស់ទេវតា
　　　មនុស្សសត្វទាំងឡាយ ។

ព្រះសិអារ្យមេត្រី　ពោធិសត្វថ្លៃ　រស្មីផែតឆាយ
នឹងត្រាស់ជាក្រោយ　ដោយពុទ្ធទំនាយ　ព្រះជន្មវែងឆ្ងាយ
　　　ប្រាំបីម៉ឺនព្រះវស្សា ។

ដើមខ្លឹមជាពោ- ធិព្រឹក្សសេដ្ឋ មានមែកផុសផ្កា
ប៉ុនកង់កងថេ បរិសុទ្ធសោភា លំអង់បុប្ផា
រុះពាយដោយខ្យល់ ។

ក្រអូបគោកាយ ក្លិនក្រៃខ្ជរខ្ជាយ សាយសព្វទៅដល់
ទិសទីទាំងដប់ អប់អស់មណ្ឌល ទ្វីបទាំងបួនស្កល់
ដាសដល់សួគ៌នាយ ។

កទ្រកល្បយូរក្តាត់ កើតសំពៅរ័តន៍ ទាំង ៥ ព្រោងព្រាយ
គេត្រា ៤ បាទ បើកៈផ្ទាះស្មាះឆ្ងាយ ខ្ទង់ផលសាសាយ
ឥតក្តីកករយោ ។

ទន្ទេងទន្ទា លះលះរលាំ លឿនលើអាពោ
សមុទ្រធំធេង បែកឆ្នេរសាគរ ត្រីអាគត្វាមមករ
ពាសពេញត្រៀបត្រា ។

ព្រះអង្គផុកសត្វ លើសំពៅរ័តន៍ សល់សែនអស្ចារ្យ
ឆ្លាស់ឆ្លងសាគរ ចេញចរយាត្រា កាន់ត្រើយគឹមហា-
និព្វានប្រពៃ ។

ឈ្មោះមឿងកែវឯក ព្រះពុទ្ធព្រះបច្ចេក កប់អស្ចារ្យ
មឿងកែវសម្រេច ទើបស្ដេចអាល័យ មឿងកែវប្រពៃ
ឥតអ្វីផ្ទឹមផ្ទាល់ ។

មឿនកែវធំធេង ឮតែស័ព្ទភ្លេង លេងល្បើយសុខសល់
សុខក្រៃលែងសុខ ឥតទុក្ខមកផ្តល់ ព្រះពុទ្ធប្រើនស្គាល់
កែងនាំសត្វទៅ ។

ឈ្មោះសត្តពោជ្ឈង្គ (១) កែវជុំវិលវង់ ប្រាំពីរជាន់នៅ
រស្មីមឿនកែវ កែវភ្លឺសន្ទៅ ពេញព្រាយព្រាលផ្ទៅ
ភ្លឺផ្លេកពេកក្រៃ ។

មឿនកែវអតិរេក សុខលន់ពន់ពេក ពុំដែលក្សិណក្ស័យ
រស់រូបកល់រៀង តាល់ទៀងប្រពៃ រូបដូចកែវថ្ងៃ
រស្មីឆាឆាយ ។

ព្រះយមរាជអរ ព្រះកាលឡេតរ សាន្តសុខសប្បាយ
សឹងបានរូបប្រាណ រុញច្រានទៅឆ្ងាយ ខំខាននៅអាយ
ស្រុកនេះសឹងភ្លើង ។

ព្រហ្មសោឡសា តាំងឆកាមា សោយសុខថ្កល់ថ្កើង
អស់ផលកម្មនៅ ចុះទៅរងភ្លើង លុះអស់កម្មឡើង
មកជាមនុស្ស ។

វិលស្លាប់វិលកើត យោនយកកំណើត រាប់ជាតិអសង្ខេយ្យា
ក្នុងដែនត្រៃភព សាយសព្វទ្វីបា វង្វេងតណ្ហា
មួយអប្រិយ ។

១— អានថា សត្តៈពោជឈង់ ។

ព្រះត្រាស់អស់ឆ្ងើយព្យា ខ្លួននៅឯណា ពុំយល់ស្មើ
គួរគិតអនិច្ចា អសារជាតិ កើតក្នុងលោកិយ
ទាន់តែសាសនា ។

ព្រះពុទ្ធគុណ អនេកអនន្ត ច្រើនក្រៃមហិមា
ខិតខំសង្កាត់ ខ្មីឃ្មាតខ្នា ក្រួញក្រោបកាយា
បង្គំសព្វថ្ងៃ ។

រំពុកព្រះគុណ គុណកែវរតន(១) ប្រសើរថ្កៅថ្ងៃ
កុំឲ្យមានដាច់ ភ្លាំងភ្លេចមួយថ្ងៃ ស្មើបានកប់ខែ-
អង្គព្រះសាស្តា ។

ហេតុនោះគួរគិត គួរតំកល់ចិត្ត ត្រេកត្រង់សទ្ធា
ធ្វើបុណ្យឲ្យទាន ជាយានអាត្មា ទាន់តែសាសនា
ស្មើអង្គព្រះហោង ។

ចេតសិកសោភ័ណ ប៉ែតម៉ឺនសែនពាន់ ប្រាំរយជាម្តង
កិលេសប្រាំរយ តែងឲ្យសៅហ្មង អស់កុសលផង
ពុំមានឡើយណា ។

អ្នកប្រាជ្ញស្គាល់ចិត្ត មូលមកសណ្ឋិត ដូចផ្កាបទុមា
ជាឯកចិត្ត ពុំភ្លាត់ចេញទ្វារ ទាំងប្រាំបួននៅនា
មូលមួយមណ្ឌល ។

---

១– អានថា រាត់តន់ សម្រួលចុងចួនឃ្លាខាងដើម ។

ចិត្តថាត្រង់ ត្រង់ត្រេះត្រូ អាណាព្រាណយល់
ភរិយាដើរឈ្នួន ដូរល្ហងសោតសល់ ចិត្តមូលមួយស្កល់
ទើបបានអរហំ ។

មនុស្សសែនកាន់កោដិ ចិត្តខេរខឹងក្រោធ ម្នោះម្នះខ្លោះខ្លាំង
ដល់ទៀបទីងស្លាប់ ទើបរកព្រះអរហំ យមបុលកើបតាំង
ចងប្រាំប្រការ ។

កាលរស់ពុំស្គាល់ រៀនយកព្រះធម៌ ពឹងពាក់រូបា
ដល់ទៀបក្សីណក្ស័យ ប្រល័យផន្ទា កសំលោកគាថា
ឡ្យដំណើរទៅ ។

រូបស្លាប់នៅកាយ ចិត្តចុះទៅនាយ កាយកើតនិត្យទៅ
ស្ពាននរកក្តើង ឆេះឡើងសន្ធៅ ពេលខ្ញុំប្រាលស្លៅ
ទីងរូបកាលណា ។

ឃើនយូរពន់ពេក រាប់ជាតិអនេក អនន្តអសង្ខ្យា
ខ្ញុំប្រាលសឹងក្តើង ឆេះឡើងខ្លាចផ្សា ស្រែកយំគោលា-
ហលហើយក្តាត់ក្តៅ ។

គិតហើយគួរខ្លាច ឆាប់រកអ្នកប្រាជ្ញ មូលមកប្រដៅ
ឡ្យរៀនព្រះធម៌ សន្លាកត់ជ្រៅ កាលខ្ញុំនិត្យនៅ
ទើបបានអរហំ ។

ធ្វើបុណ្យរយពាន់ បុណ្យតាមពុំទាន់ បាបនោះកខ្លាំង
យមបាលកក្រោធ ពិរោធក័ត្តកាំង ឆក់ទាញជើងទាំង
នាំទៅព្រៃងើយ ៗ

ស្តែងស្តាប់គួរខ្លាច គួររកអ្នកប្រាជ្ញ កុំធ្វើគោះគើយ
កុំការយសស័ក្តិ មាសប្រាក់អ្នកអើយ រៀនយកឲ្យហើយ
ក្រែងបានពុំបាន ៗ

តាមដោយសំណាង ពីព្រេងបានសាង ទើបទីងក្នាក់ប្រាណ
ចិត្តល្អថ្លាជ្រះ ស្រឡះវិញ្ញាណ ចិត្តអត់ស្រេកឃ្លាន
ពិតពុំទិទ្រា ៗ

បើយប់បានស្ងាត់ អង្គុយប្រតិបត្តិ ផ្ចង់ចិត្តភាវនា
ទឹកព្រះធម៌ថ្លៃ ប្រពៃសោភា កុំខ្ជិលឧស្សាហ៍
បរិកម្មនិត្យនៅ ៗ

ទឹកថាឥន្ទ្រា អស់ពួកទេវតា រូបល្អឥតសៅ
បានពិមានតែន៍ នៅបិតប្រាលផ្ដៅ ស្រីសួគ៌គាល់ហៅ
រាប់សែនសហស្សា ៗ

ទឹកថាមហាចក្រ មានរិទ្ធិសិទ្ធិស័ក្តិ សត្តតែន៍កែវថ្លា
ស្រីទេពអប្សរ បរិកញ្ញា ស្រីតែន៍ខត្តក
មកជាមហេសី ៗ

(នៅមានត)

# ផ្នែកអក្សរសាស្ត្រ

អក្សរសាស្ត្រខ្មែរ ខ្មែរគួរថែថ្នម
ឲ្យបានខ្ជាប់ខ្ជួន គង់វង្សគង់មាំ
ព្រោះអក្សរជាតិ គោលជាតិប្រាកដ
អក្សររលត់ ជាតិក៏រលាយ

ព.ប.

## ប្រវត្តិសម្តេចព្រះធម្មលិខិត លូ-ឯម

(ត-ចប់)

សាស្ត្រាចារ្យ ឈឹម-ស៊ុម រៀបរៀង

ការសិក្សាបាលីនិងធម្មវិន័យក្នុងវត្តលង្កា ចម្រើនសិស្សដល់ចំនួន ៧០០ រូប ក្នុង ១ ឆ្នាំ ៗ ការសិក្សានេះ ក្រៅផ្លូវការ គឺនៅក្រោមការត្រួតត្រាផ្ទាល់ នៃព្រះតេជព្រះគុណ ព្រះសិរីសម្មតិវង្ស លូ-ឯម ។ កាលតែរដូវចេញវស្សា ព្រះតេជព្រះគុណអង្គនេះ តែងចាត់ការឲ្យប្រឡងសិស្ស ដើម្បីចែករង្វាន់ដល់សិស្ស ដែលប្រឡងជាប់លេខខ្ពស់ ៗ ក្នុងវេលាដែលប្រឡងម្តង ១ រង្វាន់ផ្ទាល់របស់ព្រះថេរៈអង្គនេះ មានត្រៃចីវរដល់ ៣០ ឬ ៤០ ក៏មាន ដែលលោកប្រទានដល់សិស្សអ្នកប្រឡងជាប់លេខ ៗ

កាលពីឆ្នាំ ចធស័ក ព.ស. ២៤៧៦ គ.ស. ១៩៣៤ ព្រះតេជព្រះគុណ ព្រះគ្រូសាក្យបុត្តព្រះនាម ទឹម មេគណស្រុកកំពង់លែង ខេត្ត

កំពង់ឆ្នាំង ដែលបានយកតម្រាប់តាមវត្តលង្កា បានជូនសង្ឃដីកា១ច្បាប់ តាមរយៈរ៉េស៊ីដង់ខេត្ត និងចៅហ្វាយខេត្តកំពង់ឆ្នាំង សុំឲ្យព្រះតេជ-ព្រះគុណ ព្រះសិរីសម្មតិវង្ស ចាងហ្វាងសាលាបាលីជាន់ខ្ពស់ អធិ-បតីក្រុមជំនុំព្រះត្រៃបិដក ចាត់ការធ្វើរបៀបប្រឡងសិស្ស ព្រមទាំងសូមឲ្យចាត់អធិបតីក្រុមមេប្រយោគ ១រូប ពីភ្នំពេញទៅប្រឡងសិស្ស ដែលប្រមូលមកពីវត្តនានា ឲ្យមកប្រជុំប្រឡងនៅវត្តពោធិអណ្ដែត ដែលជាអាពាមរបស់លោក ។

ព្រះតេជព្រះគុណ ព្រះសិរីសម្មតិវង្ស ក្រោយដែលបានជំនុំព្រមនឹងលោកស្រី ការ៉ពុឺឡែស អគ្គលេខាធិការនៃពុទ្ធសាសន-បណ្ឌិត្យជាដើមហើយ ក៏បានចាត់ភិក្ខុ ឈឹម-ស៊ុម ជាសាចារ្យសាលាបាលីវត្តលង្កា និងជាក្រុមជំនុំព្រះត្រៃបិដក ឲ្យសរសេររបៀបប្រឡង ព្រមទាំងចាត់ភិក្ខុអង្គនេះ ឲ្យទៅជាអធិបតីក្រុមមេប្រយោគផង ហើយតម្រូវថាដល់ត្រឡប់មកវិញ ឲ្យធ្វើសេចក្ដីរាយការណ៍ អំពីការសិក្សាផ្លូវព្រះពុទ្ធ-សាសនា នៅខេត្តកំពង់ឆ្នាំង ជូនទៅក្រសួងពុទ្ធសាសនបណ្ឌិត្យផង ។

កាលដែលការប្រឡងនេះរួចស្រេចហើយ, ព្រះតេជព្រះគុណ ព្រះសិរីសម្មតិវង្ស ល្វី - ឯម បានទទួលសេចក្ដីរាយការណ៍ ដែលភិក្ខុ ឈឹម-ស៊ុម ធ្វើជូនទៅពុទ្ធសាសនបណ្ឌិត្យរៀបរាប់គ្រប់កិច្ចការ ហើយមានសេចក្ដីស្នើសុំសញ្ញាប័ត្រចែកសិស្សដែលប្រឡងជាប់ ព្រម

តាំងសុំឲ្យភ្ជាប់សាលាបឋមសិក្សាបាលី វត្តពោធិវ័ណ្ណត ទៅជាសាខា ក្នុងផ្លូវរាជការផងនោះ លោកក៏មានគំនិតមួយយ៉ាងធំទូលាយថា នឹងសុំបង្កើតសាលាបឋមសិក្សាបាលីជាផ្លូវរាជការ ក្នុងទីរួមខេត្តគ្រប់ខេត្ត ឲ្យដូចជាសាលាបឋមសិក្សាបារាំង - ខ្មែរដែរ ។ កាលដែលលោកនាំគំនិតនេះ ទៅពិគ្រោះនឹងសហការីរបស់លោក ក្នុងសាលាបាលីជាន់ខ្ពស់ និងក្នុងពុទ្ធសាសនបណ្ឌិត្យរួចហើយ លោកក៏បានធ្វើសេចក្តីរាយការណ៍ អំពីការសិក្សាផ្លូវពុទ្ធសាសនា ព្រមទាំងសេចក្តីសុំបង្កើតសាលាបឋមសិក្សាបាលីគ្រប់ខេត្ត ជូនទៅរាជការព្រះករុណាជាម្ចាស់ជីវិត និងរាជការអាណាព្យាបាលបារាំងសែស ។ កាលបើការនេះមានទំនងជានឹងបានសម្រេចហើយ, រាជការក៏តម្រូវឲ្យព្រះថេរៈអង្គនេះ ព្រាងព្រះរាជប្រកាស ដែលជាច្បាប់សម្រាប់សាលាបឋមសិក្សាបាលី និងកម្មវិធីបង្រៀនក្នុងសាលានោះផង ។ លោកក៏បានរៀបចំរបៀបនេះ ដោយសព្វគ្រប់ ដែលជាការមានប្រយោជន៍ដ៏ធំទូលាយ, ប៉ុន្តែវេលាដែលដំនុំសម្រេចហើយស្រេចទៅ ក៏បានត្រឹមតែបង្កើតសាលាបាលីរង បីៗ ថ្នាក់ ក្នុងវត្តនីមួយ ៗ ដែលទៅអធិការពេញចិត្តឲ្យមានប៉ុណ្ណោះ ។ ( សាលាបាលីរងដែលកើតមានក្នុងកម្ពុជរដ្ឋ ក្នុងកាលដែលសម្តេចព្រះធម្មលិខិត ល្វី - ឯម នៅកាន់ការ មានចំនួន ១១៤ វត្ត ) ។

កាលពី ព.ស. ២៤៧៤ គ.ស. ១៩៣២ ព្រះថេរៈអង្គនេះ

បានទទួលសិស្សបព្វជិតជាតិលាវ ដែលរាជការបញ្ជូនមកពីប្រទេសលាវ និងសិស្សបព្វជិតជាតិខ្មែរ ដែលរាជការបញ្ជូនមកពីដែនកូសាំងស៊ីន ចំនួន ៣០ ប្រយរូប គង់ ១ ឆ្នាំ ៗ ហើយលោកបានបើកសាលាបំពេញវិជ្ជាខ្មែរមួយ នៅវត្តលង្កា ឲ្យសិស្សទាំងនេះសិក្សា ក្រោមការត្រួតត្រារបស់លោក មានភិក្ខុ អ៊ុច-រស់, ឈឹម-ស៊ុន, តាំ-ឌុំ ជាអ្នកបង្រៀន ៗ តមក លោកបានចេញគំនិត ជាមួយលោកស្រីការប៉ឺឡែស អគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ ដើម្បីផ្សាយវិជ្ជាខ្មែរ និងពុទ្ធសាសនាបញ្ចូលទៅក្នុងប្រទេសលាវ និងដែនកូសាំងស៊ីន បានឲ្យបង្កើតសាលារៀនបាលីជាច្រើនអន្លើ ជាប់មកដល់សព្វថ្ងៃនេះ ។

ដល់មក ព.ស. ២៤៨៥ ព្រះតេជព្រះគុណ ព្រះសិរីសម្មតិវង្ស ល្វី-ឯម បានឡើងសមណស័ក្តិ ជាព្រះ ធម្មលិខិត ( ពជាគណៈ ទី ១ ) មានកិត្តិស័ព្ទល្បីល្បាញ ខាងការតម្កើងឥទ្ធិពលនៃពុទ្ធសាសនា មានសិស្សគណច្រើនរូប ដែលមានចំណេះវិជ្ជាជ្រៅជ្រះ គឺច្បាស់ក្នុងផ្លូវលោកនិងផ្លូវធម៌ ដរាបតែសិស្សនិងគ្រូខ្លះមិនចង់នៅក្រោមបង្គាប់ពួកការអាណាព្យាបាលបារាំងសែស ហើយនាំគ្នាតវ៉ាឡើង ជាហេតុនាំឲ្យខូចសេចក្តីទុកចិត្ត របស់ពួកការអាណាព្យា-បាលបារាំងសែស មកលើព្រះតេជព្រះគុណព្រះធម្មលិខិត ល្វី-ឯម ជាពន់ហ្វាង ៗ ដោយហេតុនេះ ទើបលោកសុំលាលែងឈប់កាន់

តំណែងចាងហ្វាងសាលាបាលីជាន់ខ្ពស់ និងអធិបតីក្រុមជំនុំព្រះត្រៃបិដក ក្នុងឆ្នាំនេះ ។

ក្នុងរយៈវេលាដែលព្រះតេជព្រះគុណព្រះធម្មលិខិត ល្វី - ឯម បានធ្វើការខាងផ្លូវពុទ្ធចក្រ ទាក់ទងនឹងផ្លូវអាណាចក្រនោះ លោកបានគ្រឿងឥស្សរិយយស ដូចតទៅនេះ គឺ ថ្ងៃ ១៩ - ២ - ១៧ បានមេដាយមុនីសារាភ័ណ, ថ្ងៃ ១៨-១-៣៦ បានមេដាយអស្សរិទ្ធិប្រទេសកម្ពុជា; ថ្ងៃ ៣ - ១០ - ៣៣ បានមេដាយ សឺវ៉ាលីយេរ ដឺឡូ រេស្យ៊ីយ៉ុង ដោណ្ណើរ ប្រទេសបារាំង; ថ្ងៃ ១៣-១២ - ៥១ លោកអង់ដ្រេ ម៉ារី រដ្ឋមន្ត្រីក្រសួងសិក្សាធិការបារាំង បានតាំងលោកជា ( Officier de l'instruction publique ) មន្ត្រីបណ្ណាវិជ្ជាសាធារណៈ ។

ដល់មក ព.ស. ២៤៩១ ព្រះករុណាជាម្ចាស់ជីវិត ព្រះបាទសម្តេចព្រះ នរោត្តម សីហនុវរ្ម័ន ទ្រង់ព្រះរាជតាំងសមណសក្តិជាសម្តេចព្រះធម្មលិខិត ឧត្តមប្រឹក្សាគណៈមហានិកាយ ។ លោកក៏ឋិតនៅក្នុងឋានៈជាព្រឹទ្ធបុរសមួយ សម្រាប់តំរោះផ្លូវពុទ្ធចក្រ និងអាណាចក្រនៃប្រទេសកម្ពុជា ដរាបមកដល់សព្វថ្ងៃនេះ ដែលលោកមានជរាព្យាធិ ទន់ព្រះកាយពលណាស់ហើយ ។

សម្តេចព្រះធម្មលិខិត ល្វី-ឯម ឧត្តមប្រឹក្សា ជាមហាអ្នកប្រាជ្ញ

យ៉ាងអង់អាចក្នុងប្រទេសកម្ពុជា នាសតវត្សរ៍ទី ១៩ នៃគ្រិស្តសករាជ ។ អ្នកប្រាជ្ញអង្គនេះ បានសរសេរសៀវភៅ ដែលមានប្រយោជន៍ដល់ប្រទេសនិងពុទ្ធសាសនា បាន ១១ ឈ្មោះគឺ :

១– កាយបរិហារិកាទិវត្តកថា ( សេចក្តីជាធម៌និងវិន័យសុទ្ធ ហើយស្របគ្នានឹងច្បាប់អនាម័យផ្លូវលោកសព្វថ្ងៃ ) ។

២– សមាទានវិនិច្ឆ័យ ( របៀបសមាទានសីលនៃពួកឧបាសកឧបាសិកា មុនសៀវភៅគិហិបដិបត្តិ ហើយមានដំណើរស្រដៀងគ្នា ) ។

៣– វុត្តោទ័យ ( សម្តែងអំពីឆន្ទលក្ខណវិធី របៀបតែងគាថា ( កាព្យ ) ខាងភាសាបាលី ) ។

៤– លោកនេយ្យ ( រឿងធនញ្ជយបណ្ឌិត ដែលមានបញ្ហាយ៉ាងច្រើនជាអនេក ជាគតិខាងការដឹកនាំសត្វលោកឲ្យដល់នូវសន្តិភាពក្នុងផ្លូវលោកនិងផ្លូវធម៌ ) ។

៥– បព្វជ្ជាខន្ធកៈ ( ព្រះវិន័យ ជាកម្រិតខាងការបំបួសកុលបុត្ត ជាច្បាប់មួយ ដែលបានប្រជុំអ្នកប្រាជ្ញច្រើនរូបមករួបរួមធ្វើ ហើយជាជំនឿយ៉ាងសក្តិសិទ្ធ របស់ពួកអ្នកចេះគម្ពីរបាលី ) ។

៦– វេជ្ជសារដីកា ( សម្តែងអំពីធម្មរសនិងអត្ថរស ដែលជាប្រយោគក្រៗ មានខ្លឹមសារដូចជាតែវេជ្ជ ) ។

៧ មធុរសវាហិនី ( សម្តែងអំពីធម្មរសនិងអត្ថរសដ៏ផ្អែមល្ហែម

មានរឿងនិទានជារឿងពន្យល់នូវធម្មរស ) ។

៨– ញាណកថា ( សម្ដែងអំពីព្រះប្រាជ្ញានៃព្រះសម្មាសម្ពុទ្ធ ដើម្បីជាគ្រឿងសរសោះអន្ទង នូវប្រជាជន ឲ្យជ្រះថ្លា ចំពោះព្រះពុទ្ធជាម្ចាស់ ) ។

៩– ធម្មកថាផ្សេង ៗ ជាច្រើន ដែលសម្ដេចបានសរសេរចុះក្នុងទស្សនាវដ្ដីកម្ពុជសុរិយា របស់ពុទ្ធសាសនបណ្ឌិត្យ តាំងពីទស្សនាវដ្ដីនេះកើតឡើងជាដំបូង ។

១០– អភិធម្មត្ថាធិប្បាយ ( សេចក្ដីអធិប្បាយក្នុងគម្ពីរអភិធម្មត្ថសង្គហៈ ពន្យល់យ៉ាងច្បាស់លាស់ក្នុងផ្លូវបរមត្ថ គឺចិត្ត ចេតសិក រូប និព្វាន ) ។

១១– វិន័យវិនិច្ឆ័យ ( ជាច្បាប់សម្រាប់វិន័យធរប្រតិបត្តិ ក្នុងការកាត់សេចក្ដីវិន័យ ) ។

១២– ចីវរវិភាគ ( គំរូចីវរគ្រប់ធុននិងបាលីសម្រាយជាគោលនៃការកាត់ដេរចីវរ យ៉ាងត្រឹមត្រូវគ្រប់ធុន ) ។

១៣– សម្ដេចបានចំណាយក្រដាស និងគ្រឿងប្រដាប់សរសេរ និងឈ្នួលជួលស្មៀនសរសេរចម្លងគម្ពីរធម្មបទដ្ឋកថាបាលី ( ប័នថ្មាយ ) គឺពីភាគ ៥ ដល់ភាគ ៨, គម្ពីរមង្គលត្ថទីបនីបាលី ១ ចប់, ហើយ

បានចាត់ឲ្យគណៈកម្មការពិនិត្យផ្ទៀងផ្ទាត់ បោះពុម្ពសម្រាប់សិស្សក្នុងសាលាបាលីរង និងសាលាបាលីជាន់ខ្ពស់ ។

( ចប់ )

ប្រវត្តិនេះខ្ញុំធ្វើពី ព.ស. ២៤៩៧ កាលសម្តេចគង់ព្រះជន្មនៅឡើយ សម្តេចបានពិនិត្យហើយ បានអនុញ្ញាតឲ្យខ្ញុំបោះពុម្ព ដាក់ខាងដើមសៀវភៅអភិធម្មត្ថាធិប្បាយ ដែលលោកប្រទានផ្តាច់ដល់ខ្ញុំ ក្នុងគ្រាបោះពុម្ពលើកទីពីរ ពី ព.ស. ២៤៩៧ គ.ស ១៩៥៤ ។ ឥឡូវ ព.ស ២៥០៩ គ.ស. ១៩៦៦ ខ្ញុំឈឹម-ស៊ុម បានធ្វើប្រវត្តិនេះបន្តទៅទៀត តាមឯកសារដែលខ្ញុំបានកត់ទុកខ្លីចតទៅនេះ :

---

## អវសានប្រវត្តិ
## នៃ
# សម្តេចព្រះធម្មលិខិត ល្វី-ឯម

សម្តេចព្រះធម្មលិខិត ល្វី-ឯម ក្រោយដែលនិវត្តចេញអំពីការងារក្នុងសាលាបាលីជាន់ខ្ពស់ និងក្រុមជំនុំព្រះត្រៃបិដកក្នុងពុទ្ធសាសនបណ្ឌិត្យមក រឹតតែមានឱកាស ដើម្បីបំពេញករណីយកិច្ច ក្នុងការឧបត្ថម្ភពុទ្ធ-សាសនាតមកទៀត គឺ :

១- ប្រែបន្ថែម ព្រមទាំងរៀបចំជាថ្មី នូវសៀវភៅអភិធម្មត្ថា-ធិប្បាយ ។

២- ប្រែរៀបរៀងតាមបាលីព្រះត្រៃបិដកនូវសៀវភៅវិន័យវិនិច្ឆ័យ ។

៣- រៀបរៀង ព្រមទាំងគូរគំរូ ស្បង់ចីពរគ្រប់ធុន តាមសេចក្ដីដកស្រង់ពីវិន័យ បង្កើតបានជាសៀវភៅចីវរវិភាគ ។

៤- ជាទីប្រឹក្សា ក្នុងការបង្កើតសមាគមមិត្តពុទ្ធិកវិទ្យាល័យ ហើយសម្ដេចបានឧបត្ថម្ភសមាគមនេះពេញសមត្ថភាព តមកដល់ជីវិតាវសាន ។ កាលដែលសមាគមនេះកើតឡើង តាំងនៅក្នុងផ្ទះឈ្នួលអស់ថ្លៃឈ្នួលមួយខែ ១ ជាង ១០០០ រៀល សម្ដេចក៏ទាញយកមកដាក់ក្នុងវត្តលង្កា ប្រគល់បណ្ណាល័យដែលសម្ដេចសាងផ្ទាល់ព្រះអង្គ ឲ្យជាទីស្នាក់ការនៃសមាគមមួយជាន់នេះខាងក្រោម ព្រមទាំងគ្រឿងសម្ភារៈផ្សេង ៗ ផង ដរាបមកដល់ថ្ងៃនេះ ។

៥- ជាទីប្រឹក្សា ក្នុងការបង្កើតសមាគមគិលានសង្គ្រោះ សម្រាប់ព្រះសង្ឃ ហើយសម្ដេចឧបត្ថម្ភសមាគមនេះពេញសមត្ថភាព ដរាបដល់កើតមន្ទីរពេទ្យ ដែលសព្វថ្ងៃហៅថា មន្ទីរពេទ្យព្រះកុសុមៈ(សម្រាប់ព្រះសង្ឃ) ។

៦- សម្ដេចបានតម្រូវឲ្យធ្វើរបងវត្តស៊ីធរ ដែលសម្ដេចធ្លាប់ជាចៅអធិការពីដើម ដោយការចំណាយបច្ច័យផ្ទាល់ព្រះអង្គ ១ ម៉ឺនរៀលជួយទិញសម្ភារៈផង ។

៧- ក្នុង ព.ស. ២៤៩៧ គ.ស. ១៩៥៤ សម្ដេចបានឲ្យរុះរើព្រះវិហារចាស់វត្តលង្កា ដែលសម្ដេចកសាងយូរហើយនោះ ស្ថាបនាឡើងជាថ្មីវិញ មានជាន់ពីរ មានមុខ ៤ មានកំពូលស្រួច មានហោជាង

ផ្សាយផងការចេញស្លាបចិញ្ចាចបិតែ្ណងផ្ទោះទៅទិសទាំង ៤ ។ (បច្ច័យសល់ពីបុណ្យសម្ពោធព្រះវិហារថ្មីនេះ បានអ្នកនៅខាងក្រោយយកទៅធ្វើកំពែងវត្តលង្កាទៀត ) ។

៨– វេលាដែលសម្តេចផក មានអាពាធធ្ងន់ សឹងជាប់លើសំណាង សម្តេចបានថ្វាយចុតហ្មាយមួយច្បាប់ ទៅព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សុរាម្រឹត និងសម្តេចព្រះមហាក្សត្រិយានីជាអម្ចាស់ជីវិតលើត្បូង សុំទ្រង់ជួយឧបត្ថម្ភអាចារ្យបង្រៀនទៅសាលាបាលីរង ក្នុងព្រះរាជអាណាចក្រកម្ពុជា ដែលសល់នៅក្នុងការឧបត្ថម្ភដ៏ស្តួចស្តើងរបស់ចៅអធិការ ឲ្យបាននិច្ចភត្ត ( បៀវត្ស ) គ្រាន់បន្តកម្លាំងក្នុងការបង្ហាត់បង្រៀនតទៅៗ តពីនោះមក លោកអាចារ្យបង្រៀនគ្រប់រូបបាននិច្ចភត្ត ៣០០ រៀល ១ រូប ក្នុងមួយខែ ៗ ទើបសម្តេចព្រះពោធិវង្ស ហួត-តាត បន្តសកម្មភាពនោះមកទៀត ដរាបដល់លោកអាចារ្យទាំងនោះបាននិច្ចភត្ត ១៥០០ រៀល ១ រូប ក្នុងមួយខែ ៗ ហើយសាលាបាលីរងប្រែឈ្មោះជាសាលាពុទ្ធិកបឋមសិក្សា ចូលជាផ្លូវការស៊ីបសួនហេតុមកដល់ថ្ងៃនេះ ។

សម្តេចព្រះធម្មលិខិត ល្វី ឯម មិនត្រឹមតែជាទីគោរពស្ញប់ស្ញែងនៃជនានុជនទេ ថែមទាំងជាទីស្រឡាញ់ ជាទីស្តាយស្រណោះអស់ពីពោះនៃពុទ្ធិកជនទាំងគ្រហស្ថទាំងបព្វជិតផង ។

ដល់ព.ស. ២៤៩៩ គ.ស. ១៩៥៦ សម្តេចព្រះធម្មលិខិត ល្វី-ឯម

មានអាពាធជាលើកដំបូង គឺកេតហក់រុកឈឺចាប់សព្វសព៌ាង្គកាយ ។ សម្តេចព្រះមហាក្សត្រិយានីស៊ីសុវត្ថិ កុសុមៈ ជាអម្ចាស់ជីវិតលើត្បូង ទ្រង់មានព្រះសវនីយ៍ បញ្ជាឲ្យលោកអ្នកឧកញ៉ាវិសុទ្ធិ ពេទ្យ អ៊ុន-អេម ព្យាបាលកេតនេះ ដកបដល់បានជាមួយលើក ។

ក្រោយនេះប្រហែល ៥ ខែ កេតនេះកើតឡើងវិញ ។ លោកវេជ្ជបណ្ឌិត ជួន-ជឿន និងលោក លាន-សាំន ( សិស្សសម្តេច ) បានព្យាបាលកេតនេះ ជាមួយលើកទៀត ។ លុះដល់ថ្ងៃសៅរ៍ទី ៤ ឧសភា គ.ស. ១៩៥៧ កេតនោះ បានផុសផុលឡើងទៀត លោកវេជ្ជបណ្ឌិតជាតិបារាំងនាម «វិស» និង "ប៉ាស៊ី" ព្យាបាលកេតនោះថែមទៀត ក៏ពុំបានធូរស្រាលសោះ ។

តាំងពីសម្តេចមានអាពាធពីដំបូងរៀងមក សិស្សានុសិស្សនិងពុទ្ធបរិស័ទ បានធ្វើបុណ្យប្រគេនកុសលចំពោះសម្តេចបន្ត ។ គ្នា ច្រើនលើកច្រើនគ្រា តាំងបច្ច័យថ្ងៃឧសថ និងរង្វាន់ពេទ្យ ក៏គេឥតមានភ័យថាក្រែងខ្វះកន្ទះឡើយ ។

លុះដល់បច្ចុសសម័យ ថ្ងៃអង្គារ ៩ កើតខែពិសាខ ឆ្នាំរការនព្វស័ក ព.ស. ២៥០០ ត្រូវនឹងថ្ងៃទី ៧ ឧសភា គ.ស. ១៩៥៧ វេលាម៉ោង ៥ និង ៤០ នាទី សម្តេចទទួលអនិច្ចធម្មក្នុងព្រះជន្មាយុ ៧៨ ឆ្នាំ ដោយឥតក្តីកស្មារតី កណ្តាលប្រជុំជនបុរសស្ត្រី ចាំគ្រហស្ថតាំង

បព្វជិត ដែលកំពុងមានចិត្តស្តាយស្រណោះ ដ៏ស្លុតស្លុបក្រៃពេក ។

បន្ទាប់មកក្នុងថ្ងៃដដែលនេះ ពេលម៉ោង ១៧ ព្រះករុណាព្រះបាទ សម្ដេចព្រះនរោត្ដម សុរាម្រឹត ជាអម្ចាស់ជីវិតលើត្បូង ទ្រង់ស្ដេចទៅកាន់វត្តលង្កា ទ្រង់ស្រប់ព្រះសុគន្ធវារី ចំពោះព្រះសពសម្ដេចព្រះធម្ម-លិខិត ក្នុងចំណោមព្រះសង្ឃ មានសម្ដេចព្រះមហាសុមេធាធិបតី ( ជួន-ណាត ) ជោតញ្ញាណោ សង្ឃនាយក គណៈមហានិកាយ, សម្ដេចព្រះសុធម្មាធិបតី ( កុល-ទេស ) ឥន្ទញ្ញាណោ សង្ឃនាយក គណៈធម្មយុត្តិកនិកាយ និងក្នុងចំណោមវរជន ឥស្សរជន វរជនគ្រប់ក្រសួង មានសម្ដេចព្រះឧបយុវរាជ នរោត្ដម សីហនុ នាយករដ្ឋមន្ត្រីជាប្រមុខ ដែលបានប្រោះព្រំសុគន្ធវារីបន្តបន្ទាប់មក ។ ក្នុងវេលាយប់នោះ ក្រុមមន្ត្រីក្នុងព្រះបរមរាជវាំង មានក្រុមព្រះស្នំជាដើម បានរៀបចំតំកល់ព្រះសព ក្នុងកោដ្ឋមាសព្រះរាជទ្រព្យ ប្រតិស្ឋានលើព្រះបញ្ជា ៣ ជាន់ក្នុងធម្មកុដិ លំនៅផ្ទាល់របស់សម្ដេច នាវត្តលង្កា ។ ថ្ងៃបន្ទាប់ ៗ រៀងមក មានពិធីបុណ្យទក្ខិណានុប្បទាន គឺការនិមន្តព្រះសង្ឃចំរើនបរិត្ត, ការទេសនា និងការប្រគេនចង្ហាន់សង្ឃ ៨០ អង្គ ដោយការទទួលវេនបន្តគ្នានៃសិស្សានុសិស្ស ព្រមទាំងពុទ្ធបរិស័ទ មានសម្ដេចព្រះមហាក្សត្រិយានីជាប្រធាន ជាប់រាល់ថ្ងៃអស់រយៈកាល ៧ ខែ ក៏មិនអស់ចិត្តអកចង់ធ្វើ រហូតដល់ដេកដណ្ដើមថ្ងៃគ្នា ។

ថ្ងៃ ៣ ១១ ១ ឆ្នាំរកា នព្វស័ក ព.ស. ២៥០០ ត្រូវនឹងថ្ងៃទី ៣ ខែធ្នូ ឆ្នាំ ១៩៥៧ រំកិលព្រះសពដង្ហែដោយក្បួនព្រះរាជទ្រព្យជាផ្លូវការ ទៅតំកល់ក្នុងព្រះមេរុ ដែលសាងសង់ឡើងថ្មី ខាងជើងព្រះបរមរាជវាំង ធ្វើបុណ្យបូជាព្រះសពអស់វេលា ៥ ថ្ងៃ ៤ យប់ ទើបហែព្រះធាតុមកវត្តលង្កាវិញ ។ សម្តេចក្រុមព្រះមុនីរេត ទ្រង់ទ្រព្រះធាតុទៅបញ្ចុះក្នុងប្រាង្គមុខវិហារវត្តលង្កា នៅវេលាព្រឹកថ្ងៃសៅរ៍ ១៥ កើត ខែមិគសិរ ( ៧ - ១២ - ៥៧ ) ។ ក្នុងវេនេះ មានពិធីធ្វើបុណ្យបង្ហើយកិច្ច អស់វេលា ១ ថ្ងៃ ១យប់ទៀត ជាការកក្រើករំពើកដ៏ក្រៃលែង គួរជាទីអស្ចារ្យ ។

សម្តេចព្រះធម្មលិខិត ល្វី · ឯម កើតឡើងធ្វើប្រយោជន៍ឲ្យសាធារណជន មិនត្រឹមតែក្នុងកាលគង់ព្រះជន្មនៅឡើយទេ ពោះបើសម្តេចទទួលអនិច្ចធម្មទៅហើយ ក៏អ្នកនៅខាងក្រោយតែងតែបានទទួលផលប្រយោជន៍ផ្សេងៗ ជាទីពេញចិត្តអំពីការងាររបស់សម្តេចក៏មាន អំពីឧត្តមគតិរបស់សម្តេចក៏មាន អំពីព្រះធាតុរបស់សម្តេចក៏មាន ។

## អ្នកប្រាជ្ញកើតក្នុងទីណា
## សេចក្តីចំរើនកើតក្នុងទីនោះ

ប្រវត្តិសម្តេចព្រះធម្មលិខិត ល្វី–ឯម ចប់ត្រឹមប៉ុណ្ណេះ

ថ្ងៃ ៣ ៩ ១ ឆ្នាំមមីអដ្ឋស័ក ព.ស. ២៥០៩ ត្រូវនឹងថ្ងៃទី ៦ ខែធ្នូ ឆ្នាំ១៩៦៥

ឈឹម · ស៊ុម

# វចនានុក្រមសំស្ក្រឹត-ខ្មែរ

(ត)

*ព្រះមហា ចា៉ង-ទាត់ រៀបរៀង*

អនៃភ្ឫត្យ    នបុំ. បំណុះផ្លាស់ប្តូរបាន ។

អនោកឝាយិន៑    គុ. ដែលមិនដេកក្នុងផ្ទះ, ដែលដេកក្រោមដើមឈើ។

អនោកហ    បុំ. ដើមឈើ ។

អនៅក្ឫត៑    ដែលមិនមានព្យញ្ជនជា ខម, អនៅក្រឹត ។

អនោជស៑    គុ. ខ្សោយ ។

អនៅទ្ធត្យ    នបុំ. ទឹកស្រក, កិរិយានឹង ។

អនៅបម្យ    គុ. ដែលប្រៀបមិនបាន, អនៅបម្យ ។

អនៅបធ    គុ. ដែលមិនមានការសង្គ្រោះ, ដែលមិនមាន ឱសថ ។ នបុំ. កិរិយាមិនមានសង្គ្រោះ ឬ មិន មានឱសថ ។

អន្ត    បុំ. ឆាយ, ព្រំ ។ ចុង, ទីបំផុត, ទីបំផុតពាក្យ

ឬ ប្រយោគ ។ សេចក្តីស្លាប់ ។ ទីជិតខាង ។ កិរិយា រូប, មោក្ខ, កិរិយាដោះស្រាយ ។ ចំនួនដែលរាប់ពុំ មិនបាន ។ សភាព, ស្ថានការណ៍ ។ ខាងក្នុង ។ -តសិ ទៅដល់ទីបំផុត, ទៅដល់ស្លាប់ ។ ទៅខាង ក្នុង ។ យ៉ាងតិច ។ ដោយអាការដ៏អាក្រក់ ។ អន្តាទន្តមិ ខាងនេះខាងនោះ ។ អន្តាយក្ប ញ៉ាំងដល់ទីបំផុត ញ៉ាំងទល់ស្លាប់ ។ -ករ គុ. ដែលធ្វើឲ្យស្លាប់ ។ -ករណ នបុ. កិរិយាធ្វើ ឲ្យស្លាប់, កិរិយាធ្វើឲ្យខូច ។ -កាល បុ. អន្តកាល, វេលាស្លាប់ ។ -ក្បិត ដែលធ្វើឲ្យដល់ទី បំផុត ; បុ. សេចក្តីស្លាប់ ។ -គ គុ.ដែលទៅដល់ ទីបំផុត, ដែលស្និទស្នាលក្រៃលែង ។ -គត គុ. ដែលទៅដល់ទីបំផុត, ដែលលុះទីបំផុត ។ -គមន នបុ. កិរិយាទៅកាន់ទីបំផុត ។ -គាមិន គុ. ដែលទៅកាន់ ទីបំផុត ឬ ទៅកាន់សេចក្តីស្លាប់ ។ -ចរ គុ អ្នកត្រាច់

ចរតាមព្រំប្រទល់, អន្តចរ ។ _បាល បុំ. អ្នករក្សា

ព្រំប្រទល់ ឬ ប្រាសាទ, អន្តបាល ។ _វេលា

ស្ត្រី. អន្តវេលា, វេលាទីបំផុត, វេលាស្លាប់ ។ _សទ៑

បុំ. អ្នកអង្គុយទីបំផុត, សិស្ស ។ _អន្តេវាសាយិន៑

គុ. បុំ. អ្នកនៅចុងភូមិ, ជនវណ្ណៈសូទ្រ ។ _វាសិន

បុំ អន្តេវាសិន, សិស្ស ។ _វាសិត្វ នបុំ. ភាវនៃខ្លួនជា

សិស្ស ។

អន្តក គុ. អ្នកជិតស្លាប់ ។ បុំ. សេចក្តីស្លាប់ ។ _បុរ នបុំ. ឈ្មោះ

នគរ ។ អន្តកានន នបុំ. មាត់នៃអន្តកៈ គឺ

សេចក្តីស្លាប់ ។

អន្តរ៑ ក្រិ.វិ. នៅខាងក្នុង, នៅក្នុងបន្ទប់, កណ្តាល, ចន្លោះ, ខាងក្នុង ។

_អន្តរាង្គ គុ. ដែលមានអង្គខាងក្នុង, ស្និទ្ធស្នាល ។

បុំ. កិរិយាប្រាប់អាថ៌កំបាំង ។ នបុំ. ចិត្ត ។ _អន្តរា-

ត្មក គុ. ដែលនៅក្នុង ។ _អន្តរាត្មន៑ ព្រលឹង,

ចិត្ត ។ _អន្តរាបណា ចុំ. ផ្សារព្វនខាងក្នុង ។

អន្តរាយ គុ. អន្តរាយដែលមកនៅចន្លោះ, ឧបសគ្គ, វិគ្គប្រកះភ្លា ។ អន្តរារាម គុ. ដែលត្រេកអរនៅខាងក្នុង ។ អន្តរិត គុ. ដែលបិតនៅខាងក្នុង ឬ នៅផាកណ្ដាល, ដែលបាំង, ដែលបាត់ ដែលលេបបាត់, ដែលភ្លេច ។ អន្តរិន្ទ្រិយ ឧបុំ. ឥន្ទ្រិយខាងក្នុង ។ _គិត ដែលទៅក្នុង, ដែលនៅក្នុង, ដែលបាត់, ដែលបាំងបាត់, ។ _គិតមនស គុ. ដែលមានចិត្តនិកាស់។ _គិលគត គុ. ដែលជាប់នៅបំពង់ក ។ _គិលីត គុ. ដែលស្ពាក់នៅក្នុង ។ _គិរី ចុំ ឈ្មោះប្រទេស ។ _គិយិ ឈ្មោះប្រជាជន ។ _គ្និត្យ គុ. ដែលបាំងនៅខាងក្នុង ។ _គ្និហា ឧបុំ. បន្ទប់ខាងក្នុង ។ _ជិលបរ ជលនិភាសិទ ជលេគយ គុ. ដលចរ, ដែលចរក្នុងទឹក, ដែលនៅក្នុងទឹក, ដែលអាស្រ័យនៅក្នុងទឹក ។

( នៅមានត )

# ពិចារណាដើម្បីយល់តក្កវិជ្ជា

(៣)

លោក ហ៊ុន-គីមសៀ រៀបរៀង

អាកប្បកិរិយាដែលយើងត្រូវទប់ទល់ទៅវិញនោះ រួមមានតាំងពី :

ក- ត្រូវជៀសវៀស កុំនិយាយ ឬ ឆ្លើយតប (បើក្នុងករណីអាចជៀសផុត) ។

១- ពេលខ្លះ ១ ខ្ញុំឆ្លើយមិនបាន, ចាំខ្ញុំឆ្លើយទៅថ្ងៃក្រោយ ឬសួរទៅវិញថា : បងឯងសួរដេញដោលចង់យកចាញ់ឈ្នះឬ ? បើដូច្នេះចង់យកចាញ់ឈ្នះ ខ្ញុំសុំទោសមិនឆ្លើយទេ ។ (របៀបនេះប្រើក្នុងករណីដែលជៀសមិនរួច, នាំឲ្យបែកបាក់មិត្តភាព, នាំឲ្យអន្តរាយដល់ការអប់រំ ពីព្រោះមនុស្សនិយាយចង់យកចាញ់យកឈ្នះ យើងពិនិត្យទៅឃើញយល់ណាស់) ។

ខ- មានករណីខ្លះយើងត្រូវឆ្លើយតបវិញខ្លះ ១ ដែរ បើយើងយល់ថា វាមិននាំឲ្យមានអន្តរាយទេ គឺត្រូវឆ្លើយដោយការឆ្លើ, ឆ្លើយដោយសំដី ។

ឃ- ឆ្លើយពន្យល់ដោយពាក្យផ្អែមល្ហែម ប្រើសំដីអប់រំ (ដាច់ខាតកុំខឹងកុំខ្ចាសអៀន) ប្រើអាកប្បកិរិយាទន់ភ្លន់ ស្មោះត្រង់ ឆ្លើយយ៉ាងណាឲ្យអ្នកស្ដាប់គេយល់បានថាយើងស្មោះត្រង់, មានបំណងល្អ គ្មាន

*គំនិតរករឿងឬស្អប់គេទេ កុំនិយាយដោយប្រើពាក្យទ្រគោះ នាំឲ្យគ្នាអៀនខ្មាស ធ្វើឲ្យគេចេះស្ដាយក្រោយចំពោះកំហុសរបស់គេ ដែលបានប្រព្រឹត្តខុសមកលើខ្លួនយើង . . . ។*

អ្នកពូកែលេងសំដី គឺជាអ្នកនិយាយតែការពិត, ការស្មោះត្រង់ មិននិយាយបញ្ចើចបញ្ចើ, បំអក ឬ បញ្ឆោត ... និយាយតែក្នុងស្មារតីដាស់តឿនគ្នា . ស្មារតីកសាងរិះរកផលប្រយោជន៍រួមដោយសមភាព ។

*ក្នុងការនិយាយបញ្ចេញយោបល់របស់ខ្លួនឲ្យអ្នកដទៃគេស្ដាប់ បើយើងចង់ឲ្យឆាយនិយាយ ឬថា និយាយមិនចេះចាល់ច្រក គេផ្ញើផើង មិនទាន់ យើងមិនត្រូវនិយាយបោកប្រាស់ និយាយបញ្ឆោត ឬ បំអក ដោយប្រើពាក្យផ្អែមពីរោះ តែចិត្តយើងឬស្យាទ ផ្ទុយទៅវិញ យើងត្រូវនិយាយតែការពិតឲ្យស្មោះត្រង់ កុំទម្លាប់ប្រើសំដីបន្ថែមបន្ថយ មួយយ៉ាងនេះ មួយយ៉ាងនោះ ។ល។*

*ភាគិនម្នាក់ និយាយថា " ទោះបីយើងមានមាត់ជប់និងពាក្យសំដីសម្បូណ៌យ៉ាងណាក៏ដោយ ក៏យើងមិនត្រូវនិយាយពន្លិចការពិតដែរ ពីព្រោះការពិត វាមិនដែលប្រែប្រួលទៅតាមពាក្យសំដីរបស់យើងទេ" ។*

*ផ្អែកតាមស្មារតីនៃឃ្លាខាងលើនេះ យើងយល់ថា : សំដីគឺជា*

មធ្យោបាយ សំរាប់សំដែងចេញនូវការពិត បើសំដីសំដែងការពិតបាន សំដីនោះមានតម្លៃ ពីព្រោះការពិតអាចអះអាងនូវតម្លៃឲ្យដល់សំដីនិយាយ ចុះបើសំដីនិយាយរបស់យើង សំដែងការពិតចេញមកក្រៅមិនបាន តើវាមានតម្លៃពីណាមក ? . . . នេះយើងមិនទាន់និយាយដល់ករណីខ្លះ ដែលអ្នកនិយាយការមិនពិត ត្រូវភាល់ប្រក គេហាមកេមតិះដៀលយ៉ាងអាមាសមុខថែមទៀតផង ។

ឧទាហរណ៍ដូចជាចាស់ ៗ ច្រើននិយាយថា "ងើបឡើងកូន ! មាន់រងាវហើយ ប្រញាប់ទៅស្រែ . . . " ។ ឃ្លានេះបានសេចក្ដីថា: កាលណាមាន់រងាវគឺភ្លឺហើយ ។

យើងសួរថា: ការពិត ពីព្រោះតែមាន់រងាវឬបានជាវាភ្លឺ? ឬមួយភ្លឺហើយ ទើបបានមាន់រងាវក្រោយ ?

ឧទាហរណ៍មួយទៀត ដែលយើងធ្លាប់តែឮគ្រប់ ៗ គ្នា "ណ្ហើយ កុំព្រួយចិត្តអីបងអើយ ! អាយុវាអស់ហើយបានជាវាស្លាប់ ; វាមានសំណាងបានជាត្រូវឆ្នោត " ។ល។

យើងសួរថា: ការពិត ដោយសារតែមានសំណាងឬ បានជាត្រូវឆ្នោត ឬមួយក៏ត្រូវឆ្នោតហើយ ទើបគេថា មានសំណាងក្រោយ? ។ ការពិតវាស្លាប់សិន ទើបគេថាអាយុអស់ ឬមួយក៏ពីព្រោះតែអាយុវាអស់បានជាវាស្លាប់ ? ។ល។ ទាំងនេះឯងហើយ ជាបញ្ហាដែលយើងត្រូវពិចារណាឲ្យឃើញ ដើម្បីប្រើសំដីឲ្យវាបានពិត ។

## បំពោះបញ្ហា ឬ ហេតុភេទអ្វីមួយដែលយើងមិនទាន់យល់ តើយើងត្រូវមានអាកប្បកិរិយាយ៉ាងដូចម្ដេច ?

មានបញ្ហាច្រើនណាស់ ដែលជីវិតរបស់មនុស្សត្រូវជួបប្រទះរៀងរាល់ថ្ងៃ ។ មានបញ្ហាខ្លះងាយបែបសាមញ្ញ យើងជួបភ្លាម អាចយល់បានភ្លាម ... មានបញ្ហាខ្លះទៀត បែបពិបាកជ្រាលជ្រៅ យើងប្រទះភ្លាម មិនអាចយល់បានភ្លាមទេ ។ ហេតុនេះ ក្នុងករណីដែលយើងជួបប្រទះនឹងបញ្ហា ឬ ចំណោទអ្វីមួយ ដែលយើងងឿងឆ្ងល់, មិនយល់ច្បាស់, ស្ដាប់មិនបាន ឬ ហួសមត្ថភាពរបស់យើង ។ មិនអាចយល់បាន ... យើងកុំគប្បីបោះបង់ចោល ឬ មានស្មារតីអស់សង្ឃឹមចំពោះបញ្ហានោះឡើយ ។

ផ្ទុយទៅវិញ យើងត្រូវសំគីពិចារណា ត្រិះរិះរកហេតុរកផល លបស្ទួរចាក់ចុចគេឯងឲ្យពន្យល់ ទម្លាប់រៀនសូត្រតាមមិត្រភក្ដិទោះតិច ឬ ច្រើន ... ប្ដេជ្ញាកុំបណ្ដែតបណ្ដោយ ទំលាក់ទោសទៅឲ្យវាសនាឲ្យសោះ ពីព្រោះគំនិតទំលាក់ទោសរបស់ខ្លួនទៅឲ្យវាសនា គឺជាគំនិតស្ដឹកទម្រន់ហួសសម័យ ។

ក្នុងករណីដែលយើងមានការរៀនសូត្រខ្លះ មានការចេះដឹងខ្លះ ... យើងក៏ត្រូវចេះដាក់ចិត្តគំនិតរបស់ខ្លួន ថានៅល្ងង់ជាច្រើននៅឡើយ ។ ការដាក់ចិត្តគំនិតបែបនេះ តើជាការបោកបញ្ឆោតខ្លួនយើង ឬ ?

ទេ!  ដាច់ខាតជាមិនបោកបញ្ឆោតខ្លួនឯងទេ ។ ការដាក់ចិត្តគំនិតឲ្យទាប, នៅល្ងង់ច្រើនទៀត ... ជាមធ្យោបាយមួយអាចនាំឲ្យខ្លួនយើងបានចេះច្រើនថែមទៀត ពីព្រោះថា ធម្មតាមនុស្ស តែងមានការពិបាកច្រើនណាស់ ក្នុងករណីដែលដាក់ខ្លួនថានៅល្ងង់ច្រើន (ច្រើនតែល្ងង់ពិត ហើយដាក់ខ្លួនជាចេះ) ការពិតគឺគំនិតដែលដាក់ខ្លួនថានៅទាបនៅល្ងង់ច្រើននេះហើយ ដែលនាំឲ្យយើងមានស្មារតីខំប្រឹងរៀនតទៅទៀត ឈប់សន្សំការចេះដឹងពីអ្នកដទៃ សន្សំការពិសោធឲ្យបានច្រើន ... ដើម្បីផ្ទៃលោកឲ្យកើតឲ្យបានទៅជាមេរៀនរបស់ខ្លួនទៅអនាគត ។ល។

## ហេតុណាដែលគេហៅថាវោហារ ?

បាតុភូត (Phénomène) ទាំងឡាយ នៅក្នុងសង្គមមនុស្ស វាអាចចូលទៅក្នុងវិញ្ញាណរបស់មនុស្សបាន អាស្រ័យដោយសារមនុស្សចេះប្រើឥន្ទ្រិយរបស់ខ្លួន ពោលគឺភ្នែក, ច្រមុះ, មាត់, ត្រចៀក, កាយ ។ បាតុភូតទាំងអស់និយាយសង្ខេប កាលណាវាបានចូលទៅក្នុងវិញ្ញាណរបស់មនុស្សហើយ វាអាចនាំឲ្យមនុស្សមានការពិចារណា មានការគិតការត្រិះរិះ ដែលជាចលនានៃខួរក្បាលដើម្បីយល់នូវសភាវៈទាំងនោះថាជាល្អឬអាក្រក់, ខុសឬត្រូវ ... ។ល។ បន្ទាប់ពីការត្រិះរិះឲ្យយល់មក មនុស្សត្រូវលាតត្រដាងការចាប់អារម្មណ៍របស់ខ្លួននោះ ឲ្យចេញ

មកក្រៅដោយសំដីពោលគឺការនិយាយ ។ និយាយមួយបែបទៀតថា ក្នុងសម្ភារភាវូបនីយកម្ម ( Matérialiser ) គំនិតឬសតិអារម្មណ៍ឲ្យចេញមកក្រៅ មនុស្សគេប្រើសំដីជាមធ្យោបាយ ហេតុដូច្នេះ សំដីវាមាននាទីនិងករណីយកិច្ចសំខាន់ណាស់ ក្នុងវិស័យអូសទាញគំនិត, បញ្ចុះអន្ទើលមនុស្ស តាមបំណងរបស់មនុស្ស ។

មនុស្សទាំងអស់គ្នា សុទ្ធតែចេះនិយាយ ប៉ុន្តែការចេះនិយាយឲ្យបានក្បោះក្បាយ និយាយឲ្យអ្នកស្ដាប់មានការចាប់អារម្មណ៍ត្រូវ ការនិយាយឲ្យបានទទួលជ័យជំនះជាដើមនោះ មិនមែនអ្នកណាក៏ចេះតែធ្វើបានទាំងអស់គ្នាទេ ។ ការនិយាយបែបនោះ ត្រូវមានបញ្ចូញសំឡេងលើកដាក់ . . . សិល្បៈក្នុងការណាត់ត្រដាងគំនិតឲ្យមានការទាក់ទង ... ដែលយើងហៅថា " វោហារ " ។

ដូច្នេះ " វោហារ " គឺជាអ្វី ? ។ ឆ្លើយឲ្យងាយយល់ទៅថា វោហារគឺជាសំដីនិយាយ ប្រកបដោយមានវិធីល្អណាមួយ សំដីមានផ្លែផ្កាក្បោះក្បាយ មានហេតុផលគ្រប់គ្រាន់ តាមលក្ខណៈវិទ្យាសាស្ត្រ ប្រកបដោយវិចារណញ្ញាណតក្កវិជ្ជា ដែលអ្នកស្ដាប់អាចយកទៅធ្វើជាមេរៀនសិក្សាអប់រំខ្លួនបាន ។

មនុស្សដែលមានវោហារ គឺជាមនុស្សចេះរៀបចំខ្សែគំនិតរបស់ខ្លួន ដើម្បីនិយាយឲ្យបានកុះករ, ក្បោះក្បាយ ( គ្មានការផ្ទុយនៅក្នុង

សំដីឬគំនិតរបស់ខ្លួន ) លាតត្រដាងបាននូវការពិតនិងការត្រូវហើយមាន ប្រយោជន៍ដល់អ្នកស្តាប់ នឹងនាំឲ្យអ្នកស្តាប់ងាយយល់បានផង ពីព្រោះ អ្នកមានវោហារគេអាចហៅថា វិស្វករសំដី ឬជាងសំដី ក៏បានដែរ ហេតុនេះ តោងចេះនិយាយឲ្យក្បោះក្បាយជ្រាលជ្រៅ តែត្រូវឲ្យអ្នក ស្តាប់គ្រប់ប្រភេទ ងាយយល់ ងាយស្តាប់បាន ។ល។

និយាយដល់វោហារ យើងត្រូវនិយាយដល់ការពិត, ការសុច-រិត, ការល្អ, យុត្តិធម៌, ការត្រិះរិះក្នុងគោលបំណងដោះស្រាយបញ្ហាស្មុគស្មាញ នៅក្នុងដំណើរជីវិត . . . ។ល។ ពីព្រោះថា វោហារ គឺជា មធ្យោបាយសំដីដែលគេប្រើក្នុងការនិយាយលាតត្រដាងគំនិត ឬការចាប់ អារម្មណ៍ណាមួយ ប្រកបដោយអត្ថរស មានប្រយោជន៍, ថ្លៃថ្នូរ . . . ពីព្រោះវាលាតត្រដាងបាន នូវការពិត, ការត្រូវ, សេចក្តីយុត្តិធម៌ ។ ផ្ទុយទៅវិញ បើយើងប្រើវោហារក្នុងគោលបំណងលួចបន្លំ, បោកប្រាស់ កុហក, មិនសុចរិត . . . វោហាររបស់យើង មុខតែត្រូវសាបសូន្យ, ត្រូវអស់តម្លៃ, បាត់វោហារ ពីព្រោះការបោកបាប, អំពើទុច្ចរិត, ការ បោកប្រាស់ មិនអាចរក្សាសេចក្តីថ្លៃថ្នូរ ទប់ទល់ជាស្ថាពរ ចំពោះការ សាបសូន្យបានឡើយ ។ បើយើងប្រព្រឹត្តអំពើអ្វីមួយខុស មានតែការ ទទួលកំហុសនោះដោយស្មោះត្រង់ ដើម្បីកែប្រែប៉ុណ្ណោះទេ ទើបជា ការមានតម្លៃ, បើយើងយកវោហារទៅនិយាយកែសម្រួល ឲ្យបានល្អវិញ

នោះគេភ្ជាប់ទៅហ៍សប្តុយុរអន្ទែង ពិតប្រាកដជាមិនបានល្អទេ ពីព្រោះការពិត វាមិនអាចប្រែក្លាយទៅតាមសំដីយើងបានឡើយ ។

ឧទាហរណ៍ : អ្នកមួយយល់ថា : បើចង់បំបាត់លោភ ត្រូវបំបាត់សម្ភារៈទាំងអស់ ។

អ្នកមួយទៀតត្រឡប់ជាយល់ថា : បើចង់បំបាត់លោភ ត្រូវបង្កើតសម្ភារៈនោះ ឲ្យកាន់តែច្រើនឡើងទៅវិញ ។

យោបល់ទាំងពីរនេះ តើអ្នកណាខុស អ្នកណាត្រូវ ? អ្នកមានហេតុផល ទើបថាត្រូវ ... ។ល។ (នៅមានត)

ហ៊ុន-គីមសៀ អ្នកបង្រៀនអក្សរសាស្ត្រ
នៅវិទ្យាល័យ ភ្នំពេញ

# ព្រះរាជនិពន្ធរាមកេរ្តិ៍

ភាគ ១១

(ត-ចប់)

លោក ឌឹក-គាម

ស្រាវជ្រាវ និង រៀបរៀង

កាលនោះ ព្រះបាទជនកធិបតីនោះ លុះព្រឹកព្រាងព្រះសុរិយេ ព្រះអង្គស្តេចតើនចាកទីបន្ទំបរមសយ្យាសន៍ ស្រង់ព្រះភក្រ្តស្រេច ស្តេចទ្រង់គ្រឿងរុងរឿងពណ្ណរាយ ហើយស្តេចក្រាយយាងព្រះបាទាចេញមកកាន់កេងមណីរតន៍ ៗ លុះស្តេចមកដល់ហើយ ក៏គង់លើបល្ល័ង្កកែវនៅក្រោមស្វេតច្ឆត្រ នាកណ្តាលហ្វូងសេនាមន្ត្រីសេនីយ៍យោធា ទើបស្តេចមានព្រះឱង្ការប្រាប់ទៅហោរថា ម្នាលហោរ ចូរអ្នកមើលឫក្សពេលាណាបានល្អ ដើម្បីអញនឹងអភិសេកព្រះរាជធីតា ។

គ្រានោះ ទើបលោកហោរាចារ្យធំ បានស្តាប់ព្រះឱង្ការហើយ ក៏ក្រាបថ្វាយបង្គំ ចាប់យកក្បួនទិន្តការេន គាំងលេខគុណហារលុបលេខបានលព្ធ ហើយគាំងហារសម្រេចផ្តាច់យកមកបូកតាមតម្រាសៀវភៅគេទផែនដី គុណហារទៅ ឃើញទាំងពាក់វិនយមកួនអាគ្នេយ៍ចាក់ការក្ខធំក៏ឫតផង ៗ ទំនងទំនាយឫក្សពេលាបាន មហាសិទ្ធិជោគថា ទេវាមកប្រជុំគ្នានៅភ្វារពសី ឃើញល្អព្រមហើយ ទើបក្រាបបង្គំ

ទូលសម្តេចព្រះបរមកពនរបតីថា បានឫក្សល្អនៅថ្ងៃ ៣ កើត ថ្ងៃច័ន្ទ វេលានាទីពីព្រឹក ១៦ ជាន់ឆាយនោះ ឫក្សល្អណាស់ សូមភានគ្គព្រះករុណានឹងធ្វើការមង្គលសរិវេឡូនាស្ថាពរជាសុខក្សេមក្សាន្ត គ្មានអន្តរាយពគី នឹងចំរើនសុខសិរី គ្រប់ទិនទិវាកត្រីយាម ។

កាលនោះ ព្រះបាទជនកធិបតី បានស្តាប់សេចក្តីហោរាទូលដូច្នោះហើយ ក៏ទ្រង់ត្រេកអរណាស់ ទើបត្រាស់ទៅនឹងសេនាបតីជាធំថា ចូរលោកចាត់ចែងប្រាសាទកែវជ័យឲ្យប្រពៃ ដោយគ្រឿងអលង្ការ ។

គ្រានោះ សេនាបតីក៏ទទួលព្រះឧង្ការមហាក្សត្រ ហើយក៏ក្រាបថ្វាយបង្គំលាវិលថយចេញមក ទើបចាត់ចែងតាក់តែងរៀបមហាប្រាសាទដ៏ល្អខុតាសពណ្ណរាយរុងរឿង តាំងក្រាលលាតចៀវព្រំ រៀបចំតាំងខាងក្នុងខាងក្រៅ តាំងឡប់ឡែរចំបាំងរាំងនន ហើយយកទឹកមហាខទឹកតាំង ៥ ព្រះគង្គាសុធារសដាក់ចុះក្នុងសង្ខ ហើយរៀបមានតាំងបល្ល័ង្កពេជ្រកែវមណីរតនា មានតាំងស្វេតច្ឆត្រ មានតាំងព្រះទម្រង់រតន៍កែវមរកតទៀនជ័យ បាយសីធំឆ្វេងស្តាំ ហើយបង្គាប់ទៅសង្ឃការី ដំខានប្រជាឲ្យទៅនិមន្តព្រះមហាអាចារ្យ ។

គ្រានោះ ពួកសង្ឃការីក្រាបថ្វាយបង្គំលាចេញទៅ ហើយក៏នាំគ្នាលីលាត្រាច់ត្រង់តម្រង់អាស្រមកុដិ ។ លុះមកដល់ទីអាស្រមសាលាហើយ ក៏ក្រាបនមស្ការព្រះសិទ្ធាមន្តាទក់សីជាធំ តាំងពួកគណៈយោគី

# ពិចារណាដើម្បីយល់តក្កវិជ្ជា

(៣)

លោក ហ៊ុន-គីមសៀ រៀបរៀង

អាកប្បកិរិយាដែលយើងត្រូវទប់ទល់ទៅវិញនោះ រួមមានតាំងពី :

ក– ត្រូវគេចចៀស កុំនិយាយ ឬ ឆ្លើយតប (បើក្នុងករណីអាចចៀសផុត) ។

ខ– ពេលភ្លាម ៗ ខ្ញុំឆ្លើយមិនបាន, ចាំខ្ញុំឆ្លើយទៅថ្ងៃក្រោយ ឬសួរទៅវិញថា : បងឯងសួរដេញដោលចង់យកចាញ់ឈ្នះឬ ? បើដដែកចង់យកចាញ់ឈ្នះ ខ្ញុំសុំទោសមិនឆ្លើយទេ ។ (របៀបនេះប្រើក្នុងករណីដែលចៀសមិនរួច, នាំឲ្យបែកបាក់មិត្តភាព, នាំឲ្យអន្តរាយដល់ការអប់រំ ពីព្រោះមនុស្សនិយាយចង់យកចាញ់យកឈ្នះ យើងពិនិត្យទៅឆ្ងាយយល់ណាស់) ។

គ– មានករណីខ្លះយើងត្រូវឆ្លើយតបវិញភ្លាម ៗ ដែរ បើយើងយល់ថា វាមិននាំឲ្យមានអន្តរាយទេ គឺត្រូវឆ្លើយដោយការធ្វើ, ឆ្លើយដោយសំដី ។

ឃ– ឆ្លើយពន្យល់ដោយពាក្យផ្អែមល្ហែម ប្រើសំដីអប់រំ (ដាច់ខាតកុំខឹងកុំខ្មាសអៀន) ប្រើអាកប្បកិរិយាទន់ភ្លន់ ស្មោះត្រង់ ធ្វើយ៉ាងណាឲ្យអ្នកស្តាប់គេយល់បានថាយើងស្មោះត្រង់, មានបំណងល្អ គ្មាន

គំនិតរករឿងឬស្អប់គេទេ កុំនិយាយដោយប្រើពាក្យទ្រគោះ នាំឲ្យគ្នាអៀនខ្មាស ធ្វើឲ្យគេចេះស្តាយក្រោយចំពោះកំហុសរបស់គេ ដែលបានប្រព្រឹត្តខុសមកលើខ្លួនយើង ... ។

អ្នកពូកែលេងសំដី គឺជាអ្នកនិយាយតែការពិត, ការស្មោះត្រង់ មិននិយាយបញ្ចើបបញ្ចើ, បំអក ឬ បញ្ឆោរ ... និយាយតែក្នុងស្មារតីជាស់តឿនគ្នា , ស្មារតីកសាងរិះរកផលប្រយោជន៍រួមដោយសមភាព ។

ក្នុងការនិយាយបញ្ចេញយោបល់របស់ខ្លួនឲ្យអ្នកដទៃគេស្តាប់ បើយើងចង់ឲ្យងាយនិយាយ ឬថា និយាយមិនចេះភាល់ច្រក គេដេញដេងមិនទាន់ យើងមិនត្រូវនិយាយបោកប្រាស់ និយាយបញ្ឆោរ ឬ បំអក ដោយប្រើពាក្យផ្អែមតិពេះ តែចិត្តយើងឫស្យាទេ ផ្ទុយទៅវិញ យើងត្រូវនិយាយតែការពិតឲ្យស្មោះត្រង់ កុំទម្លាប់ប្រើសំដីបន្ថែមបន្ថយ ម្តងយ៉ាងនេះ ម្តងយ៉ាងនោះ ។ល។

វាគ្មិនម្នាក់ និយាយថា “ ទោះបីយើងមានមាត់ជប់និនពាក្យសំដីសម្បូណ៌យ៉ាងណាក៏ដោយ ក៏យើងមិនត្រូវនិយាយពន្លិចការពិតដែរ ពីព្រោះការពិត វាមិនដែលប្រែប្រួលទៅតាមពាក្យសំដីរបស់យើងទេ” ។

ផ្អែកតាមស្មារតីនៃឃ្លាខាងលើនេះ យើងយល់ថា : សំដីគឺជា

សុចិត្រា សុជាតា លុះដល់ពេលវេលានាទីហើយ សម្តេចកោសិយក៏នាំព្រះនាងពាយណ៍កមាសុរិយវង្ស, នាងសុចិត្រា សុជាតា សុនន្ទា សុធម្មា និងហ្វូងទេពកញ្ញាក៏នាំអង្គព្រះលក្ស្មីសិតា ៗ ទេពនិងហ្វូងទេពនារីទូវព្រះវង្សានុវង្សទាំង ២ ជាទី ក៏នាំគ្នាហែតាមមក ៗ លុះដល់ហើយទើបឲ្យក្សត្រទាំងពីរ អង្គុយរួមស្វេតច្ឆត្រឆ្វេងស្តាំ លើបល្ល័ង្កកែវសុវណ្ណរតនា ហើយយកព្រះហត្ថាកាន់ដាក់លើគ្នា ៗ

ទើបនិយាយពីនាងទេពធីតាស្រីសួគ៌ នៅក្នុងស្វេតច្ឆត្រពណ្ណរាយនិងពួកទេវតា ដែលគេប្រជាទីនោះ លុះឃើញព្រះនាងពាយណ៍សុរិយវង្សផ្សំគ្នានឹងនាងលក្ស្មីសិតាហើយ ទាំងអស់គ្នាក៏សែនត្រេកអរសោមនស្សាហើយក៏នាំគ្នាអញ្ជលីស្រែកថ្វាយសព្ទសាធុការកង ក៏នាំគ្នាបាចសាចទិព្វបុប្ផាមាលាចុះមក ដេរដាសពាសពេញធរណី រីក្លិនក្អូបនោះក៏ក្រអូបឈ្ងុយឈ្ងប់ ពិដោរសាយសព្វដូចអប់ទុកនៅទីនោះ ក៏ថ្វាយពរជ័យសម្តេចព្រះអវតារ ចូរឲ្យបានជាប្រធានក្នុងត្រៃលោកហោង ៗ

លុះបានឫក្សពារនាទីហើយ ក៏ហោរាឲ្យបើកពាយស៊ី គោះគងជ័យ វាយភ្លេងតូរ្យតន្ត្រី ឮគឹកកងរំពងកោលាហល ហើយអង្គព្រះឥន្ទ្រកោសិយក៏អុជទៀនជ័យបង្វិលពពិលពីខាងឆ្វេងទៅខាងស្តាំ ទេពនិងមនុស្សាដេរដាសដា ក៏នាំគ្នាទទួលពពិលតាមអណ្តាប់ចុះវៀនគ្នាមក លុះគ្រប់ ៧ ជុំតាមដោយតម្រាសៃយ្យ ទេវពជក៏លត់ភ្លើងទៀនបិទថ្វាស

ព្រះហស្តនោះក៏បក់ផ្សែទៅក្រសួបស្នូវតែក្រពេះបួងច័ន្ទមាន់ហមតាំង ៤ ក្សត្រស្រេចហើយ ។

កាលនោះ ព្រះវសិដ្ឋ ព្រះវិស្វាមិត្រ និងព្រះសិទ្ធាមន្តទាំង ៣ ព្រះមហាមុនី ទើបយកនូវទឹកស័ង្ខស្រោចទៅព្រះរាមនិងនាងសិតា ទើប្រាហ្មណ៍ព្រឹទ្ធព្រមទាំងអស់គ្នា អំណោយឲ្យព្រះទាំងពីរអង្គ ចូរមានសិរីសួស្តីពិព័ទ្ធមង្គលជយាតិរេក សូមឲ្យស្តេចសោយសម្បត្តិជាសុខក្សេមក្សាន្តគ្រប់ទិនទិវាជានិរន្តរ៍សោភាគ កុំឲ្យមានរោគភយន្តរាយឡើយ ។

កាលណោះ អង្គព្រះសហស្សន័យន៍ត្រៃចក្រ និងពួកទេពតារ៉ា បណ្ដានូវអស់ទេវតាដែលចុះមកជួយនោះ លុះសម្រេចការវិវាហមង្គល ទេវ-ពជនិងទេវ: ទេពនារីទាំងពួងនោះ ក៏មានចិត្តត្រេកអរសោមនស្សត្រៃក្រហើយក៏ឲ្យជ័យព្រម ៗ គ្នាថា ចូរឲ្យព្រះអង្គទាំងពីរ មានសួស្តីសិរីតេជៈ កុំឲ្យមានទុក្ខសោករោគភ័យ សូមឲ្យព្រះអង្គបានជាទីពឹងពំនាក់ក្នុងត្រៃចក្រ គព្រះវង្សពង្សព្រះហរិរក្សជាឡាក់លោកាធាត្រី ។ លុះថ្វាយពរឲ្យស័ព្ទសាធុការហើយ ទេវានូវតាមសអស់នោះ ក៏លាព្រះបាទទសរថ និងព្រះបាទជនកធិបតី ក៏ស្តេចទៅកាន់ស្ថានទីទៃ ៗ ហោង ៗ

កាលនោះ ទាំងពីរព្រះបិតុរង្គធិបតីនាថា លុះស្រេចសម្រេចការវិវាហៈហើយ ស្តេចក៏សែនសោមនស្សត្រៃត្រេក ទើបនាំព្រះរាមសុរិយ-វង្សនិងអគ្គសីតា យាត្រាចាកទីអាសនៈ ហើយក៏ស្តេចទៅឯប្រាសាទ

ហោង ៗ គ្រានោះ វីអង្គព្រះហរិរក្សទេពសភៈនោះ លុះដល់ពេល ព្រលប់ផុតសែងព្រះសុរិយ៍នះហើយ ព្រះចន្ទ្រចែងរស្មីរះភ្លឺថ្លា ព្រះអង្គ ទ្រង់រំពឹងក្នុងចិត្តរឹតរឹងតែស្នេហានៃអង្គអគ្គរេសសីតាណាស់ ហាក់ទីង ប្រេះព្រះឧរក្លាយជូរធ្លោះហើយ ទើបព្រះអង្គស្រង់ព្រះភក្ត្រជម្រះអង្គហើយ ស្តេចទ្រង់គ្រឿងអាភរណ៍គ្រប់រឿង ល្អល្អះដូចដួងព្រះសុរិយប្រាយស្តេច ក៏ក្រោយចុះចាកវិមានកែវរតនមណី ចូលទៅកាន់ល្វែងនាងសីតាយៅវ មាល្យហោង ៗ ដល់ហើយ ព្រះអង្គក៏គង់លើបល្ល័ង្កកែវអលង្កត ហើយព្រះអង្គក៏សែនសោមនស្សព្រះចិន្តាបណ្តាលឲ្យស្ទុះក្រោកទៅអង្គុយ ជិត ពិនិត្យមើលនោមនាងទេវនារី មានពណ៌សម្បុរល្អល្អះត្រចះត្រចង់ ព្រះអង្គក៏រឹងរឹតចម្រើនព្រះទ័យថែមទៀត នាងល្អតាំងព្រះភក្ត្រផូរផង់ត្រ- ចះត្រចង់ ដូចវង្សដួងខែ ព្រះកូមោះនោះ កោងដូចកៅទណ្ឌធ្នូ រីនេត្រានាងល្អដូចភ្នែកម្រឹគា នាងល្អតាំងព្រះភក្ត្រព្រះឧស្ឋព្រះកាណ៌ ព្រះ សូរង៍ន្ទព្រះចរិតបុកតវិយោបថស្រគត់ស្រគំសមទូវនរលក្ខណាលោម ព្រម អាការៈតាំង ៣២ ក៏ឥតមានអាក្រក់ត្រង់ណានោះគ្មានឡើយ ទតហើយ វិងទតទៀត រឹតរឹងតែស្រឡាញ់ណាស់ឡើង ទើបព្រះអង្គមានព្រះ ពចាត្រាស់ទៅថា នោមអើយនោមឆ្ងៅយៅវមាល្យ ព្រះបិតុរង្គនាង ស្តេច ទ្រង់ផ្សងសច្ចាឲ្យលើកធ្នូស័យ របស់សម្តេចព្រះឥសូរលោកា ប្រាជ្ញាកេ ត្តកសាងទីងនាងយោវលក្ខណ៍ឲ្យសមសក្តិ សុរិយវង្សពង្សា បង់បាតញ

ដំណើងកាលណាហើយ ទុកក្រៀមរីងរំជួលក្តួលក្តុកចិត្តទីងទប់ពុំបាន ទើប បានជាបង្ក្រាប់ស្វែងមកមិនគិតកាយពិបាកគោកយ៉ាកឡើយ ហើយទំ ទុកត្រុក ដោយព្រៃភ្នំក្រំថ្មបរលើមក ជាហេតុបុណ្យកុសលផលាបាន សាងមកពីទាយ ទីងអង្គអូនវនិតាយុផាកក្រ ទើបបងមកលើកធ្នូសិល្ប ជ័យបាន តាំងទេពទេពគ្រប់ស្ថាន បានឃើញជាសាក្សី សូមអូនស្រី អ្នកអាណិតបែរកក្រោមកវាចាទីងបង ៗ

កាលនោះ នួននាងសីតាទេវី ក៏ថយចុះបាកចិត្តទៃនកែវគនា ហើយនាងក៏ក្រាបទូនព្រះភក្ត្រទៅ ក៏បង្កើតជួងមនោហបុទ័យដែលខ្ទាំង បណ្តាលទប់ស្មើរពុំបាន តែយាវមាល្យក៏លួចគៀងន័យន៍នេត្រ សម្លឹង មើលអង្គព្រះចក្រ ទៅឃើញជួងព្រះភក្ត្រានោះល្អដូចអង្គព្រះទិនករ គង់ ថេបរកណ្តាលអម្ពរ ដ៏គ្មានពពកបាំងបាំង នាងក៏គន់មើលសព្វគ្រប់ទៅ មិនមានឃើញត្រង់ណាឲ្យតាស់ព្រះទ័យនោះគ្មានឡើយ មើលហើយ មើលទៀត មិនហ៊ានឲ្យប្រទះព្រះនេត្រព្រះអង្គឡើយ ហើយនាង ក៏រំងឹរតែស្រឡាញ់ពេញព្រះទ័យ ធោមស្រីនាងក៏អង្គុយធ្ងាយ ទូន កាយបង្គំក្រាបស្ងៀម មិនមានវាចាថាអ្វីឡើយ ៗ ទើបអង្គ ព្រះវង្សទេវេសថា ម្នាលប្អូនសំឡាញ់បងអើយ ម្តេចឡើយក៏អ្នកក្រោក ទៅអង្គុយឆ្ងាយ រំហើងតាំងពីនោកនេះ មិនមែនជាបាប់បងក៏ហែង តែងវាចា ដោយទុបាយកល ទុបុលខិតអ្វីឯណាទីមួយ ៗ នោះក៏ទេ ៗ

គឺសម្តេចព្រះបិតុរង្គទាំងសងខាង ធ្វើការរៀបមង្គលហើយមានទាំងព្រះកោសិយខ្ញូវទេពនារីនិងទេពតាទេវ មកអភិសេកឲ្យយើងទាំង ២ រីយសសក្តិ៍សមស្មើគ្នា កុំអូនអ្នកគេចវេរត់ទៅណា ចូរគិតជាអ្នកឡើងមកលើខេនកែវមណី ជាវិមានរួមសេនង់បងហោង ។

កាលណោះ នាងសីតាទេវីបានស្តាប់ពាក្យហើយ នាងក៏លើកដៃឡើងវន្ទាទូលស្នងទៅថា ដែលព្រះអង្គទ្រង់ព្រះមេត្តាករុណានោះ ជាទីមានព្រះគុណបំផុតហើយ តែថា នឹងឲ្យខ្ញុំម្ចាស់នេះ ចូលទៅអង្គុយជិតនឹងព្រះអង្គនោះ ខ្ញុំម្ចាស់ពាល់គំនិតណាស់ មួយទៀត ដែលព្រះអង្គមានព្រះឧង្ការថា ដូចម្តេច ។ ខ្ញុំម្ចាស់ក៏ទទួលដាក់លើសិរសាទាំងអស់តាមតែលួងលូលីទ្រង់ព្រះមេត្តាប្រោស ។ ទើបអង្គព្រះនរបតីស្តីឆ្លើយតបទៅវិញថា អូនអើយអូន ដែលអូនថានោះ មិនគួរទេ ខ្លួនបងនេះ គ្មានគូនឹងរួមក្បែរស្នេហានោះទេ ទើបបានបងខំស្វាហ៍មកយកអាសាពាល់តែបានសម្រេចការ បានកែវកាលណាហើយ ទើបបានស្បើយល្ហើយល្ហៃទុក្ខាបន្តិច ។ ត្រាស់ក្សាន ព្រះអង្គក៏យាងចាកអាសនៈកែវពណ្ណរាយ ហើយចូលឱបអង្គអនង្គនួន មកដាក់លើខេនកែវអលង្ការហើយ ក្សត្រាទាំងពីរអង្គ ក៏ទ្រង់សេពសមមនោរួមសោមេត្រីប្រតិព័ទ្ធជាបរមសុខាហោង ។

កាលណោះ រីនាងសីតាយោវមាល្យ បានរួមសង្វាសនឹងព្រះ

ចក្រី នាងក៏មានសេចក្ដីបតីមេត្រីណាស់ទីនែអង្គព្រះស្វាមី ដោយស្រី នាងក៏គោរពរក្សាព្រះជនកជននីតាំងពីដើម ទូវអស់ស្រីស្នំក្រមការផង ក្រួចតាំងវៀងផ្ចាប់លងសព្វដងមកអស់ហោង ។ សម្ដេចព្រះនាង នាថក៏ទិត្យវៃបរែបអង្គខាងសម្ដេចព្រះចក្រា តាល់តែដល់ហួសវេលា ស្ដេចក៏ផ្ទំបរមសុខលក់ទៅហោង ។ លុះព្រឹកព្រាងស្វាងព្រះទិនករ ចប់ការវិភាហមង្គលហើយ ទើបអង្គសម្ដេចព្រះបាទធតរដ្ឋធិបតី ព្រះកូនស្ដេច ចង់វិលវិលត្រឡប់ទៅកាន់នគរបុរីវិញហោង ។ គិតហើយព្រះអង្គទ្រង់ ស្រង់ភាវីដម្រះព្រះអង្គស្រេច ស្ដេចទ្រង់គ្រឿងអាភរណ៍ភេទរៀងពណ្ណរាយ ស្រេចស្ដេចក៏ចុះចាកប្រាសាទកែវ ហើយស្ដេចយាងទៅគាល់ព្រះបាទ ជនកធិបតី លុះស្ដេចយាងមកដល់ហើយ ក៏គង់រួមអាសនៈដ៏ទិព្វភាស រង្សី កណ្ដាលពពួកសេនីយ៍មន្ត្រីគាល់គ្រៀបត្រា ទើបព្រះអង្គមាន ព្រះវាចាថា កូនស្រោនេះ ព្រះនគរតាំងពីដើមបានជាស្ថាពរបរមសុខ រួមនៃនគរជនជាតិ ទៅដល់អស់កប្បកល្បទីនគ្នាហោង ។ រីឯ ព្រះអង្គគម្រង់ពង្ស ចូរមានសិរីសួស្ដីសោយសម្បត្តិ ព័ន្ធភាពឲ្យបាន សេចក្ដីក្សេមក្សាន្តទៅ កុំឲ្យមានរោគាព្យាធិឡើយ ហើយខ្ញុំនឹង សូមលាវិលទៅ សុំតាំងព្រះកាមេសទិនអង្គអគ្គរេសសុណិសា ទៅកាន់ នគរទ្វារវតីសិរីអយុធ្យា នឹងបានគ្រប់គ្រងអាណាប្រជាជន ។

កាលណោះ ព្រះបាទជនកធិបតីបានស្ដាប់ព្រះវាចាហើយ ព្រះកូមី

កំពើងគិត ព្រោះដឿតព្រះអង្គស្តេចស្រឡាញ់ប្រតិព័ទ្ធព្រះរាជធីតាណាស់
ព្រះអង្គសែនព្រួយព្រះទ័យ តឹងក្នុងព្រះឧរាគិតថា ការនេះ បើអញ
ទំនងទូលទាស់មិនឲ្យទៅនោះ គំនិតក្រែងខ្លាចអំណាចព្រះទ្រង់ឫទ្ធិ គិត
ហើយទើបមានព្រះវាចាតបទៅវិញថា រីខ្ញុំសព្វថ្ងៃនេះ ដែលគ្រង
រាជសម្បត្តិពេញហៅថាសែនកំសត់ ទាំងរាជបុត្រាបុត្រី ១ នោះក៏គ្មាន
សោះឡើយ ហើយខ្ញុំក៏តាំងចិត្តគិតថា នឹងផ្ញើអាយុជីវិតលើព្រះរាម
និងនាងសីតា បំណងចង់ក្នុងចិត្តថា នឹងប្រគល់ស្វេតច្ឆត្រឲ្យសោយ
រាជសម្បត្តិតពង្សវង្សប្រក្រតីត្រាធិរាជ នៅក្នុងទីនគរមិថិលាជាមហាកេទ្វាង
លោកិយក្នុងជាត្រៃ, ឥឡូវនេះ អង្គព្រះបពិត្រនឹងនាំយកទៅ បីដូចជា
កាត់ផ្ដួនកែវជីវិត ឬកាត់ក្បាលសិរសាខ្ញុំ ១ សែនមហាទុក្ខាគ្រប់ទិនទិវា
រាត្រី សេចក្ដីទាំងនេះ នឹងទទឹងទាស់ព្រះរាជអាជ្ញាពុំបាន សូមទាន
ទ្រង់ព្រះមេត្តាខ្ញុំផង ៗ

កាលណោះ ព្រះបាទឧតវដ្តធិបតីទ្រង់បានស្ដាប់ហើយ ទើបស្ដេច
ឆ្លើយតបទៅវិញថា ណ្ហើយ, អ្នកកុំកើតទុក្ខសោកតូចចិត្តឡើយ រីមិថិលា
ជាទីនិងទាពកើក្រុងធំ មាតាក៏មិនស្ងួវឆ្ងាយប៉ុន្មានពីគ្នាទេ ហើយ
ក៏មិនពិបាកនឹងទៅនិងមកប៉ុន្មាន ឯអ្នកទាំងពីរជាបុត្រនោះគង់តែឲ្យទៅ
មកគាល់ហៀរនៅបម្រើ មិនមែនជីវិតសង្ខារក្សយកាលណា ក៏ប្រៀប
ឧបមាទៅនឹងព្រះអង្គដែរ បូរស្ដេចកុំកើតទុក្ខសោកក្នុងព្រះទ័យពេកឡើយ

កាលណោះ ព្រះបាទជនកចក្រពត្តិធិបតី បានស្តាប់សេចក្តីព្រះវង្ស ទេវិនហើយក៏ត្រេកអរហាក់ដូចបានពរទិព្វរស មកស្រង់រម្ងាប់ក្តៅ ហើយ ព្រះអង្គមានព្រះពាចាតបទៅវិញថា បើដូច្នោះ ខ្ញុំសុំផ្ញើរជបុត្រីកូនស្រី ទីនព្រះអង្គផង ចូរចិញ្ចឹមថែទាំរក្សា ដូចកូនបង្កើតក្នុងព្រះឧទរ ពោះ បើខុសត្រូវ ចូរប្រដៅខ្ញុំនាងដោយក្តីមេត្តាឲ្យបានខ្ញុំផង គ្រាស់ហើយ ទើបស្តេចប្រើស្រីបម្រើកំណាន់នោះ ឲ្យទៅអញ្ជើញព្រះកមានិននាង សីតា មកឲ្យគាប់ក្នុងគ្រាឥឡូវនេះ ។ គ្រានោះ ទើបនាងស្រី បម្រើនោះ ថ្វាយបង្គំលាទៅកាន់ប្រាសាទព្រះអង្គ ហាង ។ លុះបាន មកដល់ហើយ ក៏ចូលទៅក្រាបថ្វាយបង្គំ ទូលព្រះអង្គទាំងពីរថា ព្រះ បិតុរង្គទ្រង់បង្គាប់ ឲ្យខ្ញុំម្ចាស់មកអញ្ជើញស្តេចទាំងពីរទៅគាល់ ។

កាលណោះ ព្រះកមទិននាងសីតា បានស្តាប់ដំណឹងសេចក្តីថា ព្រះ បិតាស្តេចមានព្រះឧង្ការ ឲ្យហៅដូច្នោះហើយ ពុំលង់ឡើយ ក៏ស្តេច តែងព្រះអង្គទាំងពីរអង្គស្រេចហើយ ក៏ស្តេចយាងឡើងទៅគាល់សម្តេច ព្រះភូមិហោង ។ លុះស្តេចយាងមកដល់ហើយ ក៏ក្រាបថ្វាយបង្គំ គាល់អង្គសម្តេចព្រះបិតុរង្គទាំងពីរអង្គ រង់ចាំស្តាប់ព្រះឧង្ការ នៅទី កណ្តាលព្រះគំនាល់នោះហោង ។

កាលណោះ ព្រះបាទជនកចក្រពត្តិធិបតី ឃើញបុត្រពីរ ទាំងពីរមកគាល់ហើយ ព្រះអង្គទ្រង់ទតទៅឃើញលម្អដូចដួងព្រះសុរិយេន

និងចន្ទ្រា ទើបស្តេចមានព្រះឱង្ការទៅកាន់រាជបុត្រីថា ម្នាលសីតាកូនសម្លាញ់អាពុកអើយ កូនអើយ ចូរអ្នកស្តាប់ពាក្យអាពុកនឹងប្រដៅ ដ្បិតចៅនឹងចាកពីទ្រង់អាពុក ទៅនៅឯនគរយុធ្យាធានី ជាខ្ញុំបម្រើបាទបរិចារព្រះភស្តាស្វាមីធិរាជ ចូរកូននាងស្ងួនកាយ ផ្ញើខ្លួនផ្ញើជីវិតទុកទៅនឹងអង្គព្រះបិតានិងរាជស្វាមី ឲ្យអស់មួយជីវិតទៅ កុំកូនចៅអ្នកគិតថាខ្លួនអ្នកនេះជាអង្គអគ្គរាជទេវី ចូរកូនអ្នកបៀមកាយ អ្នកកុំមានសេចក្តីប្រមាទ ឧស្សាហ៍សង្វាតយកចិត្តទុកដាក់ នឹងកិច្ចរាជការ តាំងហ្មឺនអនង្គនាងនាថស្រីស្នំក្រមការបរិវារដោយជំនិត កូនកុំមានចិត្តធ្នាញព្យាបាទឡើយ ហើយមួយទៀត ព្រះជនកព្រះជននីទាំងពីរព្រះអង្គនោះ ប្រៀបដូចបិតាមាតាបង្កើតសិរសាអាត្មានាងហោង ៗ ចូរកូនកែវ អ្នកឧស្សាហ៍គោរព ដោយវត្តប្រណិប័តន៍ភស្តាស្វាមីទៅ នឹងមានសិរីសួស្តិមង្គល កូនកុំបង្កហេតុជាការមិនគួរ ឲ្យកើតក្តៅសៅហ្មង ដល់ល្អងធូលីព្រះបាទស្វាមីឡើយ ហើយចូរកូនស្រឡាញ់ដោយស្មោះសរជួមចិត្តជានិច្ចនិរន្តរ៍ ចូរកូនអ្នកចាំពាក្យអាពុកប្រដៅ កុំភ្លេចឡើយ ៗ

កាលណោះ រីនាងសីតាយោវមាល្យបានស្តាប់ព្រះឱង្ការ ព្រះរាជបិតាទ្រង់ឲ្យឱវាទានដំបូន្មានដូច្នោះហើយ ព្រះនាងក៏ឱនសិរពកបក្រាបបង្គំទៀបជិតព្រះបាទព្រះបិតា ហើយនាងក៏តបទូលថា ឱសម្តេចព្រះបិតុរង្គទ្រង់បារមី ! ព្រះគុណទាំងពីរធ្លាប់តែមេត្តាប្រោសប្រណីកូន

ចិញ្ចឹមកូនថែទាំបីបមថ្នមរក្សាតាំងតែពីតូចនោះ លុះដល់ធំមក ព្រះបិតាព្រះមាតាទាំងពីរ មិនដែលឲ្យមានសៅហ្មងថ្នមកូនដូចដួងជីវិត នោះបើនរូខុសត្រូវដូចម្ដេចម្ដា ព្រះអង្គក៏ទ្រង់មេត្តាប្រោសប្រដៅទូន្មាន ទាល់តែព្រះអង្គទ្រង់លាព្រត រហូតដល់វិលចូលមកព្រះនគរបុរី ព្រោះសេចក្ដីអាសូរករុណាទិងសន្ដោសប្រោសកូន ទើបតាំងពិធីលើកធ្វជសិល្បជ័យផ្សងសច្ចារកគូឲ្យស្មើយសសក្តិ ឲ្យសមវង្សសមពង្សសមត្រកូ និងឲ្យបានជាឡាក់កន្ទោងក្នុងលោកា ។ គួរឬ ខ្ញុំកូន មិនបាននៅគបស្នងសងព្រះគុណព្រះបិតុរង្គធិរាជ ទូលពណ៌នាក្សាន់ នាងក៏ទ្រង់ព្រះកន្សែងសោកា ហាក់ដូចជីវិតនឹងមរណាក្ស័យហោង ។

កាលណោះ ព្រះបាទជនកធិបតីនាថ ទាំងអង្គសម្ដេចព្រះមាតានោះ លុះឃើញកូនយំសោកាដូច្នោះហើយ ទាំងពីរអង្គក៏ទ្រង់ឱបក្រសោបបុត្រី ហើយក៏ស្រក់ទឹកនេត្រាថា ឱកូនកែវដួងជីវិត អ្នកកុំយំស្រែកពោលពណ៌នារាប់រៀបទៅថ្វី កូនអើយ ចូរកូនអ្នកកំសាន្តសោក ឲ្យស្បើយល្ហើយទៅ តង់តែអ្នកនឹងបានទៅមករកបិតាមាតា មិនមែនជាក្ស័យជីវិតនោះទេ គួរអ្នកមាសស្នេហ៍ ទៅគបស្នងព្រះបាទ ព្រះស្វាមីធិរាជធិបតី ទើបនឹងមានសិរីសួស្ដីមង្គលដល់កូន ចូរកូននាងស្ងួនចិត្តឲ្យល្អហោង ។

កាលណោះ នួនល្អងសីតា បានស្ដាប់ព្រះជនកព្រះជននី មានរាទីថាដូច្នោះហើយ នាងក៏លើកហត្ថាថ្វាយបង្គំហើយ ហាក់ដូចបាន

ទំពក់មែកស្រោចស្រង់ នាងក៏ស្រោកស្រង់ អន់ស្បើយល្ហើយល្ហៃទុក្ខសោក ទើបនាងក្រាបថ្វាយបង្គំ សុំលាឃ្លាតចាកព្រះបិតាព្រះមាតាទៅហើយ កាលណាឡើយ កូននឹងបានទៅបម្រើគាល់ហ្វៅដូចពីដើមមក ដូច្នេះសូមព្រះអង្គទាំងពីរ គង់នៅឲ្យសុខស្ពាពារមង្គលា ជានិរន្តរ៍ហោង ។

កាលណោះ ព្រះជនកធិបតី បានស្តាប់កូនហើយ ព្រះអង្គក៏នឹកអាណិតព្រះពជធីតាណាស់ ទើបព្រះអង្គទ្រង់ប្រែបែរព្រះភ័ក្ត្រត្រង់ព្រះកុមារហើយ ទើបមានព្រះវាចាថា ម្នាលព្រះកុមអើយ អ្នកនិងនាងសីតានេះ ជាគូកសាងមកជាមួយនឹងគ្នា ចូរអ្នកបញ្ចឹមរក្សាគ្នា ឲ្យសុចរិត បើខុសត្រូវដូចម្តេច អ្នកកុំអាលទោមនស្សក្រេវក្រោធពិរោធមួយទៀត អ្នកទៅនោះ ចូរឲ្យមានសិរីសួស្តីមង្គលវិបុលាការជាចិរ-និរន្តរ៍ ដូចឆត្រកែវ បើកបាំងមោលីទាំងលោកាហោង ។

កាលនោះ អង្គព្រះនារាយណ៍កុមារាធិបតី បានស្តាប់ព្រះបិតាព្រះបាទជនកហើយ ក៏ក្រាបក្រោមព្រះបាទា ហើយទូលទៅថា ដែលព្រះអង្គទ្រង់ព្រះករុណាព្រះគុណនោះជាទីបំផុត កុំឲ្យព្រួយព្រះទ័យភ័យបារម្ភ ទោះយោបើការអ៊ីៗ ទូលព្រះបង្គំជាខ្ញុំមិនឲ្យរង្កៀសដល់ព្រះអង្គាព្រះអង្គឡើយ ។ កាលគ្រានោះ ព្រះបាទធតរដ្ឋវង្ស លុះសម្រេចសទ្ទូនាហើយ ក៏លាព្រះបាទជនកធិបតីបក្រី ទើបនាំព្រះកុមារនិងនាងសីតាយាត្រាលក្សធោមឆាយ ស្តេចក៏ក្រាយចុះចាកអាសនៈ ហើយក៏យាងមកកាន់ប្រាសាទកែវពណ្ណរាយ ។

ចប់ខ្សែ ១១ ហើយមានខ្សែ ១២ ទៀត ។

# ឯកសារ សាស្ត្រាស្លឹករឹតនិងក្រាំង

*ដែលមាននៅវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យ*

លោក ញ៉ុក-ថែម រៀបរៀង

( ត )

បំណងរឿង " *សាស្ត្រា ក្រមសុភាសិត*[១] "

អ្នកនិពន្ធ *រកពុំបានឃើញ ។*

កាលបរិច្ឆេទ *ម.ស. ១៦១៥ ថ្ងៃច័ន្ទ ៣ កើត ខែកត្តិក ឆ្នាំរកា នក្សត្រ (គ.ស. ១៦៩៣) ។*

របៀបនិពន្ធ *ពាក្យកាយៈ ក្រិត្យក្រមផ្សេងៗ តាមប្រពៃណីពីបុរាណ ។*

ប្រភពរឿង *គម្ពីរព្រះធម្មសាស្ត្រពីបុរាណ ។*

លក្ខណៈឯកសារ *សាស្ត្រាស្លឹករឹត ១ ខ្សែ មាន ២៦ សន្លឹក ។*

---

១ នេះជាឯកសារក្រមបុរាណ ១ ទៀតដូចឯកសារមុននេះដែរ ប៉ុន្តែជាពិសេសក្រមនេះមានចែងអំពីន័យ នៃពាក្យសុភាសិត ៤ បទដូច្នេះ "មន្ទលេណា, សេនបថ, មណ្ឌកគតិ, សីហលោ"

មន្ទលេណា នោះ ឲ្យចៅក្រមពិចារណាសេចក្ដីសន្សឹម ៗ បីដូចស្ទឹងជ្រៅហូរទៅកាន់ស្រះត្រពាំងទាំងពួង ។

សេនបថ នោះ ឲ្យចៅក្រមរកសេចក្ដីដូចខ្លែងឆាបកូនមាន់ កុំឲ្យសត្វនោះប្រែប្រាណរួចបានឡើយ ។

មណ្ឌកគតិ នោះ ឲ្យចៅក្រមពិចារណាសេចក្ដីនោះ ដូចកង្កែបលោតទៅមុខហើយឈប់ក្រឡេកមើលឆ្វេងស្ដាំ ហើយទើបលោតទៅវិញទៀត ។

សីហលោ នោះ ឲ្យចៅក្រមពិចារណា យកអំណាចរាជសីហចេញអំពីគូហា ស្រែកនូវសម្រែកពន្លឺក ឲ្យសត្វអម្រឹតផងខ្លាច ទើបរកសេចក្ដីឃើញ ។

ចារជាអក្សរជ្រៀង ១ ទំព័រ មាន ៩ បន្ទាត់ ។ ឯកសារនេះ ពុទ្ធសាសនបណ្ឌិត្យ បានមកអំពីវត្តកណ្ដាលជុំ ខេត្តកំពង់ស្ពឺ លេខ ៩៨៣ ។

អត្ថបទផ្ដើម សុភមស្តុ សួស្តីស្រីសុភមង្គល ពហុលចេស្ដា ជយាតិរេក ១៦១៩ ស.ក. គោនក្សត្រ ៣ កើត កត្តិកមាសា ចន្ទវារ សាស័ព្ទគិមហោកឡានុក្កូលសម្បូរពិមលផុលអំពីព្រះរាជហឫទ័យ ព្រះបាទសម្ដេចព្រះឧង្ការ ព្រះជ័យចេស្ដាពរា ឥស្សរបរមសុរិន្ទ កូមិន្ទកូនាថ បរមខត្តិយសុរិយោវង្ស ពង្សា . . . ។ល។

អត្ថបទបញ្ចប់ មួយសោត នរជនផង មានក្ដីទៅប្ដឹងចៅក្រម បើចៅក្រមនោះ មានជម្ងឺឈឺដល់ស្លាប់ហើយ គង់តែកំណត់ពាក្យនៅដៃប្រពន្ធ កូនចៅក្រម មុននោះ ចៅក្ដីមកប្ដឹងចៅក្រមឯក្រោយវិញទៀត នោះឲ្យចៅក្រមឯក្រោយបង្គាប់ឲ្យយកកំណត់ពាក្យ អំពីប្រពន្ធកូនចៅក្រមមុន ដែលស្លាប់នោះ ឲ្យនាំមកប្រគល់នៅដៃចៅក្រមឯក្រោយវិញ ទើបស្រឡះអំពីប្រពន្ធកូនចៅក្រមមុននោះ ។ បើពុំបានកំណត់កំណត់ ចៅក្រមមុនប្រគល់ដល់ចៅក្រមឯក្រោយនោះឡើយ ។ បើយូរទៅ បាត់កំណត់ពាក្យគេ នៅដៃប្រពន្ធកូនចៅក្រម ដែលស្លាប់

នោះហើយ ច្បាប់នោះឲ្យសង្កិតគេ តាមរបស់តិចច្រើននោះ ឯង ឯក្រយាពិន័យនោះ ពុំឲ្យត្រូវប្រពន្ធកូននោះឡើយហោង ។ នេះច្បាប់សុភាសិត ។

\+ \+ \+

បំណងរឿង " សាស្ត្រា ក្រមធសភរិយា(១) "

អ្នកនិពន្ធ រកពុំទាន់ឃើញ ។

កាលបរិច្ឆេទ ម.ស. ១៦១៥ ឆ្នាំមមែនក្សត្រ ខែបុស្ស ថ្ងៃអាទិត្យ (វេលាព្រះជ័យជេស្ឋា គ.ស. ១៦៩៣)

របៀបនិពន្ធ ពាក្យកាយ ក្រិត្យក្រមផ្សេងៗតាមប្រពៃណីពីបុរាណ

ប្រភពរឿង គម្ពីរព្រះធម្មសាស្ត្រពីបុរាណ ។

លក្ខណៈឯកសារ សាស្ត្រាស្លឹករឹត ១ ខ្សែ មាន ២៩ សន្លឹក ។ចារជាអក្សរជ្រៀង ១ ទំព័រ មាន៥ បន្ទាត់ ។

ឯកសារនេះ បានមកពីវត្តគោក្តាលជុំ ខេត្តកំពង់ស្ពឺ ចុះលេខ ៩៨៣ ។ ចាស់គ្រាំគ្រាណាស់ហើយ គួរចារចម្លងសារជាថ្មី

---

១ ច្បាប់ទសភរិយានេះ អ្នកនកញ៉ាពិភក្សសេនីយ៍ ចារចប់នៅថ្ងៃ ៦ កើត ខែពិសាខ ឆ្នាំថោះនក្សត្រ ឯកស័ក ។

នេះក៏ជាច្បាប់ បុរាណ ១ ទៀត ស្តីពីច្បាប់ខុសលែង ដែលត្រូវក្នុងសម័យពីដើម ប្រហែលជាមតិក ក្នុងសម័យ ដូចច្បាប់មុនៗ នេះទៀតដែរ ។

អត្ថបទផ្ដើម: សុភមស្តុ ស្វស្តីស្រីសុភមង្គល ពហុលវេស្ថា ជយា
តិរេក ១៦១៨ មមែនក្សត្រ បុស្សមាសា អាទិត្យវារ មន្ទិ
ព្រះបាទសម្ដេចនរោច ព្រះបរមបពិត្រ អ្នកជាអម្ចាស់ . . .
ទើបព្រះបាទអ្នកជាអម្ចាស់ ត្រាស់បើកព្រះអំណាច ឲ្យទក-
ញ៉ាសុភាធិបតី ជាមាត់ផ្លូវក្រោមឲ្យស្រដីមុខពជការសារពើជំនុំ
សេចក្ដី យកខ្វាត់ អប្បក្ករចូលជាជង្វាយ ថ្វាយព្រះបាទអ្នក
ជាអម្ចាស់ច្បាស់ដោយនូវព្រះមាត្រានោះនេះ ។
មាត្រា ១ ពោះយោបីកជវង្សវ្រុនធ្នា ទកញ៉ាព្រះដី ទៅ ហ៊ុន
មានការ ឥតការ . . . ។ល។

អត្ថបទបញ្ចប់. បើប្រុសចង់លែងស្រី ស្រីពុំចង់លែងឡើយ ឲ្យចែក
របស់សំបាច់ជាភាគ ២ ភាគ ១ បានប្រុស ភាគ ១ បាន
ស្រី ។ ឯច្បាប់ឲ្យព្រះសុភាធិបតីពិចារណាគេទោស ទាំង
ស្រីទាំងប្រុស បើស្រីទោសធ្ងន់ ហើយលែងប្រុស ឲ្យផាត់តែ
ទ្រព្យដើមចេញ ឯទ្រព្យសំបាច់ត្រូវបានប្រុសទាំងអស់ហោង ។
មាត្រា ១ សោត ច្បាប់ព្រះរាជក្រិត្យ ត្រូវមុខការទកញ៉ាសុភា·
ធិបតីឲ្យបានដឹងនោះ ទុកជាមេបាម្ដាយឪពុក ប៉ាំងបំបាត់មុខ
ការព្រះបាទអ្នកជាអម្ចាស់ត្រាស់ពហូសក្តិឲ្យពិន័យជីង ៣ តម្លឹង
១៧ ហោង ។ នេះច្បាប់ទសករិយាសូរេចម៉្សះហោង ។

( នៅមានត )

# រឿងសាមកុក

ឧកញ៉ាវិបុលរាជសេនា

ទី-ភាគ ៦

ប្រែរៀបរៀង

(ក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ អ្នកវាងវៃឆ្លាតបើបានអាន
នឹងចេះឧបាយកលចំណាន ទាំងមានសន្តានស្នេហាជាតិ

យូរ—អ៊ុន

កាសៀនទីប្រឹក្សាទូលថា ក្នុងស្រុកឡុកអៀងនេះ ទូលបង្គំយល់ឃើញជាងម្នាក់ឈ្មោះ នៅអ្នក ឯនៅអ្នកនោះប្រកបតាំងថ្វីដៃ និងសេចក្តីរិះគិតប៉ិនណាប់ចំនួនណាស់ ចេះវិសេសលើសជាងឈើទាំងពួង ។ ចូចូក៏ឲ្យហៅនៅអ្នកចូលមកគាល់ ហើយត្រាស់ថា ចូរអ្នកធៀបផែនដីវាំងតាំងឲ្យមានព្រះទីនាំង ស្តេចចេញដំនុំដកការផែនដី ឯទីខាងមុខព្រះទីនាំងធំ ឲ្យធ្វើជាព្រះលាន មានសួនផ្កាចេនាផ្សេង ៗ ខាងល្វែងក្នុងឲ្យសង់ជាមន្ទីរដំណាក់ តាមថ្នាក់តូចធំ ឲ្យសមល្អជាងរបស់បុរាណ ។ នៅអ្នកក៏បានគូររាសជាផែនទីវាំងដំណាក់ ៩ ខ្នង ខាងមុខមានព្រះពជ-ពេនធំមាំមួនណាស់ ខាងក្នុងមានដំណាក់តូចធ្លាស់ជាលំដាប់គ្នា, លុះគូរផែនទីរួច ក៏យកទៅថ្វាយចូចូ ៗ ពិគ្រោះមើលសព្វគ្រប់ហើយ ត្រាស់ថា របៀបនេះល្អណាស់ សមគួរជាទីកន្លែងរបស់អ្នកមានបុណ្យ ស្អាត

ល្អគួរនឹងចិត្តយើងហើយ តែនៅខ្វះដើមឈើធំដែលត្រូវធ្វើសសរកេន្ទាង យើងមិនឃើញទីណានឹងមានឡើយ ។

ទៅអ្នកទូលថា មានព្រៃឈើមួយអន្លើ ឈ្មោះព្រៃអៀកឡុង បម្ងាយពីនេះប្រហែល ៣០០ សិន ( ១២ គីឡូ ) ជាយព្រៃនោះមានសាលទេព្រក្សមួយខ្នងគេសង់ទុកមក ជិតសាលទេព្រក្សនោះ មានដើមសាឡីមួយធំខ្ពស់ណាស់ កំពស់ប្រហែល ២០ ព្យាម ( ៤០ ម៉ែត្រ ) ទូលព្រះបង្គំឃើញថា ទឹងយកធ្វើជាសសរកេន្ទាងបាន ប្ដូមានអំណរណាស់ ត្រាស់ថា បើដូច្នោះ មានតែទៅកាប់ឈើនោះឲ្យយើងចុះ ។

ខណៈនោះ មនុស្សទាំងពួង ក៏នាំគ្នាទៅកាប់ឈើនោះ លុះទៅដល់ហើយ ក៏ផ្តាកាប់ទឹងជីងឬទឹងបកពន្លាកដាប់ក៏ពុំមុតសោះឡើយ ហើយក៏នាំគ្នាទៅទូលប្ដូវិញ ប្ដូមិនជឿ ក៏នាំគ្នាចេញទៅមើល ប្រហែល ៣០០ នាក់ លុះទៅដល់មុខសាលទេព្រក្ស ប្ដូចុះពីលើសេះ ក្រឡេកទៅឃើញដើមសាឡីខ្ពស់ធំ ត្រង់ល្អគ្មានបៀចសោះ ទើបឲ្យមនុស្សយកពូថៅ ចូលទៅកាប់ក៏មិនមុត អ្នកចាស់ប្រុជាក្នាក់ឆ្នាំស្រុកនោះ ក៏នាំគ្នាទូលចាស់ឃាត់ថា ដើមសាឡីនេះ ជាឈើចាស់បុរាណ មានចាស់ទុំនាំនិយាយតៗគ្នា មកថា អាយុឈើនេះ ប្រហែល ៣០០ ឬ ៤០០ ឆ្នាំហើយ មានទេព្រក្សខ្មោចបិសាច ឋិតនៅលើដើមឈើនេះ សូមកុំឲ្យទ្រង់បង្គាប់ឲ្យកាប់ឡើយ ។

ចុច្ឆព្រុដូច្នោះ កឹខឹងខ្លាំងណាស់ថា អញបានធ្វើជាធំសម្រេចកិច្ច-ការគ្រងស្រុកនេះជាង ៤០ ឆ្នាំហើយ អស់អាណាប្រជានុរាស្ត្រគ្រងស្រុក និងអារក្សអ្នកតាឯណា ដែលនៅដំបន់មណ្ឌលនានា ដែលត្រូវឡើងស្រុកនេះ កំសឹងតែជួកពឹងប្រស្រ័យ នៃបុណ្យអំណាចអញទាំងអស់ អញត្រូវការនឹងយកឈើនេះ ទៅធ្វើប្រាសាទពិមាន បើមានទេព្រក្សអ្នកតានៅលើឈើនេះ ព្រមឱ្យយើងឬមិនព្រមឱ្យ ថាម្ដេចក៏ថាមកចុះ លុះនិយាយហើយ ក៏គន្ទ្រាក់យកដាវហូតចេញពីស្រោម កាប់ដើមឈើសាឡីនោះ លុះកាប់ហើយ ក៏ពុស់ឡើងស្រែកយំទ្រហឹងលើចុងឈើ ដ៏ឈើនោះ ក៏ហូរចេញមកជាឈាមស្រស់ ៗ ៗ ចុច្ឆឃើញដូច្នោះ ក៏តក់ស្លុតរន្ធត់ស្មារតី បោះដាវចោលពីដៃ ហើយក៏ឡើងជិះសេះត្រឡប់ទៅកាន់វិញ ៗ លុះដល់ពេលយប់នោះ ក៏បណ្ដាលឱ្យចុច្ឆក្ដៅអន្ទះអន្ទែង ទឹងដេកក៏មិនលក់ ទឹងអង្គុយក៏មិនសុខ រសាប់រសល់ត្រឡប់ប្រែប្រួល ទាល់តែដល់យាមពីរ ទើបក្រោកចេញទៅអង្គុយលើកៅអី ធ្វេសលក់ទៅយល់សប្តិឃើញថា មានមនុស្សសក់វែង ដណ្ដប់សំពត់ខៀវ ដៃកាន់ដាវ ដើរតម្រង់ចូលមកឈរចំពីមុខចុច្ឆ ហើយលើកដៃចង្អុលមុខចុច្ឆ ស្រែកគំហកថា អញជាទេព្រក្សនៅលើដើមឈើសាឡី អញមិនព្រមឱ្យឈើនេះទេ គឺឈើនេះជារបស់អញ ឯងនឹងយកធ្វើទីលំនៅ នៅទទឹងទទឹងព្រះចៅហៀនគេ អញដឹងថាបុណ្យវាសនាឯងអស់ប៉ុណ្ណឹងហើយ អញនឹងសម្លាប់ឯងចេញឥឡូវនេះ ៗ

ចុច្ចុភ័យណាស់ ស្រែកយំឲ្យទាហានជួយ ទេព្រោះគេគ្រាក់ដាវ កាប់ចុច្ចុ ចុច្ចុភ័យណាស់ ភ្ញាក់ឡើងស្រែកដោយសំឡេងខ្លាំង ពេះ តែឲ្យឈឺក្នុងលលាដ៍ក្បាលខ្លាំងណាស់ លុះវេលាព្រឹកក៏ឲ្យហៅពេទ្យមក មើលការរោគ ពេទ្យបានមកត្រឹតែលាបថ្នាំ ទាល់តែអស់បំណេះ រោគនោះក៏មិនបាត់ឈឺ បណ្ដាមុឺនទាំងធំទាំងតូច ឃើញដូច្នោះក៏ជាទុក្ខព្រួយទាំងអស់គ្នា ។

ខណៈនោះ មានទីប្រឹក្សាម្នាក់ទូលថា មានគ្រូពេទ្យម្នាក់ឈ្មោះ ហ៊ីគា ចេះព្យារោគវិសេសណាស់ ទ្រង់ជ្រាបស្គាល់ឬទេ ចុច្ចុឆ្លើយថាពេទ្យនោះហើយឬ ដែលព្យាបុសដីថាយ នៅស្រុកគាំង-គាំងនោះ ហ៊ូហ៊ុមទូលថា នោះឯងហើយ ចុច្ចុថា យើងស្គាល់ដែរ តែថាពេទ្យនោះ ចេះវិជ្ជាមិនជាប្រមាណទេ ហ៊ូហ៊ុមទូលថា ពេទ្យនោះ សព្វថ្ងៃនៅស្រុកដីគួន ខេត្តថៃកុក សម័យនេះ គ្មានអ្នកណាប្រៀបស្មើទេ បើមើលរោគនណា ៗ ជួនកាលក៏ឲ្យថ្នាំផឹកខ្លះ លាបខ្លះ ជួនកាលក៏វះ ពុះ ដុត រំលាងចេញតែត្រឹមដកដៃចេញផុត ជម្ងឺក៏បាត់ឈឺចាប់ភ្លាម បើជារោគក្នុងពោះ ឲ្យផឹកថ្នាំចូលទៅ ម្ចាស់ខ្លួនក៏សន្លប់ បាត់ស្មារតី មិនដឹងខ្លួនប្រាណ ទើបយកកាំបិតវះពោះនោះស្រាវយក ពោះវៀនចេញមកក្រៅ លាងជំរះឲ្យអស់ស្មោកគ្រោក ហើយញាត់ចូលទៅវិញ ឲ្យដូចដើម ហើយដេរសាច់នោះ រួចលាបថ្នាំ ជម្ងឺខ្លះ

ក៏ជាក្តងរោគ ១ ខែ ខ្វះ ២០ ថ្ងៃ សះស្រឡះដូចដើមវិញ ។

មានមួយថ្ងៃនោះ ពេទ្យហ្លួងគោដើរទៅតាមផ្លូវថ្នល់ បានឮសំឡេងមនុស្សថ្ងូរនៅលើផ្ទះក្បែរផ្លូវ ក៏ដឹងថា រោគនោះមានពស់ពិសនៅក្នុងខ្លួន ។ ក៏ដើរចូលទៅស្រែកហៅអ្នកផ្ទះ ឲ្យចុះមកប្រាប់ថា អ្នកជម្ងឺនោះយើងនឹងមើលឲ្យជាបាន ទើបឲ្យយកខ្ទឹមគុយឆាយបុកឲ្យល្អិតដាក់ទឹកលាយប្រហែល ២ នាឡិ ឲ្យអ្នកជម្ងឺនោះផឹកឲ្យអស់ កាលណាអ្នកជម្ងឺនោះផឹកថ្នាំនោះអស់ទៅ ក៏ក្អួតធ្លាក់ដោយតាំងពស់វែង ២ ហត្ថបាយក្បូនចេញមកផង ជម្ងឺនោះក៏ជាស្រឡះអស់ទៅ ។

គ្រាមួយ កាន់តែងពួកស្រុកតាំងឡើងឈឺក្នុងពោះ ចេះតែក្អួតគ្រូកគ្រាក ៗ ទទួលទានបាយក៏មិនបាន ទៅជាស្គមលឿងអស់តាំងមុខមាត់ ទើបអញ្ជើញឲ្យពេទ្យហ្លួងគោទៅមើល ពេទ្យនោះ ឲ្យផឹកថ្នាំលេបអស់ទៅ ក្អួតចេញមកវិញ សុទ្ធតែដង្កូវមានក្បាលក្រហម នៅរស់រើកចំនួនប្រហែលជា ២ នាឡិ កាន់តែងសួរថា ហេតុអ្វីបានជាខ្ញុំកើតរោគដូច្នេះ ពេទ្យហ្លួងគោប្រាប់ថា ព្រោះអ្នកឯងយកសាច់ត្រីឆៅ ទៅភ្លាស៊ី បានជាកើតរោគដូច្នេះ ទោះបើនឹងក្អួតចេញមកប៉ុណ្ណោះហើយ ក៏នៅមិនទាន់ជាស្រឡះទេ លុះដល់ ៣ ឆ្នាំ រោគនេះនឹងត្រឡប់កើតឡើងវិញទៀត កាលបើកើតឡើងទៀតហើយ មើលមិនជាទេ គឺ

ដល់កំណត់អាយុរបស់អ្នកហើយ លុះកន្លងមក ៣ ឆ្នាំ គាត់ក៏ស្លាប់ ដូចពាក្យហោរាថាមែន ។

គ្រាមួយ មានអ្នកជម្ងឺម្នាក់ ឈឺទន់ពេកពកហើមឡើងខាងលើគ្របក្លៀក ចេះតែកើតឈឺចាប់ខ្លាំងណាស់ ទើបយកគ្រូពេទ្យហោរាទៅមើល ពេទ្យហោរាសំឡឹងមើលយល់ថា ដុំពកនោះមានសត្វបក្សីកើតនៅក្នុងនោះ អ្នកទាំងពួងឮដូច្នោះក៏នាំគ្នាសើច ពេទ្យហោរាក៏យកកាំបិតវះពកនោះចេញ ស្រាប់តែឃើញសត្វចាប ១ ហោះចេញមកហើរទៅ ពកនោះក៏ជាស្រឡះ ។

គ្រាមួយ មានម្នាក់ខ្ញុំហាំជាប់ទេះដើរបាត់ទៅ របស់នោះក៏បង្កើតជាដុំសាច់លេចយុរយារចេញមក ២ ដុំ, មួយដុំចេះតែឈឺចាប់ មួយដុំទៀតចេះតែរមាស់ ទើបគេគ្រូហោរាទៅមើល គ្រូហោរាឃើញហើយថា ដុំសាច់ដែលចេះតែឈឺនោះមានម្ជុលនៅខាងក្នុងចំនួន ១០ ម្ជុល ឯដុំសាច់ដែលចេះតែរមាស់នោះ មានគ្រាប់ស្កា(១) ពីរ នៅខាងក្នុង ១ ខ្មៅ ១ ស; អ្នកទាំងពួងមិនជឿ ពេទ្យហោរាក៏យកកាំបិតវះចេញ បានម្ជុលនិងគ្រាប់ស្កាដូចពាក្យថា, អ្នកទាំងអស់គ្នាក៏ជឿថាដូចទេពតា; វេលានេះ ពេទ្យហោរាមកនៅក្នុងផ្ទះផងតិរសៀ ឯទ្រនោះមិនឆ្ងាយណាស់ ជិតណាស់ទេ សូមឲ្យប្រាប់ហៅយកមករក្សាព្រះពក់នេះចុះ មុខជាទិន្នសះជាមិនខាន ។

---

១ កូនស្កាសម្រាប់ល្បែងមួយប្រភេទ ក្នុងពួកល្បែងបគ្រង ។

ចុច្ចុបានឮហ្លួហ៊ុមសរសើរខ្លាំងណាស់ ក៏ត្រាស់ប្រើបំរើឲ្យស្រូតទៅហៅពេទ្យហ្លួគោ ១ ក៏បានចូលមកគាល់ ហើយក៏ឲ្យកែគន្ធព្រះអង្គមើលសរសៃនៅកព្រះហស្ត ពេទ្យហ្លួគោមើលហើយ ក៏ទាយថា ព្រះរោគនេះ ពីព្រោះខ្យល់សៀតបាក់ក្នុងព្រះកេសា ដែលទ្រង់សោយព្រះឱសថមកច្រើនណាស់ មិនមែនត្រូវនឹងព្រះរោគនេះទេ ដែលនឹងរក្សាព្រះរោគបែបនេះ ដោយថ្នាំសោយ និងថ្នាំលាប ក៏មិនត្រូវដែររោគយ៉ាងនេះបានតែវះទើបជា ចុច្ចុសួរថា អ្នកឯងនឹងត្រូវការវះយ៉ាងម្តេច ពេទ្យហ្លួគោទូលថា ទូលព្រះបង្គំ នឹងថ្វាយព្រះឱសថ ឲ្យទ្រង់សោយ ទាល់តែស្រវឹងស្មៀមទៅមិនដឹងព្រះអង្គ ទើបនឹងវះគាស់យកលលាដ៍ព្រះកេសា ដោយពូថៅដែលមុត ហើយនឹងលាងជំរះ ព្រះរោគក្នុងលលាដ៍ព្រះកេសានោះ ឲ្យអស់ហើយស្អាត ទើបលើកយកមកប្រកបគ្នាឲ្យដូចដើមវិញ ហើយដេរនឹងចេស លាបថ្នាំឲ្យអស់ស្នាម ទើបព្រះរោគនេះជាដាច់ ។

ចុច្ចុឮដូច្នោះ ក៏ទ្រង់ក្រោធខ្លាំងណាស់ ត្រាស់ថា ឯងនឹងក្លែងសម្លាប់អញឬ បានជាមកនិយាយយ៉ាងនេះ ហ្លួគោទូលថា កាលគ្រា គួនអ៊ុត្រូវព្រួញនៅចុងស្មា ទូលព្រះបង្គំជាខ្ញុំ បានទៅរក្សាប្អូសនោះ គួនអ៊ុអង្គុយឲ្យទូលព្រះបង្គំវះដកយកព្រួញចេញ ហើយក៏កោសរូសទាល់តែអស់ពិសថ្នាំ ដែលប្រឡាបជាប់នឹងឆ្អឹងនោះចេញអស់ ហើយគួនអ៊ុ

គ្មានខ្មាចស៊ើបសោះឡើយ ឯព្រះពេញព្រះអង្គនេះបន្តិចបន្តួចទេ តែនឹង
ខ្មាចអ្វី ទូលព្រះបង្គំរះហើយក៏នឹងជាស្រឡះ មិនត្រូវខ្មាចទេ ។

ចុច្ចថា ដែលមានប្រុសចុងស្នា នឹងត្រូវការគោះកន្លួរ នេះឈើទៅ
កន្ទួរក្បាល មកពុះវះគើរកន្លួរណាស់ទៅហ្ន៎ តាមនុស្សយ៉ាងនេះ គឺក
គប់គិតគ្នាជាពួកម៉ាករបស់ខ្លួនអ្វី រមកធ្វើកលមាយាក្លែងចង់សម្លាប់អញ
ឲ្យស្លាប់ ចុច្ចក៏បង្គាប់ពួកទាហានធ្វើង ស្តាំ ឲ្យចាប់យកខ្លួនពេទ្យហ្លួគោ
ទៅដាក់គុកក្នុងខណៈនោះ ហើយថា អញនឹងរយពិចារណាសួរឲ្យធ្វើយ
យកការណ៍ជាក្រោយទៀត ។

គាសៀង ទីប្រឹក្សាក៏ទូលទាស់ឃាត់ថា សូមទ្រង់ពិគ្រោះពិចារណា
ឲ្យល្អិតបន្តិចទៅទៀតសិន ព្រោះពេទ្យហ្លួគោនេះ ចេះជំនាញណាស់,
សព្វថ្ងៃនេះ បើនឹងជ្រើសរើសរកអ្នកឯណា មកប្រៀបផ្ទឹមឲ្យត្រឹមស្មើ
ក៏ពុំបាន គួរតែទ្រង់សង្កេតនាំពីងគិតសិន កុំអាលធ្វើឲ្យកើតសេចក្តី
អន្តរាយឡើយ ។ ចុច្ចស្រែកគំហកហើយថា ពេទ្យយ៉ាងនេះ រកគិត
តែប្រទូសរ៉ាយនឹងយើងក្នុងគ្រានេះ ប្រាកដដូចកាលគ្រាកៀតប៉េង ប្រុង
នឹងធ្វើប្រទូសរ៉ាយដល់យើងពីកាលមុននោះ ត្រូវតែឲ្យក្រុមមឿងរយសួរ
យកចម្លើយឲ្យច្បាស់, ទាហានក៏នាំយកខ្លួនពេទ្យហ្លួគោ បញ្ជូនទៅ
ឲ្យក្រុមមឿងដាក់គុកតាមបង្គាប់ចុច្ច ។

(នៅមានត)

# ឯកសារ កម្ពុជសុរិយា

(ក)

លោក ឌឹក-គាម ប្រមូលរៀបរៀង

រឿងរបស់លោកពុតគ្គ៍ជាតិចិនមួយរូបឈ្មោះហ្វួនឆាង: ហ្វូនទិពទួមន្ត្រី ញ៉ុក - ថែម ទ.ក. ១, ទំព័រ ១៥, ឆ្នាំ ១៩៤៥, (ម.៥២/១៧) ។

រឿងល្បើកក្បាហ្វុងកែង : លោកផេង - ថ្រី ទ.ក. ១០, ទំព័រ ១១៤៩, ឆ្នាំ ១៩៦២, (ម ៥២/៣៤) ។

រឿងកំដរជនញ៉ី : ឃុនអគ្គកោវិទ ជា-យូ ទ.ក. ៩, ទំព័រ ៨៣៨, ឆ្នាំ ១៩៥៦, (ម.៥២/២៨) ។

រឿងស៊ីថាយញ៉ាប់ : លោក ឌុ.គាម ទ.ក ១២, ទំព័រ ១២៦៤, ឆ្នាំ ១៩៦៤, (ម.៥២/៣០) ។

រឿងស្រីវិបុលកេរ្តិ៍ : លោក លី - ធាមតេង ទ.ក. ១២, ទំព័រ ១២៥៣, ឆ្នាំ ១៩៦៤, (ម.៥២/៣៦) ។

រឿងហ្មូចចាត : លោក មាស-ប៉ាំ ទ.ក. ៧, ទំព័រ ៤៩១, ឆ្នាំ ១៩៤៨, (ម.៥២/២០) ។

រឿងបាឡាឌិត : លោក ប៉យ - ប៊ុក ទ.ក. ៣, ទំព័រ ២៧៧, ឆ្នាំ ១៩៥៧, (ម.៥២/២៩) ។

រឿងអណ្ដើកមាស : លោក លី-ធាមតេង ទ.ក. ៨, ទំព័រ ៧៤៧, ឆ្នាំ ១៩៥៧, (ម ៥២/២៩) ។

រឿងឯកអង្គក្សត្រ : លោក ហង់ហាប់អាន ទ.ក. ៤, ទំព័រ ៣៧៣, ឆ្នាំ ១៩៥៨, (ម.៥២/៣០) ។

ភេកចិត្ត : លោក ស៊ុន-ហ៊ាន ទ.ក. ៦, ទំព័រ ៦១៧, ឆ្នាំ ១៩៥៩, (ម.៥២/៣១) ។

កំស្ទួងឆឆ្លោង : ទ.ក. ១២, ទំព័រ ១២៨៨, ឆ្នាំ ១៩៦៣, (ម.៥២/៣៥) ។

លក្ខណៈភូមិសាស្ត្រស្រុកខ្មែរ : ទ.ក. ២១, ទំព័រ ៦, ឆ្នាំ ១៩៤១, (ម.៥២/១៣) ។

លទ្ធិកម្មសុត្តិពិធីដុតខ្លួនឲ្យស្លាប់តាមប្ដីដែលស្លាប់ទៅហើយរបស់ស្ត្រីឥណ្ឌា : ទ.ក. ២១ – ២២, ទំព័រ ៥, ឆ្នាំ ១៩៤២, (ម.៥២/១៤) ។

លទ្ធិព្រះពុទ្ធសាសនានិងលទ្ធិប្រជាធិបតេយ្យ : ក្រុមជំនុំទំនៀមទម្លាប់, ទ.ក. ១០, ទំព័រ ៧៣៨, ឆ្នាំ ១៩៥២, (ម.៥២/២៤) ។

លៀងអារក្សក្នុងវេលាមានជម្ងឺ : ទ.ក. ១-២-៣, ទំព័រ ១៦៣, ឆ្នាំ ១៩៣៩, (ម.៥២/១១) ។

លោកគ្រូពេទ្យបាធីបេ : ទ.ក. ១, ទំព័រ ៨៣, ឆ្នាំ ១៩២៦ - ២៧, (ម.៥២/១) ។

លោកធម្មចរិយា (កាព្យ) : លោកគ្រូ ប៉ាន - តេង ទ.ក. ៣, ទំព័រ ១១៣, ឆ្នាំ ១៩៤៤ (ម.៥២/១៦) ។

លោកធម្មសូត្រ : ព្រះគ្រូញាណសំវរ ញាណ-ឈឹន ទ.ក. ១០, ទំព័រ ៥៩៣, ឆ្នាំ ១៩៤៣, (ម.៥២/១៥) ។

លោកធម៌ : ព្រះទបាលវង្ស មុឹង - សែស ទ.ក. ៨, ទំព័រ ៥៦៣, ឆ្នាំ ១៩៥៣, (ម.៥២/២៥) ។

លោកធម៌ ៨ ប្រការ (កាព្យ) : ព្រះសាសនសោភ័ណ ជួន-ណាត ទ.ក. ១, ទំព័រ ៣១, ឆ្នាំ ១៩៣១, (ម.៥២/៤) ។

លោកន័យ (កាព្យ) : ឧកញ៉ាវង្សសារពេជ្ញ នង ទ.ក. ១២, ទំព័រ ១៩៣, ឆ្នាំ ១៩៣៨, (ម.៥២/១០), ទ.ក. ៣, ទំព័រ ១៣៣, ឆ្នាំ ១៩៣៧ ;

លោកបាលធម៌ : ព្រះមហា មាស - ស៊ុមន៍ ទ.ក. ៥, ទំព័រ ៤៩៤, ឆ្នាំ ១៩៥៩, (ម.៥២/៣១) ។

ព្រះបាឡាត់អរិយកស្សប គុន-ណួន ទ.ក. ១២, ទំព័រ ៩១២, ឆ្នាំ ១៩៥១, (ម.៥២/២៣) ។

លោកប៉ូលរេយណូដ៍ សេនាបតីប្រទេសរាជអញ្ជើញ

មកក្រុងកម្ពុជា : ទ.ក. ១ - ៦, ទំព័រ ៥, ឆ្នាំ ១៩៣៣, (ម.៥២/៥) ។

លោកឡេវេស៊ីដធ័ស៊ិតេរីយ៉េសិលវ៉េស្ត្រ អញ្ជើញមកមើលព្រះរាជបណ្ណាល័យពុទ្ធសាសនបណ្ឌិត្យ, កន្លែងសិក្សាពុទ្ធអក្សរនិងរេនពុទ្ធ ដែលបានតាំងសំរាប់បោះព្រះត្រៃបិដក : ទ.ក. ៧-១២, ទំព័រ ២៣, ឆ្នាំ ១៩៣៣, (ម.៥២/៥) ។

លោកអ្នកសចារី : ទ.ក ១, ទំព័រ ៧៧, ឆ្នាំ ១៩២៦ ២៧, (ម.៥២/១) ។

លោកនិព្វាយ : លោក ប៊ូ·ប៊ូ ទ.ក. ១២, ទំព័រ ១០ប់ទ, ឆ្នាំ ១៩៥៧ (ម.៥២/២៩) ។

លោកិយលោកុត្តរបញ្ញាកថា : ព្រះអាចារ្យ ទូច-ឡុង ទ.ក. ៣, ទំព័រ ១៧០, ឆ្នាំ ១៩៥២, (ម.៥២/២៤) ។

លោកុត្តរចិត្ត : អ្នកឧកញ៉ា ទា-សាន ទ.ក. ៣, ទំព័រ ២៤៦, ឆ្នាំ ១៩៦២, (ម.៥២/៣៤) ។

សំដៅដើមហេតុនៃការដែលបានស្គាល់ប្រសាទអង្គរ : លោកវិកទ័រគោលូបែហ្វ ទ.ក. ១១, ទំព័រ ២៧, ឆ្នាំ ១៩២៧, (ម ៥២/២) ។

ល្ខោនទោល : អ្នកឧកញ៉ាទេពពិទូរក្រសេម ទ.ក. ៣, ទំព័រ
១៦១, ឆ្នាំ ១៩៤៨, (ម.៥២/២០) ។

ល្ខោនចាមោជ័យ : ក្រុមជុំទំនៀមទម្លាប់ខ្មែរ ទ.ក. ៣,
ទំព័រ ៣២៤, ឆ្នាំ ១៩៦៤, (ម.៥២/៣៦) ។

ល្ខោនស្បែក : អ្នកស្រីពេជ-សល់ ទ.ក. ៥, ទំព័រ
៥៥៧, ឆ្នាំ ១៩៥៩, (ម.៥២/៣១) ;
អ្នកឧកញ៉ាទេពពិទូរ ឈឹម-ក្រសេម, ទ.ក. ២, ទំព័រ ១០០,
ឆ្នាំ ១៩៤៨, (ម.៥២/២០) ។

ល្បើកក្រើនជាតិ : លោក ប៊ូ-ប៉ូ ទ.ក. ៣, ទំព័រ
១៨៦, ឆ្នាំ ១៩៥២, (ម.៥២/២៤) ។

ល្បើកច្បាប់ក្រិត្យក្រម : ទ.ក. ៤៣-៤៤, ទំព័រ ២៧,
ឆ្នាំ ១៩៤២, (ម.៥២/១៤) ។

ល្បើកច្បាប់ក្រិត្យក្រម : ព្រះគ្រូសុទ្ធវង្ស ទិក, ទ.ក.
១-២-៣, ទំព័រ ៨៣ ឆ្នាំ ១៩៣៧, (ម.៥២/៩) ។

ល្បើកបឋមសិក្សា ( កាព្យ ) : ទ.ក. ៧, ទំព័រ
៦៣៧, ឆ្នាំ ១៩៥៨, (ម.៥២/៣០) ។

ល្បើកច្បាប់សង្ឃ : ក្រមង៉ុយ ទ.ក. ៧-៨-៩,
ទំព័រ ១០៥, ឆ្នាំ ១៩៣៧ (ម.៥២/៩) ។

ល្បើកាឡាហុងតែង : (មើលពាក្យខាង រឿងល្បើកឡាហុងតែង)។

ល្បែងចត្រង្គ : លោក យូរ - អ៊ុន ទ.ក. ១០, ទំព័រ ១០៨២, ឆ្នាំ ១៩៦៤ (ម.៥២/៣៦) ។

ល្បែងបោះប្រមាត់ : គ្រ. ទ.ក. ៤, ទំព័រ ៤៤៣, ឆ្នាំ ១៩៦៣, (ម.៥២/៣៥) ។

ល្បែងទាញព្រ័ត្រ : លោក ចាប-ពិន ទ.ក. ៧, ទំព័រ ៥៤៤, ឆ្នាំ ១៩៥៣, (ម.៥២/២៥) ។

ល្បែងប្រណាំងទូកខ្មែរ : សាមណេរ ព្រាប - ឌិប ទ.ក. ៨, ទំព័រ ៥៧៤, ឆ្នាំ ១៩៤៩, (ម.៥២/២១) ។

ល្បែងផ្សេងៗ : លោកយោក្ស៊ែត ម៉ៅ-ម៉ី ទ.ក. ៧, ទំព័រ ៤៨៥, ឆ្នាំ ១៩៤៩, (ម.៥២/២១) ។

វចនានុក្រមសំស្ក្រឹត : វិរិយបណ្ឌិតោភិក្ខុ ប៉ាង - ខាត់ ទ.ក. ១, ឆ្នាំ ១៩៤៧, (ម.៥២/២៩) ។

វចីកថា : ព្រះមហា អ៊ុម - ផេង ទ.ក. ៩, ទំព័រ ៨១៣, ឆ្នាំ ១៩៥៦, (ម.៥២/២៨) ។

វចីសត្តិការគាថា : ព្រះវិនយធម្ម ថោង - យុ ទ.ក. ៣, ទំព័រ ២៤១, ឆ្នាំ ១៩៦០, (ម.៥២/៣២) ។

វត្តប្បដិវត្ត : ព្រះតេជព្រះគុណព្រះធម្មលិខិត ល្វី - ឯម ទ.ក. ៦, ទំព័រ ៣៣៣ ឆ្នាំ ១៩៤៣, (ម.៥២/១៥) ។

វត្ថុសីលរាជជាតកា : លោកអាចារ្យ ឈឹម-ណាក់

ទ.ក. ១, ទំព័រ ២៤, ឆ្នាំ ១៩៥៦ (ម.៥២/២៨) ។

វណ្ណកិត្តិកុណាកថា : ព្រះបិដកវិជ្ជា ហ៊ុម ទ.ក. ៤,

ទំព័រ ១៧១, ឆ្នាំ ១៩២៧. (ម.៥២/២) ។

វណ្ណកតិរឿងនារាយណ៍ឧសាវតារ : ឧកញ៉ាទេពពិទូរ

ក្រសេម ទ.ក. ៥, ទំព័រ ២២៥, ឆ្នាំ ១៩៤៥

(ម.៥២/១៧) ។

ប្រវត្តិព្រះពុទ្ធសាសនាខ្មែរនៅខេត្តមាត់ជ្រូក កម្ពុជា-

ក្រោម : លោក ឱ - គាម ទ.ក. ៦, ទំព័រ ៥៧៧,

ឆ្នាំ ១៩៦៥, (ម.៥២/៣៧) ។

វត្ថុគ្រឿងតំណាង : លោកស្រី - អ៊ី ទ.ក. ៦, ទំព័រ

៦៦៥, ឆ្នាំ ១៩៥៩, (ម.៥២/៣១) ។

វប្បធម៌ពុទ្ធសាសនា : ព្រះញាណវិរិយ កិទ-សាខុំ ទ.ក.

៦, ទំព័រ ៥១១, ឆ្នាំ ១៩៥៨ (ម.៥២/៣០) ។

វម្មិកាបញ្ញា : ព្រះមហា ច័ន្ទ - ហុន ទ.ក. ៣, ទំព័រ

១៧២, ឆ្នាំ ១៩៥៤, (ម.៥២/២៦) ។

វយប្បកាសជឺ : អាចារ្យហ៊ឹម ទ.ក. ១ - ៤ - ៣,

ទំព័រ ២៣, ឆ្នាំ ១៩៣៨, (ម.៥២/១០) ។

វណ្ណៈ : លោកតាប - ពិន ទ.ក. ១១, ទំព័រ ៨៥៣, ឆ្នាំ ១៩៥៣, (ម.៥២/២៥) ។

វលាហជាតក : ព្រះឧត្តមមុនី អ៊ុម - ស៊ូ ទ.ក. ៣-៦, ទំព័រ ៦០, ឆ្នាំ ១៩៣១, (ម.៥២/៤) ។

វិសាលសូត្រ ( កាព្យ ) : ឃុនសុរិត្តវេទ យូរ - អ៊ុន ទ.ក. ៥, ទំព័រ ៣៥១, ឆ្នាំ ១៩៥០, (ម.៥២/២២) ។

វិចារប្រស្រ័យរបស់លោកអង្គ ជ្រ - ស្ម៉ែរ : ទ.ក. ៤, ទំព័រ ៣, ឆ្នាំ ១៩៤១, (ម.៥២/១៣) ។

វិលុត្តាពេតិយ : លោកតាប - ពិន ទ.ក. ៨, ទំព័រ ៦២៣, ឆ្នាំ ១៩៥៤, (ម.៥២/២៥) ។

វិជ្ជាគុណកថា ( កាព្យ ) : គ្រូ ឈឹម - ស៊ុម ទ.ក. ២ - ៣, ទំព័រ ៣៧, ឆ្នាំ ១៩៣៥, (ម.៥២/៧) ។

វិជ្ជាទិកថា : ព្រះមហា តាប - ប៊ិន : ទ.ក. ៣, ទំព័រ ១៦៣, ឆ្នាំ ១៩៥៣, (ម.៥២/២៥) ។

វិជ្ជារក្សាចិត្តក្នុងបច្ចុប្បន្ន : ឃុនបណ្ណានុរក្ស ប៊ូ - ប៉ូ ទ.ក. ៦, ទំព័រ ១៣៧, ឆ្នាំ ១៩៤៩, (ម.៥២/២១) ។

វិទូទក : ព្រះមហា ឡឿក - អម៌ ទ.ក. ១, ទំព័រ ២៧, ឆ្នាំ ១៩៥៩, (ម.៥២/៣១) ។

(នៅមានត)

## អត្ថបទផ្នែកទំនៀមទម្លាប់

# រឿងព្រេងនៅក្នុងឃុំស៊ីធរ

លោក រឹម-ហ៊ុយ រៀបរៀង

ឃុំស៊ីធរឋិតនៅក្នុងស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល ចម្ងាយពីព្រះរាជធានីភ្នំពេញ ប្រមាណជា ៣៥ គ.ម. និង មានចម្ងាយពីព្រែកតាមាក់ ( សាលាស្រុកខ្សាច់កណ្ដាល ) ប្រមាណជា ១៥គ.ម. ។

ដើម្បីធ្វើដំណើរទៅកាន់ឃុំនេះ, យើងត្រូវជិះកប៉ាល់ទៅចុះនៅកំពង់ផែព្រែកតាមាក់ រួចជិះរ៉ឺម៉កម៉ូតូ តម្រង់ទៅទិសអគ្នេយ៍ កាត់វាលស្រែនិងគុម្ពោតឈើប្រហែលជា ៧ គ.ម. ។ ផុតពីវាលស្រែនេះ យើងនឹងឃើញភូមិមួយ ឈ្មោះភូមិព្រែកបាស់, ជាប់នឹងភូមិនេះ មានភូមិមួយទៀត ឈ្មោះភូមិគោកវិហារសួ, ចេញពីភូមិនេះទៅ រ៉ឺម៉កយើងត្រូវលិចកប់ខ្លួនចូលទៅក្នុងព្រៃមួយយ៉ាងធំ ហើយវែងប្រមាណជា ២ គ.ម., មុននឹងចេញផុតពីព្រៃនេះ យើងនឹងឃើញគេហដ្ឋានតូច ៗ ចំនួន ២០ ខ្នងដែលលាក់ខ្លួនពួននៅក្នុងព្រៃនោះ ហើយយើងនឹងបានឃើញវាលស្រែដ៏ធំធេងមួយវែងឆ្ងាយ ប្រកបដោយគុម្ពោតពោធិ៍ ៗ, ជាប់នឹងវាលស្រែនេះ មានព្រៃឈើខៀវខ្ចី ៗ គគោះទៀត យើងនឹងឃើញគេហដ្ឋានតូចធំ លាយចម្រុះគ្នា បានបង្កប់ខ្លួននៅក្នុងព្រៃពោះ ១ ៗ កន្លែងនេះ គេហៅថា ភូមិកាត់ខ្លួ ឬ ភូមិព្រះស្រែ ។ នៅជាប់នឹងភូមិ

នេះ មានភូមិមួយទៀត ឈ្មោះភូមិព្រៃបាំង ។ មកដល់ត្រង់ភូមិនេះ បើយើងតោលកន្ទុយភ្នែក យ៉ាងវែងឆ្ងាយទៅខាងជើង ឆ្លងកាត់បឹងមួយ យើងនឹងឃើញភូមិមួយ ឈ្មោះភូមិទាងបាន ដែលបិតនៅប៉ែកខាងជើងនៃមាត់បឹងនោះ ។ បើយើងងាកបែរមកខាងត្បូងវិញ យើងនឹងឃើញបឹងមួយយ៉ាងវែង ហៅថា បឹងស៊ីធរ , ហើយបើយើងតោលកន្ទុយភ្នែកឡើងផុតពីបឹងនោះបន្តិចទៅទៀត យើងនឹងបានឃើញគេហដ្ឋានជាច្រើនខ្នង ដែលមានដំបូលប្រក់ក្បឿង និងប្រក់ស្លឹកលាយចម្រុះគ្នា បានផុះចេញអំពីចុងព្រៃជាតិនានា ហាក់ដូចជាអណ្ដាតភ្លើងដែលកំពុងឆេះព្រៃ ភូមិនេះឯងហើយដែលគេហៅថា ភូមិស៊ីធរ ។ ភូមិទាំងអស់ដែលបានរៀបរាប់មកនេះ សុទ្ធតែមានរឿងព្រេង ទាក់ទងដោយភូមិ-សាស្ត្រ ហើយនិងប្រវត្តិសាស្ត្រខ្មែរ ។

រឿងព្រេងនោះ ខ្ញុំបានឮចាស់ ៗ និយាយញឹកញាប់ ដែលអាចចូលមកដិតជាប់នៅ ក្នុងខួរក្បាលខ្ញុំ តាំងពីខ្ញុំបិតនៅ ក្នុងវ័យកុមារនៅឡើយ ៗ តែដោយហេតុខ្ញុំ បានឃ្លាតចេញពីទីនោះ មកសិក្សានៅភ្នំពេញអស់រយៈពេលចំនួន ១៥ ឆ្នាំមកហើយ, ការចេះចាំនូវរឿងព្រេងនោះ ក៏បានសាត់ចេញបន្តិចម្ដង ៗ ស្ទើរតែរកនិយាយប្រាប់អ្នកដទៃមិនកើត ។ តែក្នុងពេលថ្មី ៗ នេះ ខ្ញុំបានទៅសាកសួរចាស់ ៗ ជាច្រើនមានលោក គឹម-កាយ ជាដើម ដែលជាអ្នកមានប្រាជ្ញាវាងវៃមានស្មារតី

រីឯប៊ុន គាត់មានអាយុ ៦០ ឆ្នាំហើយ តែគាត់នៅមានសុខភាពបរិបូរនៅឡើយ ។ គាត់បានទិតានរឿងព្រេងនោះយ៉ាងក្បោះក្បាយ ដែលអាចយកជាការត្រឹមត្រូវបាន ។ រឿងព្រេងនោះ ទាក់ទងទៅនឹងប្រវត្តិឈ្មោះភូមិ ទៅនឹងបុរាណដ្ឋាន ហើយនឹងបុរាណវត្ថុ ដែលមាននៅក្នុងភូមិនោះ ។ ដូច្នេះ, ដើម្បីឲ្យងាយដល់ការអធិប្បាយ និងឲ្យងាយដល់អ្នកអានផង, ខ្ញុំសូមចែករឿងនេះ ជាបីផ្នែកគឺ:

១- អំពីប្រវត្តិឈ្មោះភូមិ

២- អំពីបុរាណវត្ថុ

៣- អំពីបុរាណដ្ឋាន

ជាបឋម, ខ្ញុំសូមអធិប្បាយ អំពីប្រវត្តិឈ្មោះភូមិតាំងនោះសិន ។ ភូមិតាំងនោះ មានរឿងព្រេងនិទានដូចតទៅនេះ :

មានសេចក្ដីដំណាលថា កាលពីព្រេងនាយ មានព្រះមហាក្សត្រមួយព្រះអង្គ មានព្រះនាមមិនប្រាកដ មានព្រះកាយធំសម្បើមណាស់ និងរកមានជនណាមួយ ទៅប្រៀបផ្ទឹមពុំបាន, ព្រះអង្គទ្រង់មាន អគ្គ-មហេសីមួយព្រះអង្គ ព្រះនាមព្រះនាង ស មានរូបឆោមលោមពណ៌ល្អឆើតឆាយ លើសស្រីទាំងឡាយនៅក្នុងព្រះនគរ ។ តែព្រះអង្គបានប្រតិព័ទ្ធលើនារីមួយរូបទៀត ឈ្មោះនាង បាន ជាកូនអ្នកងារ មានមាឌ

ធំសម្បើមណាស់ដែរ ហើយបានគប់ប្រុសពូគ្នាទៅត្រង់កន្លែងមួយ ដែលឋិតនៅខាងជើងភូមិស្រីសឈរ ( ស៊ីធរ ) និងភូមិព្រៃបាំង ដែលគេហៅកន្លែងនោះថា ភូមិនាងបាន ៗ រហូតមកដល់សព្វថ្ងៃនេះ ៗ តាំងពីបានគប់ប្រុសពូជាមួយ នាងបាននោះមក ព្រោះគន្ធុំបូរបានទៅគង់នៅជាមួយនាងស ដែលជាមហេសីដើម ដូចកាលពីមុនទៀតឡើយ ៗ

ចំណែកនាងស ក្រោយដែលបានដឹងថា ព្រះស្វាមីរបស់នាងទ្រង់មានមហេសីថ្មីទៀត ព្រះនាងក៏បានទទួលនូវការទុក្ខសោកក្រៀមក្រំយ៉ាងខ្លាំង ដោយត្រូវសេចក្ដីប្រណែនប្រច័ណ្ឌគ្របសង្កត់ ក៏ធ្វើដំណើរចេញពីលំនៅរបស់ខ្លួនមកតាមព្រះស្វាមី តែនាងមិនហ៊ានចូលទៅដល់ព្រះស្វាមីទេ គឺឈរលបមើលតែពីចម្ងាយ ៗ រីឯព្រះស្វាមី កាលបើទ្រង់ជ្រាបថា: នាងសមកឈរលបមើលដូច្នោះ ក៏យករាំងននមកបាំង ដើម្បីកុំឲ្យនាងសនោះមើលឃើញ ៗ

មានរឿងក៏ដូច្នេះហើយ បានជាគេឲ្យឈ្មោះភូមិទាំងនោះថា ភូមិនាងបាន ភូមិព្រៃបាំង ភូមិមេសប្រច័ណ្ឌ និង ភូមិស្រីសឈរ រហូតដល់សព្វថ្ងៃនេះ គឺភូមិដែលនាងបាននៅនោះ គេឲ្យឈ្មោះថា ភូមិនាងបាន ៗ ភូមិរបស់នាងស គេឲ្យឈ្មោះថា ភូមិមេសប្រច័ណ្ឌ ៗ កន្លែងដែលនាងសឈរលបមើលព្រះស្វាមី គេហៅថាភូមិស្រីសឈរ ហៅក្លាយមកទៀត

ថា ភូមិស៊ីធរ ។ កន្លែងដែលព្រះពជាយកពាំងនៃនបាំង គេឲ្យឈ្មោះថា ភូមិព្រៃបាំង ។

រឿងនេះ ដូចជាសមហេតុ សមផលដែរ បើយើងគិតទៅដល់ឈ្មោះភូមិ ហើយនិងការតាំងនៅនៃភូមិទាំងនោះ ដូចជាភូមិព្រៃបាំង មានព្រៃដុះបាំងភូមិស្រីសឈរ និងភូមិនាងបាន មិនឲ្យមើលគ្នាឃើញ ។

ប្រវត្តិឈ្មោះភូមិទាំងនេះ មានត្រឹមតែប៉ុណ្ណោះ ។ តអំពីនេះទៅ ខ្ញុំសូមអធិប្បាយ អំពីរឿងរ៉ាវនៃបុរាណដ្ឋាន និង បុរាណវត្ថុខ្លះ ដែលមាននៅក្នុងភូមិទាំងនេះ ជាពិសេសចំពោះភូមិស្រីសឈរ និងភូមិនាងបានដូចតទៅ :

នៅក្នុងភូមិនាងបាន មានវត្តមួយឈ្មោះមហានិវេសស្ថាន ឬ វត្តនាងបាន ។ នៅក្នុងព្រះវិហារនោះ មានព្រះពុទ្ធរូបបុរាណមួយព្រះអង្គ មានព្រះកាយធំសម្បើមណាស់ បណ្ដោយព្រះរូប ប្រវែងប្រមាណជាង ១០ ម. ទទឹងព្រះរូប ប្រវែងប្រមាណជា ១ ម. ។

មានសេចក្ដីថា ព្រះពុទ្ធរូបនេះ បានអណ្ដែតមកតាមព្រែកមួយដែលហូរពីជើងមកត្បូង អ្នកស្រុកឃើញដូច្នោះ ក៏បបួលគ្នាយកខ្សែព្រួរទៅចងក្រៀក ទាញយកព្រះពុទ្ធរូបនោះមក តែទុកជាអ្នកស្រុកយកខ្សែព្រួរយ៉ាងធំ ។ ហើយគេណ្ដោមមនុស្សយ៉ាងច្រើនយ៉ាងណា ក៏មិនអាចនិមន្តយកព្រះពុទ្ធរូបនោះបានឡើយ ។ នៅទីបំផុត គេយកតែខ្សែអម្បោះញ

សារសែរទៅចង់ រូបគេនិមន្តព្រះអង្គមកបានដោយឆាប់ ។ ឯព្រែកដែលព្រះពុទ្ធរូបអណ្តែតមកនោះ គេហៅថាព្រែកព្រះ ។ រហូតមកដល់សព្វថ្ងៃនេះ ។

ភូមិស្រីសឈរ ឬភូមិស៊ុធរ មានបឹង ថ្លុក ត្រពាំង ដីទួល និងដំបូកជាច្រើន ។ នៅប៉ែកខាងកើតភូមិ ជាប់នឹងមាត់បឹងស៊ុធរ មានដីទួលមួយកន្លែង គេហៅថា ទួលបាសាណ តែសព្វថ្ងៃគេហៅក្លាយមកថា « ទួលកាណសា » ។ តាមប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា បានចែងថា : ទួលនេះជាកន្លែងរាជធានីចាស់ មុនរាជធានីភ្នំពេញ ក្នុងរជ្ជកាលព្រះបាទសម្តេចព្រះពញាយ៉ាត ប្រហែលនៅក្នុងសតវត្សទី ១៥ ។ ក្រៅពីដីទួលនេះ គ្មានអ្វីអាចសំគាល់បានថាជារាជធានីចាស់ឡើយ ។

នៅខាងលិចភូមិ មានស្រះមួយយ៉ាងធំ បណ្តោយប្រមាណជា ៥០០ ម. ទទឹងប្រមាណជា ៣០០ ម. គេហៅស្រះនោះថា "ថ្កុល" ។ នៅមាត់ស្រះប៉ែកខាងកើត ចៀងអគ្នេយ៍បន្តិច មានអ្នកតាមួយ ។ អ្នកស្រុកបានដំណាលតៗ មកថា: កាលពីដើម អ្នកតានោះ ពូកែសក្តិសិទ្ធិណាស់ បើចង់បានវត្ថុអ្វីៗ ដូចជាគ្របឆ្នាំងឈើ·ចាស-គុ-ចាន ។ល។ គ្រាន់តែយកទៀនធូបទៅអុជបន់ស្រន់អ្នកតានោះ នឹងបានវត្ថុទាំងនោះដូចសេចក្តីប្រាថ្នា ។ ម្យ៉ាងទៀត បើចង់មើលពស់ត្រូវធ្វើតាមរបៀបខាងលើនេះ នឹងបានឃើញពស់ក្លាម ។ នៅកល់តែថ្ងៃសីល អ្នកតានោះតែងបង្ហូតគោមទៅលើអាកាសជានិច្ច ។

នៅខាងជើងផ្សាល ចម្ងាយប្រហែលជា ១ គ.ម.មានបឹងតូចមួយ គេហៅថាបឹងក្រចាស ។ នៅប៉ែកខាងជើងនៃមាត់បឹងនោះ មានអ្នកតាមួយដែរ អ្នកតានេះ ពូកែស័ក្តិសិទ្ធិដូចជាអ្នកតាផ្សាលដែរ ។ តែសព្វថ្ងៃនេះ អ្នកតាទាំងពីរនេះ មិនពូកែស័ក្តិសិទ្ធិ ដូចសំដីដែលគេនិយាយតៗ មកនោះទេ ។

នៅទិសត្បូងសានបឹងក្រចាស មានបឹងមួយទៀត គេហៅថាបឹងក្រពើ មានបណ្តោយប្រមាណ ៦០០ ម. ទទឹងប្រមាណ ២០០ ម. ។ តាមសេចក្តីដំណាលតៗ មកថា: កាលដែលព្រះមហាក្សត្រមានរាជធានីនៅទួលបុរាណ ទ្រង់បានឲ្យជីកស្រះនេះឡើង ដើម្បីចិញ្ចឹមក្រពើ ។ នៅខាងជើងបឹងក្រពើ ចម្ងាយប្រហែល ៣០០ ម. មានទួលមួយហៅថាទួលព្រះរាជទាន មានកំពែង ៤ ជ្រុងទ្រវែង បណ្តោយពីកើតទៅលិចប្រវែងប្រមាណ ៥០ ម. ទទឹងពីត្បូងទៅជើង ប្រមាណជា ៣០ ម. មានកំពស់ពីដីធម្មតា ប្រមាណ ១ ម. ៥០ ដោយយកដុំថ្មបាយក្រៀមទៅរៀបជាជួរ ៗ ។ នៅលើទួលនោះ មានតែរុក្ខជាតិដុះពាសពេញ ដូចជា ដើមត្បែង, ដើមឫស្សីជាដើម ។ នៅជុំវិញទួលនេះ មានតែវាលស្រែ ហើយនិងថ្លុកត្រពាំង ។ ពួកកសិករដែលភ្ជួររាស់ដីនៅជុំវិញទួលនេះ តែងជួបប្រទះនូវវត្ថុបុរាណផ្សេងៗ ជាច្រើន ដូចជា ចាន ពាង ក្រឡ ជាដើម ។

តាមសេចក្តីដំណាលត ៗ មកថា ភ្នំដាទួលនេះមានឈ្មោះថា "ទួលព្រះពជទាន" ដូច្នេះ ព្រោះនៅត្រង់កន្លែងនេះ ព្រះមហាក្សត្រទ្រង់ធ្វើបុណ្យដាក់ទានវត្ថុផ្សេង ៗ ដល់ប្រជាកស្ត្រ ៗ តែសព្វថ្ងៃគេហៅក្លាយមកថា "ទួលព្រះពជទាល" វិញ ។

នៅកណ្តាលភូមិស៊ុផនោះ មានវត្តមួយ ឈ្មោះវត្តព្រះពជនិវេសន្ថាន ឬ វត្តស្រីសឈរ ហៅវត្តស៊ុផរ ។ វត្តនេះហើយ ដែលសម្តេចព្រះធម្មលិខិត ល្វី-ឯម ធ្លាប់បានទៅធ្វើជាចៅអធិការប៉ុន្មាន ១៤ ឆ្នាំ គឺជាវត្តមានកាយុចាស់ជាងគេនៅតំបន់នោះ ។

នៅក្នុងវត្តនោះ មានចេតិយបុរាណធំ ៗ ប្រាំមួយ : បួននៅខាងមុខព្រះវិហារ, ពីរនៅខាងក្រោយព្រះវិហារ ។ ក្នុងចំណោមចេតិយទាំង ៦ នេះ, ចេតិយ ៤ ធ្វើអំពីថ្មបាយក្រៀម និងពីរធ្វើអំពីឥដ្ឋ ។ ចេតិយទាំងអស់នេះ មានការរង្គោះរង្គើបាក់បែកអស់ខ្លះហើយ ហើយគេមិនដឹងថា នៅក្នុងចេតិយនេះ មានបញ្ចុះវត្ថុទេ ។ តែតាមសេចក្តីដំណាលត ៗ មកថា ចេតិយទាំងនេះ គេសាងឡើង ដើម្បីបញ្ចុះព្រះអដ្ឋិធាតុ ព្រះមហាក្សត្រ ព្រះពជៈវង្សានុវង្ស ដែលគង់នៅពជទានទួលបាសាណ ។

អ្នកស្រុកភាគតិចទេ បាននិយាយថា ចេតិយនៅមុខព្រះវិហារ ពូកែស័ក្តិសិទ្ធិណាស់ បើគេបាញ់កាំភ្លើង តម្រង់ទៅចេតិយទាំងនោះ

គ្រាប់កាំភ្លើងមិនអាចចេញបានឡើយ ។

ឯកន្លែងស្រីសឈរនោះ មានរឿងដំណាលថា ជាភូមិលំនៅរបស់នាងស ដែលជាអគ្គមហេសីព្រះរាជា ដែលបានពោលមកហើយ ។

ចំណែកព្រះមហាក្សត្រ ក្រោយដែលទ្រង់បានជ្រាប នូវសោកណា-កាពស្ត្រីនោះហើយ ព្រះអង្គក៏ចាត់ព្រះរាជបំរើ ឲ្យទៅនាំនាងនោះយកមកធ្វើជាព្រះអគ្គមហេសី ។ តាំងពីពេលនោះមក ព្រះអង្គទ្រង់សព្វព្រះរាជហឫទ័យនឹងនាងនោះណាស់ ។ អាស្រ័យហេតុនេះហើយ បានជា ព្រះអង្គទ្រង់ឲ្យកសាងវត្តស្រីសឈរនោះឡើង ដើម្បីជាអនុស្សាវ-រីយ៍ដល់លំនៅព្រះអគ្គមហេសីនោះផង និង ដើម្បីផ្គាប់ចិត្តព្រះអគ្គមហេសីដែលជាទីពេញព្រះទ័យនោះផង ព្រោះនាងនោះមានសទ្ធាជ្រះថ្លាបំពោះព្រះពុទ្ធសាសនាខ្លាំងណាស់ ។

រឿងព្រេងដែលខ្ញុំលើកយកមកសរសេរនេះ មានកន្លែងខ្លះប្រកបទៅដោយការអស្ចារ្យពេក ដែលមិនគួរជឿបាន តែខ្ញុំមានសេចក្ដីជឿជាក់ថារឿងនេះពិតជានឹងអាចផ្ដល់ប្រយោជន៍ ដ៏សំខាន់ដល់ជនជាតិយើង ព្រោះជារឿងប្រកបដោយលក្ខណៈជាតិខ្មែរសុទ្ធ ៗ ដូចជាចង្អុលបង្ហាញនូវជំនឿឬ ទំនៀមទម្លាប់, ប្រពៃណី និងសាសនារបស់ជនជាតិខ្មែរ ព្រមទាំងឈ្មោះ ភូមិ ស្រុក ខេត្ត ក៏ជាឈ្មោះខ្មែរ ឋិតនៅក្នុងស្រុកខ្មែរ ។

ដោយអាស្រ័យហេតុនេះហើយ ទើបយើងអាចចាត់រឿងព្រេងនេះថាជារឿងទាក់ទងទៅនឹងភូមិសាស្ត្រ ហើយនិងប្រវត្តិសាស្ត្រខ្មែរ ។

# ជីវប្រវត្តិ

## របស់ខ្ញុំឈ្មោះ អៀង-សាយ

(ក)

មួយទៀត រឿងកូន ខ្ញុំស៊ូពិបាកខ្លួនខ្ញុំ ឲ្យតែកូនបានរៀនចេះដឹងជ្រៅជ្រះវៃឆ្ងាយ ខ្ញុំមិនសន្សំទុកមាសប្រាក់ ដីភូមិ ផ្ទះសម្បែង ទ្រព្យសម្បត្តិអ្វី ទុកជាកេរ្តិ៍មរតក ឲ្យកូនទេ ខ្ញុំចាយប្រាក់ឲ្យរៀនឲ្យចេះច្រើន គឺចំណេះនោះហើយ ទុកកេរ្តិ៍ជាមរតកដែលខ្ញុំត្រូវចែកឲ្យ ។

ដោយខ្ញុំចូលចិត្តខាងល្បែងលេងកលថ្មីឲ្យប្លែក ខ្ញុំបានរួមគំនិតជាមួយបងប្អូនខ្ញុំបង្កើត ជាក្រុមកុនសៀក ១ ក្រុម មានក្មេងប្រុស៤នាក់ គឺសុទ្ធតែកូនក្មួយរបស់ខ្ញុំ, ខ្ញុំនិងបងប្អូនខ្ញុំ នាំក្មេងហាត់លេង លោតចាក់ចូលក្នុងកងរង្វង់ភ្លើង ដើរលើខ្សែលួស ដាំដូងលោតដោយស្មៀតថ្ងៃក ១ ។ ពួកក្រុមសៀកនោះឲ្យឈ្មោះថា ក្រុមខេមរវិជ្ជា បានចូលលេងនៅពេញល្ហោន ពេញកុនច្រើនផង គឺក្នុង គ.ស. ១៩៣២ ខ្ញុំធ្វើការពេជការពេលថ្ងៃ ពេលយប់ខ្ញុំទៀតគិតពីរឿងកុនសៀក ខ្ញុំបានតែងចំនុក ឲ្យក្មេងច្រៀងបើកពេង រៀងរាល់ពេលបើកកំដែន សេចក្តីថា :

យើងខ្ញុំសូមសុំជំរាបផ្ទាល់ សូមលោកអ្នកស្គាល់កុនសៀកថ្មី
ឈ្មោះក្រុមខេមរវិជ្ជាល្បី កើតឡើងនៅដីក្រុងភ្នំពេញ ។
ឈ្មោះសែមសាយសឿងជាមេក្រុម យើងខ្ញុំចាប់ផ្តើមហាត់ទន្ទេញ

បំណងប៉ុនប៉ងគិតបំពេញ ឲ្យកុនសៀកចេញមានសាសន៍ខ្មែរ
ដៀតសាសន៍ចិន យួន ក្លឹង បារាំង គេពូកែខ្លាំងមកហូរហែ
មកលេងបន្តួតព្រួតបន្ទែ ជាតិយើងចេះតែត្រូវប្រព្រឹត្ត ៗ
កុំឲ្យថោកទាបប្រៀបជាងគេ ថាទេបើលោកអ្នកមិនគិត
យើងខ្ញុំឆាទាជាគំនិត ឲ្យតែមូលមិត្តមានមេត្រី ៗ
សូមសុំសរសើរដោយស្មោះត្រង់ កុំចង់ផ្តាគ្នាយើងអើ
កុំពោលបន្អាប់ផ្កាប់សំដី យល់ខុសត្រូវក្តីគួរស្ងៀមស្ងាត់ ៗ
អត់ឲ្យបណ្តោយដល់ចាស់ទៃ ចេះថ្មីតែងតែមានក្លាំងក្លាក់
កូនគេចង់ចេះលេងមិនទាន់ស្ទាត់ យូរទៅប្រាកដជាពូកែ ៗ
សូមសុំពរជ័យពីលោកអ្នក ដែលមានចិត្តស្ម័គ្រដល់ជាតិខ្មែរ
ស្រេចហើយនឹងចេញលេងហូរហែ តាមរឿងថ្មីទើបតែចេះអើយ ៗ

ល្បែងលេងកលថ្មីនៃអ្នក ដែលពួកខ្ញុំលេងក្នុងកាលនោះ បើកាប់រឿងហូរហែទៅ ការងារសេចក្ដី តែបើមិនកាប់រឿងផង មិនបានប្រាប់ពីលេងយ៉ាងម៉េចខ្លះ ដូច្នេះគ្រាន់តែកាប់រឿងខ្លីៗ តាមសេចក្តីក្នុងប្រក្រាម ដែលលេងកាលនោះ ខ្ញុំមានទុកកម្មវិធីនៅសល់តាំងពីកាលនោះមកគឺ :

១– កាត់ខ្សែឲ្យដាច់ ហើយធ្វើឲ្យឃើញជាប់វិញ

២– យកក្រដាស ស មកធ្វើឲ្យទៅជាក្រដាសប្រាក់

៣– ប្រើពងមាន់ឲ្យឡើងអង្រែ

៤- បង់ប៉ិចមុខ ខ្ទប់ភ្នែក អាចអានអក្សរបាន

៥- យក•សមកធ្វើឲ្យទៅជាត្រីស

៦- ឲ្យគេចងស្លាបសេក ឬចងកដៃជាប់ ធ្វើឲ្យរបូតចំណងបាន

៧- ចានទទេ ធ្វើឲ្យមានទឹកនៅក្នុងចាន

៨- លេបប្រាក់កាក់ហើយធ្វើឲ្យទៅនៅក្នុងហោប៉ៅអ្នកមើល

៩- យកទឹកខ្មៅ ឬទឹកសាអ៊ីវចាក់លើក្រូនកន្សែងអ្នកមើល ហើយ ធ្វើឲ្យស្អាតវិញ

១០- យកគ្រាប់ឈើមកដាំឲ្យដុះមានផ្កា ផ្លែ បេះបរិភោគបាន

១១- សូមចិញ្ចៀនលោកអ្នកមើលមកវាយឲ្យបែក ហើយធ្វើឲ្យ បានល្អវិញភ្លាម ។

១២- ចាក់ទីងកាំបិតមុតចេញឈាម ឲ្យសះជាភ្លាម ឬវះពោះស្រាវ ពោះវៀន (រឿងវះពោះស្រាវពោះវៀន មានផ្ដើលក្នុងពេង ល្ខោនមួង ដោយមានអ្នកមើលម្នាក់ឃើញស្ពង់ពេក ទៅ ជាខ្លាចឈាមវិលងងឹតមុខដួលធ្លាក់ពីលើកៅអី) ។

១៣- កាន់គ្រាប់ឡូកឡាក់ ១ ដុំ ឲ្យមើលហើយធ្វើឲ្យបាត់ពីនេះ ទៅ ឲ្យឃើញនៅឯណោះវិញ ។

១៤- លេងឲ្យក្មេង បី-បួន នាក់ ចូលក្នុងហិប ១ ដុំ បិទឲ្យជិត បើកហិបឲ្យមើលបាត់ក្មេងទាំងអស់ ។

១៤- មានលេងធ្វើឲ្យក្មេងស្រី ក្លាយទៅជាក្មេងប្រុស ។

រឿងល្បែងថ្មីនក្លែកនេះ ពួកខ្ញុំបានលេងឲ្យគេមើល ច្រើនកន្លែង ច្រើនដង ឯអ្នកមើលក៏បានឃើញជា សាក្សីច្រើនណាស់ដែរ ។

កាលលេងវាយចំពៀន មានព្រះអង្គម្ចាស់ចន្ទលេខា ជាសាក្សី ដោយទ្រង់បានទតយល់ច្បាស់ គឺខ្ញុំបានសូមខ្ចីព្រះទំរង់ពេជ្រចាំងត្រាប់ អំពីសម្ដេចព្រះអយ្យកោ ដែលទ្រង់គង់នៅជាសម្ដេចសុធារសនៅឡើយ យកមកវាយបែកខ្ទេចខ្ទី ហើយធ្វើឲ្យបានល្អថ្វាយទៅសម្ដេចវិញ ហើយទ្រង់បានទតឃើញ ខ្ញុំសូមខ្ចីអាវអំពីក្មេងម្នាក់ យកមកហែកដុតហើយ ធ្វើឲ្យបានល្អសងទៅក្មេងនោះវិញផង ។

មានរឿងខ្ចីកូនកន្សែងលោកអ្នកមើល មកហែកហើយដុត រួច ធ្វើឲ្យបានល្អសងទៅគេវិញ នៅចំពោះមុខលោកអ្នកមើលជាច្រើន ក្នុងឱកាសពិធីចែករង្វាន់នៅសាលាឧស្សាហកម្ម ។ មានរឿងច្រើនណាស់ ខ្ញុំមិនអាចនឹងសរសេរឲ្យអស់បានទេ ខ្ញុំគ្រាន់តែបន្ថែមរឿងមួយថា កាល ខ្ញុំបានលេងកលថ្មីនក្លែកម្ដង ក្នុងឱកាសពិធីចែករង្វាន់ដល់សិស្ស នៅ វិទ្យាល័យស៊ីសុវត្ថិ ចំពោះមុខឥស្សរជនជាន់ខ្ពស់ជាច្រើន មាននាយ ទាហានជាតិជប៉ុន បី-បួន នាក់ មករួបរួមផង គឺក្នុងសម័យដែលមាន ទាហានជប៉ុនមកជាច្រើនក្នុងស្រុកយើង ។

កាលនោះ ខ្ញុំបានលេងបួន-ប្រាំ រឿង មានរឿងមួយហៅថា

"រកមុខចោរឲ្យឃើញ" រឿងនេះទៅជាមានរឿងទាក់ទងនឹងរឿងជប៉ុន ។

ខ្ញុំដកកាបូបចេញពីក្នុងហោប៉ៅដាក់លើតុ ខ្ញុំនិយាយថា លោកអ្នកណាចង់ធ្វើចោរ សូមមកយកកាបូបខ្ញុំនេះ ទៅទុកនៅខ្លួនចុះ តែចាំឲ្យគេបិទមុខ ខ្ទប់ភ្នែកខ្ញុំឲ្យជិតសិន កុំឲ្យខ្ញុំមើលឃើញ ដល់យកកាបូបបាត់ទៅ ត្រូវស្រាយបើកមុខខ្ញុំ, ខ្ញុំនឹងសួរក្បាលខ្មោច ដែលនៅលើតុនេះ ឲ្យវាប្រាប់ថាចោរនៅឯណា ខ្ញុំរកមុខចោរនោះឃើញភ្លាម ៗ

ខ្ញុំនិយាយហើយហៅគេឲ្យមកយកសំពត់សវែង រុំបិទមុខខ្ទប់ភ្នែកឲ្យជិត ៗ តាមតែអ្នកណាចង់ធ្វើចោរ មកយកកាបូបនោះ បាត់កាបូបទៅហើយ ទើបគេស្រាយមុខខ្ញុំ ៗ សួរក្បាលខ្មោចដែលមានតែឆ្អឹងលលាដ៍ក្បាល មានភ្នែកក្រហូង ប្រមុះក្រហាក ធ្មេញស្រេញនោះ ហើយខ្ញុំដាក់ត្រចៀកទៅជិតមាត់វា មួយស្របក់ ខ្ញុំដើរត្រង់ទៅចាប់ដៃក្មេងម្នាក់ ដែលអង្គុយជិតលោកអ្នកធំម្នាក់នៅជួរមុខ និយាយថា នាងនេះហើយ ជាចោរលួចកាបូប ៗ នៅឯណាឲ្យមកខ្ញុំវិញ ៗ ក្មេងនោះបង្ហើបគូទ យកកាបូបឲ្យខ្ញុំ ៗ និយាយថា លោកអ្នកណាចង់ល ចង់លួច សូមមកលួចចុះ ១០ ដង ១០០ ដង ក៏ខ្ញុំរកមុខឃើញដែរ ៗ ថាហើយខ្ញុំហៅគេឲ្យមករុំបិទមុខខ្ញុំទៀត ៗ មួយស្របក់គេស្រាយបើកមុខខ្ញុំ, ខ្ញុំសួរក្បាលខ្មោចរកចោរ ម្តងនេះខ្ញុំដើរទុនសូមផ្លូវទៅតាមចន្លោះកៅអីជួរមុខ ទៅចាប់លោកម្នាក់ អង្គុយនៅជួរបន្ទាប់

លោកធ្វើជាមិនដឹងខ្លួន ថែមទាំងប្រកែកថា ឥតបានទៅយកកាបូបនោះទេ ។ ខ្ញុំនិយាយថា សូមលោកឲ្យកាបូបមកខ្ញុំវិញភ្លាម កុំនាំឲ្យខាតពេល ដ្បិតខ្ញុំដឹងច្បាស់ណាស់ថា លោកនេះពិតជាចោរលួចកាបូបខ្ញុំ សូមឲ្យមកខ្ញុំវិញ ទឹងបានដាក់ឲ្យលោកឯទៀតលួចលមើលផង កុំឲ្យយឺតយូរពេល ។ លោកនោះសើច លូកយកកាបូបពីក្នុងអាវឲ្យមកខ្ញុំ ដោយមានពាក្យថា អស្ចារ្យមែន ។ លោកអ្នកមើល ទះដៃសរសើរគ្រប់គ្នា ខ្ញុំយកកាបូបមកដាក់លើតុ ហើយសួរថា ប៉ុណ្ណឹងល្មមជឿថា ខ្ញុំអាចចាប់ចោរឬទេ ? បើថានៅមិនទាន់ជឿជាក់ទេ ខ្ញុំសុំឲ្យលមើលម្ដងទៀត ។ ក្រោយពីបានព្រមាត់ស្រែកថា សូមលមើលម្ដងទៀត ឲ្យគ្រប់ជា ៣ ដង ខ្ញុំហៅគេឲ្យមកបង់រុំបិទមុខ បិទភ្នែកបាន ១ ស្របក់ គេស្រាយបើកមុខ ខ្ញុំសួរក្បាលខ្មោច ហើយដើរទៅរកលោកសក្តិ ១ ជាតិជប៉ុន ទុនគោរពបន្តិច រួចខ្ញុំបង្អួលខ្លួនលោកនោះ ហើយលាបាតដៃហុចទៅ ធ្វើកិរិយាដូចជាថា លោកនេះលួចកាបូប ត្រូវឲ្យខ្ញុំវិញ ។ ពេលនោះ គេទះដៃប្រសព្វនៅជុំវិញ នាំឲ្យសក្តិ ១ ជប៉ុនក្រោកឈរទុនគោរព ហើយដកកាបូបពីហោប៉ៅខោ ហុចមកឲ្យខ្ញុំ រួចទុនគោរពទៀត ។

បន្ទាប់ពីនោះ គេសូមរុំបិទមុខខ្ញុំម្ដងទៀត ដល់បើកមុខសួររកចោរ ឃើញនាយទាហានជប៉ុនម្នាក់ផ្សេងទៀត អង្គុយជិតគ្នានោះ ។

ខ្ញុំស្មានថា ជប៉ុនជាប្រជាជាតិមួយ មានគំនិតប្រាជ្ញាវាងវៃណាស់

ផ្ទុយទៅវិញ ខ្ញុំឃើញច្បាស់ថា ម.បួន នាក់ ដែលមកមើលឃើញខ្ញុំលេងកាលនោះ ក៏ជឿថា មែនទែន ដោយគំនិតល្ងង់យល់ថាក្បាលខ្មោច ចេះខ្សឹបប្រាប់ខ្ញុំ បានជាខ្ញុំថាត្រូវដូចនេះ ៗ ដោយក្រោយពីពេលនោះមក បួនប្រាំថ្ងៃ គេនាំគ្នាមករកខ្ញុំនៅសាលា មានទាំងអ្នកប្រែភាសាមកជាមួយផង ចៅហ្វាយនាយខ្ញុំ ក៏ប្រើគេឲ្យនាំគេមកជួបនឹងខ្ញុំដែលកំពុងតែបង្រៀនសិស្សនៅក្នុងថ្នាក់ ៗ

គេមកសូមឲ្យខ្ញុំសួរក្បាលខ្មោច រកមុខចោរ ដោយមានគ្នាគេម្នាក់បាត់កាបូប ១ មានប្រាក់ពីរយេននិងឯកសារយ៉ាងសំខាន់នៅក្នុងនោះ ៗ

ខ្ញុំចង់សើច តែមិនហ៊ានសើចនឹងគំនិតល្ងង់ មិនយល់ការថា កាលដែលខ្ញុំលេង ៗ ដោយល្បិចកិច្ចកល មិនមែនលេងដោយក្បាលខ្មោចខ្សឹបប្រាប់ទេ ឯក្បាលខ្មោចនោះសោតទៀត ក៏ជាក្រដាសស្អាប់ធ្វើជាក្បាលខ្មោចក្លែងក្លាយ យកមកបំភាន់គំនិត លេងជាល្បែងជូនក្មេង ៗ តែដោយគេជឿស៊ប់ពេករកប្រកែកមិនបាន ម្យ៉ាងទៀតដោយខ្ញុំជឿទុកចិត្តខ្លួនថាជាអ្នកមានគំនិតប្រាជ្ញាម្នាក់ដែរ ចង់រកកាបូបដែលបាត់នោះម្ដងល្បងលមើល ហើយទទួលថា ចាំខ្ញុំសួរក្បាលខ្មោចលមើលក្រែងគេប្រាប់ ៗ

ក្រោយពីបានទៅជួបនឹងនាយទាហាន ដែលបាត់កាបូប ខ្ញុំសួរដេញដោលសព្វគ្រប់ ហើយគិតពិចារណាមើលតាមចម្លើយ រួចនាំទៅគ្រប់ទីកន្លែងដែលទៅណាមកណា ធ្វើអ្វីខ្លះកាលពីមុនពេលដែលដឹងថា

បាត់នោះ សូម្បីអាមេក ដែលធ្លាប់ទីនខ្ញុំខំដើរស្អួរ ហើយបង្អាក់កុំឲ្យសួរបែបនោះ ឲ្យខ្ញុំសួរក្បាលខ្មោចវិញ ក៏ខ្ញុំនៅតែស៊ើបសួរដោយប្រាប់ថា កាលដែលបាត់កាបូបនោះ ខ្មោចមិនបានដឹងមិនបានឃើញឯណា ត្រូវតែសួរឲ្យអស់ ដើម្បីទៅនិយាយប្រាប់ខ្មោចឲ្យវារកមើល តើកាបូបនៅទីដៃចោរណា ៗ

តាមការពិត ខ្ញុំពាល់គំនិតនឹងយកល្បិចកិច្ចកលថ្មីមករកកាបូបនេះ ទើបខ្ញុំប្រឌិតគំនិតតាមគេតាមល្បិចកិច្ចកលក្លូត ដេទិចទីវ ទៅវិញ ដោយខ្ញុំធ្លាប់បានអាន « រ៉ូម៉ង់ប៉ូលិសស៊ីយេ » រឿងប្រលោមលោកបែបខាងស៊ើបអង្កេត ដែលមានឈ្មោះប៉ាំងកៀកគុង ជា ដេទិចទីវ ៗ

រឿងរកកាបូបនេះពាវែងណាស់ បើខ្ញុំសរសេរឲ្យហូរហែ ធ្វើជារឿងប្រលោមលោកបាន ១ សៀវភៅ ៗ ដូចនេះ កុំឲ្យជីវប្រវត្តិរបស់ខ្ញុំ ក្លាយទៅជារឿងប្រលោមលោក ហើយកុំឲ្យវែងទៅទៀត សូមបញ្ចប់ថា ខ្ញុំរកឃើញកាបូបនោះ នៅគុម្ពផា មុខការិយដ្ឋាន១ ដែលមានពួកឃ្មួន ជាអ្នកប្រកបការរកទទួលទាន មានស្រីម្នាក់រើសបានកាបូបនោះ ដោយដប៉ុនពាំឲ្យជ្រុះធ្លាក់ ពីហោប៉ៅខាងក្រោយ ៗ ខ្ញុំបណ្ដោយឲ្យអ្នករើស យកប្រាក់ពីរយទៅចុះ ឲ្យតែកាបូបនិងឯកសារសំបុត្រក្រដាសទាំងប៉ុន្មានមកខ្ញុំ ៗ យកទៅដាក់ក្នុងគុម្ពផា ៗ

(នៅមានត)

# ផ្នែកកំណត់និងប្រវត្តិការណ៍

## សេចក្តីរាយការណ៍

អំពីសកម្មភាព នៃពុទ្ធសាសនបណ្ឌិត្យ

ក្នុង ៣ ត្រីមាស ឆ្នាំ ១៩៦៦

( ត-ចប់ )

*ទី៧–បានរៀបចំទីកន្លែង សំភារគ្រឿងនានាតាំងនៅក្នុងកណ្ណានិកេតន៍ របស់ក្រសួងឲ្យស្អាតមានរបៀប កត់ត្រាចំនួនត្រឹមត្រូវ ដូចជា ព្រះពុទ្ធរូបមាស ត្រៃប្រណីត ៗ តាំងនៅខាងមុខ នាក្រសួងធម្មការ និង ត្រៃសំណាង ត្រៃទេសនា ជាដើម ។*

### យោបល់រួម:

*ការដែលបានរៀបចំត្រឹមត្រូវទៀងទាត់បែបនេះ គឺដោយសារសហប្រតិបត្តិការយ៉ាងជិតស្និទ្ធ របស់បុគ្គលិក ក្នុងក្រសួងទាំងមូល ជាជំនួយ ក្រោមឱវាទណែនាំ និងយកចិត្តទុកដាក់ផ្ទាល់ របស់ឯកឧត្តមអនុរដ្ឋលេខាធិការក្រសួងធម្មការ ។*

### ៣–ផ្នែកបំណុលបំណាយ :

#### ក–ផ្នែកចំណាយ :

*តាមព្រះរាជឱវាទរបស់សម្តេចព្រះប្រមុខរដ្ឋ និង ព្រះរាជរដ្ឋាភិបាល ព្រមទាំងឯកឧត្តមចៅក្រសួង វិជ្ជាឋានបានត្រិះរិះសន្សំនិងសំចៃថវិកា*

ខាងចំណាយដែលមានគ្រោងទុកក្នុងថវិកាបានសល់ រហូតមកដល់ថ្ងៃទី ៣០ កញ្ញា ១៩៦៦ នេះ ដូចតទៅគឺៈ

– ផ្នែកសំលៀកបំពាក់ ៤.៤០០ រៀល ដែលមិនទាន់ប្រើប្រាស់ ហើយនិងពាក់ការផ្តល់ឱ្យបុគ្គលិកផ្នែកបណ្ណាគារ និងអ្នកបើកបរថយន្ត ។

ផ្នែកបោះពុម្ព ១៥០ រៀល ។

សរុបប្រាក់សល់ចំនួន បួនពាន់ប្រាំរយហាសិបរៀល (៤៥៥០ រៀល) ។

១– ផ្នែកចំណូល :

សូមជំរាបថា ក្នុងចំណូលនេះ រដ្ឋបាលបានខិតខំផ្សាយនូវការជាវសៀវភៅនានា របស់ក្រសួងយ៉ាងសកម្មណាស់ ប៉ុន្តែទឹកប្រាក់ដែលបានទទួលអំពីការលក់ ហើយត្រូវយកទៅដាក់ឃ្លាំង ឃើញថយអំពីឆ្នាំមុនដោយមានបុព្វហេតុ ដូចជំរាបតទៅខាងមុខ ។

ប្រាក់ចំណូលមកទល់នឹងថ្ងៃទី ៣០ កញ្ញា នេះ មានចំនួន : ១.៣២៨.២៤៧រ៨១ បើធៀបទៅនឹងចំណូល ៣ ត្រីមាស ក្នុងឆ្នាំ ១៩៦៥ ដែលមានចំនួន : ១.៧៧៥.៣៤២រ៣៤ នោះ ឃើញចំណូលក្នុង ៣ ត្រីមាសឆ្នាំនេះ ថយជាងមុន ចំនួន ៣៤៧.០៩៤រ៥៣ ។

ការថយចំណូលចំនួនដូចប្រៀបធៀបខាងលើនេះបណ្តាលមកពីៈ–

១– ក្រសួងធម្មការ បានចំបែកយកសៀវភៅចំនួន ១៦ មុខ

របស់ហិបធម្មសម្បត្តិបេញទៅកាន់គាប់ ដោយគណៈកម្មការពិសេស សូមបញ្ជាក់ថា ពីដើមមក សៀវភៅ ១៦ មុខនេះ វិជ្ជាបានលក់យកប្រាក់បញ្ចូលថវិកាជាតិ ហើយដកកម្រៃបំណេញ ១០ ភាគរយប៉ុណ្ណោះប្រគល់ជាគុណប្រយោជន៍ជូនហិបធម្មសម្បត្តិ ។

២– សៀវភៅ ២៤ មុខ ដែលពុទ្ធិកវិទ្យាល័យតែងបោះពុម្ព ដោយថវិកាផ្ទាល់ ហើយប្រគល់មកឲ្យវិជ្ជាបានលក់ ប្រមូលយកកម្រៃដាក់ឃ្លាំងនោះ ក្នុងឆ្នាំនេះ គ្មានបានបោះពុម្ពមួយសោះ ។ សៀវភៅនេះត្រូវអស់ ៣ មុខ ដែលដាច់ណាស់គឺ :

កច្ចាយនរូបគម្ពីរ ភាគ ១

ធម្មបទដ្ឋកថា ភាគ ១ និង ភាគ ២ ។

៣– បវេសនកាលនៃសិស្សឆ្នាំនេះ ចូលមកក្នុងខែកញ្ញា ដែលខុសពីឆ្នាំ ១៩៦៤ ចូលក្នុងខែសីហា ។ សូមជំរាបថា សៀវភៅសិក្សាលក់ដាច់ជាងគេ ។

៤– មានឧបសគ្គខ្លះ ក្នុងការផ្សាយសៀវភៅ របស់រាជការទៅលើផ្សារសាធារណៈ ព្រោះ :–

ទី ១– យើងឲ្យកម្រៃការគរយ ដល់ឈ្មួញអ្នកលក់តែត្រឹម ១០ ភាគរយ ជាហេតុឲ្យឈ្មួញនៅឆ្ងាយ ។ មិនហ៊ានមកទិញយកទៅលក់ ព្រោះគ្មានបំណេញ ។ ឯឈ្មួញ ឬបណ្ណាគារផ្សេងៗវិញ គេហ៊ានឲ្យកម្រៃដល់អ្នកជាវដុំ ដល់ទៅ ៣០ ឬ ៤០ ភាគរយឯណោះ ។

ទី៥– ឈ្មួញបោះពុម្ពសៀវភៅសិក្សា ប្រវែងប្រណាំងជាមួយ រាជការយើងយ៉ាងសកម្ម ។ សូមជម្រាបថា រឿងនេះក្រសួងបានសរសេរ ចុតហ្មាយ សុំឲ្យក្រសួងអប់រំជាតិជួយផ្សាយ និងលៃលកជួយរាជការផង អំពីរឿងសៀវភៅសិក្សានេះ ។ វិជ្ជាស្ថានបានតាំងផ្ញើសៀវភៅ ទៅក្រសួងអប់រំជាតិថែមទៀត ដើម្បីធ្វើជាគំរូឲ្យជួយផ្សាយ ប៉ុន្តែធ្វើយ៉ាងណាក៏លក់មិនឈ្នះឈ្មួញ ដែលមានមធ្យោបាយខាងជំនួញដេញដើររាជការ យ៉ាងប៉ិនប្រសប់ ។

យោបល់រួមចំពោះបំណុល :

ចំពោះបំណុលនេះ វិជ្ជាឋានសង្ឃឹមប្រាកដថា នៅត្រឹមមាសទី ៤ មុខជានឹងបានកើនប្រាក់ច្រើន មិនចាញ់ឆ្នាំ ១៩៦៨ ទេ ពីព្រោះ :

១– សាលាមធ្យមសិក្សាទើបនឹងចូលរៀន ។

២– ព្រះត្រៃបិដកបោះពុម្ពឆ្នាំនេះ ចំនួន ៦ ក្បាល គឺពីភាគ ៨៤ ដល់ ៩០ នឹងចេញនៅដំណាច់ឆ្នាំនេះ ។

៣– ក្នុងសម័យកឋិនទាននេះ ឧបាសក ឧបាសិកា តែងជាវសៀវភៅផ្នែកធម៌ច្រើនណាស់ជារៀងរាល់ឆ្នាំ ។

បើធៀបទៅនឹងថវិកាជាតិ សម្រាប់បោះពុម្ពសៀវភៅនានា ( រួមទាំងព្រះត្រៃបិដក ៦ ក្បាល ) ក្នុងឆ្នាំ ១៩៦៦ នេះ ដែលមាន ១.៤៩៨.០០០៛០០ នោះ យើងឃើញថា រាជការនៅខ្វះតែបំណុល

១២៩.៧៥២៛១៩ ប៉ុណ្ណោះ ទឹងរួចខ្វះគឺ : ១.៤៥៨.០០០៛ - ១.៣២៨.២៤៧៛៨១ = ១២៩.៧៥២៛១៩ ។ ដូច្នេះកងការមុខជាទឹងចំណាញនៅដំណាច់ឆ្នាំ ១៩៦៦ នេះ ។

## ៤_ ការបោះពុម្ពផ្សាយ :

កន្លងឆ្នាំ ១៩៦៦ នេះ បំពោះថវិកាគ្រោងចំនួន ១.៤៥៨.០០០៛០០ សម្រាប់បោះពុម្ពផ្សាយ ។ វិជ្ជាឋាន បានបោះពុម្ពសៀវភៅជាចាំបាច់ ដែលអស់ពីឃ្លាំង ព្រមទាំងសៀវភៅថ្មីខ្លះ ដូចតទៅ :-

| លេខរៀង | ឈ្មោះសៀវភៅ | ចំនួន | សេចក្ដីផ្សេងៗ |
|---|---|---|---|
| ១ | ព្រះត្រៃបិដក ភាគ ៨៥ | ១.៥០០ | |
| ២ | -ដ- - ៨៦ | ១.៥០០ | |
| ៣ | -ដ- - ៨៧ | ១.៥០០ | |
| ៤ | -ដ- - ៨៨ | ១.៥០០ | |
| ៥ | -ដ- - ៨៩ | ១.៥០០ | |
| ៦ | -ដ- - ៩០ | ១.៥០០ | |
| ៧ | ទស្សនាវដ្ដីកម្ពុជសុរិយា ១២ លេខ; ១ លេខបោះពុម្ព ៥០០ ក្បាល រួមមួយឆ្នាំ.... | ៦.០០០ | |
| ៨ | ហាន់យន្ត | ៤.៩០០ | |

| | | |
|---|---|---|
| ៩ | មាតាបិតុឧបដ្ឋានកថា | ៣.០០០ |
| ១០ | គតិលោក ភាគ ៣ | ៥.០០០ |
| ១១ | កាកី | ៦.៥០០ |
| ១២ | បទានុក្រមកាមកើត | ៥.០០០ |
| ១៣ | រឿងសព្វសិទ្ធិ | ១០.០០០ |
| ១៤ | អនុមោទនាវិធី | ៤.០០០ |
| ១៥ | គោតកុលកុមារ | ២.៥០០ |
| ១៦ | ស័ង្ខសិល្បជ័យ | ៣.០០០ |
| ១៧ | សុបិនកុមារ | ៥.០០០ |
| ១៨ | តុក្កតាក់ទកថា | ១.០០០ |
| ១៩ | មហាវេស្សន្តរជាតក ភាគ ១ | ១.០០០ |
| ២០ | -ដ- - ២ | ១.០០០ |
| ២១ | -ដ- - ៣ | ១.០០០ |
| ២២ | -ដ- - ៤ | ១.០០០ |
| ២៣ | -ដ- - ៥ | ១.០០០ |
| ២៤ | -ដ- - ៦ | ១.០០០ |
| ២៥ | -ដ- - ៧ | ១.០០០ |
| ២៦ | -ដ- - ៨ | ១.០០០ |

| | | |
|---|---|---|
| ២៧ | -ដ- — ៩ | ១.០០០ |
| ២៨ | -ដ- — ១០ | ១.០០០ |
| ២៩ | -ដ- — ១១ | ១.០០០ |
| ៣០ | -ដ- — ១២ | ១.០០០ |
| ៣១ | -ដ- — ១៣ | ១.០០០ |
| ៣២ | សត្តបរិត្ត-ទ្វាទសបរិត្ត | ៣.៥០០ |
| ៣៣ | គិហិបដិបត្តិ | ១០.០០០ |
| ៣៤ | ប្រជុំរឿងព្រេង ភាគ ២ | ២.០០០ |
| ៣៥ | កមគ្តើ ភាគ ៣ | ៤.០០០ |
| ៣៦ | -ដ- — ៤ | ៣.០០០ |
| ៣៧ | មួយពាន់ ១ យប់ ភាគ ៥ | ២.០០០ |
| ៣៨ | — — ៦ | ២.០០០ |
| ៣៩ | — — ៧ | ២.០០០ |
| ៤០ | — — ៨ | ២.០០០ |
| ៤១ | — — ៩ | ២.០០០ |
| ៤២ | — — ១៣ | ២.០០០ |
| ៤៣ | — — ១៤ | ២.០០០ |
| ៤៤ | — — ១៥ | ២.០០០ |

| | | |
|---|---|---|
| ៤៥ | ច្បាប់ផ្សេង ៗ | ២.០០០ |
| ៤៦ | ពុទ្ធសែន | ១០ ០០០ |
| ៤៧ | បាតិមោក្ខសង្ខេប | ៣ ០០០ |
| ៤៨ | ធានកថា | ២.៤០០ |
| ៤៩ | មួយពាន់១យប់ ភាគ ២០ | ២.០០០ |
| ៥០ | ព្រហ្មចរិយកថា | ២.៤០០ |
| ៥១ | សាមណេរវិន័យ | ៨.០០០ |
| ៥២ | វិសុទ្ធិមគ្គ ភាគ ២ | ១.០០០ |
| ៥៣ | ពុទ្ធសាសន៍ សង្ខេប | ១.៥០០ |

បូករួមចំនួន : ១៤៨.៧០០ សៀវភៅ

សរុបចំនួនសៀវភៅ ដែលបានបោះពុម្ព ក្នុងឆ្នាំនេះគឺមាន ៖

— សៀវភៅ ៥៣ មុខផ្សេង ៗ គ្នា រួមទាំងទស្សនាវដ្ដីនិង ព្រះត្រៃបិដក ។

— ចំនួនសរុបនៃសៀវភៅទាំង ៥៣ មុខឡើងដល់ ១៤៨.៧០០ សៀវភៅ ។

## យោបល់រួម :

បើគិតទៅតាមចំនួនសៀវភៅ ដែលអ្នកជាត្រូវការនោះ ក្រសួងនៅខ្វះសៀវភៅច្រើនមុខណាស់ ដែលមកដល់សព្វថ្ងៃនេះ មុខខ្វះត្រូវអស់

លើងទៅហើយ ៗ ចំណែកសៀវភៅរបស់ធម្មសម្បត្តិ និង របស់ពុទ្ធិកវិទ្យាល័យ ក៏ខ្វះមុខខ្វះជាច្រើន ដែលពុំទាន់បោះពុម្ពទៅឡើយសោះ សំរាប់លក់ឲ្យពុទ្ធបរិស័ទ ដូចជា :

ក - របស់ក្រសួងគឺ អស់សៀវភៅឈ្មោះ :

១- មួយពាន់មួយយប់ ភាគ ១០-១១-១២-១៥-១៦-
១៧-១៨-១៩-២១-២២-
២៣-២៤-២៩-៣០-៣១-
៣២-៣៣-៣៤-៣៥-៣៦
៣៧-៣៨-៣៩-៤០-៤១
៤២-៤៣ ដល់ ៥០ ។

២- គតិលោក ភាគ ១

៣- ប្រជុំរឿងព្រេង ភាគ ១

៤- ពន្លឺកាសុទ្ទីប

៥- ពាក្យកាព្យថ្លែងរឿងពុទ្ធប្បវត្តិ

៦- សេចក្តីលើកដាស់តឿន

៧- ពិធីទូទសមាស ភាគ ១

៨- ព្រះបាទអសោក

៩- ព្រះចន្ទគុប្ត

១០– តេនប្បកា

១១– ព្រះសុជន

១២– ស្រវបេក

១៣– វចនានុក្រមខ្មែរភាគ ១–២

១៤– សិលាចារឹកនគរវត្ត

១៥– សីលនិទ្ទេស

១៦– សុរិយាគ្រឡើងស័ក

១៧– អត្តានុសាសនី

១៨– អំពីប្រាសាទខ្ទះនៅអង្គរ

១៩– ទំនៀមការផ្ចាល់ខ្លួន

២០– ទុំទាវ

២១– នានាជាតក

២២– បញ្ចអភិណ្ហបច្ចវេក្ខណៈ

១_ របស់ពុទ្ធិកវិទ្យាល័យ គឺអស់សៀវភៅឈ្មោះ :

១– កច្ចាយនរូបត្ថម្ភ ភាគ ១ – ២

២– ធម្មបទភាគ ១–២

២_ របស់ហិបធម្មសម្បត្តិគឺអស់សៀវភៅឈ្មោះ :

១– សាសនសុភាសិត ភាគ ១

២- ចតុប្បារិសុទ្ធិសីល

៣- ប្រជុំកងធម៌ ថ្នាក់ត្រី ទី ១

៤- ពុទ្ធប្បវត្តិ ទូរេនិទាន ទី ១

## សេចក្តីសង្កេត :

ក- ចំពោះសៀវភៅទាំងឡាយរបស់ក្រសួង ដែលអស់ក្នុងឆ្នាំនេះ វិជ្ជាឋាននឹងអាចបោះបានទាល់តែក្នុងឆ្នាំ ១៩៦៧ សំរាប់ថវិកាផ្តល់មកថ្មី ។

១- វិជ្ជាឋានស្តាយ ដោយសៀវភៅទាំងឡាយ បោះពុម្ពដោយថវិកាខាងពុទ្ធិកវិទ្យាល័យ និងហិបធម្មសម្បត្តិ ដែលអស់ពុំបានបោះពុម្ពក្នុងឆ្នាំនេះ ដើម្បីផ្តល់ចំពោះសេចក្តីត្រូវការរបស់ពុទ្ធបរិស័ទនោះ ។

## ៥- ការទាក់ទងចំពោះអង្គការនានា :

ក្នុងឆ្នាំ ១៩៦៦ វិជ្ជាឋានបានធ្វើការទាក់ទងប្តូរខាងវប្បធម៌ជាមួយអង្គការនានាក្នុងប្រទេស និង ក្រៅប្រទេសបានយ៉ាងសកម្ម ដូចជា ៖

### ក- ក្នុងប្រទេស :

### ១- ជាមួយអង្គការជាតិ :

-បានទាក់ទងនឹងសមាគមនានា ដោយប្តូរឯកសារខាងវប្បធម៌ ( មានសៀវភៅ និង ទស្សនាវដ្តីផ្សេង ៗ ) ។

- វិជ្ជាឋានបានផ្តល់សៀវភៅ ជូនសមាគមអ្នកនិពន្ធ សមាគម

សាស្ត្រាចារ្យខ្មែរ សមាគមបុគ្គលិកសិក្សា និង ទីចាត់ការគរុកោសល្យនៃក្រសួងអប់រំជាតិ ។

- តាមសេចក្ដីសំរេច នៃកិច្ចប្រជុំការងាររបស់ក្រសួង វិជ្ជាឋាននឹងផ្ដល់សៀវភៅរបស់ខ្លួន ដល់សមាគមនិស្សិតទូទៅ នៃប្រទេសកម្ពុជា ដើម្បីជាការផ្សាយនូវវប្បធម៌ នៅមុនដំណាច់ឆ្នាំនេះ ។

- បានទាក់ទងនឹងបណ្ណាល័យជាតិ ដែលផ្ដល់ឯកសារសំខាន់ៗ មកដំកល់ទុកនៅបណ្ណាល័យរបស់ក្រសួងយើងជាច្រើន ចាប់តាំងពីដើមឆ្នាំ ១៩៦៦ មក ។

## ២– ជាមួយអង្គការបរទេស :

- វិជ្ជាឋានបានទទួលអំណោយសៀវភៅ អំពីអង្គការបរទេសខ្លះ ដើម្បីដំកល់ទុកជាសាធារណប្រយោជន៍ នៅបណ្ណាល័យរបស់ខ្លួនដូចជា :

- ពីដើមឆ្នាំបានទទួលសៀវភៅ ផ្សេង ៗ ចំនួនជាង ៣០០ ក្បាល ពីមូលនិធិអាស៊ី ។

- ពីថ្ងៃ ១៧ - ៤ - ៦៦ បានទទួលសៀវភៅ ៣០០ ក្បាល ពីស្ថានទូតចិនប្រជាមានិត ។

- ពីថ្ងៃ ១២-៧-៦៦ បានទទួលសៀវភៅជាង ៥០០ ក្បាល ពីក្រុមវប្បធម៌នៃស្ថានទូតសហភាពសូវៀត ។

- ហើយនឹងបានទទួលនូវទស្សនាវដ្ដី សារពត៌មាន ជាហូរហែ

ពីអង្គការវប្បធម៌ដទៃច្រើនទៀត សំរាប់ដាក់តម្កល់ទុកនៅបណ្ណាល័យ ដូចជា អំពីស្ថានទូតចិន ឥណ្ឌា រុស្ស៊ី បារាំង កូរ៉េ ជប៉ុន យៀកណាមខាងជើង អាល្លឺម៉ង់ខាងកើត ឥណ្ឌូណេស៊ី ជាដើម ។

១- ក្រៅប្រទេស :

វិជ្ជាល័យបានទាក់ទងជាប្រក្រតី ជាមួយអង្គការវប្បធម៌នានា នៅបរទេស មាន :

- អង្គការនៃការសិក្សាស្រាវជ្រាវជាន់ខ្ពស់ នៅ ប្រ៊ុកសែល ប្រទេសបែលហ្ស៊ិក ។

- អង្គការអាល្លឺម៉ង់ខាងការសិក្សាពុទ្ធសាសនា «នៅបែរឡាំង» សាធារណរដ្ឋអាល្លឺម៉ង់ខាងកើត ។

- អង្គការសិក្សាស្រាវជ្រាវជាន់ខ្ពស់ នៃក្រុងប៉ារីស និង សាលាបុងបូញ៉ាប្រទេស ។

- អង្គការសិក្សាស្រាវជ្រាវជាន់ខ្ពស់ នៅហុងកុង ស្តីពីពុទ្ធសាសនា, នៅក្រុងឡុងដ៏ នៃចក្រភពអង់គ្លេស, នៅក្រុងតូក្យូ នៃប្រទេសជប៉ុនជាដើម ។

- អង្គការស៊ីប៊ែរ្យកនៃសាធារណរដ្ឋសង្គមនិយមសូវៀត ។

គ- ការទទួលភ្ញៀវសំខាន់ៗ :

ក្នុងឆ្នាំនេះ វិជ្ជាល័យបានទទួលគណៈប្រតិភូនិងអ្នកប្រាជ្ញបរទេស

ជាហូរហែពុំដាច់ ដែលបានភ្ជាប់អារម្មណ៍ ចំពោះសារប្រយោជន៍ នៃពុទ្ធសាសនា វប្បធម៌ និង អារ្យធម៌ខ្មែរ ។

គួរកត់សំគាល់នូវនាមអ្នកប្រាជ្ញធំៗ ខ្លះ ដែលបានចូលមកស្រាវជ្រាវសិក្សា ក្នុងវិជ្ជាឋានគឺ :

— លោក សង់ឌីកុហ្វហ្វែរ ជានាយក និងអ្នកនិពន្ធនាយកនៃទស្សនាវដ្ដី " លីគួរ៉ិយេរឌឺលុយណេស្កូ " (ថ្ងៃ ២១.៥.៦៦) ។

— ពពួកនិស្សិតខាងបណ្ណាល័យដឹកនាំអ្នកបច្ចេកទេសបារាំងឈ្មោះ កញ្ញា ហ្សឺណឺវីយ៉េវ ហ្សង់វីយេ (ថ្ងៃ ២៦-៤-៦៦) ។

— លោក ម៉ែលគុន អូសបោន អ្នកប្រាជ្ញជាតិអូស្ត្រាលី (ថ្ងៃ ២៦-៤-៦៦) ។

— លោក ហ្សង់ ហ្វីលីយ៉ូហ្សា អ្នកប្រាជ្ញយ៉ាងធំនៃប្រទេសបារាំង ខាងរឿងបុរាណប្រទេស ( ថ្ងៃ ១០-៥-៦៦ ) ។

— លោក អាគេ ហាក់ឡង់ និង ស្រេហ្គាគង់ហ្គោ ស៊ុវហុល ស្រេដេន អ្នកប្រាជ្ញជាតិ ស៊ុយអេដ្វារ ( ថ្ងៃ ១០-៥-៦៦ ) ។

— ព្រះគ្រូ ស៊ុយកូ អ៊ីស៊ីស៊ុយគី អ្នកប្រាជ្ញជាតិជប៉ុន (ថ្ងៃ ២៤-៥-៦៦ ) ។

— លោក ដូស៊ីយេក ហ្សេយ៉េលហ្សង់ស្គី អ្នកសារពត៌មាន ប៉ូឡូញ ( ថ្ងៃ ១៦-៦-៦៦ ) ។

- ក្រុមយុវជនជាតិបារាំងចំនួន ៣០ នាក់ នៃក្រុម « អាសស៊ីន ទែរ ហ្សីនី » ( ថ្ងៃ ២០.៨.៦៦ ) ។

កញ្ញាស៊ីលវេតី ស៊ុណាយ បារបារ៉ា វ្រូគ្ចប៊ែយែរ ជាតិអល្លឺម៉ង់ ( ថ្ងៃ ១៥.៨.៦៦ ) ។

## ៦_ កិច្ចប្រជុំការងារ និង ពិធីសំខាន់ ៗ:

ក្នុងរយៈ ៣ ត្រីមាសនេះ វិជ្ជាឋានបានប្រជុំការងារ ដើម្បីពិភាក្សាកិច្ចការក្នុងក្រសួងចំនួន ១៨ ដង និងមានបញ្ជូននូវសេចក្តីកត់ហេតុនៃការប្រជុំទាំងនោះគ្រប់ពេល ជូនទៅក្រសួងធម្មការ ដើម្បីជ្រាបជាពត៌មានចំពោះសេចក្តីសម្រេចនានាជាកស្តុតាង ។

ចាប់ពីឆ្នាំនេះតទៅ វិជ្ជាឋានបានសម្រេចធ្វើនូវពិធីបុណ្យខួប របស់វិជ្ជាឋាន ដែលកំណត់នៅថ្ងៃ ១២ មករា រៀងរាល់ឆ្នាំ ។

ចំពោះឆ្នាំនេះ ខួបទី ៣៦ នៃការបង្កើតវិជ្ជាឋាន បានធ្វើយ៉ាងឧឡារិក កាលពីថ្ងៃអាទិត្យទី ២៩ មករា ១៩៦៦ ក្រោមអធិបតីភាពនៃសម្តេចព្រះពោធិវង្ស និងឯកឧត្តម ទ្រឹញ ហ៊ាញ អនុរដ្ឋលេខាធិការ ក្រសួងធម្មការ ។

## សេចក្តីសន្និដ្ឋាន:

កិច្ចការទាំងអស់ ដូចក្នុងសេចក្តីរាយការណ៍ ដែលបានសម្រេចលទ្ធផលដ៏ប្រសើរនេះ គឺកើតឡើងដោយសារ:

— គោរពទៅតាមនយោបាយនៃសង្គមរាស្ត្រនិយម ក្រោមព្រះរាជកិច្ចដឹកនាំដ៏ភ្លឺស្វាង នៃអគ្គសម្តេចព្រះប្រមុខរដ្ឋ ព្រះបិតាជាតិ និងព្រះរាជរដ្ឋាភិបាល ។

សហប្រតិបត្តិការយ៉ាងជិតស្និទ្ធ របស់បុគ្គលិក ជាសហការីនៃវិជ្ជាឋាន ហើយនិងក្រសួងធម្មការ ដែលមានឯកឧត្តម អនុរដ្ឋលេខាធិការ ព្រមទាំងក្រសួងនានា ក្រោមឱវាទនៃក្រសួងធម្មការ ។

នៅត្រីមាសទី ៤ នៃឆ្នាំនេះ វិជ្ជាឋាន មុខជានឹងបានសម្រេចនូវលទ្ធផលមួយកម្រិតថែមទៀត ជាពិសេស គឺខាងផ្នែកការផ្សាយវប្បធម៌អារ្យធម៌ជាតិ និងការប្រមូលប្រាក់ចំណូល ដែលបានមកពីការលក់សៀវភៅនានាសម្រាប់ថវិកាជាតិ ។

ភ្នំពេញ ថ្ងៃទី ៣០ កញ្ញា ឆ្នាំ ១ ៦៦

នាយកនៃពុទ្ធសាសនបណ្ឌិត្យ

ហត្ថលេខា ៖ ឈាង-ហ៊បអាន

៣

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

ឆ្នាំទី ៣៩ ខែ មីនា

ព.ស. ២៥០៩ គ.ស. ១៩៦៧

- ភ្នំពេញ -

...U CAMBODGE
P.K. 1
1967 . 3

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ
បេញរាល់ខែ ពីពុទ្ធសាសនបណ្ឌិត្យ

## បញ្ជីរឿង

ផ្នែកសាសនា ទំព័រ

១– បញ្ហាព្យាករណ៍ពីពុទ្ធសាសនា លោក សម-ថាំង ប្រែ-រៀបរៀង (ត) . . . . ២២៩
២– ព្រះត្រៃលក្ខណ៍ លោក ព្រួប-ភុម ស្រាវជ្រាវ–ដកស្រង់ (ត-ចប់) . . ២៣៩

ផ្នែកអក្សរសាស្ត្រ

៣– ការយកគ្នាជាប្ដីប្រពន្ធ (វិចារណកថា) លោក ផេង-ផ្រីវ រៀបរៀង . : . ២៥១
៤– គួរតម្រង់ទិសអក្សរសាស្ត្រឱ្យចំគោលដៅ លោក មាស-យុត្ត រៀបរៀង. . . . ២៦១
៥– វចនានុក្រម សំស្ក្រឹត-ខ្មែរ ព្រះមហា ជាំង–ខាត់ រៀបរៀង (ត) . . . . . ២៦៧
៦– ពិចារណាដើម្បីយល់តក្កវិជ្ជា លោក ហ៊ុន គឹមសៀ រៀបរៀង (ត) . . . ២៧១
៧– ព្រះរាជនិពន្ធរាមកេរ្តិ៍ លោក ឱ. ធាម ស្រាវជ្រាវ (ត) . . . . . . ២៧៩
៨– ឯកសារ សាស្ត្រាស្លឹករឹតនិងក្រាំង លោក ញ៉ុក-ថែម រៀបរៀង (ត) . . . ២៨៧
៩– រឿងសាមកុក អ្នកឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង (ត) . . . . ២៩១
១០– ឯកសារកម្ពុជសុរិយា លោក ឱ.ធាម ប្រមូលរៀបរៀង (ត) . . . . . . ២៩៩
១១– ជីវប្រវត្តិរបស់ខ្ញុំ ឈ្មោះ អៀង-សាយ (ត) . . . . . . . . . . . ៣០៧
១២– អត្ថបទផ្នែកទំនៀមទម្លាប់ ចូលឆ្នាំថ្មី អ្នកស្រី ពេជ្រ-សល់ រៀបរៀង . . . . ៣១៥

ផ្នែកកំណត់និងប្រវត្តិការណ៍

១៣– សេចក្ដីរាយការណ៍ អំពីសកម្មភាពពុទ្ធសាសនបណ្ឌិត្យ ត្រីមាសទី ៤-១៩៦៦ . . ៣២២
១៤– អនុស្សាវរីយ៍មហាសន្និបាតមន្ត្រីសង្ឃទី ២៣ . . . . . . . . . . ៣៣០

មួយឆ្នាំមាន ១២ សៀវភៅ តម្លៃជាវ ២៣០រ០០ ៗ

## ផ្នែកសាសនា

ពាក្យឃាត់មិនឲ្យ ធ្វើការអាក្រក់
ជាការពារមក, ឲ្យធ្វើល្អទៅ,
ឲ្យដុសខាតចិត្ត កុំឲ្យហ្មងសៅ,
បីនេះលោកហៅ ពុទ្ធសាសនា ។

ប.ព.

# បញ្ហាព្យាករណ៍ពីពុទ្ធសាសនា

(ត)

លោក សម-ថាំង ប្រែ - រៀបរៀង

ប្ញុ. ព្រះសទ្ធម្មទេសនានោះ នាំពួកបញ្ចវគ្គិយឲ្យបានផលដូចម្ដេចខ្លះ?

វិ. កោណ្ឌញ្ញដែលចាស់ជាងគេ ជាអ្នកដឹងច្បាស់បានលះបង់អស្មិមានះមុនគេ ហើយទទួលគោរពស្ដាប់ព្រះធម៌របស់ព្រះអង្គនោះ បានជាសាវ័កសំរេចព្រះអរហត្តផលក្នុងខណៈនោះ ។ ឯព្រាហ្មណ៍៤រូបទៀតបានយកតំរាប់តាមហើយក៏បានសំរេចអរហត្តផលជាលំដាប់ទាន់ក្រោយដែរ ។

ប្ញុ. ព្រះអង្គទ្រង់ប្រៀនប្រដៅជនណាតទៅទៀត ?

វិ. ទ្រង់ប្រៀនប្រដៅសេដ្ឋីបុត្រឈ្មោះ យស និងបិតាដែលជាមហាសេដ្ឋី ។ លុះបាន ៣ ខែ សាវ័កក៏បានកើនឡើងមានចំនួន ៦០ រូប ។

ប្ញុ. ស្ត្រីណាខ្លះ ដែលបានជាសាវិកាមុនគេបង្អស់ ?

វិ. គឺមាគ៌ានិងកិរិយានៃព្រះយស ។

បុ. ព្រះពុទ្ធជាម្ចាស់ទ្រង់ធ្វើអ្វីតទៅទៀត ?

វិ. ទ្រង់ប្រជុំអស់ពួកសាវ័កព្រះអង្គ ហើយបង្ហាត់បង្រៀនប្រៀនប្រដៅព្រះធម៌ដ៏ជ្រាលជ្រៅ ទើបទ្រង់ចាត់ឲ្យទៅប្រកាសផ្សាយសាសនាគ្រប់ទិសទាំងពួង ។

បុ. អត្ថរស របស់ព្រះពុទ្ធសាសនាដូចម្តេច ?

វិ. ព្រះពុទ្ធសាសនាជាផ្លូវដឹកនាំសត្វ ឲ្យរួចចេញចាកទុក្ខទាំងពួង ដោយចរិយាការប្រព្រឹត្ត តាមគន្លងដំណើរ ដែលនឹងអធិប្បាយទៅខាងក្រោយ ។

បុ. គន្លងដំណើរទៅកាន់អរហត្តផលនោះឈ្មោះអ្វី ?

វិ. ឈ្មោះថាផ្លូវដ៏ប្រសើរមាន ៨ ប្រការ ។

បុ. ផ្លូវនោះជាភាសាបាលីហៅថាដូចម្តេច ?

វិ. អរិយោ អដ្ឋង្គិកោ មគ្គោ ។

បុ. ព្រះសម្មាសម្ពុទ្ធ ទ្រង់យាងទៅកាន់ទីណាទៀត ?

វិ. ទៅកាន់ព្រៃឧរុវេឡ ។

បុ. មានហេតុកើតដូចម្តេចនៅទីនោះ ?

វិ. ព្រះអង្គប្រដៅសាស្តាម្នាក់ ឈ្មោះកស្សប ដែលល្បីល្បាញដោយចំណេះវិជ្ជា ហើយដែលជាគណាចារ្យយ៉ាងធំ ព្រមទាំងពួកជដិល

ដែលជាសិស្សគណ ប្រកាន់ខាងលទ្ធិបូជាយ័ញ ឲ្យបានលុះដោយនូវសំណាញ់ញាណរបស់ព្រះអង្គ ។

ប្ញ. មហាបុរសណាមួយ ដែលបានលុះដោយដំបូន្មាន របស់ព្រះអង្គដែរ ?

វិ. ព្រះបាទពិម្ពិសារ ជាព្រះចៅនៃដែនមគធៈ ។

ប្ញ. សាវ័ករបស់ព្រះអង្គពីររូបណា ដែលបេះដូង ជ្រៅជ្រះជាងសាវ័កទាំងពួង ហើយជាទីគាប់ព្រះហឫទ័យរបស់ព្រះអង្គ មាននាមអ្វីខ្លះ?

វិ. គឺព្រះសារីបុត្ត និង ព្រះមោគ្គល្លាន ដែលពីដើម ជាសិស្សនៃសាស្តាម្នាក់ឈ្មោះ សញ្ជ័យ ។

ប្ញ. ចុះសាវ័កទាំងពីររូបនេះ បានជាបុគ្គលល្បីល្បាញឆ្នើមដោយសារអ្វី ?

វិ. ព្រះសារីបុត្ត ជាបុគ្គលឆ្នើមខាងបញ្ញា មោគ្គល្លានជាបុគ្គលឆ្នើមខាងឥទ្ធិរិទ្ធិ ។

ប្ញ. ចុះឥទ្ធិពលដ៏ក្រៃលែងនៃសាវ័កទាំងពីររូបនេះគួរឲ្យអស្ចារ្យឬទេ?

វិ. ជាធម្មតារបស់មនុស្សទាំងពួងទេ ឥទ្ធិពលអាចកើតឡើងបានដោយការហ្វឹកហ្វឺនហាត់ពត់ចិត្ត ។

ប្ញ. ព្រះបរមគ្រូ ព្រះអង្គបានជ្រាបដំណឹងពីព្រះញាតិវង្សដែរឬទាំងពីឃ្លាតឆ្ងាយមក ?

វិ. មែនពិត, ប្រាំពីរឆ្នាំក្រោយមក, កាលព្រះអង្គសម្រេច

ព្រះឥរិយាបថ នៅក្នុងក្រុងរាជគ្រឹះ ព្រះបាទសុទ្ធោទនៈ ជាព្រះពុទ្ធបិតា បានបញ្ជូនទូតទៅសូមនិមន្តព្រះអង្គ ឲ្យចូលមកព្រះរាជវាំង ដើម្បីទ្រង់បានឃើញយល់ព្រះភក្ត្រ មុននឹងទ្រង់ទិវង្គត ។

ប្រ. ព្រះអង្គយាងទៅឬទេ ?

វិ. ព្រះអង្គយាងទៅ ។ ព្រះពុទ្ធបិតា ទ្រង់ធ្វើបច្ចុគ្គមនាការទទួល ដោយសេចក្ដីសោមនស្សដ៏ក្រៃលែង មួយអន្លើដោយព្រះញាតិវង្ស និងពពួករដ្ឋមន្ត្រី ។

ប្រ. ព្រះអង្គព្រមត្រឡប់មកទទួលសោយរាជសម្បត្តិ ដូចដើមឬទេ ?

វិ. ទេ, ទ្រង់បានអធិប្បាយពន្យល់ព្រះវររាជបិតា ដោយព្រះមធុរពាចាថា ព្រះសិទ្ធត្ថរាជកុមារ បានលះបង់ភាវៈជាក្សត្រក្នុងកាលមុននោះហើយ ក្នុងពេលនេះ តថាគតបានទៅក្នុងលក្ខណៈ ជាព្រះពុទ្ធមួយព្រះអង្គ ហើយមនុស្សសត្វទាំងឡាយ សឹងជាញាតិមិត្ររបស់តថាគតទាំងអស់ឥតមានរើសមុខ ។ ព្រះសទ្ធម្មរបស់តថាគតនេះ អាចញុំងសត្វទូទៅឲ្យប្រតិបត្តិតាម ពុំមែនដូចស្ដេចផែនដី ដែលគ្រាន់តែគ្រប់គ្រងមនុស្សមួយកុលសម្ពន្ធ ឬមួយប្រជាជាតិប៉ុណ្ណោះទេ ។

ប្រ. ទ្រង់បានយល់ព្រះភក្ត្រព្រះនាងយសោធរា និងព្រះរាហុលកុមារឬទេ ?

វិ. បាន, ព្រះនាងមានសេចក្ដីវិយោគសោកសង្រេងដោយសេចក្ដី

ស្នេហាចំពោះព្រះអង្គ ហើយបានទាំងត្រាស់ប្រើព្រះរាហុលកុមារ ឲ្យទៅសូមសម្បត្តិជាកេរ្តិ៍មតិក តំណតអំពីព្រះអង្គទៀតផង ដើម្បីឲ្យសមឋានៈជាព្រះរាជបុត្រនៃព្រះមហាក្សត្រ ។

បុ. ព្រះអង្គបានធ្វើដូចម្ដេច ?

វិ. ព្រះអង្គបានប្រោសប្រទាន ព្រះធម៌វិសេសទេសនា បំផុតជាឱសថដ៏វិសេស រំងាប់បង់នូវទុក្ខសោក ។ ព្រះពុទ្ធបិតា ព្រះរាជកុមារ ព្រះអគ្គមហេសី ព្រះអានន្ទជាព្រះអនុជ ទេវទត្តជាបងប្អូនជីដូនមួយនិងជាបងថ្លៃរបស់ព្រះអង្គ សឹងបានលុះ ដោយនូវធម្មាភិសម័យ ហើយបានជាពុទ្ធបរិស័ទទាំងអស់ ។ បុគ្គលក្រៅពីនេះ គឺព្រះអនុរុទ្ធដែលជាអ្នកប្រាជ្ញខាងអភិធម្ម និងព្រះឧបាលិ ជាជាងកាត់ព្រះកេសទាំងពីររូបនេះ សឹងមានកិត្តិស័ព្ទល្បីល្បាញទូទៅ ។

បុ. ស្ត្រីណាដែលបានចូលបួសក្នុងពុទ្ធសាសនាមុនគេអស់ ?

វិ. ព្រះនាងបជាបតី ត្រូវជាព្រះមាតុច្ឆា និងជាព្រះមាតាចិញ្ចឹមនៃសិទ្ធត្ថកុមារ, ក្នុងពេលជាមួយគ្នានោះ ព្រះនាងយសោធរា និងស្ត្រីឯទៀត ៗ សឹងបានបួសជាភិក្ខុនីទាំងអស់ ។

បុ. ព្រះបាទសុទ្ធោទនៈ កាលបើឃើញព្រះនន្ទ, ទេវទត្ត ជាព្រះភាគិនេយ្យ, ព្រះនាងយសោធរា ជាសុណិសា និងព្រះរាហុលកុមារ ជាព្រះរាជនត្តា ចូលបួសក្នុងព្រះពុទ្ធសាសនាដូច្នោះ តើទ្រង់មានព្រះទ័យវិតក្កដូចម្ដេចខ្លះ ?

ឆ. ទ្រង់សោកស្តាយជាទីបំផុត ហើយបានចូលទៅសំពះសុំពរអំពីព្រះបរមគ្រូថា អំណើះតទៅ សុំកុំឲ្យបំបួសកុលបុត្រ ដែលមាតាបិតាឬអាណាព្យាបាល ពុំបានអនុញ្ញាតឲ្យបួសនោះសោះឡើយ ។

ប្រ. ទេវទត្តបានជាអ្វី ?

ឆ. បានជាបុគ្គលប្រកបដោយប្រាជ្ញាចេះចាំធម៌វិន័យ ដោយឆាប់រហ័ស ក៏ប៉ុន្តែភិក្ខុនេះ មានសេចក្តីប្រណែនឈ្នានីសពន់ពេក ក៏ត្រឡប់ជាចង់អាឃាដព្យាបាទនឹងព្រះអង្គវិញ ។ ភិក្ខុនេះ បានទាំងញុះញង់ព្រះបាទអជាតសត្រូវ ជាព្រះរាជបុត្រព្រះបាទពិម្ពិសារ ឲ្យធ្វើបិតុឃាដ ហើយឲ្យចូលធ្វើជាសិស្សខ្លួនទៀតផង ។

ប្រ. ចុះទេវទត្តព្យាបាទព្រះអង្គបានសម្រេចឬទេ ?

ឆ. ទេ, អំពើទុច្ចរិតដែលភិក្ខុនេះបានប្រព្រឹត្ត សឹងវិលត្រឡប់មកដល់ខ្លួនវិញ ទាល់តែដល់នូវមរណកាល ដោយទុក្ខវេទនាជាទីបំផុត ។

ប្រ. ព្រះបរមសាស្តា ព្រះអង្គសំដែងធម៌ទេសនា ប្រោសសត្វបានប៉ុន្មានឆ្នាំ ?

ឆ. បាន ៤៥ ឆ្នាំ, ក្នុងកាលនោះ ព្រះអង្គទ្រង់ប្រោសប្រដៅវេនេយ្យសត្វជាច្រើនលើកច្រើនគ្រា តែងតែធ្វើពុទ្ធដំណើរប្រោសទេសនាក្នុងវេនប្រាំបីខែ នៅរដូវប្រាំង មួយអន្លើដោយភិក្ខុសង្ឃទាំងពួងជាពុទ្ធបរិវារ ឯរដូវវស្សាទ្រង់គង់នៅក្នុងបណ្ណសាលា និងក្នុងវិហារដែលពពួក

កថា និងសេដ្ឋីសាងថ្វាយដោយសេចក្ដីជ្រះថ្លា ។

ប្ញ. វិហារដែលមាននាមល្បីល្បាញជាងគេ ឈ្មោះអ្វីខ្លះ ?

វិ. ឈ្មោះជេតវនារាម, វេឡុវនារាម, បុព្វារាម, និគ្រោធារាម និងឃោសិតារាម ។

ប្ញ. ព្រះអង្គប្រោសខ្លួនបុគ្គលណាខ្លះ ?

វិ. បុគ្គលគ្រប់តំណែង គ្រប់ជាតិនិងគ្រប់វណ្ណៈគឺ ក្សត្រិយ៍ និងកម្មករ, អ្នកមានធនធាន, អ្នកក្រីក្រលំបាក, អ្នកមានបុណ្យអំណាច និងអ្នកទាបថោក, អ្នកប្រាជ្ញរបេះដូង, អ្នកល្ងង់ខ្លៅ ។ ព្រះធម៌របស់ព្រះអង្គ សឹងជាទីពេញចិត្ត គួរដល់បុគ្គលគ្រប់ឋានៈទាំងអស់ ។

ប្ញ. ចូរអ្នកអធិប្បាយអំពីដំណើរ ដែលព្រះសម្មាសម្ពុទ្ធទ្រង់រំលាងខន្ធចូលបរិនិព្វានមកមើល ?

វិ. នៅថ្ងៃពេញបូណ៌មីខែវិសាខ ក្រោយបឋមពោធិកាលចំនួន ៤៥ វស្សា ព្រះបរមគ្រូទ្រង់ជ្រាបច្បាស់ថា ទៀបនឹងចូលកាន់បរិនិព្វានហើយ ព្រះអង្គធ្វើពុទ្ធដំណើរទៅកាន់កុសិនគរ ស្ថិតនៅចម្ងាយប្រមាណ ១២០ ម៉ែលពីនគរពារាណសី នៅក្នុងព្រៃសាលវ័នខែពួកមល្លក្សត្រដ៏ជាឧបវត្តនៈនៃក្រុងកុសិនារា ក្នុងចន្លោះដើមសាលព្រឹក្សទាំងគូ ។ ព្រះអង្គឲ្យចាត់ចែងរៀបបញ្ញាសនាក្រឡាព្រះបន្ទំ ហើយទ្រង់ផ្ទំផ្តោះព្រះកេសាទៅឧត្តរទិសតាមបវេណី ។ ព្រះអង្គសំដែងព្រះសទ្ធម្មទេសនាប្រោសវេនេយ្យសត្វជា

ចុងក្រោយបំផុត រួចហើយ ទ្រង់ក៏ផ្តែផ្តាំលាពួកពុទ្ធបរិស័ទ បរិនិព្វាន ក្នុងទីនោះ ។

ប្ញ. ពេលក្រោយបង្អស់ ព្រះអង្គបានប្រោសបុគ្គលណាទៀតទេ ?

វិ. ទ្រង់បានប្រោសបណ្ឌិតព្រាហ្មណ៍ម្នាក់ ឈ្មោះសុភទ្ទបរិព្វាជក និងមល្លក្សត្រទាំងឡាយ ព្រមទាំងពួកបរិវារនៃស្តេចទាំងនេះ ។

ប្ញ. លុះដល់ពេលគ្រឹស្មាន ព្រះអង្គធ្វើអ្វីខ្លះ ?

វិ. ព្រះអង្គដំកល់ព្រះហឫទ័យជាសមាធិញាណ, ញ៉ាំងឈានឱ្យកើតឡើងហើយ, ហើយក៏រលត់ខន្ធចូលកាន់ព្រះមហានិព្វាន ។

ប្ញ. ព្រះអង្គទ្រង់ប្រទានពុទ្ធឱវាទ ចុងក្រោយបំផុត ដូចម្តេចខ្លះ ដល់សាវ័កទាំងឡាយ ?

វិ. ថា ម្នាលភិក្ខុទាំងឡាយ ! ចូរអ្នកពល់គ្នា ចាំឱ្យជាក់ច្បាស់ថា សង្ខារទាំងឡាយមានកិរិយាអស់ទៅ និងសូន្យទៅជាធម្មតា ទៅសល់តែសេចក្តីពិត ទើបចិត្តថេរគង់នៅជាផលពេញបាន ចូរអ្នកទាំងឡាយខំប្រឹងញ៉ាំងប្រយោជន៍របស់ខ្លួនឱ្យសម្រេច ដោយសេចក្តីមិនប្រមាទ ។

ប្ញ. មានគស្តុតាងអ្វីខ្លះ ដែលបញ្ជាក់ឱ្យឃើញច្បាស់ថា ព្រះសិទ្ធត្ថកុមារ បានត្រាស់ជាព្រះពុទ្ធមែន ?

វិ. ការគង់នៅនៃអាយុសង្ខាររបស់ព្រះអង្គ ជាគ្រឿងបញ្ជាក់ឱ្យឃើញងាយជាក់ស្តែង ដូចជាមនុស្សគ្រប់រឿងក៏ដែរ ។

ប្រ. ចូរអ្នកអធិប្បាយរៀបរាប់ អំពីភស្តុតាងទាំងនោះមកមើល ?

វិ. ១ ភស្តុតាងជាសាក្សី អ្នកដែលបានចូលជិតស្និទ្ធស្នាលនឹងព្រះអង្គ ។

២– ការរកឃើញសំណល់ទីយដ្ឋាន និងបុរាណវត្ថុបាក់បែក ដែលមានពណ៌នាអំពីរឿងព្រះអង្គ ។

៣ - សិលាចារឹកលើផែនថ្ម, សសរថ្ម, ព្រះស្តូបដែលស្តេចគ្រប់គ្រងផែនដីបានកសាងទុកជាអនុស្សាវរីយ៍ ចំពោះវិញ្ញាណក្ខន្ធព្រះអង្គ ជាតំណា ក្រោយដែលព្រះអង្គចូលបរិនិព្វានទៅ ដើម្បីបញ្ជាក់ក្នុងរឿងរ៉ាវផ្សេង ៗ ។

៤– មានព្រះភិក្ខុសង្ឃជាតំណតៗ មានចន្លោះ អាចឲ្យដឹងពីប្រវត្តិរបស់ព្រះអង្គជាប់តមក គ្រប់ៗ ជំនាន់ ។

៥– កាលពីក្នុងឆ្នាំ ដែលព្រះអង្គចូលកាន់បរិនិព្វាន និងនៅខណៈផ្សេង ៗ ជាបន្ទាប់មក ក្រុមជំនុំភិក្ខុសង្ឃសឹងបានប្រជុំ ដើម្បីផ្ទៀងផ្ទាត់ធម៌វិន័យរបស់ព្រះអង្គ និងប្រកាសផ្សាយធម៌វិន័យនេះ ដោយត្រឹមត្រូវជាតំណពីគ្រូអាចារ្យមកសិស្ស រហូតដល់យើងសព្វថ្ងៃនេះ ។

៦– ក្រោយដែលបានធ្វើពិធីថ្វាយព្រះភ្លើង រំលាយព្រះបរមសពរួចហើយ ស្តេចទាំង ៨ នគរ សឹងបានចែកចាយព្រះសារីរិកធាតុ ហើយបានកសាងព្រះស្តូបដាក់តម្កល់ជាទីគោរពគ្រប់កន្លែង ។ ព្រះអដ្ឋិធាតុដែលបានទៅព្រះបាទអជាតសត្រូវ គេដាក់តម្កល់ក្នុងស្តូប នៅក្រុងរាជគ្រឹះ ហើយ --

មិនទាន់ទាំងបាន ២០០ ឆ្នាំផង ព្រះបាទធម្មាសោក ទ្រង់បានទិមន្តយកពីកន្ទែងនេះ ទៅចែកចាយគ្រប់ទីដំបន់ ក្នុងព្រះរាជអាណាចក្ររបស់ព្រះអង្គ ។ ព្រះមហាកដាធិកដអង្គនេះ បានរកឃើញទំនងគ្រប់យ៉ាងជាទីសំអាងថាជាព្រះអដ្ឋិធាតុ របស់ព្រះសម្មាសម្ពុទ្ធពិតប្រាកដ ព្រោះព្រះអដ្ឋិធាតុទាំងនេះ សឹងជាទីថែរក្សានិងគោរពបូជារបស់ស្តេចបត្តៈ ។

៣– មានសាវ័ករបស់ព្រះអង្គជាច្រើន ដែលបានសម្រេចអរហត្តហើយនៅមានអាយុសង្ខាររស់នៅអស់កាលយូរ ៗ ដូច្នេះ គ្មានហេតុអ្វីនឹងជាវិនាស់ មិនឲ្យព្រះអរហន្តពីរ បី អង្គ គង់នៅជាតំណគ្នាមក តាំងពីថ្ងៃដែលព្រះបរមគ្រូចូលគាន់បរិនិព្វាន មកទល់នឹងរជ្ជកាល នៃព្រះបាទអសោកនោះឡើយ ដើម្បីឲ្យព្រះមហាកដាធិកដអង្គនេះ បានជួបប្រទះនឹងអ្នកដែលរស់នៅជំនាន់ព្រះសម្មាសម្ពុទ្ធនេះ ហើយនឹងបានដឹងហេតុច្បាស់ប្រាកដ ក្នុងរឿងនៃព្រះអង្គផង[1] ។

---

១– មានសិស្សរបស់ព្រះមហាអានន្ទ ២ រូប ដែលនៅមានព្រះជន្មស្ថិតនៅអស់រយនៃឆ្នាំ ។ ជំនាន់ព្រះបាទអសោក បានចូលប្រជុំ នៅពេលលើកទុតិយសង្គាយនា, នៅក្នុងការលើកសង្គាយនា ដែលព្រះបាទអសោកទ្រង់ចាត់ចែង ក៏មានសិស្សរបស់លោក ចូលរួមផងដែរ ។

(នៅមានត)

# ព្រះត្រៃលក្ខណ៍

(ត-ចប់)

ឲ្យត្រេកសាទរ    ចិត្តទឹកភ្លឹកអរ    ទឹកព្រះធម៌ថ្លៃ
ទំរៀនរក្សា    កាន់នាសព្វថ្ងៃ    ទឹកតែព្រះត្រៃ-
សីលសរណគមន៍ ។

បើបានធម៌ហើយ    កុំគិតខ្លាចឡើយ    សម្បត្តិឥន្ទ្រព្រហ្ម
សម្បត្តិមហាចក្រ    សិទ្ធិស័ក្តិឧត្តម    បានហើយទំគំ
សាងសំទៀតទៅ ។

យកសង្ឃជាញាតិ    ចិត្តកុំឲ្យឃ្លាត    ឲ្យចិត្តនឹងនៅ
រក្សាព្រះធម៌    បិដកក្នុងក្រៅ    ដែលលោកប្រដៅ
ដោយពុទ្ធវាណី ។

ព្រះធម៌សោភ័ណ    ប្រាំបីម៉ឺនបួនពាន់    ខន្ធព្រះគម្ពីរ
ព្រះធម៌ជាយាន    ជាស្ពានសោភី    ចម្លងទៅទី
មឿងកែវថ្លៃថ្លា ។

ព្រះធម៌សេដ្ឋ    ប្រោសជាកម្លាំង    ដាស់តឿនប្រាជ្ញា
បច្ចុប្បន្ននេះបាន    ទៅឋានសួគ៌ា    ពាន់ព្រះសិការ្យ
ក្នុងកាលនេះនៃ ។

យមបាលទាំងបួន    ដែលនៅក្នុងខ្លួន    ប្រចាំសព្វថ្ងៃ

ចាប់ចិត្តពុំបាន សឹងក្បួនអស់ក្រែ អរឲ្យពារថ្ងៃ

នៃអ្នកនោះណា៎ ។

កាលសត្វអស់កម្ម ព្រះយមរាជផ្តាំ ទ្រង់ព្រះមេត្តា

អស់ចិត្តកុមារី ក្បក្រីក្បក្រា បានរួចទុក្ខា

នរកទាំងឡាយ ។

ឲ្យមានចិត្តក្បួន រកវៀនឲ្យបាន បិដកគង់កាយ

ទើបអស់បាបផង បំណងសោយ រូបរួចសប្បាយ

ពីនរកនោះនៃ ។

ចិត្តកុមារអេរ មូលមកស្តាប់ស្រែ ព្រះបន្ទូលថ្ងៃ

ព្រះយមរាជា ក្រាបលាមកខ្ញី ឡើងមកកើតវៃ

ទាន់ព្រះសាសនា ។

ឲ្យខំរៀនចិត្ត គោរពប្រតិបត្តិ សាងសីលភាវនា

កុំឲ្យមានហ្មង ផ្តាំផ្គងឡើយណា៎ ចិត្តមានមេត្តា

ធ្វើបុណ្យឲ្យទាន ។

ព្រះយមរាជផ្តាំ ចិត្តបេះបង់ចាំ យកមកខ្ទួនាន

កុំឲ្យភ្លេចចិត្ត បង់បាត់វិញ្ញាណ ដល់ស្លាប់បានឋាន

សម្បត្តិសួគ៌ា ។

អស់ហើយទូវចិត្ត　　បុណ្យព្រេងមកស្ថិត　　ឲ្យចិត្តជ្រះថ្លា
ពុំស្តាយជីវិត　　ក្រមេចក្ដីណា　　លែងតែអាត្មា
　　បានព្រះធម៌ថ្លៃ ។

បើមានជីវិត　　សៅឆ្ងាយមែនពិត　　កប់អសង្ហើយ
តែងកើតរវល់　　អំពល់ពេកក្រៃ　　ឈ្មោះខ្លួននៅដៃ
　　ព្រះកាលកាឡ ។

ថ្កុំថ្កើងថ្កុលក្រៃ　　ហេតុពលសេន័យ　　កប់សែនសហស្ស
បញ្ជីស្ទាប់មក　　កត់យករូបា　　ឥតអ្នកឯណា
　　ប្រកែកនៅបាន ។

ទោះបីមហាចក្រ　　ឥន្ទព្រហ្មយមក្ស　　ពិតពទាគស្ថាន
ខ្លួនប្រកទ្ធនោ　　ទុកយូរនៅប្រាណ　　កប់ផ្ចាំគោជលាន
　　មុខសែនអសង្ហើយ ។

សឹងមានអាជ្ញា　　ព្រះកាលកាឡា　　មកគៀនសព្វថ្ងៃ
ពុំដឹងកំណត់　　ប្រាកដនឹងក្ស័យ　　គ្រប់រូបទទៃ
　　សឹងស្លាប់ដូចគ្នា ។

រូបក្ខនជាខ្លួន　　មានទ្វារប្រាំបួន　　រាយោគក្សា
បបរីអាបោ　　គេជោចគ្នា　　ជួយរួមរក្សា
　　រូបរស់សព្វថ្ងៃ ។

ចិត្តចេញពោលចង់ រូបក្អួនសូស្រស់ ដូចៗសរិស័យ
អាណិតរូបនៅ ចិត្តទៅទីវៃ យមបាលក្រោធក្រៃ
ថាខែតវ្ទាន ៗ

មុខស្រ្កមុខខ្ពែ ចិត្តមិនពៅខ្សៀ ចិត្តក្តែសាមាន្យ
ខ្ចីរូបក្អួន កត់កាន់ជាប្រាណ អញ្ញការពុំបាន
ភប់ផាតិអសន្ធៀ ៗ

មិនចិត្តរើរូប អញឲ្យធ្វើទោស រូបមិនសព្វថ្ងៃ
ចងបញ្ចុសាខា រូបាធ្ងន់ក្រៃ ចងអស់សរសៃ
តាំងសាមសិបសង ៗ

មាត់មិនថ្ងូរខ្លាំង ហើយអស់កម្លាំង អត់អាហារផង
ធាតុភ្លើងក្ដៅលន់ ពោកពន់កន្លង យមបាលព្រួតចង
ចិត្តកុមារំ ៗ

អជ្ឈត្តិកទាន ចិត្តកុមារមាន ចិត្តស្មោះខ្លះខ្លាំង
មួយពាន់បានមួយ ជាត្រួយអរហំ ប្រោសសត្វទូទាំង
មួយសែនចក្រវាឡ ៗ

ប្រាជ្ញប្រុះគិតយល់ ពុំឲ្យអំពល់ ក្នុងវដ្តសង្សារ
ខូចខ្លាចបារមី វិរ្យចេស្តា ព្រះកាលគៀនពារ
រូបក្អួនសព្វថ្ងៃ ៗ

ព្រះចូលនិព្វាន សករាជយូរបាន វស្សាមួយរយម្ភៃ-
ឆ្នាំទើបកើតក្សត្រ ចុលចក្រមកនៃ ព្រះនាមក្សត្រថៃ
ធម្មាសោករាជា ។

ព្រះទ័យសង្វាត ចង់លើកព្រះធាតុ ប្រើអរហន្តា
និងព្រះមហិន្ទត្ថេរ ទៅប្រែសាស្ត្រា ឯកោះលង្កា
ប្រាំរយព្រះអង្គ ។

សឹងហៀរហោះថ្កាន ដល់លង្កាបាន រំពេចពុំលង់
ប្រែត្រៃបិដក ទំនុកបម្រុង ធម៌ព្រះពុទ្ធអង្គ
ប្រាំបីម៉ឺនបួនពាន់ ។

ប្រាំរយឆ្នាំបាយ កើតក្សត្រពណ្ណពយ ក្រុងមិលិន្ទសោភ័ណ
មានប្រាជ្ញាច្បាស់ រហ័សរួសរាន់ ដូចកលជវ័ន
សុបណ្ណពជរ៉ៃ ។

ព្រះអរហន្តា ម៉ឺនសែនសហស្សា អ្នកប្រាជ្ញផងនៃ
សឹងចាញ់ប្រាជ្ញា គោទ៏ទៃ រត់ទៅពួនព្រៃ
ខ្លបខ្លាចប្រាជ្ញា ។

សម្តេចកោសិយ ប្រាថ្នាសព្វសេចក្តី ពីតុបិតា
អញ្ជើញទេវបុត្រ ឲ្យច្យុតមកជា នាគសេនប្រាជ្ញា
ផ្ចាញ់ក្រុងមិលិន្ទ ។

ថ្កើងព្រះសាសនា  អស់អរហន្តា  វិលវិធមកថ្កាន

មនុស្សផងក្រេកអរ  សាទរគ្រប់ប្រាណ  អរហន្តហោះឆ្ពាន

ប្រោសសត្វសព្វថ្ងៃ ។

សកពជយូរឆ្ងាយ  ប្រាំបីរយឆ្នាយ  កើតមហាក្សត្រថ្លៃ

អភ័យទសគ្រាមណី  រិទ្ធីជាញជ័យ  ផ្ចាញ់ទមិឡអឡេតិរ្វយ៍

អន្តរធានបង់ ។

មួយពាន់ព្រះវស្សា  សូន្យអស់អក្ខព  សូន្យសត្តពោជ្ឈង្គ

ប្រាំបីមុនបួនពាន់  គម្ពីរសូន្យសុង  ក្តៅផល់ទៅអង្គ

សម្តេចឥន្ទ្រា ។

អញ្ជើញទេវបុត្រ  ឲ្យអ្នកច្យុត  ចុះចាកសួគ៌ា

ប្រែព្រះធមិពី  សីហឡលង្កា  ផ្សិតជម្ពូទ្វីបា

សូន្យព្រះធម៌ថ្លៃ ។

ឃោសទេវបុត្រស្តាប់  កោសិយប្រាយប្រាប់  ជ្រាបស្រេចហើយនៃ

លាទេពអប្សរ  បវរស្រីថ្លៃ  ចុះចាកមកឮ

ចាប់បដិសន្ធិ ។

ត្រកូលព្រាហ្មណ៍ថ្លៃ  គ្រប់ទសមាសនៃ  ចេញចាកអំពី

ទេរមាគា  ជ្រះថ្លាសោភី  ព្រះវរជននី

ព្រះជនកអាក្រៃ ។

ដាំឡើងបួសជា សាមណេរហើយណា ជាភិក្ខុប្រពៃ
រៀនបប់គម្ពីរ វិន័យធម៌ថ្លៃ រៀនបប់ព្រះត្រៃ-
បិដកជ្រាលជ្រៅ ។

ព្រះអរហន្ត ជាគ្រូឧបជ្ឈាយ៍ អ្នកតែងប្រដៅ
ព្រះពុទ្ធឃោសា ប្រាជ្ញាជ្រាលជ្រៅ គ្រូអស់ប្រដៅ
គេស្ងៀមព្រងើយ ។

ព្រះពុទ្ធឃោសា ទឹកក្តងចិន្តា ថាគ្រូអញអើយ
អស់ធម៌ប៉ុណ្ណះ ឬបេះនៅឡើយ ទើបលោកកន្ទើយ
ពិតពុំបារបែង ។

អរហន្តជ្រាបថា ព្រះពុទ្ធឃោសា ជៀលគ្រូខ្ទង់
គ្រៀងទណ្ឌកម្ម ចងចាំពុំលែង អារុំសោព្រះស្តែង
ទៅកោះលង្កា ។

រកប្រែព្រះត្រៃ- បិដកធម៌ថ្លៃ ជាមគធភាសា
ទើបអស់មន្ទិល សរិលអាត្មា ដែលជៀលឧបជ្ឈាយ៍
ជាគ្រូនោះនៃ ។

ព្រះពុទ្ធឃោសា ទូលព្រះពុទ្ធដីកា កុំព្រួយព្រះទ័យ
ទទួលទៅប្រែ បន្ទធម៌ថ្លៃ ត្បិតខុសវិន័យ
ខ្ញុំសូមទោសា ។

អ្នកលាចុះទៅ គង់លើសំពៅ អស់ឈ្មួញគេគ្រា
បើកក្តោងកណ្តាល ប្រវាលជលសា ក្តៅដល់ការសនា
សម្តេចសហស្សន័យន៍ ។

មកប្រាប់សំពៅ ឲ្យលូនលឿនទៅ កណ្តាលជលស័យ
សមុទ្រធំធេង បែកផ្សែងពេកក្រៃ មើលមិនយល់ព្រៃ
ប្រាំពីរទិវា ។

ពុទ្ធទត្តគេរ វិលមកពីប្រេ ធមិពីលង្កា
ដល់កណ្តាលសមុទ្រ ជួបពុទ្ធឃោសា ប្រគេនដៃកបារ
ដែលព្រះឥន្ទ្រថ្វាយ ។

ព្រះពុទ្ធឃោសា ដល់កោះលង្កា មើលយល់បន្ទាយ
សំពៅសហស្រ គេគ្រារៀនកាយ កំពែងវែងឆ្ងាយ
ថាក់ថ្មល់ខ្វាត់ខ្វែង ។

ពស្ត្រទៅគាប់គាន់ ប្រាសាទកំងវ័ណ្ណ មុខជាប់ត្រៃឡែងកែង
មានកំពូទបាទ គ្រជាបបែកផ្សែង គ្រដួចលើសលែង
កុំផងទាំងឡាយ ។

ព្រះចន្ទ្រមកែវគូរ កុំផ្ទេកសន្ទោ គ្រចះពណ្ណកាយ
ធញ្ញណ្ណាវង្ស រស្មីព្រោងព្រាយ មនុស្សផងក្រាបថ្វាយ
បង្គំសព្វថ្ងៃ ។

ព្រះពុទ្ធឃោសា គង់នៅលង្កា ចារប្រែទបី
ចប់អស់វិន័យ គម្ពីរធម៌ថ្លៃ ចប់បិដកត្រៃ
ប្រាំបីម៉ឺនបួនពាន់ ៗ

រួចទើបទេសនា ប្រោសស្តេចលង្កា មនុស្សម្រាមហាជន
មីរមកដេរដាស ពេញពាស ពកពន់ ទេវតាខ្ញាប់ខ្ញាន់
ស្តាប់ព្រះធម៌ថ្លៃ ៗ

បូជាមាសប្រាក់ កែវកង់កេទ: សំពត់អាវស្បៃ
អស់អ្នកកេត្រា ចែកគ្នាទីទៃ អរឲ្យពរជ័យ
ព្រះពុទ្ធឃោសា ៗ

លាចុះសំពៅ បើកក្តោងលឿនទៅ ទើបអស់ទេវតា
ជួយជូនមកដល់ មណ្ឌលនគរ ថ្វាយគ្រូបដ្ឋាយ៍
គង់នៅសុខសាន្ត ៗ

ដល់ព្រះសាសនា ពីរពាន់ព្រះវស្សា ប្រាំរយឆ្នាំមាន
អ្នកបុណ្យមកលើក សាសនាថ្កើងថ្កាន អស្ចារ្យអោះមាន
ឆ្នាំកុរឯកស័ក ៗ

សព្វសត្វសញ្ញី កោលាកោល៍(១) ឥតទីសំណាក់
មមីទៅព្រៃ ក្សីណក្ស័យឥតអាក់ ទទ្ទឹងរកអ្នក
បុណ្យបារមីតា ៗ

---

១. កោលាហល?

កប់បាទពីរពាន់ បរិយេសប្ដ័ប័ញ្ច ឆ្នាំពេងបក្សា
ស័កខានពីរពាន់ ប្រាំមួយរយព្រះវស្សា ម្ភៃយូរយារ
ឯមុខនៅឡើយ ។

ហៃអស់អ្នកផង ចិត្តបេះចាំចង កុំធ្វើព្រងើយ
រំពឹងសកកាជ ខ្វាចកុំគោះគើយ កុរឯកស័កហើយ
កើតអស្ចារ្យក្រៃ ។

១ កេចដូតរួច ចិត្តគិតព្រឺព្រួច កុរឯកស័កថ្ងៃ
ឆ្នាំចវិលមក រកគ្នាទីទៃ មនុស្សផងក្រាស់ក្រៃ
វន្ទាមហាក្សត្រ ។

ពីរពាន់ប្រាំមួយរយ មនុស្សផងកុំភ្លាយ ឲ្យគិតប្រយ័ត្ន
រំពឹងធម៌ថ្លៃ ប្រពៃបរមត្ថ ព្រះធម៌សណ្ឋិត
ផ្លូវព្រះនិព្វាន ។

ឯអស់អាជ្ញា ព្រះកាលកាឡា សល់សែនគោជិលាន
តែងមកសព្វឆ្នាំ ប្រចាំគ្រប់ប្រាណ ដល់ខ្លួនពុំខាន
មហាជនគ្រប់គ្នា ។

ឥឡូវនេះជួន ប្រយ័ត្នគ្រប់ខ្លួន ឆ្នាំពេងបក្សា
ស័កវៀងទៅរក ឆ្នាំរករកា ច-កុរទើបជា
បរិបូណ៌បុណ្យបាន ។

ហៃ សាធុជនផង    ចូរស្ដាប់គ្រាប់គ្រង    ទីទៃគ្រប់ប្រាណ
រៀនពុទ្ធសករាជ    អាចជាប្រធាន    ចាំរៀនឲ្យបាន
ដាក់ប្រាណគ្រប់គ្នា ។

ឲ្យគិតរំពឹង    ហើយឲ្យដឹង    សព្វទិនទិវា
ថាខ្លួនអញអើយ    ព្រះកាលកាឡា    តៀនសព្វវេលា
ទាំងយប់ទាំងថ្ងៃ ។

កុំឲ្យលោភា    ទោសាមោហា    ចិត្តកាចចង្រៃ
កុំលួចភរិយា    កូនគេសព្វថ្ងៃ    ដោយសករាជថ្ងៃ
កុំភ័យឡើយហោង ។

លុះដល់កំណត់    នឹងបានសម្បត្តិ    មាសប្រាក់កែវកង
សម្បូណ៌សមបុណ្យ    លើសលន់កន្ទង់    ត្បូងសូរ្យកាន្តផង
បទុមរាគរ័តន៍ ។

សំពត់កោសេយ្យ    ស្រូវកោដ្ឋសាលី    ដុះដល់កំណត់
ទិសទាំងប្រាំបី    បារមីព្រះពុទ្ធ    ដោយបុណ្យផ្គង់ផ្គត់
មកលើកព្រះសាសនា ។

ព្រះពុទ្ធមានបុណ្យ    ព្រះតេជព្រះគុណ    ជាម្ចាស់សិរីសា
ព្រះអង្គតែងប្រោស    ទាំងសព្វសត្វា    សោឡសព្រហ្ម
ជម្ពូទ្វីបនៃ ។

ព្រះអង្គនិត្យនៅ រូបល្អឥតសៅ តាំងប្រុសតាំងស្រី
ដំណើរញ៉ែងញ៉ង ម៉ង្ហានប្រិមប្រិយ រូបហាក់ដូចស្រី
សួគ៌ិបាទពណ្ណភយ ។

ព្រះអង្គអម្ចាស់ មានបារមីណាស់ រស្មីធានះយ
ដោយសព្វព្រឹក្សា លគាវល្ងិកយ សត្វផងសម្ចាយ
សប្បាយសាន្តសុខ ។

ដោយគេជញ្ញាណញេយ្យ ព្រះអង្គម្ចាស់ថ្លៃ និរភ័យនិរទុក្ខ
បច្ចុប្បន្ននេះនៃ ប្រពៃសាន្តសុខ និញានទំនុក
សូមរេចម៉េះហាន ។

# ព្រួប-ភុម

ស្រាវជ្រាវ-ចម្លងដកស្រង់ ពីសាស្ត្រាស្លឹករឹត នៅបណ្ណាល័យពុទ្ធសាសនបណ្ឌិត្យ ដោយបានពិនិត្យផ្ទៀងផ្ទាត់សម្រួល ជាមួយក្បួនស្លឹករឹតដទៃទៀត មានក្បួនច្បាប់របស់ឈ្មោះ ទៀង-រ៉ែន (ស.) នៅឃុំពាម ស្រុកកំពង់ត្រឡាច កំពង់ឆ្នាំង ជាដើម ។

# ផ្នែកអក្សរសាស្ត្រ

អក្សរសាស្ត្រខ្មែរ ខ្មែរគួរថែថ្នម
ឲ្យបានខ្ជាប់ខ្ជួន គង់វង្សគត់មត់
ព្រោះអក្សរជាតិ គោលជាតិប្រាកដ
អក្សររលត់ ជាតិក៏រលាយ

ព.ប.

## ការយកគ្នាជាប្ដីប្រពន្ធ

(វិចារណកថា)

ការយកគ្នាជាប្ដីប្រពន្ធ ជាបញ្ហាមួយដ៏ស្មុគ្រស្មាញ ដែលគួរតែលើកយកមកពិចារណាដោះស្រាយដែរ ព្រោះដំណើរជីវភាពរបស់គ្រួសារដែលនឹងប្រព្រឹត្តទៅសុខស្រួល ឬមិនសុខស្រួលទេនោះ ស្រេចនៅលើប្ដីប្រពន្ធជាធំបង្អស់ ។ តាមការសង្កេតក្នុងបច្ចុប្បន្ន ឃើញថាមានការប្រឆាំងគ្នា រវាងអ្នកប្រកាន់ទំនៀមទម្លាប់ និង អ្នកសម័យនិយម ។

តាំងពីបុរាណកាលមក ខ្មែរប្រកាន់យកទម្លាប់ថា ការទុកដាក់កូនចៅឲ្យមានគូស្រករ តែងសម្រេចទៅលើអ្នកអាណាព្យាបាល មានឪពុកម្ដាយជាដើម បើកូនឬចៅណាស្រឡាញ់គ្នាជាប្ដីប្រពន្ធដោយចិត្តឯង គឺស្រឡាញ់គ្នាដោយចិត្តនឹងចិត្ត ឥតបានឲ្យដំណឹងដល់ឪពុកម្ដាយជាមុន, គេនិយមទុកថាកូនចៅនោះ មិនគោរពប្រពៃណី មិនគោរពមាតាបិតា

ទុកថាជាអ្នកធ្វើឲ្យកិត្តិយស និងកេរ្តិ៍ឈ្មោះវង្សត្រកូលអាប់ឱន ឈ្មោះថាជាអ្នកធ្វើឲ្យស្មើគ្រួសារស្រអាប់ ព្រោះបើដំណើរជីវភាពគូស្រករថ្មីនោះមានសភាពយ៉ាងណាក៏ដោយចុះ សូមឲ្យតែគោរពទំនៀមទម្លាប់ គឺថាលុះត្រាតែឪពុកម្ដាយទុកដាក់ឲ្យ ទើបបានត្រឹមត្រូវ ទើបបានប្រសើរ ទើបបានពេញកិត្តិយស ទើបឈ្មោះថាការយកគ្នាជាប្ដីប្រពន្ធពេញលក្ខណៈច្បាប់សម្រាប់ស្រុកភូមិ ។

ខាងក្រោយដែលទំនៀមទម្លាប់នៃបស្ចិមទិសបានចូលមក ទំនៀមទម្លាប់នេះ ក៏បានដើរពាក់គន្លងបន្តិចម្ដងៗ លើទំនៀមទម្លាប់ជាតិ ។ អំពីរឿងយកគ្នាជាប្ដីប្រពន្ធ, ទម្លាប់នៃបស្ចិមទិស មានសភាពផ្ទុយគ្នាស្រឡះពីទម្លាប់ជាតិខ្មែរ ។ បស្ចិមទិស និយមបណ្ដោយឲ្យកូនប្រុសស្រីជ្រើសរើសគូស្រករដោយខ្លួនឯង គឺថាឲ្យកូនប្រុសស្រីស្ទួរចិត្តគ្នាទៅវិញទៅមក ឲ្យបណ្ដើរគ្នាលេង ដើម្បីស្ទួរចិត្តគ្នា បើពេញចិត្ត បើស្រុះស្រួលគ្នាហើយ ទើបនាំដំណឹងនោះទៅដាក់បន្ទុកឪពុកម្ដាយ ។ ក៏ចាត់ធ្វើពិធីអាពាហ៍ពិពាហ៍ឲ្យទៅ ។

ឯទំនៀមទម្លាប់នៃបស្ចិមទិសនេះ ឃើញថាគាប់ប្រសើរណាស់ដែរ ប្រសិនបើសាមីជន អាចនិយមប្រកាន់ឲ្យត្រឹមត្រូវរហូតបាន, តែបើតាមការសង្កេត ឃើញថាមួយដំបរនឹងបួនទេ ។ ហេតុអ្វីបានជាថាដូច្នេះ? រឿងនេះ មិនខុសគ្នាពីដំណើរកោះហោរ ឲ្យកាយលេខអត្ថៈមើលផគាកសិ

របស់កូនប្រុសស្រី មុនទឹងយកគ្នាជាប្តីប្រពន្ធនោះឡើយ ។ គេធ្វើដូច្នេះ ដើម្បីអ្វី ? ដើម្បីឲ្យកូនប្រុសស្រី បានទទួលសុភមង្គល ខាងក្រោយអាពាហ៍ពិពាហ៍, តែបំណងនេះ តើបានសមប្រកប ចំពោះអ្នកដែលគេហោរឲ្យគន់គូគ្រប់ ៗ គ្នាឬទេ ? ចំពោះបញ្ហានេះ, មិត្តអ្នកអានទាំងឡាយមានការពិសោធន៍ចំពោះខ្លួនស្រាប់ហើយ ។ តាមការពិសោធន៍ ដែលខ្ញុំបានជាប់ប្រទះ គឺដូច្នេះ : ខែណាមិនបានរកហោរគន់គូឲ្យកូនប្រុសស្រី មុនទឹងយកគ្នាជាប្តីប្រពន្ធ ? បើហោរទាយថាមិនល្អ ត្រូវតែផ្អាក បើហោរទាយថាល្អ ត្រូវតែផ្សំផ្គុំឲ្យបានគ្នាជាប្តីប្រពន្ធ ។ តើសុភមង្គល ត្រូវតែបានគ្រប់គ្នា តាមដូចទំនាយហោរ ឬយ៉ាងណា ? - ឆ្លើយថា: មានបានដូចទំនាយក៏មាន មានមិនបានដូចទំនាយក៏មាន ។

ឯការយកគ្នាជាប្តីប្រពន្ធ ក៏មានសភាពដូច្នោះដែរ : ខែគាត់ទំនៀមថា ក្នុងការយកគ្នាជាប្តីប្រពន្ធ, កូនប្រុសស្រី មិនត្រូវនននទាទតាមអំពើចិត្តខ្លួនទេ ។ រឿងនេះ ជាភារៈដាច់មុខនៃឪពុកម្តាយ ។ ចំណែកខាងបស្ចិមទិស និយមប្រកាន់ថា បណ្តោយទុកឲ្យកូនប្រុសស្រីស្វែងរកស្នេហាដោយខ្លួនឯងសិន បើមានការព្រមព្រៀងគ្នាហើយ ទើបឪពុកម្តាយរៀបចំឲ្យ ព្រោះគេយល់ថា ដំណើរជីវភាពទឹងអាចប្រព្រឹត្តទៅប្រកបដោយសុភមង្គលបាន លុះណាតែគោលចាំងពីរមានកម្លាំងស្មើគ្នា ដើម្បីទាញកូសរថនេះផង ហើយមានការស្រុះស្រួលគ្នាផង ។

ចំពោះរបៀបតាំងពិធីផ្សេងនេះ : មួយថា ស្រេចលើឪពុកម្ដាយ មួយថា ស្រេចនៅលើកូន ៗ តើត្រូវនិយមយកណាទុកជាការប្រសើរ ?

តាមការពិចារណាឲ្យល្អិតល្អន់ និង តាមការពិនិត្យសង្កេតមើលយ៉ាងម៉ត់ចត់ ឃើញថា របៀបតាំងពិធីនេះ មិនអាក្រក់ជាងគ្នា មិនល្អជាងគ្នាទេ ឧបមាដូចជាគេធ្វើលេខបូក : ៤+៣ ត្រូវឃើញលទ្ធផល "៧" ហើយបើគេដាក់លេខ ៣ មុន រួចដាក់លេខ ៤ ក្រោយ : ៣+៤ ក៏នៅតែហុចលទ្ធផលដូចគ្នាគឺ ៧ នេះឯង ។

ជនជាតិខ្មែរ និយមទុកស្រីក្រមុំជារបស់មានតម្លៃបរិសុទ្ធ ។ ដូច្នេះទើបខ្មែរប្រើពាក្យម្យ៉ាង ដែលប្រទេសដទៃមិនធ្លាប់មាន សម្រាប់ហៅស្រីក្រមុំ គឺ « ស្រីព្រហ្មចារី ឬ ព្រហ្មចារី » ប្រែថា អ្នកប្រព្រឹត្តធម៌ប្រសើរបរិសុទ្ធ ។ ដោយទុកស្រីក្រមុំជារបស់ប្រសើរបរិសុទ្ធនេះហើយ បានជាខ្មែរមិនព្រមអនុញ្ញាតឲ្យស្រីក្រមុំ មានការទាក់ទងខាងផ្លូវស្នេហាជាមួយនឹងបុរសណាលតែសោះ សូម្បីតែដោយកំបាំងក៏ដោយ មុនការរៀបអាពាហ៍ពិពាហ៍ ព្រោះខ្លាចការទាក់ទងនេះ ក្លាយទៅជាការសៅហ្មងដែលជាហេតុនាំឲ្យខូចកិត្តិយសនៃខ្លួនផង នៃត្រកូលផង ធៀបឧបមាដូចសំពត់កុងកី កាលបើយកមកលាតត្រដាងលាតាកណ្ដាលខ្យល់កណ្ដាលថ្ងៃហើយ មុខជានឹងមានការមិនស្អាតមកប៉ះពាល់ ដែលជាហេតុធ្វើឲ្យសៅសម្បុរខ្វះមិនខាន ។

សួរថា ៖ ដែលខ្មែរប្រកាន់ទំនៀមថា ត្រូវទុកឲ្យឪពុកម្ដាយជាអ្នករៀបចំទុកដាក់ ហើយសាមីខ្លួនចាំតែទទួលយក តើការនិយមនេះ រមែងធ្វើឲ្យគូស្រករថ្មីបាក់បែកគ្នាជានិច្ច មិនដែលគេសុខមង្គលឃើញ ឬយ៉ាងណា ? ដែលបស្ចិមប្រទេសប្រកាន់ទំនៀមបណ្ដោយឲ្យកូនសួរចិត្តគ្នាមុនឲ្យហើយស្រេច រួចសឹមឪពុកម្ដាយរៀបចំការឲ្យជាក្រោយ, តើការនិយមនេះ រមែងធ្វើឲ្យគូស្រករបានស្រុះស្រួលគ្នាតែគ្រប់រូប ហើយចេះតែរកសុខមង្គលឃើញរហូតទៅឬយ៉ាងណា ?

ចំណែកសំនួរទាំងពីរនេះ គួរគប្បីពិចារណាដែរ ព្រោះច្បាប់ខាងតុលាការនៃបស្ចិមទិស ក៏មាននៃផ្លូវមាត្រាខ្លះ ស្ដីពីបើកសិទ្ធិឲ្យប្ដីប្រពន្ធលែងលះគ្នាបានដែរ ។ ឯច្បាប់តុលាការខ្មែរ ក៏មានរឿងនេះដូចគ្នា ។ ដូច្នេះនឹងសម្រេចថា ខាងណាប្រសើរជាងខាងណាក៏មិនបាន បើប្រកាន់ថាបស្ចិមទិសប្រសើរ ម្ដេចក៏មានការលែងលះគ្នាដែរ បើចោទទម្លាក់ទោសថា ទំនៀមខ្មែរនិយមក្ដាប់សិទ្ធិ ក្នុងការជ្រើសរើសគូស្វាមីភរិយា ក៏មិនឃើញការនិយមនេះបណ្ដាលឲ្យគូស្រករថ្មី ចេះតែបែកបាក់គ្នាគ្រប់តែគ្រួសារទៅ ក៏ឃើញតែមានគ្រួសារ នៅរួមសុខទុក្ខជាមួយគ្នា ពាសពេញទាំងប្រទេស បង្កើតជាកូន តួនជាចៅយ៉ាងច្រើន ៗ

សព្វថ្ងៃ កម្ពុជាមានពលរដ្ឋជាងប្រាំមួយលាននាក់ដែរ ដែលចេះរួបរួមគ្នា ក្រោមការដឹកនាំដ៏ថ្លៃថ្លានៃសម្ដេចឪ ដើម្បីកសាងជាតិដូចអាឡ-

ប្រទេសដទៃ ៗ ឬមួយគេយល់ថាចំនួនពលរដ្ឋប៉ុណ្ណោះ មិនសមនឹងទំហំប្រទេស ដោយមកពីគ្រួសារគ្មានស្នេហារួម ដែលជាមូលហេតុបណ្ដាលឲ្យខ្វះការកើតកូនល្មម? បើយល់ដូច្នេះ ហាក់ដូចមិនសូវសម ព្រោះគ្រួសារភាគច្រើនរបស់ខ្មែរ សុទ្ធសឹងមានកូនច្រើនលើសពីចំនួនប្រាំ ៗ បើយល់ថា គ្រួសារខ្មែរភាគច្រើន សម័យមុន មិនសូវចេះក្បួនអនាម័យ ក្នុងការចិញ្ចឹមទារកនោះ ទើបដូចជាត្រូវគ្រាន់បើ ៗ

ខ្ញុំធ្លាប់បានដឹងបានឮមកជាញឹកញយថា គ្រួសារប្ដីប្រពន្ធរបស់ជនបស្ចិមប្រទេស និងជនជាតិយើងខ្លះ ដែលប្រកាន់តាមប្រពៃណីបស្ចិមប្រទេស ក៏គង់មានការទាស់ទែងខ្វែងគំនិតគ្នា មិនបានសុខស្រួលនឹងគ្នា រហូតដល់ទៅមានការបាក់បែកលែងលះគ្នា ក៏មានច្រើនដែរ ៗ

តាមយោបល់ផ្ទាល់របស់ខ្ញុំ, ខ្ញុំយល់ឃើញថា បើទំនៀមទាំងពីរនេះមិនជាល្អ មិនជាអាក្រក់ជាងគ្នាទេ គួរតែជនខ្មែរយើង និយមប្រកាន់ទំនៀមរបស់ខ្លួនជាការប្រសើរជាង : ទី ១– ឲ្យឃើញថាយើងជាអ្នកជាតិនិយម, ទី ២– ស្រីនិងប្រុសដូចស្រមោចនិងស្ករ; ស្រមោចនៅជិតស្ករ វៀរលែងតែស្រមោចអរហន្ត ទើបមិនរើមរាម ទើបមិនលួចលាន់នាយអាយបណ្ដើរ បើស្រមោចបុថុជ្ជនធម្មតាទេ ចំពោះរឿងហ្នឹងមិនបាច់ពោលឲ្យវែងឆ្ងាយឡើយ ម្ល៉ោះហើយព្រហ្មចរិយធម៌ ដែលឪពុកម្ដាយខំថែរក្សាមក មុខជានឹងត្រូវសៅហ្មងខ្លះមិនខាន នឹងជាឲ្យគ្មានសោះ

នោះ ឥតអន្តឹមានឡើយ ៗ ត្រង់នេះហើយ ជាកិត្តិយសដ៏ធំ របស់គ្រួសារ ហើយនឹងក្លាយទៅជាពូជមិនល្អតកូនតចៅផង ៗ

យុវជនជាអ្នកក្រាស់ទៅដោយកាមកត ជាអ្នកមានការពិះសាធន៍ស្តួចស្តើង លុះបានជួបនឹងទ្រឹស្តីបរទេស សមនឹងវិស័យ ឬចំណុចចិត្តខ្លួន ក៏នាំគ្នាផ្ដេកខ្លួនប្រួស ៗ ទៅតាមឥតបង្អង់ ដូចពាក្យចាស់ ៗ តែងនិយាយថា " ដេកផ្ទុំផ្ទួល រមួលផ្សំគ្រេច " ហើយនាំគ្នាលើកដំកើងនូវទ្រឹស្តីនេះថា ល្អប្រសើរជាងប្រពៃណីរបស់ខ្លួន ដែលធ្លាប់មានហូរហែពីព្រេងនាយមក ៗ

សូមយុវជនទាំងពីរភេទ ពិចារណាឲ្យជិតដល់ល្អិតល្អន់ចុះ : ការប្រកាន់ទំនៀមទម្លាប់ជាតិនេះ ជាការលើកដំកើងជាតិម្យ៉ាងដែរ ហើយមាតាបិតាអ្នកទាំង ក៏សប្បាយចិត្តរីកថ្លើមប្រមាត់ ដោយសារអ្នកទាំង ៗ កាលបើមាតាបិតា មានកិត្តិយសហើយ ឈ្មោះថាអ្នកទាំងបានបំពេញចំពោះមាតាបិតា នូវករណីយកិច្ចជាកូនប្រកបដោយធម៌ និងដោយកតញ្ញូតា ៗ មាតាបិតា មិនមានការសប្បាយរីករាយអ្វី ជាងបានឃើញអ្នកទាំងគោរពលោក ធ្វើតាមដំបូន្មានលោកឡើយ ៗ ដូច្នេះ ការគោរពនិងការស្ដាប់នូវដំបូន្មានដ៏សុតត្រង់នៃមាតាបិតា ចាត់ទុកជាកតញ្ញូតាមួយផ្នែកធំរបស់កូនចំពោះលោក ហើយសិរីសួស្ដីនិងសុភមង្គលគ្រប់ប្រការក៏នឹងអាចកើតមានដល់អ្នកទាំងជាពិតប្រាកដ ៗ

ដោយហេតុមកពីខ្ញុំបានសរសេរ អំពីរឿងទំនៀមទម្លាប់ខាងយកគ្នា ជាគូប្រចាំជីវិតរួចហើយនោះ ខ្ញុំសូមបន្ថែមបន្តិច នូវរឿងដំណើរជីវភាព នៃគ្រួសារខ្លះ ដែលមានសភាពមិនសូវសុខស្រួល រវាងស្វាមីភរិយា បណ្តាលមកច្រើនតែពីផ្នែកខាងទ្រព្យសម្បត្តិ ។

ក្នុងគ្រួសារខ្លះ ជួនកាល ប្តីជាកូនអ្នកមានធនធានច្រើន ឯ ប្រពន្ធក្រីក្រ ។ ជួនកាលប្រពន្ធ ជាកូនអ្នកមានធនធានច្រើន ប្តីក្រីក្រ ។ គ្រួសារដែលប្តីនិងប្រពន្ធមានកេរ្តិ៍មិនស្មើភាគគ្នានេះហើយ ច្រើនប្រទះនឹង ពាក្យកោសរួសរកគ្នាគឺពាក្យថា : "មកស៊ីដោយសារតែអញ" ។ លុះ ពាក្យអប្រិយនេះលេចធ្លោឡើង ដំណើរនៃគ្រួសារនោះក៏ត្រូវប្រែមានសភាព រអាក់អួល ជួនកាលរហូតដល់មានការបែកបាក់លែងលះគ្នាផងក៏មាន ។

ឯការដែលពោលថា ខាងនេះឬខាងនោះ " មកស៊ីដោយសារតែ អញ ", បើតាមយោបល់ខ្ញុំ គឺជាការមិនគួរពោលតែសោះ ។ ហេតុ បានជាហ៊ានថាមិនគួរ ព្រោះមុននឹងទទួលយល់ព្រមយកគ្នាជាគូប្រចាំជីវិត ម្នាក់ ៗ សឹងបានស៊ើប បានពិនិត្យយ៉ាងម៉ត់ចត់ អំពីទ្រព្យសម្បត្តិ រួចស្រេចអស់ហើយ ហេតុអ្វីក៏យកសំដីអប្រិយ " ស៊ីដោយសារ " មកប្រើ ធ្វើឲ្យរលាយខ្សែជីវិត ដែលបានរៀបបញ្ចូលគ្នាយ៉ាងស្អិតមាំ ហើយនោះ ។ ច្បាប់មនុស្សធម៌ប្រាប់ថា : ប្តីប្រពន្ធមានខ្សែជីវិតតែមួយ បានន័យថា មានក្រពះតែមួយ សម្រាប់ផ្ទុកអាហារ ។ បើមនុស្សពីរ

នាក់ មានក្រពះតែមួយ, តើគួរឲ្យខ្មាសផងឬទេ ដែលយកពាក្យ “ស៊ីដោយសារ” មកប្រើ? ។

សួរថា : បើមិនឲ្យយកសំដីនេះមកប្រើ តើត្រូវធ្វើដូចម្តេច ?

ឆ្លើយថា : ត្រូវតែតាំងចិត្តសាមគ្គី អត់ឱនគ្នាទៅវិញទៅមក រួមសុខទុក្ខជាមួយគ្នា កសាងគ្រួសារតទៅ គឺថាត្រូវតាំងចិត្តថា ប្តីរបស់អញ, ប្រពន្ធរបស់អញ, ទ្រព្យរបស់អញ ជាទ្រព្យរបស់ប្រពន្ធអញ, ទ្រព្យរបស់អញ ជាទ្រព្យរបស់ប្តីអញ, អញនិងប្រពន្ធអញ គឺជាអញតែមួយ, អញនិងប្តីអញ គឺជាអញតែមួយ ។ ទុក្ខរបស់អញ ជាទុក្ខរបស់ប្រពន្ធអញ, ទុក្ខរបស់អញ ជាទុក្ខរបស់ប្តីអញ ។ ឯការសប្បាយរីករាយក៏ដូចគ្នា ។

មានប្តីប្រពន្ធភាគច្រើនណាស់ ដែលខ្វះការអប់រំយ៉ាងប្រសើរ តែងគិតថា ប្រពន្ធផ្សេង ខ្លួនឯងផ្សេង ប្តីផ្សេង ខ្លួនឯងផ្សេង រហូតដល់ទ្រព្យសម្បត្តិទៀត ក៏មានបែងចែកឲ្យនៅផ្សេងពីគ្នាដែរ ។ តាមយោបល់ខ្ញុំ, ប្តីប្រពន្ធប្រភេទនេះ មិនសមនឹងហៅថា “ប្តីប្រពន្ធ” ឡើយ គួរហៅត្រឹមតែ “ប្រុសស្រី” បានហើយ គឺថាប្រុសអញ ស្រីអញ ។ ពាក្យថា ប្រុសស្រី មានន័យផ្សេងឆ្ងាយពីពាក្យថា ប្តីប្រពន្ធ ព្រោះប្តីប្រពន្ធ ជាខសន្យាមួយយ៉ាងឧឡារិកធំណាស់ ជាខសន្យាដែលមានមនុស្សដីនក្តីរាប់រយ រាប់ពាន់នាក់ បានទទួលដឹងឮ ហើយនិងធ្វើជាសាក្សីផង ។

បើតាមយោបល់របស់ខ្ញុំ, ពាក្យអប្រិយៈនេះ ពាក្យតាក់រុកនេះ ភាគច្រើនបណ្តាលមកតែពីមាតាបិតា ដែលមានការអប់រំ ឬមានពូជត្រកូលមិនសូវប្រសើរ ជាមាតាបិតាដែលគិតតែផលប្រយោជន៍ខាងសម្ភារៈច្រើនជាងផលប្រយោជន៍ខាងផ្លូវចិត្ត ។ តាមដែលធ្លាប់បានដឹងមក រវាងប្តីប្រពន្ធ មិនសូវជាមានការស្ទីជាធំដុំប៉ុន្មានទេ, តែលុះមាតាបិតាយកក្មេងមកដុតពីក្រោយញួយ ១ ប្តីប្រពន្ធក៏ត្រូវតែបែកបាក់គ្នា ។

សូមជំរាបបញ្ជាក់ថា : អត្ថប្រយោជន៍ខាងផ្លូវចិត្ត មានសភាពប្រសើរក្រៃលែងជាងអត្ថប្រយោជន៍ខាងសម្ភារៈ ។ មិនមែនមានចំនួនតិចទេ ដែលគ្រួសារប្តីប្រពន្ធប្រកបដោយអត្ថប្រយោជន៍ខាងសម្ភារៈដ៏បរិបូរ ហើយទទួលរងទុក្ខវេទនាក្រៀមក្រំ ជួនកាលរហូតដល់ស្លាប់ខ្លួនក៏មាន ព្រោះតែប្តីប្រពន្ធនេះ ខ្វះអត្ថប្រយោជន៍ខាងផ្លូវចិត្ត ហើយមិនមែនមានចំនួនតិចទេ ដែលប្តីប្រពន្ធខ្វះអត្ថប្រយោជន៍ខាងសម្ភារៈ តែបែរជាមានដំណើរជីវភាពគ្រួសារយ៉ាងសប្បាយរីករាយ ដោយសារតែគេមានអត្ថ-ប្រយោជន៍ខាងផ្លូវចិត្តបរិបូរ ។

ដូច្នេះ គួរអស់លោកអ្នក និយមគិតអត្ថប្រយោជន៍ខាងផ្លូវចិត្តឲ្យច្រើនជាងអត្ថប្រយោជន៍ខាងសម្ភារៈបន្តិច ទើបដំណើរជីវភាពគ្រួសារអាចប្រព្រឹត្តទៅដោយប្រពៃ ដូចជាខ្សែទឹកស្ងឹមក្នុងពេលស្ងប់ខ្យល់ ។

ផេង-ជ្រីវ

# គួរតម្រង់ទិសអក្សរសាស្ត្រឲ្យបំគោលដៅ

កវីនិពន្ធរបស់សហជីវិន មាស-យុគ្គ

ស្រណោះផ្គរលាន់ពាន់វេលា ផ្គរព្រួខ្ញូរខ្ញារនៅផ្ទៃមេឃ
ឲ្យអសារយើងគេហៀរទឹកភ្នែក យំយែកដេកគិតរឿងកំសត់ ។
អាណិតនាង-អ្នកកូនចៅជាតិ ដែលប្រព្រឹត្តឃ្លាតបែបបទ
ប្រឡូកល្បុកលេងល្បែងផ្ដូរចិត្ត បាក់ផ្អាក់បត់ចុះខុសគោលដៅ ។
សៀវភៅប្រលោមលោមនារី រកស៊ីដក់ក្អកព្រោចនៅ
ពេញបណ្ណាគារហៀរពេញក្រៅ ទីដៅខ្មៅល្ងិតគិតតែលុយ ។
ព្រោះតែអស់លោកអ្នកនិពន្ធ លោភលន់ជួនពិតគំនិតផ្ទុយ
យករឿងល្បែងធម៌ស្ទូរឆ្គុយ ពាក់លុយយកលាភការពារស្នាក់គ្រោក
អក្សរសាស្ត្រខ្មែរបែរខុសទិស ប្រឡាក់ថ្នាំពិសប្រលោមលោក
ព្រលឹងសិល្បៈប្រឡាក់ជោក យោលយោគទៅតាមស្នាមស្នេហា ។
គឺរឿងប្រឌិតគិតប្រដូច ប្រដៅផ្លូវខូចខាងកាមា
ត្រអាលស្រាលស្រើបហើបហុំហា ចរចាទ្វន់ឆ្លើយគើយកៀកគង់ ។
ឧបតេហិតហូបស្រូបក្នុងក្ដួប បទបែប “ នេះ-នុះ ” ខុសទំនង
ទំនើងចិត្តក្មេងលេងក្រាបពង ផ្គាំផ្គង់ឆ្កួតកាមញ៉ាមតណ្ហា ។
ក្មេងខ្ចីស្នាក់នៅទន់ជ្រាយ រាំងាយជិតដាមស្នាមចរិយា
មើលកានបានដឹងឃើញយ៉ាងណា ចិន្តាព្រឺព្រួចផ្ទួចដោតដាប់ ។

ខ្ចិលខាងល្បែងលេងលួចលាក់ ជ្រៅកក់ថ្នាក់ផ្ទើរភ្លើភ្លេចឆាប់
ភ្លេចអស់ទាំងខ្នាតគួរគាប់ ឆ្ងាយឆ្ងាប់ព្រោះហើនភ្លើនផ្លូវខុស ។
ដឹងកលយល់កិច្ចល្បិចស្នេហា ចរចារលោមលួងល្បួងស្រីប្រុស
គេះគៀវស្រៀវស្រើបហើបឡើងចុះ ស្របស្រុះផ្ទុះថ្មើមហើមប៉ុនល្អី ។
នេះគឺឥទ្ធិពលប្រលោមលុយ ដូចនុយដាក់ដោតបញ្ឆោតត្រី
ពុំអាចទាញចេញទង់លង់លោកិយ ប្រុសស្រីពើងទ្រូងប្រឡោងខាម ។
ប្រឡាសប្រាសចាកគន្លងធម៌ ឈ្លូនរំលោភរំលៅទៅរកកាម
បេះក្បួនប្រលោមប្រឡូកតាម ប្រឡាក់ជាប់ស្នាមស្រមាមប៉ាក់ ។
ស្រមោលការអានរឿងមិនល្អ សីលធម៌ធ្លុះធ្លាយជ្រាយរវាក
កូនយើងកូនគេរបូលធាក ប្រាសចាកតម្រាប់ច្បាប់មេបា ។
ភាគពេលដោលដំគ្រាំលោក រលីងប៉ុនគ្រាកក្រៀមខ្ទោចផ្កា
ក្រឡាប់ផ្កាប់ចុះខុសចរិយា យាយតាភាស់ក្អកមិនគ្រែកផង ។
កូនចៅស្រីប្រុសចុះផ្លូវព្រើល ភ្ញាក់ផ្អើលមើលអានរឿងសៅហ្មង
គ្រប់ក្រៅមានរូបស្រស់ល្អនល្អង ញ៉ែងញ៉ង់ស៊ុំផក់លក់លោហិត ។
ខាងក្នុងផ្ទៃរឿងមានរសជាតិ ឃ្មៀងឃ្មាតតម្រាប់ច្បាប់ក្រមក្រឹត្យ
ពិសពាលពើតពុលជម្រុលចិត្ត លូកលិទ្ធជ្រៅកក់លាក់ក្រោយខ្នង ។
គ្រអាលស្រាលស្រើបហើបស្នេហ៍ស្និទ្ធ គៀកកិតគេះគៀវស្រៀវស្រួបស្រង
ដួបដួនទួនស្រីខ្ទីលំអង ត្រើបក្រេងលំអគេសរកាម ។

គោចចាប់ក្តាប់ជាប់គាប់អារម្មណ៍　ឃើញសមទំនេរពាហៃបហៃលតាម
ស្រងល់ខ្វល់ខ្វក់ស្រក់ហោម　ដិតស្នាមដាមស្នឹមពាំទុក្ខ ។
ទុក្ខទាំងជាំជោកពោកព្រួយព្រឺ　ដួលឈឺចាប់ទេះប្រេះទ្រា
ព្រោះព្រើលប្រលោមនោមបាតផ្សារ　ចរិយាខ្វិចខ្វុសចុះយ៉ាប់យ៉ាក ។
កំសត់អាយុផងទន់ទៀបទេរ　ឆាកវេកកាមដាមប្រកាក
ប្រតាងប៉ោងពោះឈ្មោះគោក　ម៉ែឪស្រងាកស្រងោចចិត្ត ។
ការអានកំសាន្តរឿងផ្ដេសផ្ដាស　ឥតការអៀនខ្មាសប្រាសក្រមក្រឹត្យ
ស្ទឹមល្អក់ស្រក់ស្រោចខ្មោចខ្មៅល្ងិត　ចាស់ទុំភាស់ចិត្តស្បិតក្រឡេក ។
ខ្វះវីងប្រឹងទំនេរប្រទេច　ក្មេងគេចមុខសើចសម្ញេក
ភ្លេចការសូត្ររៀនញៀនគម្រែក　ផ្តួលផ្តេកខាងល្បែងលេងឡូកឡាយ
ទំពក់ភ្ជាក់ខ្លួនជួនខកជ្រុល　ពិសពុលពេញពោះពិបាកស្រាយ
ទើបព្រមសារភាពជំពប់ម្តាយ　ជួយកាយជួយកេះកៃលៃងបាន ។
នេះឯងគឺខ្មាំងខ្មោចបិសាច　គ្រោះកាចចង្រៃភ័យសាមាន្យ
ស្មាក់ចាំបេះបោចខូចខ្លួនប្រាណ　រុញច្រានពន្លិចក្តិចពន្លក ។
ពន្លីសីលធម៌កំផុនផាប　ផលបាបផ្ដាប់ស្អុយហុយហុចមក
ខ្វល់ខ្វក់ល្អក់ល្អាមតាមជ្រៀតជ្រក　កៀងយកព្រលឹងយុវជន ។
ហេតុនេះគួរយើងទំរិះគិត　ពិនិត្យស្រិតស្នៃលៃរូបមន្ត
ឲ្យត្រូវផ្លូវត្រង់អង្គនិពន្ធ　ទោរទន់ទៅតាមស្នាមទីដៅ ។

ទុកជាលំអអក្សរសាស្ត្រ កុំឲ្យប្រឡាសប្រាសចេញក្រៅ
ភ្លើតភ្លើនស៊ីជក់ក្នុងក្បួនម្ហូបនៅ សោកសៅក្ដៅនេះប្រេះថែបធា ៗ
នាំកើតទុក្ខទាំជាំជាប់ប្រាណ រំខានខួបចិត្តកុមារ
រវាតឃ្លាតភ្លេចកិច្ចសិក្សា រត់ចូលរាំបារតាមមិត្តម៉ាក ៗ
តាមកិច្ចល្បិចល្បែងតែងឲ្យទុក្ខ ឲ្យគាំសគ្រប់មុខទុក្ខតោកយ៉ាក
សោកសៅក្ដៅក្ដួលអួលឥតស្រាក គួរផ្អាកកុំផ្អើលព្រើលតាមចង់ ៗ
ខ្ញុំសូមគោរពអ្នកនិពន្ធ ដែលមានចិត្តជួនស្ម័គ្រស្មោះត្រង់
ជួយស្ទាក់ញាក់ស្ទៃលៃផ្ចិតផ្ចង់ កែច្នៃត្រូវត្រង់ឲ្យកូនចៅ ៗ
គឺជួយស្ទួយស្ទង់អក្សរសាស្ត្រ កុំនាំផ្ដេសផ្ដាសខុសគោលដៅ
កុំឲ្យរវាតឃ្លាតចេញក្រៅ ហ្មងសៅចរិយាកុមារខ្មែរ ៗ
ព្រោះតាមធម្មតាការមើលអាន ប្រៀបបាននឹងការអប់រំដែរ
និស្ស័យចិត្តថ្មើមផ្ដើមបត់បែរ ទៅតាមស្នាមខ្សែរឿងនោះឯង ៗ
បើរឿងប្រលោមលោះដោយកាម ស្អាកស្នាមដាមល្អក់ដក់ត្រាំក្រែង
នាំវិលវិលខុសចុះផ្លូវល្បែង កូនគេកូនឯងតែងអបអរ ៗ
កើតការពុកផុយស្អុយផ្អេះផ្អាប ដុនដាបសាបសូន្យសីលធម៌
ព្រោះការកើតកើនច្រើនកុះករ នៃរឿងមិនល្អអក្សរសាស្ត្រ ៗ
ហេតុនេះពួកយើងអ្នកនិពន្ធ ត្រូវបេះរះគន់គិតអៀនខ្មាស
កុំនាំក្មេង ៗ វង្វេងផ្ដាស ប្រែប្រាសចូលព្រៃគួរភ័យព្រួយ ៗ

កុំចង់ចំណេញតែលុយកាក់ គ្រោះថ្នាក់ពុកផុយស្អុយល្អួយ
លោយឆ្ងាយប្រេះបេះតែពួយ ត្រូវជួយស្ទួយស្ទួនវង្សវេណី ៗ
ផលក៏ពុកសនាយុវជន យើងអ្នកនិពន្ធត្រូវសំគី
ទាញទប់តម្រង់ផ្លូវទិសទី ឲ្យបានវឌ្ឍគ្រប់វិស័យ ៗ
យុវជនជាតិយើងជាកម្លាំង តតាំងទប់ស្កាត់គ្រោះចង្រៃ
គួរយើងអប់រំទំកែខៃ ជួយថែឲ្យល្អកវែងឆ្ងាយ ៗ
គឺតាមរយៈអក្សរសាស្ត្រ យើងត្រូវប្រកាសប្រកួតផ្សាយ
គំនិតត្រឹមត្រូវផ្លូវក្លីសាយ ឧបាយសាងជាតិឲ្យឃ្លាតទុក្ខ ៗ
ត្រូវលើកទឹកចិត្តខាងការងារ ស្ទុះស្ទួឲ្យជឿនលឿនទៅមុខ
បង្កើតភោគផលសល់គរទុក ពោរពេញជង្រុកទុកលក់ដូរ ៗ
សេដ្ឋកិច្ចជាតិយើងថ្កើនខ្ពង់ខ្ពស់ យើងរស់រុងរឿងថ្កើងសម្បូណ៌
សម្បត្តិធនធានមានហៀរហូរ ជីភាពថ្ងៃថ្ងូរសប្បាយ ៗ
ជាតិយើងត្រូវការជាបឋម នូវអ្នកដឹកនាំក្មេងចាំងឆ្លាយ
ឲ្យផុះគំនិតគិតខ្វល់ខ្វាយ ចង់កាយកាប់គាស់កាស់ការដី ៗ
ធ្វើស្រែយកស្រូវឲ្យបានច្រើន កើតកើនទិន្នផលមួយៈជាបី
ប្រើជីគីមីប្រែភាពដី ឬគាស់កានច្នៃដីច្រើនណាស់ ៗ
សេដ្ឋកិច្ចប៉ុចពកពន្លកឡើង ចុះថ្កើងឬស្លាប់ឆាប់រហ័ស
អាស្រ័យយើងខ្មែរភាំងក្មេងចាស់ ប្រែផ្លាស់គំនិតគិតធ្វើការ ៗ

ទ្រទ្រង់ស្ងួនស្ងៃលៃតម្រប　　ត្រង់ផ្លូវប្រសើរមានខ្លឹមសារ
បណ្តុះគំនិតបុត្តកុមារ　　ឲ្យចេះស្នេហាកសិកម្ម ។
នេះឯងគោលដៅល្អវិសេស　　ដែលព្រះមគ្គុទ្ទេសក៍ទ្រង់ផ្តែផ្តាំ
ឲ្យខ្មែរគ្រប់ប្រាណបានចងចាំ　　កុំឆាកឆ្វេងស្តាំនាំប្រេះឆា ។
យុវជនយើងឡើងច្រើនថ្ងៃ　　អាស្រ័យមានច្បាប់ក្បួនតម្រា
ជាព្រញប្រាប់ផ្លូវត្រូវយាត្រា　　នេះជាមុខការអ្នកនិពន្ធ ។
ស្រណោះផ្គរលាន់ឮរណ្តំ　　ផ្គរព្រួយបារម្ភខំរិះគន់
ក្រែងកំពូកសនាយុវជន　　ចាប់ទាន់ជួនពាប់ជាប់អវិជ្ជា ។
ទើបផ្គរលាន់ឮញាប់ចន្ត　　អង្វរកូនចៅខ្មែរគ្រប់គ្នា
ឲ្យចេះរួបរួមព្រមសាមគ្គា　　កុំបែកខ្ញែកគ្នាទៅឆ្វេងស្តាំ ។
ត្រូវខំបំរើប្រយោជន៍ខ្មែរ　　ធ្វើស្រែចំការច្បារដំណាំ
កាប់គាស់កាស់ដីដាក់ជាតដាំ　　បងចាំចាប់ចិត្តស្មុគនិត្យនៅ ។
នេះឯងទីដៅមានខ្លឹមសារ　　ដែលខ្មែរត្រូវការយាត្រាទៅ
ណោងចាប់យកផលដល់ដំពៅ　　កុំនៅស្ងួរស្ងួកកក់កំផែល ។
កុំធ្វើគុញគុះគៀតាល់ប្រែក　　ក្រែងខកខ្យកខុសចុះទឹកហែល
តែដល់ជោរជន់ពន្ធន់ក្រែល　　ក្របែលចោលខ្លះទើបផ្លាស់បាន ។

# វចនានុក្រមសំស្ក្រឹត-ខ្មែរ

( ត )

ព្រះមហា ប៉ាង-ខាត់ រៀបរៀង

---

_ជលៅឃ ប៉ុ. ឱឃៈទឹកខាងក្នុង ។ _ជ្យោតិស៑ គុ. ដែលភ្លឺខាងក្នុង; ប៉ុ. ពន្លឺខាងក្នុង ។ _ទ៌កាហ នប៉ុ. ចន្លោះនៃថ្ងៃផង ។ _ទ៌ាហ ប៉ុ ភ្លើងក្នុង ។ _ទ៌ុ.ខ គុ. ដែលមានទុក្ខខាងក្នុង ។ _ធ៌ិន នប៉ុ. អន្តធាន, ធនខាងក្នុង ឬ កំណប់ទ្រព្យ ។ _ធ៌ា ស្ត្រី. -ធ៌ិ នប៉ុ. ទីបំពួន ។ _ធ៌ាន នប៉ុ. កិរិយាតាំងនៅខាងក្នុង, កិរិយាលេបបាត់ ។ _ធ៌ានគតិ ស្ត្រី. កិរិយាធ្វើឱ្យបាត់ទៅ ។ ធ៌ានបរ គុ. ដែលចរទៅមើលមិនឃើញ ។ _ធៃយ៌ នប៉ុ. ភាពមាំមួនខាងក្នុង ។ _ធ្វាន្ត នប៉ុ. ទីងងឹតខាងក្នុង ។ _នគរ នប៉ុ. រាជនិវេស ។ _និខាត គុ. ដែលធ្លាក់ ។ _នវេឝន នប៉ុ. បន្ទប់ខាងក្នុង,

អត្ថពិសេស ។ -និហិត គុ. ដែលតម្កល់ខាងក្នុង ។ ដែលរៀបចំខាងក្នុង ។ -ពាប្ប គុ. ដែលមានទឹកភ្នែកទីខ្ទួនទុកហើយ; បុំ. ទឹកភ្នែកខាងក្នុង ។ -ភិវឌ្ឍតិ ក្រិ. ដុះខាងក្នុងលាស់ទៅ ។ -ភាវ បុំ. អត្តភាព, កិរិយាបាត់បង់, សេចក្ដីស្លាប់, ភពដែលនៅខាងក្នុង ។ -ភិន្ន គុ. ដែលបែកខាងក្នុង ។ -ភូត នបុំ. អត្តភូត, កិរិយាកើតខាងក្នុងចិត្ត ។ -ភូមិគត គុ. ដែលបិតនៅខាងក្នុងផែនដី ។ -ភោម ដូចគ្នា ។ -ភេទ បុំ. អន្តភេទ, កិរិយាបែកធ្លុះខាងក្នុង ។ -មទាវិស្ម គុ. ដែលអាចមទៈបិតនៅពួដ៏ខាងក្នុង ។ -មនសិ គុ. ដែលមានចិត្តទៀយណាយ, ដែលមានចិត្តព្រួយ ។ -មិញ្ជិរ នបុំ. បណ្ដូលស្រីស្រីង្គារ ។ -មិមិសិ នបុំ. ចិត្ត ។ -មុខ គុ ដែលមានមុខបែរទៅខាងក្នុង ។ -មោទ បុំ. សេចក្ដីរីករាយខាងក្នុង ។ -យាមិនី បុំ. ព្រលឹង, កិរិយានាំខាងក្នុង,

ព្រាហ្មណ៍ ។ _លីន គុ. ដែលជួនខាងក្នុង, ដែលមិនចេញឲ្យឃើញ, ដែលកំបាំង ។ – រម្សិក បុំ. អ្នករក្សាបន្ទប់ស្រីស្រីង្គារ ។ _វិស្ត្រ ឬ -វាស នបុំ. សំពត់, អាវប្រដាប់ ។ –វាណី គុ ដែលបេះ ។ _វាស បុំ. កិរិយានៅខាងក្នុង ។ _វិប៉ គុ ដែលមានពិសនៅខាងក្នុង ។ –វិហ្វុល គុ ដែលមានកករល្អក់ឮជំខាងក្នុង ។ វិត្តិ ឬ ... ស្រ្តី កិរិយាប្រព្រឹត្តខាងក្នុង ។ _វេទិ បុំ. អ្នកអន្តវេទិ, បណ្ដាជននៅចន្លោះមហានទីគង្គានិងយមុនា; -វេទី ស្រ្តី. ឈ្មោះប្រទេស ។ –ហាស បុំ កិរិយារីករាយខាងក្នុង ។ _ហិត គុ ដែលគ្រប, ដែលបិទ, ដែលគេមើលមិនឃើញ ។ _អន្ត:ករណ នបុំ. ចិត្ត, មនោសញ្ចេតនា ។ _កោប បុំ. (អណ្ដាតភ្លើងជំខាងក្នុង) កំហឹង ។ _បាល ឆ្មាំរាជនិវេសន៍ ។ _បុរ អន្ត:បុរ, ប្រាសាទដែលដាច់ឆ្ងាយ, បន្ទប់ស្រីស្រីង្គារ,

ស្រីស្រីង្គារៈ អន្តៈបុរិកា ។ –បុរបរ បុំ. អ្នកយាម ប្រាសាទស្រីស្រីង្គារ, អ្នកដែលចូលប្រាសាទស្រីស្រីង្គារបាន។ –បុរជន អន្តៈបុរជន, ស្ត្រីនៅក្នុងប្រាសាទស្រីស្រីង្គារ ។ –ប្រកាឝ អន្តៈប្រកាស, ចក្ខុវិស័យខាងក្នុង ។ –ប្រកូតិ ស្ត្រី. បន្ទាយវន្ត ។ –ប្រជ្ញ គុ. ដែលមានការចេះនៅខាងក្នុង ។ –ប្រមោទ បុំ. សេចក្តីរីករាយខាងក្នុង ។ –ឝរីរស្ថ គុ. ដែលឋិតនៅខាងក្នុងសរីរៈ ។ ឝល្យ នបុំ សរដែលមុតចូលខាងក្នុង ។ –ឝាន្តិ ស្ត្រី. អន្តៈសន្តិភាព, សេចក្តីក្សេមក្សាន្តចូលខាងក្នុង។ –សំជ្ញ គុ. ដែលមានកិរិយាដឹងចូលខាងក្នុង, ដែលមិនសំដែងឧបសិការ ។ –ស័ត្ត នបុំ សារចូលខាងក្នុង ។ –សទស៑ នបុំ. សាលប្រជុំ ។ –សលិល គុ ដែលមានទឹកហូរចូលខាងក្នុង; –សលិលម ក្រ.វិ ចូលទឹក ។

(នៅមានត)

# ពិចារណាដើម្បីយល់តក្កវិជ្ជា

(ក)

លោក ហ៊ុន-គីមសៀ រៀបរៀង

## ជំពូកទី ១

## អ្វីដែលហៅថាតក្កវិជ្ជា

និយាយខ្លីទៅ តក្កវិជ្ជា គឺជាមុខវិជ្ជាមួយបែប, ឬអាចថាជាវិទ្យាសាស្ត្រមួយយ៉ាង សិក្សាអំពីវិធីត្រិះរិះ, របៀបពិចារណានៃគំនិតរបស់មនុស្ស ។ (យើងទាំងអស់គ្នា កំពុងតែប្រុងប្រៀបសិក្សាមុខវិជ្ជាមួយខាងការពិចារណាក្នុងវិធីប្រើវោហារ ការលេងសំដីឲ្យគ្រោះក្បាយ ដែលភាសាបារាំងហៅថា La logique ) ។

ជាធម្មតា រៀងរាល់ថ្ងៃ ក្នុងការនិយាយទាក់ទងគ្នាទៅវិញទៅមក យើងទាំងអស់គ្នា សឹងតែបានឮនិងបានប្រើវិធីនិយាយ តាមក្បួនតក្កសាស្ត្រ ស្ទើរតែគ្រប់គ្នាទាំងអស់ មានអ្នកខ្លះថែមទាំងបានយល់ច្បាស់នូវអត្ថរូបនិងអត្ថន័យនៃពាក្យថា « តក្កវិជ្ជា » នេះទៅទៀតផង ។

ពាក្យថា : « តក្កវិជ្ជា » នេះ គេអាចប្រើការនៅក្នុងករណីខុសគ្នា ហើយអត្ថន័យរបស់ពាក្យនេះ ក៏មានរូបភាពខុសគ្នា ដោយអនុលោមទៅតាមករណីនីមួយ ៗ ផងដែរ ។ ហេតុនេះ ចំពោះរូបអ្នកណាមួយដែលគេមិនសូវធ្លាប់ត្រចៀកនឹងពាក្យថា: តក្កវិជ្ជា នេះទេ គឺអាច

នាំឲ្យគេយល់ច្រឡំងាយណាស់, ពិសេសគឺនាំឲ្យគេពិបាកយល់, ស្តាប់មិនសូវបាន ហើយពិបាកនឹងធ្វើការសង្កេតតាមដានថែមទៅទៀតផង ។ ហេតុដូច្នេះ អ្នកដែលរៀនតក្កវិជ្ជា គប្បីយកចិត្តទុកដាក់ចំពោះប្រការនេះ ដើម្បីចៀសវាងការរិះគន់ ពីសំណាក់មហាជនក្នុងមជ្ឈដ្ឋានខ្លះ ដែលគេមិនធ្លាប់ស្តាប់ គេថាខ្លួនយើងមាត់វែង ប្រកែកយកតែឈ្នះ, ប៉ុន្តែផ្ទុយទៅវិញ ការប្រកែកដោយសំដីគ្មានបំណងយកឈ្នះចាញ់ទេ ។ល។

យើងសូមជូនឧទាហរណ៍ពាក្យថា តក្កវិជ្ជានេះ ក្នុងករណីខុសគ្នាខ្លះៗ ដែលមានអត្ថន័យក៏ខុសគ្នាដែរ ដល់មិត្តទាំងអស់គ្នា ដើម្បីធ្វើការពិចារណា កត់សំគាល់ដូចតទៅនេះ ៖

ក– « តក្កវិជ្ជាសម្ភារៈ ខ្លាំងជាងតក្កវិជ្ជាបែបណាទៀតទាំងអស់ » ។ ពាក្យថា តក្កវិជ្ជា ក្នុងករណីបែបនេះ មានន័យថាៈ វិធាន (Loi) ឬថា ៈ ច្បាប់ធម្មជាតិ ( Loi de la nature ) ឧទាហរណ៍ ៈ វត្ថុទាំងអស់ កាលណាត្រូវក្តៅរីក ... សភាពបែបនេះ វាជាការធម្មតា របស់គ្រឿងសម្ភារៈទាំងអស់ជាកំហិត ។ ថៅកែរោងចក្រឧស្សាហកម្មណាមួយ តែកាលណាជិះជាន់កម្មករតូចតាចខ្លាំងពេក ប្រព្រឹត្តអំពើព្រៃផ្សៃហួសពេក, ថៅកែនោះ គេចមិនរួចពីការប្រឆាំងតបរបស់កម្មករឡើយ ទោះចង់ឬមិនចង់ក៏ដោយ ពីព្រោះច្បាប់ធម្មជាតិ ឬថា តក្កវិជ្ជានៃសម្ភារៈ គឺវាយ៉ាងនេះឯង ។

១– « គាត់នេះ និយាយស្តាប់មិនបាន, និយាយចាប់ចុងព្រយុងដើម ដូចឆ្នាំប៉ូលត្រឡោក ឬថា និយាយគ្មានតក្កសាស្ត្រ » ។ លោកនេះ និយាយពូកែ, និយាយចេះច្បាប់, និយាយឆាយស្តាប់ » ។ ក្នុងករណីបែបនេះ, ពាក្យថា តក្កសាស្ត្រ មានន័យថា ការប៉ុនប្រសប់ចងក្រងគំនិត ដើម្បីនិយាយឲ្យក្បោះក្បាយ ឬវិធីនិយាយមានរបៀប, មានហេតុមានផល, មានខុតមានខន្ធ.. ។

ឧទាហរណ៍ : ដៃមួយទះមិនឮទេ, ហេតុនេះ រឿងហេតុដែលកើតឡើង មិនមែនមកតែអំពីមនុស្សម្នាក់ទេ ( និយាយមានតក្កសាស្ត្រ ) ។

ដើមត្នោត មិនទៅជាដើមដូងទេ, ហេតុនេះ មនុស្សល្ងង់ មិនអាចទៅជាមនុស្សចេះបានទេ ( និយាយគ្មានតក្កសាស្ត្រ ) ។

២– « យើងត្រូវរៀនតក្កវិជ្ជា » ។ ក្នុងករណីបែបនេះ ពាក្យថា : តក្កវិជ្ជា មានន័យថា វិទ្យាសាស្ត្រខាងវិធីប្រើពាក្យសំដី, ការពិចារណាត្រិះរិះក្បួនគំនិត ដើម្បីនិយាយឲ្យបានរឹងប៉ឹង, ក្បោះក្បាយ, ជាក់លាក់, មានហេតុមានផល ... ។ល។ ហេតុដូច្នេះ សៀវភៅតក្កវិជ្ជានេះ ក៏មានន័យដូចករណីទី ៣ នេះអីចឹងដែរ គឺជាវិធីប្រមូលផ្តុំគំនិត ដើម្បីនិយាយឲ្យបានពូកែ បានសេចក្តីថា : ការសិក្សាអំពីរូបភាពនៃការលាតត្រដាងនូវគំនិត ប្រកបដោយលក្ខណៈសិល្បៈយ៉ាងក្បោះក្បាយម៉ាំមួន ... ។ តក្កវិជ្ជាដែលយើងនឹងពិភាក្សាគ្នាតទៅនេះ គឺជាតក្កវិជ្ជារូបភាព ដែលភាសាបារាំងហៅថា Logique formelle ។

# ការពិចារណា មានវិធានដែរឬ ?

មាន ! ពីព្រោះតែវាមានហ្នឹងហើយ បានជាមានក្បួនខ្នាតសម្រាប់សិក្សា ដែលគេហៅថា តក្កវិជ្ជា ហ្នឹងឯង ។

មានអ្នកខ្លះ និយាយថា : តាំងពីខ្ញុំកើតមក ខ្ញុំធំឡើង, ខ្ញុំចេះនិយាយ, ខ្ញុំចេះគិត . . . ខ្ញុំគិតរួចហើយ ខ្ញុំនិយាយចេញមកភ្លាម គ្មានចាំបាច់វិធាន ឬ ក្បួនខ្នាតអ្វីទេ ម្ដេចក៏គេចេះតែស្ដាប់ខ្ញុំបានដែរ?

យើងទាំងអស់គ្នា អាចឆ្លើយតបវិញថា « គេចេះតែស្ដាប់បានមែនហើយ ចំពោះការនិយាយបន្តិចបន្តួចនោះ ហើយម្យ៉ាងទៀត នៅក្នុងគំនិតអ្នកនិយាយនោះ ក៏ត្រូវមានការត្រិះរិះគិតគូរខ្លះ ៗ អំពីងដែរ ប៉ុន្តែសុំប្រាប់ថា មានករណីខ្លះ ការដែលនិយាយបន្តិចបន្តួចនោះ គេស្ដាប់បាន ដោយគេកាត់ស្មានខ្លះផង » ។ មិត្តអ្នកអានទាំងអស់គ្នា ជ្រាបស្រាប់ហើយថា កាលបើនិយាយដល់ការកាត់ស្មានផ្សំដូច្នេះហើយ គឺយើងមិនបាច់និយាយដល់ការទៀងទាត់, ត្រឹមត្រូវឬជាក់លាក់ទេ, ជាក់លាក់ឯណាបាន បើកាត់ស្មានបែបនេះទៅហើយ ។

មុនដំបូងបង្អស់ យើងត្រូវទទួលស្គាល់ថា តក្កសាស្ត្រជាវិទ្យាសាស្ត្រខាងវិធីផ្សំផ្គុំគំនិត ( រៀបចំគំនិតដែលយើងគិតរួចស្រេចមកហើយ ) ។ ក្បួនវិទ្យាសាស្ត្រនេះ គ្មានប្រកាន់វណ្ណៈទេ គឺជាមគ្គរួម សម្រាប់មនុស្សទូទៅក្នុងលោកឥតរើសមុខ ។

យើងទាំងអស់គ្នា ពិចារណាឧទាហរណ៍ខាងក្រោមនេះល្បង មើល បើយើងសង្ស័យថា ក្រែងលោពុំគ្មានវិញ្ញាណ :

ក- យើងទាំងអស់គ្នា ធ្លាប់ឮម្ដាយបំពេរកូនហើយសួរកូនថា : « អាពៅដេកលក់ហើយឬនៅកូន ? » កូនឆ្លើយ : « ដេកលក់ហើយម៉ែ »

ខ- លោកគ្រូសួរសិស្សថា « ប្អូនឯង កើតអុតធ្ងន់ណាស់ឬ កាលពីក្មេង បានជាមុខសុទ្ធតែស្លាកខ្ទិញខ្ទុញយ៉ាងនេះ ? »

សិស្សឆ្លើយ : « បាទ ! ខ្ញុំកើតអុតធ្ងន់ណាស់កាលពីតូច ម្ដាយខ្ញុំប្រាប់ » ។ គ្រូសួរ : « ប្អូនឯងមានស្គាល់ទេ បើឈឺធ្ងន់យ៉ាងនោះ ? » សិស្សឆ្លើយ : « បាទ ! គ្រង់ស្គាល់ឬទេ ខ្ញុំមិនដឹងដែរ ចាំខ្ញុំទៅសួរម្ដាយខ្ញុំមើល ? » ។

កាលណាតែស្ដាប់ឮភ្លាម គេអស់សំណើច មិត្តមានឆ្ងល់ឬទេ ពីព្រោះហេតុអ្វីបានជាគេអស់សំណើច យើងពិចារណាល្បងមើល ? ។

យើងសុំជូនឧទាហរណ៍មួយទៀត ដើម្បីបញ្ជាក់ដូចតទៅ ៖

មានបុរសម្នាក់ជាអ្នកដំណើរ ដើរមកជួបនឹងកសិករម្នាក់កំពុងតែភ្ជួរស្រែ ; អ្នកដំណើរនោះ ឈរទ្រឹងនៅមួយកន្លែង ហើយស្រែកសួរទៅអ្នកភ្ជួរស្រែថា : « បងអើយ ! ដើរប៉ុន្មានម៉ោងទៀត ទើបបានដល់មាត់ស្ទឹង ? » ។ អ្នកភ្ជួរស្រែងើបមើលមុខ ហើយភ្ជួរស្រែតទៅទៀត ដោយគ្មាននិយាយអ្វីទាំងអស់ ។

អ្នកដំណើរឃើញដូច្នោះ ក៏ដើរទៅមុខទៀតដោយទឹកស្មានថា : « អ្នកភ្ជួរស្រែនោះ ប្រហែលជាមនុស្សគមិនចេះនិយាយ » ។ លុះអ្នកដំណើរ ដើរបានប្រហែលជាដប់ឬម្ភៃជំហាន ស្រាប់តែអ្នកភ្ជួរស្រែនោះស្រែកហៅឲ្យ ត្រឡប់មកវិញ ហើយនិយាយប្រាប់ថា : « បងឯងដើរពីនេះទៅដល់មាត់ស្ទឹង ប្រហែលជាមួយម៉ោងកន្លះ » ។

អ្នកដំណើរបែរខឹង ក៏សួរទៅវិញថា : « ចុះអំបាញ់មិញ ម្ដេចក៏បងឯងមិនប្រាប់ខ្ញុំ? » ។ អ្នកភ្ជួរស្រែតបថា: «អំបាញ់មិញ បងឯងឈរនៅស្ងៀមមួយកន្លែង ហើយសួរខ្ញុំ ខ្ញុំមិនដឹងជាកម្លាំងបងឯងដើរលឿនឬដើរយឺតយ៉ាងណាទើបឆ្លើយឲ្យពាក់ត្រូវ, ដល់ខ្ញុំឃើញល្បឿនបងឯងដើរហើយ ទើបខ្ញុំឆ្លើយទៅឲ្យពាក់ត្រូវប្រាកដ កុំឲ្យបងឯងខឹងថាខ្ញុំនិយាយមិនចេះស្មាន » ។

ករណីទាំងអស់ខាងលើនេះ យើងទាំងអស់គ្នាយល់ថា : តែរបៀបមិនច្បាស់ នាំឲ្យគេអ្នកស្ដាប់ ក៏យល់មិនច្បាស់ដែរ តែគេអ្នកស្ដាប់យល់មិនច្បាស់ ក៏នាំឲ្យការនិយាយទៅកាន់គ្នានោះ ក៏មិនបានសម្រេចដូចបំណង បានសេចក្ដីថា : ការនិយាយឬការសួររបស់យើងនោះទាស់គ្នាហើយ មែនឬទេ ? ។

តាមធម្មតា ការនិយាយទាស់គ្នា មនុស្សយើងច្រើនតែដឹង, ប៉ុន្តែត្រង់ទាស់កន្លែងណា, ទាស់របៀបណា, ហេតុអ្វីបានជាទាស់គ្នា . . .

បើយើងពិចារណាតាមក្បួនតក្កវិជ្ជា ហើយយើងឃើញថា ក៏ខុសនឹងវិធាន នៃការរៀបចំគំនិតសម្រាប់និយាយ ។

យើងទាំងអស់គ្នាពិនិត្យមើល មានមនុស្សខ្លះ និយាយដោះសាថា

« ប្រមុះបារាំងក៏គោង

ពូទៅ ប្រមុះគាត់គោង-

ហេតុនេះ ពូទៅ ជាជាតិបារាំង » ។

និយាយដោះសាយ៉ាងនេះ តើត្រូវដូចម្តេចកើត ? ដូចគ្នានឹងរបៀបដោះសា គ្មានប្លែកចេញនៃពួកទស្សនវិទូពីដើម ផ្នែកបស្ចិមប្រទេសខ្លះ ដែលជាពួកគំនិតនិយម ( Idéaliste ) ច្រើនយកឧទាហរណ៍ពីរឿងសូក្រាតថា :

« ជនក្រិចជាមនុស្សគរ

សូក្រាតជាជនក្រិចម្នាក់

ហេតុនេះ សូក្រាតជាមនុស្សគរ » ។ និយាយដោះសារបៀបនេះ បើក៏ត្រូវ គឺជាការហេងមួយហើយ ពីព្រោះនៅក្នុងករណីខាងលើ ក៏មានត្រូវខ្លះ ក៏មានខុសខ្លះ ប្រមុះគោង មិនមែនមានតែបារាំងទេ ដូចគ្នានឹងជនក្រិចអីចឹងដែរ មានជនក្រិចខ្លះគរខ្លះមិនគរ ក៏មិនគរទាំងអស់គ្នាទេ ។

ឧបមាខ្លួនថា : « ខ្មែរកាន់ព្រះពុទ្ធសាសនា

ខ្ញុំមិនមែនជាខ្មែរ

ហេតុនេះ ខ្ញុំមិនមែនជាពុទ្ធសាសនិកជន »

បើជួបនឹងគំនិតនិយាយបែបខាងលើនេះ កុំថាឡើយតែយើងជាអ្នកស្តាប់ សូម្បីតែខ្លួនគេជាអ្នកនិយាយនោះ ក៏គេស្តាប់ខ្លួនគេមិនបានដែរ ពីព្រោះនិយាយខុសនឹងវិធាននៃគំនិត បើយើងរៀនតក្កវិជ្ជា ទើបយើងយល់ច្បាស់ចំពោះប្រការនេះ ។

កាលណាគេមិនទាន់យល់ច្បាស់នូវវិធាននៃគំនិតទេ ទោះបីគេសួរមនុស្សដែលមានកំហុសហើយហ្នឹងក៏ដោយ ក៏អ្នកសួរ នៅតែខ្វាយ ទៅបានជាងអ្នកដែលមានកំហុសនោះដែរ ឧទាហរណ៍ដូចជា ម្តាយប្រើកូនឲ្យទៅយកសៀវភៅ នៅលើតុដែលឪពុកមិននៅ កូននោះរើកកាយសៀវភៅពាសពេញនៅលើតុ ដល់ឪពុកត្រឡប់មកវិញ សួរដឹងរឿងក៏ខឹងហើយហៅកូនមកបន្ទោសថា :

ហេតុម្តេចបានជាមករើកកាយសៀវភៅពាសពេញលើតុយ៉ាងនេះ?

កូន : ម៉ែប្រើខ្ញុំឲ្យយកសៀវភៅឲ្យគាត់ ។

ឪពុក : ចុះហេតុដូចម្តេច ក៏ឯងមិនចាំអញមកសិន ?

កូន : ម៉ែគាត់ប្រញាប់ពេក ចាំឪមិនបាន ។

ឪពុក : ចុះបើម៉ែឯងប្រើឲ្យស៊ីអាចម៍ តើឯងស៊ីទេ ?

កូន : បាទ ! ប្រើឲ្យយកសៀវភៅ ហើយនិងប្រើឲ្យស៊ីអាចម៍ អាពីរនេះ វាខុសគ្នាទេឪ ។

(នៅមានត)

# ព្រះរាជនិពន្ធរាមកេរ្តិ៍

## ភាគ ១២

លោក ឌឹក-គាម

ស្រាវជ្រាវ និង រៀបរៀង

និយាយតាំងតែពីព្រះបាទទសរថ ក្រោយដែលបានតែងពិធីអាពាហ៍ពិពាហ៍ព្រះរាមរួចហើយ ក៏លើកយកពលវិលត្រឡប់ទៅនគរវិញ ប្រទះជួបនឹងរាមេសូរ ច្បាំងគ្នានឹង មេសូរ ១ ពាញ់ហួតដល់ទូគីនិងទូក ២ ស្លាប់ ទូគីទៅច្បាំងនឹងពាលី ១ សម្លាប់ទូគីស្លាប់ ។

លុះព្រះបាទទសរថ មកដល់ប្រាសាទកែវហើយ ក៏មានព្រះឱង្ការប្រាប់ទៅនឹងសេនាជាធំថា ចូរភាត់ថែងរៀបពលសកលយោធាត្រៀមទុកឱ្យស្រេច ដ្បិតអញនឹងលើកទ័ពត្រឡប់ទៅកាន់បុរីហោង ។ គ្រានោះ រីសេនាទាំង ៤ នាយ ទទួលព្រះឱង្ការហើយ ក៏ក្រាបថ្វាយបង្គំលា ការថយចេញមកចាត់ចែង តែងរេហ៍ពលសកលយោធា, ឱ្យអង្គសម្ដេចព្រះពម្មាអាគារ យំពល ពាហន ៦ ម៉ឺនជាទ័ពស្រួចមុខ, រីពលនោះឱ្យស្លៀកពាក់អាវកម្ពីពណ៌ផ្ទៃមេឃកាន់កាំភ្លើងប្រនេះថ្មុ, យោធា ៤ សែនជាកងទ័ពហ្លួង ពាក់អាវពណ៌ស៊ីម្ពូ កាន់លំពែងនិងដាវដងវែង, ព្រះលក្ស្មណ៍និងព្រះស្រុត្រឃ្នុជា ជាកងទ័ពបែកទ្វេងស្ដាំ មានពលយោធា ៤ ម៉ឺនសេនា ពាក់អាវពណ៌ស៊ីច័ន្ទកាន់ធ្នូស្នា. ព្រះភិរុតប៉ុផ្ទា កំផែ

ជាកងទ័ពខាងក្រោយឲ្យការសត្រូវតាំងពួង ពេលទិននាយ គឺកាយរៀប ឲ្យដើរខាងជាគូមួយគូ ៗ រៀងទៅ, ពេល ៦ ម៉ឺនកីន ពាក់អាវសុទ្ធសឹង តែពណ៌សុជម្ពូ កាន់លំពែងជាខែរ ចងក្បូរមាកេមបាមរ៍ តាំងសេះតាំងដំរី រៀបរបៀបឲ្យដើរជាជួរ ៗ តាមតំណែងភ្នាក់ងារទ្រមកជាអ្នកជិះ, មួយទៀត ពេលថ្មើរដើរដីង គឺរៀបរយតាមអណ្ដាប់អណ្ដាយគ្នាទៅហោង, ពេល ខាងព្រះបាទជនកធិបតី ដែលព្រះអង្គទ្រង់ព្រះរាជទានកជជគាតាំងស្រី ប្រុស ១ ម៉ឺន ៦ ពាន់នោះ គឺរៀបរយឲ្យនៅសងខាងថ្នេងស្ពាំ ហើយ គឺរៀបតាំងកដរថៃកពណ្ណរាយ រង់ចាំស្ដេចទ័ងយាត្រាហោង ។

កាលនោះ ព្រះបាទធតរដ្ឋធិបតីនោះ លុះអស្ដុរគត្ដផុតសែងព្រះ សុរិយា ក្សត្រាក៏ចូលកាន់ទីព្រះបន្ទំកម្មព្រះទយា ព្រះអង្គក៏ត្រេកអរ ណាស់ ដៀតបានកូនប្រសារដូចចិត្តប្រាថ្នា ព្រះអង្គក៏ពេញស្រឡាញ់ លន់ទឹងគណនាពុំបាន, ក្នុងវេលានោះ ព្រះអង្គទ្រង់ផ្ទំមិនស្ងួលក់ផែន នេះ ព្រោះព្រះអង្គទ្រង់ពឹងគិតតែនឹងត្រឡប់ទៅនគរវិញ, លុះពាល់តែ ស្វាងអរុណរះឡើងហើយព្រះអង្គក៏ស្ដេចតើនចាកទីបន្ទំ ក៏បបួលក្សត្រ តាំង ៨ ទៅស្រង់ពរហោង ។ ភ្នាក់ងារក៏ថ្វាយព្រះសង្ខសេចកួងាក ឲ្យស្ដេចស្រង់ ។ ព្រះអង្គស្រង់ព្រះកាយវិត្ថុះស្រេចហើយ ក្សត្រតាំង ៨អង្គ ក៏ទ្រង់គ្រឿងលម្អល្អះធេតឆាយពណ្ណរាយ តែរៀងកល់ព្រះអង្គ គ្រប់ប្រដាប់ សម្រាប់តែងស្រេចកាលណាហើយ ស្ដេចក៏យាងយាត្រាឡើងគង់លើ

ព្រះរាជរថ ហើយបង្គាប់ប្រាប់ទៅនាយសារថី ឲ្យត្រៀមរថជ័យបោកបក់ ជាកំណត់, រីព្រះកុមារាធិបតីសូរ្យវង្សនោះ ក៏ស្ដេចឡើងលើគយោធាទៅជាទ័ពមុខហោង ៗ ទើបអង្គព្រះបាទធតរដ្ឋស្ដេចក៏កៀនយោធា ឲ្យគោះគងទូងស្គរជ័យ យកបុក្សពារពលាទាំង ចេញតាមសម្ដេចព្រះកុមារាធិបតីជា គ ១ គ្នា ទៅតាមផ្លូវមគ្គាគាំពនាលី ៗ ក្នុងគ្រានោះ មានសត្វបក្សីត្រចៀកកាំនៅក្នុងរថក្នុងជ័ បណ្ដាលនាំឲ្យមានហេតុ ៗ សត្វនោះក៏ហើរមក ហើយក៏ចាបចឹកទង់ជ័យ ហើយក៏ហើរទៅខាងស្ដាំឲ្យឃើញនិមិត្តច្បាស់នឹងភ្នែក ហើយក៏ហើរទៅកាន់ព្រៃហេមវន្តវិញហោង ៗ

កាលណោះ ព្រះបាទធតរដ្ឋធិបតីនោះ លុះឃើញសត្វត្រចៀកកាំនោះហើរមកចាបចឹកទង់ជ័យដូច្នោះ ទើបព្រះអង្គរំពឹងជញ្ជឹងគិតក្នុងព្រះទ័យថា ពីដើមមុនមក មិនដែលដូច្នេះសោះ ទោះតាំងទេពទេកោះនៅឋានសួគាល័យក្ដី តាំងទសទិសាក្ដី សុទ្ធតែខ្លាចក្រែងបារមីអញទាំងអស់ ក្នុងគ្រានេះអស្ចារ្យណាស់ ឬមួយនឹងមានពៀរពួកពាលបច្ចាមិត្រ ទើបសត្វនោះហើរមកបណ្ដាលប្រាប់ហេតុអញហ្ន៎, ព្រះភូមិទ្រង់រំពឹងគិតហើយ ក៏រឹងរឹតតែចូលសង្ស័យក្នុងព្រះទ័យណាស់ ទើបមានព្រះឧង្ការត្រាស់ឲ្យហៅហោរាមកទាយនិមិត្តហេតុនោះឲ្យដឹងប្រាកដ ៗ

គ្រានោះ រីសេនានោះបានស្ដាប់ព្រះឧង្ការហើយ ក៏ថ្វាយបង្គំលាទៅស្រែកហៅ កាកកាកផាគាលាហល ៗ គ្រានោះ រីឃុនហោរា-

ចារ្យនិងយាយចាស់ ជាប្ដីប្រពន្ធមកនឹងគ្នាជាយូរយារហើយ គេទៀងដេះដារ នោះក៏មិនសូវដើរលឿនឡើយ ហើយក៏ដេះមកជាមួយនឹងគ្នា ក៏និយាយចំអកចំអន់ឡកលេងនឹងគ្នាជាប្ដីប្រពន្ធជាទីសប្បាយ សើចលេងក្អាកក្អាយហាស់ហាយហេហា, លុះបានឮសូរសម្រែកគេស្រែកហៅថា សម្ដេចព្រះបមក្ដដឲ្យហៅក៏ភ័យក្រែត ហើយក៏ស្រែកចាប់យកតម្រាក្បួនគម្ពីរ ក៏មិនឃើញសោះឡើយ ហើយក៏ថាអញទុកដាក់ត្រង់ហ្នឹង តើយាយចាស់ឯងយកទៅទុកឯណាបាត់, វិតាហោរានោះ ខំរកតម្រាម្ហូរើកវិលវល់ទំមតាម ៗ ទៅ ក៏ទាល់តែក្បាលត្បាក់ពីក្បូងដំបូលចុះមកដល់ដី ក៏យរលះរលាំង ខំប្រគាំងឈោងឡើងទៅរកក្បួនតម្រាវិញ បានឃើញហើយ រត់ម្ហូមាតាំងឈឺតាំងជា មកដោយប្រញាប់ ៗ

កាលណោះ ព្រះបាទនគរដ្ឋធិបតីនោះ ឃើញយុទ្ធហោរាចារ្យមកដល់ហើយ ព្រះអង្គក៏និយាយកយរឿងប្រាប់ទៅហោរាចា ម្នាលហោរអើយ ចូរអ្នកទាយទំនាយនិមិត្តហេតុនោះឲ្យគិតប្រាកដ ព្រោះឆ្កែឆានសត្វណាហើរមកឆាបឆក់ចកទងជ័យ ហើយកហើរទៅកាន់ព្រៃពនាល័យ, អញសែនឆ្ងល់នឹងហេតុហ្នឹងណាស់ ជាការចង្រៃដូចម្ដេចហ្ន៎ អ្នកហោរា?

គ្រានោះ តាហោរាចារ្យ បានស្ដាប់ព្រះឱង្ការហើយ ថ្វាយបង្គំប្រណម្យវន្ទិយស្រេចហើយ ក៏តាំងពារគោរមើលក្បួនតម្រាពិជ័យសង្គ្រាម-យុទ្ធ តាំងយាមត្រីទ្វិច្ចក្ស តាមតិថីពេលពេលានាទីទៅ ទើបបាន

ដំណើរហេតុ ហើយក៏ក្រាបបង្គំទូលទៅតាមក្បួនតម្រាថា សត្វសកុណនេះ ត្រូវក្នុងតម្រាថា វាហើរមកពីទិសខាងត្បូងចំពោះប្រាកដ ថាត្រូវមាន ចាបគ្រោះក្នុងវេលានេះ ហើយវាហើរទៅទិសខាងស្តាំវិញ ជាទីដ៏មាន ពួកពាឡបច្ចាមិត្រ មកបៀតបៀនបំណាយយាយី, តែក្នុងទំនាយទាយ ថា ព្រះអង្គនឹងត្រូវមានជ័យជំនះឈ្នះអស់សត្រូវ បើទុកជាសត្រូវនោះ មានគ្នាច្រើន ដល់ទៅ ១ សែន ១ លានកោដិក្តី ក៏ប្តូរមកចាំងចក្រ ពង្សក្តី ក៏នឹងចាញ់រិទ្ធិបារមីព្រះអង្គៈហោង ។ មួយទៀត រីព្រះកិត្តិ-យសឈ្មោះនឹងល្បីខ្ចរទៅចាំងត្រៃលោកាហោង ។

កាលនោះ ព្រះបាទធតរដ្ឋរាជានោះ ទ្រង់បានស្តាប់ទំនាយហោរ ទាយព្យាករណ៍ហើយ ព្រះអង្គក៏ទ្រង់ក្សេមក្សាន្តសម្រាន្តព្រះទ័យ ទ្រង់ព្រះ សម្រួល សើចញញឹមញញែមរីករាយ ចាំងស្រែកយកទៅកាន់អាឃិ អគ្គមហេសីទាំង ៣ ផង ស្រេចហើយព្រះអង្គក៏ឱ្យតៀនពលសកល យោធី ដើរតាមផ្លូវគីរីក្នុងទីហេមពានាល័យ លុះកន្លងផ្លូវព្រៃជ្រលង ដងព្រៃព្រះជ្រៅមកបានបន្តិច ។

ទីនិសម្តែងពីកម្មរសូរអស្សុក ស្ថិតនៅក្នុងពីមានទេតា ជាពាក់ កណ្តាលភ្នំព្រះសុមេរុបពិត ក្នុងជាន់ចាតុម្មហារាជិកា ។ អស្សុរនោះ ដំណោនីកាច មានអំណាចមហិមា មានរឿងដូចភ្លើងក្រុង គ្រាន់តែ ល្បីត្រទ្រូឈ្មោះវានោះ ក៏សឹងស្ទប់ស្ទែងត្រៃភពសស្កាវណាស់ ហើយ

អសុរានោះក៏មានចិត្តអហង្ការ មិនចាំដឹងបុស្បាសាមាន្យ ក៏ស្រែកខ្ទរខ្ទ្រាន ក្រាប់ទៅតាំងត្រៃត្រា ពោះតាំងពួកសុររាក្សមនុស្សវិជ្ជាធរសុវណ្ណគ្រុឌ ក៏កោតក្រែងខ្លាចអំណាចឥតអ្នកណានឹងក្លាហានតទល់បានឡើយ ៗ ថ្ងៃមួយនោះ ក៏គិតចង់ចេញទៅប្រពាតលេងក្នុងព្រៃព្រឹក្សពនាវេស គិតហើយ អសុរាក៏តែងគ្រឿងរុងរឿងអលង្ការពេញដោយនូវទិព្វវត្ថា ក៏ធ្វើសក្ការបូជ ព្រះបាទវេស្សវ័ណ កុម្ភណ្ឌចាប់យកពូថៅតេជ ហត្ថាម្ខាងកាន់ធ្នូសរជ័យ ស្រេចហើយនៃ ក៏វាហោះចាកវិមានរាគនា សំដៅទៅសក្កាគេជះ ហោះទៅកណ្តាលកណ្តាប់ពពកជ្រកស្រទាប់មេឃ ទៅទាល់តែដល់ដែនខនគរ មិថិលាមហាបុរីហើយ អសុរាក៏ចុះឈប់នៅនាដាយមាត់ព្រៃ ហើយ អសុរី ក៏ក្រោធយាត្រាដើរមើលអស់សត្វទ្វិបាទចតុប្បាទ ពងសីហានូវគជ-សារសិង្ហគោ នូវគោគោត្រមហិង្សាសព្វសត្វនានា ទីងពណ៌នាពុំអស់ឡើយ ៗ អសុរាវិទ្ធនោះ ក៏ដើររមើលរៀង ៗ ធៀងខេត្រដោយមាគ៌ា លីលាលេងទតសព្វសត្វ ខំរុកកាត់ពនាល័យទៅបានបន្តិច ក៏សង្កាតគយគន់ លបទន្ទួបល្បួចមើលតាមប្រកបវិរិនោះ ៗ លុះឃើញពួកពស់កលយោធា តាំងពងវេទ រេះរេសះ ដំរី ឧដ្ឋ លា លើកមកគគ្រឹកគគ្រេងកក្រើកតាំងព្រះធរណី អសុរាវិទ្ធក៏យាត្រាចូលទៅ ដៃកាន់ពូថៅតេជគណ្ណកាយ បង់ដំដែងឈរនៅកណ្តាលពនាវេស ក៏សម្ដែងតេជដៃជាអ្នកក្លាហាន ហើយក៏ស្រែកប្រកាសប្រាប់ទៅថា រ៉ុយនែ

អាមនុស្សប៉ុនសត្វស៊ុច ហៅហ្វាយនាយអាឯង តើមាននាមករណ៍ឈ្មោះអ្វី ? មួយទៀត តម្បន់ស្ថានបុរីនៅស្រុកណា នគរណា ? ហើយនាំគ្នាមកក្នុងព្រៃនេះ រកប្រយោជន៍អ្វី ?

គ្រានោះ អែសព្ទួកពលទាំងពួង ទើពស្រួចមុខនោះ លុះក្រឡេកមើលទៅឃើញកុម្ភណ្ឌអសុរនោះ មានរូបធំក្រៃមហិមាដូច្នោះហើយ ក៏កិតភ័យញ័ររន្ធត់ស្លុតស្លុង ទាំងពលនាយក៏បែរចេនស្តាំ រីសេនាពា-ហានខ្លះ មានស្មារតីមិនស្លូវភ័យពេក ក៏ស្រែកតបពាក្យទៅវិញ ថា ម្នាលអសុរ រីនាមករណ៍ឈ្មោះសម្តេចព្រះចក្រីនោះ ឈ្មោះហៅព្រះបាទធតរដ្ឋនរបតី ជាចមកំពូលពិនជាទីត្រៃលោកា ស្តេចគ្រងបុរីស្រីអយុធ្យាធានី ព្រះអង្គលើកពលទ័ពយោធាទៅតែងការពិពាហមង្គល គឺអង្គសម្តេចព្រះរាមរាជឱរស ដែលលើកធ្នូសិល្បជ័យក្នុងបុរីមិថិលា ព្រះអង្គបានទាំងសីតាហើយ ស្តេចក៏នាំពលទៅកាន់វៀងជ័យវិញ, ឯងមិនដឹងហេតុ ទើបបានមកសួររកនាមឈ្មោះធ្វើអ្វី ? រីធ្នូបារមីព្រះរាមនរបតីនោះ ព្រះអង្គក៏ទ្រង់អានុភាពវិសេសណាស់ កុំមកអួតអាងកាងក្រពារ ចង់តតេជដៃ នឹងក្ស័យជីវិតពុំលែងឡើយ ។

កាលនោះ រីពមេស្សូរយក្ស បានស្តាប់ហើយ ក៏គ្រោធក្រេវក្រញៅ ក្រញ៉ង ខឹងខាំមាត់ ហើយក៏ឆ្លើយតបទៅវិញ ដោយពាក្យពោលថា

នែកាមនុស្ស អាឯងថា ម្ចាស់របស់ឯងនោះ ឈ្មោះកមេសធំមានរិទ្ធិតេជ ដៃក្លាហាន អើថ្ងៃនេះហើយនឹងឃើញដៃគ្នា រីជីវិតជីកទៅហ្វាយនាយឯង នោះ នឹងស្លាប់ពុំលែងនឹងដៃអញ រីឯខ្លួនអញនេះ ដូចជាព្រះកាល បណ្តាលមកបំផ្លាញប្រហារជីវិត ចាំហើយអសុររិទ្ធិ ក៏គ្រវីផ្គរសរសិល្ប ជ័យ តន្ត្រំព្រះបាទាសម្តែងនូវអំណាចដូចរាជសីហា អសុរក៏ស្ទុះផ្ទាត លោតក្រូតចូលទៅសំពងកាយពលយោធាទាំងពួងហោង ។

គ្រានោះ រីអស់ពួកពលសកលយោធាទ័ពមុខនោះ ក៏ក្រែងស្ញែង រិទ្ធិអសុរ ភាល់ប្រាជ្ញានឹងចូលតដៃ ក៏ភ័យរត់ទៅទិសតាសទិសទៃ ញ័រជើង ដៃជ្រកពួនខ្លួនក្នុងអរញ្ញក ។ អសុរក៏ខំឃាតសង្ហាត្រេកដេញ ហាក់ដូច កេសររាជសីហា ចូលដេញហ្វូងម្រឹគាហោង ។ គ្រានោះកមេស្វរ អសុរនោះ លុះដេញពលទៅតាល់តែដល់មុខព្រះរាជរថរត្នសុវណ្ណ កុម្ភណ្ឌ ក្រឡេកភ្នែកមើលទៅ ឃើញអង្គព្រះរាមា និងនាងសីតាទន្តលក្ខណ៍ សម្បុរព្រះភ័ក្ត្រដូចទេពលេខា ទើបស្រែកទៅថា ហ៊ឺយមនុស្សអហង្ការ ក្លាហាន ហើយហ៊ាននាំស្រីមកកាត់មុខអញ ហើយហ៊ានលើកខ្លួនឯង ជាឈ្មោះកម ឲ្យត្រូវនឹងនាមអញដ៏ជាធំក្រៃ រីខ្លួនឯងនេះ នឹងក្ស័យ ប្រល័យជន្ម ប្រពន្ធឯងនោះ អញនឹងនាំយកទៅឥឡូវនេះ ។

(នៅមានត)

# ឯកសារ សាស្ត្រាស្លឹករឹតនិងក្រាំង

ដែលមាននៅវិជ្ជាស្ថាននៃពុទ្ធសាសនបណ្ឌិត្យ

លោក ញ៉ុក-ថែម រៀបរៀង

( ៩ )

បំណងជើង " សាស្ត្រា សិទ្ធិធាន "

អ្នកនិពន្ធ អម្បូកក្សត្រី "ម៉ុក"(១)

កាលបរិច្ឆេទ ព.ស. ២៤០៦ (គ.ស. ១៨៦៣) ។

របៀបនិពន្ធន៍ ពាក្យកាព្យ: បទកាកគតិតែ ១ ដល់ចប់ ។

ប្រភេទរឿង បញ្ញាសជាតក ។

លក្ខណៈឯកសារ សាស្ត្រាស្លឹករឹត ២ ខ្សែចប់ ។ ខ្សែទី ១ មាន

---

១— លោកអម្បូកក្សត្រី នាមដើមឈ្មោះ ម៉ុក នេះ ជាកវី មានថ្វីដៃ ១ រូប ក្នុងសម័យឧដុង្គ ។ លោកកវីម៉ុក បាននិពន្ធរឿង១ទៀត ហៅថា "រឿងទេវន្ទ" លោកបានស្រង់ប្រែសម្រួល អំពីគម្ពីរបញ្ញាសជាតកដែរ កាលពីឆ្នាំ ១៨៥៩ ។ លោកជាមន្ត្រី ១ រូបក្នុងរាជ្យសម្ដេចព្រះនរោត្តមជននី នៅចុងសម័យឧដុង្គមានជ័យ ។ កាលនោះ សម្ដេចព្រះវររាជជននី កំពុងទ្រង់ផ្ដើមសាងសង់ព្រះវិហារផ្សេង ៗ មានព្រះវិហារអដ្ឋារសជាដើម នៅភ្នំព្រះរាជទ្រព្យ ។ ទ្រង់មានព្រះសវនីយត្រាស់ប្រើលោកឲ្យនិពន្ធរឿងព្រះសិទ្ធិធាន ព្រមទាំងប្រោសប្រទានងារជាឧកញ៉ាអម្បូកក្សត្រី ត្រាស់ប្រើឲ្យឧកញ៉ា សេនីយេ ជួយថមូងផង ។

កវីនេះ មានលក្ខណៈប្លែកពីកវីដទៃ ៗ គឺចូលចិត្តនិយមប្រើតែពាក្យកាព្យ១បទរហូតដល់ចប់រឿង ទោះបីជារឿងវែងយ៉ាងណាក្ដី ។ល។

៣៤ សន្លឹក, ខ្សែទី ២ មាន ៣៧ សន្លឹក ។ ឯកសារនេះ ពុទ្ធសាសនបណ្ឌិត្យបានចារចម្លងតាមច្បាប់វត្តហារខេត្តកណ្ដាល កាលពីឆ្នាំមមែបញ្ចស័ក ត្រូវនឹងថ្ងៃទី ៣ វិច្ឆិកា ១៩៤៣ ចុះលេខ ១.៣៧៩ ។

អត្ថបទផ្ដើម: នមោខមា នមស្សិត្វា ពុទ្ធុត្តមំ តមោនុទំ លោក-នាថំ នាថោវរំ វិញ្ញាណា ។ អញ្ញុំគោរព ព្រះម្កុដ លើសលុប លើសលែងលោកា លោកនាថំ វិញ្ញាណា ប្រសើរជាតិជា ទីពំនឹងនិត្យ ។ តមោនុទំ មោហតណ្ហា ព្រះអង្គអាចបំទ អាចបាំងតណ្ហា មោហាផ្ទូរជិត ផ្ទូរជាតិមិន ជិត មិនដល់ព្រះអង្គ . . . . . . ។ល។

អត្ថបទបញ្ចប់: សង្ហនាទំ សុជាតកំ ចនិដ្ឋគោ និតានអំពី ពោធិ-វេរ វរលោកុត្តមោ វរលក្ខណ៍ថ្លៃថ្លា ។ អន្ទោលយកជាតិ ជាព្រះសង្ហនាទ នៅក្នុងបញ្ញា-សជាតកកត់ ដោយបទគាថា បរិបូណ៌ចូលជា ខ្សែពីរស្រេចហោង ។

បំណងជើង « សាស្ត្រា មង្គលសូត្រ[១] »

អ្នកនិពន្ធ រកពុំទាន់ឃើញ ។

កាលបរិច្ឆេទ គ្មានបញ្ជាក់ក្នុងអត្ថបទ ។

របៀបនិពន្ធ ពាក្យ៧ កម្រងកែវ លំនាំទេសនា ។

ប្រភពរឿង មង្គលសូត្រ លទ្ធិពុទ្ធនិយម ។

លក្ខណៈឯកសារ សាស្ត្រាស្លឹករឹតមាន ២ ផ្សែ ។ ផ្សែទី ១ មាន ៣៦ សន្លឹក, ផ្សែទី ២ មាន ៣១ សន្លឹក ។ ឯកសារនេះ ពុទ្ធសាសនបណ្ឌិត្យបានមកពីវត្តព្រែកថ្មីង ចុះលេខ ១៣៨៧ ។

អត្ថបទដើម៖ វេលានេះ ទ្រង់សំដែងក្នុងមង្គល ៣៨ ប្រការ ដោយ យ៉ ៗ ជាខវត្តប្រតិបត្តិ ថាតាមបាលីអដ្ឋកថា ទូរពោហារ ឲ្យ សមគួរទ្រង់សតិបញ្ញាស្មារតីប្រុសស្រីទាំងពួង ដែលមានមនោ- សទ្ធា ទ្រង់ចង់បាក្យាឲ្យជំនង់ឆ្ងាយ ទ្រង់ជាយស្តាប់ ហើយ

---

១– សាស្ត្រានេះ តាមឯកសារដើម ដាក់ចំណងជើងថា « សេចក្តីពហុសូត្រ » ផ្ទុយឈ្មោះទៅវិញ ប្រហែលជាអ្នកចារចម្លងភាន់ច្រឡំទេ ព្រោះផ្នែកអត្ថបទទាំងមូល ថ្លែងអំពីមង្គល ៣៨ ប្រការ ប៉ុណ្ណោះ ។ ក្នុងទីនេះ បានកែតម្រូវតាមអត្ថបទ ។

អធិប្បាយតាមដំណើរថា :

ឯកសម័យ គ្រាមួយនោះ សម្តេចព្រះបរមសាស្តាចារ្យ ចរិយាវ៉ៃ ព្រះអង្គស្តេចគង់នៅ ក្នុងព្រះជេតពន មហាវិហារ ដែលអនាថបិណ្ឌិកសាងថ្វាយ ពុំឆ្ងាយអំពីក្រុងសាវត្ថី ។ល។

**អត្ថបទបញ្ចប់**: មង្គល ៣៨ ប្រការ ចូរខំស្វាហាប់តាំងចិត្ត ខំប្រព្រឹត្តឲ្យបរិសុទ្ធបរិបូណ៌ ក្នុងខន្ធសន្តាន ក៏នឹងបានសេចក្តីសុខ សិរីសួស្តីវិឡូនមង្គលចំរើនសុខក្សេមក្សាន្ត បានផលគ្រប់ទិវារាត្រី ដូចខ្ញុំព្រះករុណាវិសជ្ជនាមកដូច្នេះ ចប់មង្គល ៣៨ ប្រការ ដោយយ៉ ៗ ខ្លី ៗ ជាខន្តប្រតិបត្តិ ផ្លូវបព្វជិតនូវគ្រហស្ថ ដែលសិក្សាតាមផ្លូវលោកិយ តាំងផ្លូវបរលោក បាននាំទិពានឲ្យបានចំរើន នូវប្រាជ្ញាសាធុជន ៗ បើមិនទាន់បានសម្រេចនូវមគ្គផល គង់នឹងលើកខ្លួនតំកល់ ឲ្យផុតពីអបាយភូមិ ដោយអំណាចប្រព្រឹត្ត នូវមង្គលទាំងឡាយ ដូចបានអធិប្បាយមកនេះ ៗ សូមសេចក្តីចំរើនចូរមានដល់អ្នក ដែលបានមើល ឬស្តាប់គ្រប់ទិវារាត្រី ចប់មង្គល ៣៨ ប្រការតែប៉ុណ្ណេះ ។

(នៅមានត)

# រឿងសាមកុក

ឧកញ៉ាវិបុលរាជសេនា

ង្វ · កាន

ប្រែរៀបរៀង

( គ )

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ អ្នកកងវៃឆ្លាសបើបានអាន
នឹងចេះឧបាយកលចំណាន — ទាំងមានសន្ដានស្នេហាជាតិ

យូរ—អ៊ុន

ឯកាយ ដែលជានាយកួយុំពេទ្យហ៊្វតោ ដឹងថា ហ៊្វតោជាគ្រូពេទ្យដេះយ៉ាងពូកែ ក៏ប្រតិបត្តិគ្រូ ជូនស្រា បាយ មានសាច់ជ្រូក-មាន់-ទាឲ្យបរិភោគពល់ពេលពុំដែលដាច់ ៗ ពេទ្យហ៊្វតោ មានកតញ្ញូតា ដឹងគុណកួយុំ ក៏និយាយថា ខ្ញុំនេះមុខជានឹងស្លាប់ប្រាកដហើយ ខ្ញុំមិនមានរបស់អ្វីនឹងតបស្នងសងគុណនាយទេ ខ្ញុំមានតែវិជ្ជាការខាងពេទ្យល្អណាស់ ខ្ញុំក៏មិនទាន់បានប្រាប់កូនសិស្សណាទៅឡើយ, ចូរអ្នកយកសំបុត្ររបស់ខ្ញុំនេះ ទៅឲ្យភរិយាខ្ញុំ យកតម្រាពីផ្ទះមក ខ្ញុំនឹងចង្អុលបំភ្លឺឲ្យយល់ទាល់តែអស់ កួយុំបានឮដូច្នោះ ក៏មានអំណរណាស់ និយាយថា ខ្ញុំបាទបានវិជ្ជាការពេទ្យរបស់លោកហើយ ខ្ញុំបាទមិនធ្វើការគេទៅទៀតឡើយ នឹងធ្វើការខាងពេទ្យ រក្សាកេតឲ្យល្បីឮទូទៅ ដើម្បីនឹងយករង្វាន់ទាន់ទៅថែសារពើថ្នាំចិញ្ចឹមជីវិតគាត់ប្រសើរជាង ៗ

ហ៊្លូគោ ក៏សរសេរសំបុត្រឲ្យកូយុំ ។ ក៏នាំយកសំបុត្រទៅឯតំបន់កូមិគិមសៀ ជូនទៅភរិយាហ៊្លូគោ ។ ភរិយាហ៊្លូគោក៏ប្រគល់តម្រារបស់ប្ដីតាមសំបុត្រនោះមកឲ្យកូយុំ ។ បានតម្រានោះហើយ ក៏យកទៅឲ្យហ៊្លូគោ ។ ក៏ចង្អុលបំភ្លឺប្រាប់វិជ្ជាពេទ្យ ដល់កូយុំនោះ លុះគ្រាតែបានដឹងស្គាល់យល់គ្រប់ប្រការ ហើយក៏ប្រគល់តម្រានោះឲ្យទៅកូយុំទាំងអស់, កូយុំបានតម្រានោះហើយ ក៏មានចិត្តត្រេកអរពន់ប្រមាណ បានយកតម្រានោះទៅទុកក្នុងទីលំនៅ, លុះកន្លងយូរទៅ ពេទ្យហ៊្លូគោ ក៏ធ្វើកាលកិរិយាក្ស័យជីវិតក្នុងគុកនោះទៅ ។ កូយុំក៏ឲ្យមន្ត្រីភ្នាក់ងារនាំយកសេចក្ដីទៅទូលព្រះចៅវុយអ៊ឹងថា ពេទ្យហ៊្លូគោស្លាប់ហើយ, កូយុំក៏ចាត់តែងគ្រឿងសែនព្រេន នាំសពពេទ្យហ៊្លូគោទៅបញ្ចុះតាមទំនៀម ។

ឯភរិយាកូយុំ ឃើញតម្រាក៏គិតថា ត្រូវការអ្វីនឹងរក្សាតម្រានោះទុក, ត្រូវដែលថាវិសេសណាស់ ម្ដេចក៏ស្លាប់ក្នុងគុក, បើប្ដីអញយកទុកក៏គង់តែដូចគ្នា ។ គិតហើយ ក៏យកតម្រានោះ ទៅដុតភ្លើងអស់ទៅ ។ វេលានោះ ទទួលកូយុំទៅផ្ទះ ក្រឡេកឃើញភរិយាយកតម្រាទៅដុតភ្លើងដូច្នោះ ក៏ស្ទុះទៅដណ្ដើមបាន ២-៣ សន្លឹក; ក្រៅអំពីនោះក៏ឆេះអស់ ។ កូយុំខឹងណាស់ ស្រែកជេរភរិយា ហើយថា ហេតុម្ដេចបានជាហ៊ានឯងយកតម្រាអញទៅដុតភ្លើងបំផ្លាញ ? ប្រពន្ធឆ្លើយថា បើហ៊្លូគោគ្រូអ្នកឯងវិសេសណាស់ ម្ដេចក៏ស្លាប់ក្នុងគុក, អ្នកឯងយក

តម្រានោះទុកប្រយោជន៍អ្វី? ឯកូឃុំនោះភាល់គំនិត ក៏អង្គុយគិតទុក្ខ ស្តាយតម្រានោះពន់ប្រមាណណាស់ ចេះតែដកដង្ហើមធំ ហើយគិតថា អំណោះពីថ្ងៃនេះទៅ តម្រាវិសេសយ៉ាងនេះអស់មានហើយ, ឯសទ្ទឹក ដែលយកបាននោះ បានតែបែបមើល ជ្រូក, មាន់, ទា, ប៉ុណ្ណោះ ។

ខណៈនោះ ឯចូចូដែលមានកេតឈឺក្នុងក្បាល ក៏បណ្តាលឲ្យកើត តាប់ធ្ងន់ឡើង ៗ ហើយព្រួយវិតក្ក ក្រែងកងទ័ពស្រុកតាំងតាំងទងស្រុក សែឈ្នះ លើកមកធ្វើអន្តកាយ មានចំពើសុំបការណ៍ចូលទៅទូលថា ស៊ុនគួនស្រុកតាំងតាំង មានសំបុត្រមកដល់; ចូចូក៏ឲ្យហៅអ្នកកាន់ សំបុត្រនោះចូលទៅ ហើយយកសំបុត្រនោះទៅមើល ឃើញសេចក្តីថា ខ្ញុំបាទស៊ុនគួន មានចិត្តស្វាមីភក្តិចូលមកជ្រកកោនពីងបុណ្យសម្ភារ ព្រះ ចៅវ៉ុយអង់តទៅ, ឯបណ្តាអាណាខេត្តទាំងពួង ក៏ឡើងទ្រង់អស់ហើយ ឃើញនៅសល់តែស្រុកសែឈ្នះ និងស្រុកតាំងពួនប៉ុណ្ណោះ ហេតុនេះ សុំឲ្យទ្រង់លើកទ័ពទៅកំទេចឡើងពិចុះ មុខជាបានដោយងាយ ៗ

ចូចូបានស្តាប់ ក៏អស់សំណើច ហើយថា មើលចុះស៊ុនគួន វា បញ្ឆោតយើង ឲ្យដើរជាន់លើគំនរភ្លើង ហើយទីប្រឹក្សាម្នាក់ឈ្មោះតាន់កុន ធ្វើយថា ផែនដីព្រះចៅហានទេ ក៏រៀវរេយមកយូរណាស់ហើយ; គ្រា នេះ អាស្រ័យដោយព្រះតេជព្រះគុណទ្រង់ ទើបបានបរិបូណ៌មាំមួន ឡើង អស់អាណាប្រជារាស្ត្រ ក៏បានប្រកបសុខក្សេមក្សាន្ត ដោយ

ស្ត្របានជ្រកម្លប់ព្រះបរមពោធិសម្ភារបារមី ហើយមានតាំងសេចក្ដីស្ម័គ្រ ស្រឡាញ់ព្រះអង្គខ្លាំងណាស់, ឯស៊ុនគួននេះ ក៏បន្ទាបខ្លួនចូលមកពឹងបុណ្យព្រះអង្គជាយូរគ្រាន់ហើយ គួរតែទ្រង់ទីងឡើងសោយរាជ្យជាអម្ចាស់ផែនដីឲ្យពេញទៅ ។

ចូឆូឮដូច្នោះ ក៏អស់សំណើច ហើយថា យើងបានទំនុកបំរុងផែនដីរបស់ព្រះចៅហៀនតេមក សឹកសត្រូវក៏រាបទាប រាស្ត្រក៏បានសេចក្ដីសុខក្សេមក្សាន្តមកយូរហើយ ព្រោះគំនិតរបស់យើង ។ ក៏បានសម្រេចកិច្ចការ ជាធំបំផុតលើសអស់មុខមន្ត្រីទាំងឡាយ មិនមាននរណាទឹងស្មើផល បើយើងតាំងខ្លួនជាម្ចាស់ផែនដី ជំនួសព្រះចៅហៀនតេ ក៏ដូចជាមិនសមគួរ យើងត្រូវធ្វើតែល្មមល្អមើលដូចជីវប៊ុនអង ដែលធ្វើការទុកឲ្យកូនប្រុសរបស់ខ្លួនប៉ុណ្ណោះក៏បាន ។ សុម៉ាអ៊ីថា បើវេលានេះ ស៊ុនគួនបានព្រមចំណុះចូលមកជាខ្ញុំទ្រង់ហើយ គួរតែទ្រង់ទីងតាំងលើកស៊ុនគួនជាទីនាម៉ឺនធំ ដើម្បីជាពួកក្រុមរបស់យើង បំរុងទុកឲ្យចាំស្កាត់ទ័ពគេទៀត ។ ព្រះចៅវុយក៏យល់ឃើញត្រូវ ទើបតែងត្រាតាំងស៊ុនគួនជាចៅហ្វាយស្រុកគេងជីវ ហើយចាត់បំរើឲ្យនាំត្រាតាំងចេញទៅប្រគល់ស្រុកគេងជីវឲ្យស៊ុនគួន ។

ចំណែកខាងចូឆូ កើតបណ្ដាលកាន់តែខ្លាំងឡើង ក្នុងថ្ងៃមួយនោះ ចូឆូយល់សប្ដិឃើញថា សេះ ៣ ស៊ីស្មៅក្នុងពេងជាមួយគ្នា លុះព្រឹក

ឡើង ក៏ពណ៌នាយល់សប្តិនោះឲ្យវិប្រីក្រាតាំងពួងស្តាប់ហើយថា កាល
គ្រា ម៉ាថេង, ម៉ាហ៊ុរ ម៉ាថៀត ៣ នាក់អាពុកទិន្នគូនគិតប្រទូសពីយ
ទិន្នយើង ។ ក៏យល់សប្តិឃើញយ៉ាងនេះដែរ ហើយយើងបានកំចាត់
ចេញអស់ហើយ, ឥឡូវយល់សប្តិឃើញដូចេះទៀត តើទិន្នអាក្រក់ល្អ
ឬការម្តេច ? កាសៀន្ទូលថា ទូលបង្គំពិគ្រោះឃើញលក្ខណៈយល់
សប្តិនេះល្អណាស់ មុខហាក់ទូលទិន្នមានបុណ្យឡើងទៀត ទ្រង់កុំព្រួយ
គក្កពេកឡើយ ។ ចូចួពុជហោះ ក៏គ្មានសេចក្តីពិការលសង្ស័យសោះ ។
លុះថ្ងៃមួយនោះ ពេលកណ្តាលយប់ ចូចួឃើញក្បាលណាស់ ហេះ
តក្តៅក្រហាលក្រហាយដេកមិនលក់សោះ លុះដល់ពេលយាម ៣ ក៏
ក្រោកចេញទៅអង្គុយ នៅលើកៅអីខាងលៃង្គៅ បានឮសម្លេងបំផុត
ភាគៅហៅកព្រៃ បែរក្រឡេកមើលទៅ ស្រាប់តែឃើញព្រះនាងហុកហៅ
និងព្រះកជទូរសទាំង ២ ហើយនិងហុកគួនបិតាព្រះនាងហុកហៅ នូវ
កំងស៊ុនបិតានាងតាំងគុយហ៊ុយ នូវអស់ស្ត្រីបក្ខពួកប្រហែល ២០ នាក់
កនឈាមហូប្រឡាក់ក្រហមពេញអស់ទាំងខ្លួន ឈរនៅលើអាកាស
ហើយថា ចូចួអើយ ! អ្នកឯងយកអាយុជីវិតមកឲ្យយើងវិញ ។ ចូចួ
ក៏ភ្ញាក់ក្រឡេកបាប់ទៅត្រូវម៉ាត់ទ្វារ ហើយក៏ឲ្យក្រវល់ក្រវាយខ្លាំងណាស់
ម៉ាំងក៏អស់ដួលចុះក្នុងទីនោះ ។ បណ្តាមនុស្សម្នាដែលបំរើថែទាំ ក៏
នាំគ្នាគ្រាហ៍លើកចូចួទៅឲ្យនៅក្នុងដំណាក់ដដែល, លុះនៅមកក្នុងថ្ងៃមួយ

នោះ វេលាកណ្ដាលយប់ ចូវជូដេកមិនលក់សោះ ចេះតែឮសម្ដែងខ្មោច បិសាចតាំងស្រីតាំងប្រុស ស្រែកយំឮទ្រហឹងអឹងកងទាល់តែភ្លឺ, លុះព្រឹកឡើង ចូវជូឲ្យប្រជុំនាម៉ឺនមុខមន្ត្រីទាំងពួងមកព្រមគ្នាហើយ និយាយថា យើងបានធ្វើសឹកសង្គ្រាមជាយូរលង់ តាំងពី ៣០ ឆ្នាំមកហើយ មិនដែលបានឮសម្ដែងខ្មោចបិសាច មកស្រែកយំឲ្យប្រាកដដូច្នេះឡើយ វេលានេះ មានខ្មោចបិសាចមកលងបន្ទាយ ស្រែកយំឮទ្រហឹងអឹងកង ជាចំឡែកពេកណាស់ តើនឹងមានហេតុភេទដូចម្ដេច ?

ឯនាម៉ឺនទាំងពួងក៏ទូលថា សូមឲ្យទ្រង់រកគ្រូហ្មឹងខ្មោចបិសាចមក រៀបសែនពលិការ តាមរបៀបបុរាណ មិនយូរប៉ុន្មានគង់នឹងបាត់ ។ ចូវជូដកដង្ហើមធំ ហើយថា បុរាណមាននិយាយទុកមកថា កម្មអកុសលមកដល់ខ្លួនហើយ ទោះនឹងចេះដោះស្រាយប្រការម្ដេច ក៏មិនផុតពីសេចក្ដីស្លាប់បាន, ឥឡូវ បើកម្មមកដល់ហើយ ក្រៅស្លាប់ក៏គ្មាននរណានឹងជួយបាន ចូវជូ ក៏មិនបានរៀបសែនខ្មោច, រំលងមកក្នុងថ្ងៃមួយនោះពេក ក៏គាត់តែក្រើកឡើងធូរជាងពីដើម ចេះតែល្ងឹងល្ងើយទន់ទៅ ៗ ទើបឲ្យហៅហៃហ្វីទុនចូលមក ។

ឯហៃហ្វីទុន មកដល់ទ្វារវាំង ក្រឡេកទៅឃើញព្រះនាងហុកហៅ នាងតាំងគុយហ៊ុយនិងព្រះរាជបុត្រទាំង ២ ហើយនិងហុកអ៊ួន, តាំងស៊ុន ទូវស៊័ត្រីបក្សួកឈរពីមុខលង់បន្ទាបជាខ្មោចស្រស់ៗ, ហៃហ្វីទុន ក៏ដួល

សន្ទប់នៅទី នោះ, ពួកបារាំងក៏នាំគ្នាគ្រាហ៍លើកទៅឯផ្ទះវិញ, ហៃហ៊ុំទុន កំចាប់ផ្ទុំឈើជាប់ព្រោះបិសាច ។ ចូចូក៏ឲ្យហៅ ចូហង, តានកុយ, កាសៀង, សុម៉ាអ៊ី ឲ្យចូលទៅដល់គ្រែដំណេកខាងក្នុង ទើបនិយាយផ្តាំផ្ញើបុត្រកិរិយានិងស្រុកទេស ការពារការ ទឹកដី ឲ្យបណ្តាមុខមន្ត្រីទាំង ៤ នាក់នោះ ។ មន្ត្រីទាំងនោះ ក៏ទូលថា ព្រះពេកនេះ មិនជាទម្ងន់ប៉ុន្មានទេ គង់តែមើលទៅជាវិញ ។

ចូចូថា: យើងបានធ្វើការណេគ្គសង្គ្រាម លើសជាង ៣០ ឆ្នាំ ហើយ សត្រូវទាំងប៉ុន្មាន យើងក៏បានបង្ក្រាបឲ្យរាបទាបអស់ហើយ ផែនដីសព្វថ្ងៃ ក៏បានសេចក្តីសុខក្សេមក្សាន្តទាំងអស់ ឃើញនៅចន្លោះតែស្រុកកាំងតាំង និងស្រុកសៃឈួន ដែលស៊ុនគួន និងឡៅពីឈរជាធំ យើងបង្ក្រាបពុំទាន់បាន, ឥឡូវជម្ងឺកង្ក្រុះណា ក៏កាន់តែធ្ងន់ណាស់ទៅហើយ ដែលនឹងសង្ឃឹមឲ្យបានទៅជាគៀន ធ្វើការសង្គ្រាមតទៅជាមួយគ្នាទៀតពុំបានឡើយ, ហេតុនេះ យើងសូមផ្តាំផ្ញើការធុរៈផែនដីនេះ ឲ្យអស់អ្នកទាំងឡាយ ចូរជួយយកចិត្តទុកដាក់ពិគ្គិតក្សា តាមការផងចុះ កូនប្រុសរបស់យើងមួយឈ្មោះចូផាំង, កើតពីនាងឡៅស៊ី ក៏ទទួលអនិច្ចកម្មក្នុងស្រុកអ៊ុនសៀទៅហើយ, នៅតែកូន ៤ នាក់ ដែលកើតពីនាងពៀនស៊ី ឈ្មោះ ចូភី ១, ចូពៀង ១, ចូស៊ុត ១, ចូហ៊ឹម ១, យើងព្រួយរិតក្តណាស់នឹងចូស៊ិតនោះ ព្រោះកូនមួយនេះសំដីមិនមាំទាំត្រង់ណាសោះ

រមែងស្រវឹងស្រា នឹងកាន់ការមិនខ្ជាប់ខ្ជួន បើនឹងតាំងជាជំនួយខ្លួនយើងក៏ពុំបាន, ឯចុងបៀននោះ វាជាមនុស្សមានកម្លាំងពលំក៏មែន តែជាមិនសូវចេះគិតការអ្វីសោះ, ចុងហ៊ឹមនោះ វាជាមនុស្សលោភទ្រព្យសម្បត្តិ, ដែលនឹងឃើញគំនិតមារយាទមធ្យ័ត តែចុងគីជាបុត្រច្បង មានប្រាជ្ញាកន្ទងលើសឯទៀត ព្រមទាំងសេចក្ដីឆ្លៀវឆ្លាតពន់វៃជាងគេ បើនឹងផ្ទុកផ្ទេរការពារការឲ្យជាជំនួសខ្លួនយើងក៏បាន បើប្រសិនជាយើងអស់បុណ្យក៏ត្រូវពសនាទៅហើយ អ្នកទាំងឡាយ ចូរជួយអនុគ្រោះតាំងចុងគីនោះ ឲ្យស្ដីរាជការជំនួសយើងតទៅចុះ ។

ខណៈនោះ ចុងហាង, គាទកុយ, គាសៀង, សុម៉ាអ៊ី បានឮចុងចូថា ជាពាក្យបណ្ដាំសព្វគ្រប់ដូច្នោះ ក៏នាំគ្នាសោកាល័យសង្រែសង្រេងរង្វើងស្មារតី មន្ត្រីទាំងនោះក៏នាំគ្នាថយចេញមកវិញ ។ ចុងចូក៏ឲ្យបំរើយកឈើក្រអូបយ៉ាងល្អឈ្មោះចេងហៀងមកចែកឲ្យភរិយាទាំងពួង ហើយក៏ផ្ដាំប្រដៅថា បើយើងអស់បុណ្យរាសនាហើយ នាងរាល់គ្នាចូរខំស្វាហ៍យកចិត្តទុកដាក់ ហ៊ឹកហាត់ក្នុងការដេរប៉ាក់គ្រប់ ជារបរចិញ្ចឹមជីវិតទៅថ្ងៃមុខ នាងចូរនាំគ្នាទៅនៅលើប្រាសាទតាំងសឺតតៃ ។

(នៅមានត)

# ឯកសារ កម្ពុជសុរិយា

(ក)

លោក ឌឹក-គាម ប្រមូលរៀបរៀង

វិទ្យាទេសនា : កណ្ឌទី ១ ព្រះតេជព្រះគុណព្រះសាក្យវង្សគ្រូបង្រៀនសំស្ក្រឹតនៅសាលាបាលីជាន់ខ្ពស់ ទ.ក. ៧, ទំព័រ ៣, ឆ្នាំ ១៩៤២, (ម ៥២/១៤) ។

កណ្ឌទី ២ : ព្រះតេជព្រះគុណព្រះសិរីសម្មតិវង្ស បានហ្វាន សាលាបាលីជាន់ខ្ពស់ ទ.ក. ៨, ទំព័រ ៣, ឆ្នាំ ១៩៤២, (ម.២៥/១៤) ។

កណ្ឌទី ៣ : ព្រះតេជគុណព្រះពុទ្ធឃោសាចារ្យ (ជ-ណាត) បានហ្វានសាលាបាលីជាន់ខ្ពស់ ទ.ក. ៩, ទំព័រ ៣, ឆ្នាំ ១៩៤២, (ម.២៥/១៤) ។

កណ្ឌទី ៤ : ព្រះបាឡាត់ឃោសនាគ ហ-ចៀវ ទ.ក. ១០, ទំព័រ ៣, ឆ្នាំ ១៩៤២ (ម.៥២/១៤) ។

កណ្ឌទី ៥ : លោកគ្រូអាចារ្យ ម៉ុញ-ណាគ្រី ទ.ក. ១១-១២, ទំព័រ ១, ឆ្នាំ ១៩៤២, (ម.៥២/១៤) ។

កណ្ឌទី ៦ : សាខុម ទ.ក. ១៣-១៤, ទំព័រ ១, ឆ្នាំ ១៩៤២, (ម.៥២/១៤) ។

កណ្ឌទី ៧ : ព្រះគ្រូមុនីសុមេធ (កេត ឋិតសីលោ)

ទ.ក. ១៥-១៦, ទំព័រ ១, ឆ្នាំ ១៩៤២, (ម.៥២/១៤) ។

កណ្ឌទី ៨ : . . . . . .

កណ្ឌទី ៩ លោកអាចារ្យ យូរ - អ៊ុន ទ.ក. ១៧ - ១៨, ទំព័រ ១, ឆ្នាំ ១៩៤២, (ម.៥២/១៤) ។

កណ្ឌទី ១០ : លោកអាចារ្យ ញូង - សឿង ទ.ក. ១៩-២០, ទំព័រ ១, ឆ្នាំ ១៩៤២, (ម ៥២/១៤) ។

កណ្ឌទី ១២ : លោកគ្រូអាចារ្យ ពាង - សុខ ទ.ក ២១ - ២២, ទំព័រ ១, ឆ្នាំ ១៩៤២, (ម.៥២/១៤) ។

កណ្ឌទី ១៣ : ព្រះគ្រូវិនយធម្ម ហ៊ុ - ជា ទ.ក. ២៣-២៤, ទំព័រ ១, ឆ្នាំ ១៩៤២ , (ម.៥២/១៤) ។

កណ្ឌទី ១៥ : លោកអាចារ្យ កៅ - ស៊ុម ទ.ក. ១-២-៣, ទំព័រ ១, ឆ្នាំ ១៩៤៣, (ម.៥២/១៥) ។

កណ្ឌទី ១៦ : លោកអាចារ្យ ឈឹម - ស៊ុំ ទ.ក. ១-២-៣, ទំព័រ ១៦, ឆ្នាំ ១៩៤៣, (ម.៥២/១៥) ។

កណ្ឌទី ១៧ : ព្រះមហា សោម - ឡុប ទ.ក. ១ - ២-៣, ទំព័រ ២៧, ឆ្នាំ ១៩៤៣, (ម.៥២/១៥) ។

គោរសំអាត : ព្រះវិសុទ្ធវង្ស ហួត - តាត ទ.ក. ៧-៨-៩, ទំព័រ ១១១, ឆ្នាំ ១៩៣៩, (ម.៥២/១១) ។

វិធីតុបតែងព្រះពុទ្ធសាសនា ឲ្យចំរើន នៅក្នុងឯករៈ
កម្ពុជា : ជី គឹម - ហាក់ ទ.ក ១១, ទំព័រ ៤៧,
ឆ្នាំ ១៩៣០, (ម.៥២/៣) ។

វិធីធ្វើចំការច្បារដំណាំ : អ្នកស្រែម្នាក់ ទ.ក. ២០, ទំព័រ
១២, ឆ្នាំ ១៩៤១, (ម ៥២/១៣) ។

វិធីធ្វើក្រដាសដោយដៃ នៅប្រទេសលាវ : ទ.ក. ១៥,
ទំព័រ ៣, ឆ្នាំ ១៩៤១, (ម.៥២/១៣) ។

វិធីបង្កាត់ធុបក្នុងកិច្ចការសម្រាលកូន : ព្រះមហា ឈឹម-
ក្រសេម ទ.ក. ១-២-៣ ទំព័រ ៣៥, ឆ្នាំ ១៩៣៧
(ម.៥២/៩) ។

វិធីបង្ការរោគ : ដុកទ័រឡូរង់ ទ.ក. ១-២-៣. ទំព័រ
១៩, ឆ្នាំ ១៩៣៧, (ម.៥២/៩) ។

វិធីរក្សាគភ៌ : ទ.ក. ២-៣, ទំព័រ ៥៨ ឆ្នាំ ១៩៣៥,
(ម.៥២/៧) ។

វិធីរក្សារាងកាយ : ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម ទ.ក. ៥,
ទំព័រ ២២៥, ឆ្នាំ ១៩៤៧, (ម.៥២/១៩) ។

វិធីកប់ថ្ងៃ-ខែ-ឆ្នាំ-រដូវ (កាព្យ) : ព្រះគ្រូញាណ-
សំវរ ញាណ-ឈឹន ទ.ក. ២, ទំព័រ ៩៥, ឆ្នាំ ១៩៤៦,
(ម.៥២/១៨) ។

វិធីសម្រាលក្មួន : ទ.ក. ៥-៤-៦, ទំព័រ ៥៤, ឆ្នាំ ១៩៣៤, (ម.៤២/៧) ។

វិធីរកដ៏សំឡេង : លោកអាចារ្យ សេ - កោ ទ.ក. ៩, ទំព័រ ៥៥៩, ឆ្នាំ ១៩៥៧ (ម.៤២/១៩)

វិធីអប់រំចិត្ត : លោក ស៊ុន - ហ៊ិន ទ.ក. ៩, ទំព័រ ៦៥៣, ឆ្នាំ ១៩៤៥, (ម.៤២/២៦) ។

វិធីអប់រំជនជាតិខ្មែរ : លោក ក៏យ - ប៊ុក ទ.ក. ៧, ទំព័រ ៦៤១, ឆ្នាំ ១៩៤៦, (ម.៤២/២៨) ។

វិទុរជាតក : ទ.ក. ២, ទំព័រ ១៣៥, ឆ្នាំ ១៩៦៥, (ម ៤២/៣៦) ។

វិជយកថា : ព្រះបាឡាត់អរិយកស្សប តុង - ពួន ទ.ក. ៩, ទំព័រ ៦៥៣, ឆ្នាំ ១៩៤១, (ម ៤២/២៣) ។

វិជ័យនិងការប្រតិបត្តិ : លោក គិត - ពិន ទ.ក. ៩, ទំព័រ ៧០៥, ឆ្នាំ ១៩៤២, (ម.៤២/២៩) ។

វិបត្តិសតិសម្បជញ្ញៈ : លោក ផេង - ជ្រៅ ទ.ក. ១, ទំព័រ ៥៩, ឆ្នាំ ១៩៦៣, (ម.៤២/៣៤) ។

វិរុទ្ធវត្ថុគាថា : ព្រះវិកញ្ញាណ សោម - ឡុប ទ.ក. ៣, ទំព័រ ១៧៩, ឆ្នាំ ១៩៤៥, (ម.៤២/២៧) ។

វិវត្តន៍នៃអក្សរខ្មែរ : លោក ឌ តាម ទ.ក. ៣, ទំព័រ
២៨៥, ឆ្នាំ ១៩៦៥, (ម.៥២/៣៧) ។

វិកធម្ម.ប : ព្រះឧបាលិវង្ស ម៉ឹង - សែស ទ.ក. ៦, ទំព័រ
៤១២, ឆ្នាំ ១៩៥៥ (ម ៥២/២៧) ។

វិកប្បសមកថា : ព្រះភិក្ខុ ហេន - ធឿន ទ.ក. ៥,
ទំព័រ ៣២៣, ឆ្នាំ ១៩៥៤, (ម.៥២/២៦) ។

វិសារទធម៌ : ព្រះមហាឧត្តមវិជ្ជា កែ - អឿន ទ.ក. ៨, ទំព័រ
៥៨១, ឆ្នាំ ១៩៥២, (ម.៥២/២៤) ។

វីរបុរសតីរូបដល់ទ្វីបអាស៊ី : លោក ព៉យ - ប៊ុក ទ.ក. ១០,
ទំព័រ ៥០៧, ឆ្នាំ ១៩៤៧, (ម ៥២/១៩) ។

វីរិយកថា : យុទ្ធបណ្ឌិតក្ស ប៊ូ - ប៉ូ ទ.ក. ៣, ទំព័រ ៦០៣,
ឆ្នាំ ១៩៣៧, (ម.៥២/២៩) ។ អ្នកឧកញ៉ាសុភាធិបាដ ស៊ូរ
ទ.ក. ៨, ទំព័រ ៨៧, ឆ្នាំ ១៩២៦ - ២៧ (ម.៥២/១) ។

វីរិយកថា : អាចារ្យ សួរ - ហាយ ទ.ក. ៧ - ៨ - ៩,
ទំព័រ ២៣៥, ឆ្នាំ ១៩៣៧, (ម.៥២/៩) ។

វីរិយារម្ភកថា : ព្រះគ្រូ កែ - អឿន ទ.ក. ១០, ទំព័រ ៧២៣,
ឆ្នាំ ១៩៥៤, (ម ៥២/២៦) ។

វេយ្យាករណ៍និងធាតុសព្ទខ្លះ : ទ.ក. ៧, ទំព័រ ៧៤១,
ឆ្នាំ ១៩៦៥, (ម.៥២/៣៧) ។

វេយ្យាករណ៍សំស្ក្រឹត : ព្រះវិសុទ្ធិវង្សហួត - តាត ខ.ក. ៧ - ៨ - ៩ ទំព័រ ១៦៣, ឆ្នាំ ១៩៣៨, (ម.៥២|១.) ។

វេរកថា : ព្រះសាសនមុនី កឹម-គូរ ខ.ក. ២, ទំព័រ ១១១, ឆ្នាំ ១៩៦៤, (ម.៥២/៣៦) ។

វេរប្បតិវេរកថា : ព្រះគ្រូមុនីសោភណ សោម - ឡុច ខ.ក. ១, ទំព័រ ៣២, ឆ្នាំ ១៩៤៧, (ម.៥២/១៩) ។

វេទព្វជាតក : ម.ឯកនិបាតជាតក ។

វេរូបសមកថា : ព្រះគ្រូញាណមុនី ឡេង - រម ខ.ក. ៩, ទំព័រ ៤៨១, ឆ្នាំ ១៩៥៩, (ម.៥២/៣១) ។

វេសារជ្ជករណធម៌ : ព្រះមហា សុខ - យូរ ខ.ក. ៣, ទំព័រ ២៣៩, ឆ្នាំ ១៩៥៩, (ម.៥២/៣១) ។

សកម្មភាពនៃក្រុមជំនុំទំនៀមទម្លាប់ខ្មែរ: លោក តាប ពិន ខ.ក. ១០, ទំព័រ ៩០០, ឆ្នាំ ១៩៥៧, (ម ៥២/២៩) ។

សកម្មភាពនៃក្រុមជំនុំទំនៀមទម្លាប់ខ្មែរ បរិយាយពីចំរៀងនិងប្រយោជន៍ចំរៀង : លោកតាប - ពិន ខ.ក. ២, ទំព័រ ១៣១, ឆ្នាំ ១៩៥៥, (ម.៥២/២៧) ។

សកម្មភាពនៃពុទ្ធសាសនបណ្ឌិត្យ : លោកតាប - ពិន ខ.ក. ១, ទំព័រ ៧២, ឆ្នាំ ១៩៥៣; ខ.ក. ២, ទំព័រ

១៦១, ឆ្នាំ ១៩៥៣; ទ.ក. ៥, ទំព័រ ៣៨៤, ឆ្នាំ ១៩៥៣; ទ.ក. ៦, ទំព័រ ៤៦៣, ឆ្នាំ ១៩៥៣; ទ.ក. ៧, ទំព័រ ៥៤៤, ឆ្នាំ ១៩៥៣; ទ.ក. ៨, ទំព័រ ៦១៩, ឆ្នាំ ១៩៥៣; ទ.ក. ៩, ទំព័រ ៧០៣ ឆ្នាំ ១៩៥៣; ទ.ក. ១០, ទំព័រ ៧៨៣, ឆ្នាំ ១៩៥៣; ទ.ក. ១១, ទំព័រ ៨៥៣, ឆ្នាំ ១៩៥៣ (ម ៥២/២៥) ។

សន្ត្រាន : អាចារ្យ គឹម - អាន ទ.ក ១ - ២ - ៣ ទំព័រ ២១១, ឆ្នាំ ១៩៣៨. (ម.៥២/១០) ។

សង្ខិតន័យពីប្រវត្តិព្រះពុទ្ធសាសនានៅប្រទេសកម្ពុជា ជាអតីតកាល : ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ ទ.ក. ១, ទំព័រ ៨, ឆ្នាំ ១៩៥៥, (ម.៥២/២៧) ។

សង្គហធម៌ : ព្រះបាឡាត់ឧត្តមលិខិត សុង - ស៊ីវ ទ.ក. ៧, ទំព័រ ៤៨៣; ឆ្នាំ ១៩៥៣; (ម.៥២/២៥) ។ ព្រះវិន័យធម្ម យូរ - ប៉ុណ្ណ ទ.ក. ២, ទំព័រ ១៤៤, ឆ្នាំ ១៩៤៨, (ម ៥២/២០) , ទ.ក. ៤, ទំព័រ ២៥៦ ឆ្នាំ ១៩៥១ (ម.៥២/២៣) ។

សង្គហធម៌ ៤ ប្រការ : លោក ឈឹម - ស៊ុម ទ.ក. ២; ទំព័រ ១៦៨, ឆ្នាំ ១៩៦៥, (ម.៥២/៣៧) ។

សង្គាយនាព្រះត្រៃបិដកប្រទេសកម្ពុជា : ពុទ្ធសាសន-
បណ្ឌិត្យ ទ.ក. ៣, ទំព័រ ១៣៩, ឆ្នាំ ១៩៥៣,
(ម.៥២|២៥) ។

សង្គាយនាយ៉ាងសង្ខេបរបស់ព្រះពុទ្ធសាសនា : ទ.ក.
១៦, ទំព័រ ៣, ឆ្នាំ ១៩៤១ (ម.៥២|១៣) ។

សង្គ្រាមកាំបាំង : ឃុនបណ្ណានុរក្ស ប៊ូ-ប៉ូ ទ.ក. ១២, ទំព័រ
៩៣, ឆ្នាំ ១៩៥៥, (ម.៥២|២៧) ។

សង្គ្រាមរវាងកីក្កកាំងនិងព្រះព្រហ្ម : លោក លាង-ហ៍បអាន
ទ.ក. ១២, ទំព័រ ១២៧៧, ឆ្នាំ ១៩៦០, (ម.៥២|៣២) ។

សង្ឃសរណគាថា : ព្រះមហា កុន-ប្រិញ ទ.ក. ៤, ទំព័
៣១៣, ឆ្នាំ ១៩៥៦, (ម.៥២|២៨) ។

សង្ឃសោភណគាថា : ព្រះមហា ជាន់-ខុក ទ.ក. ១២,
ទំព័រ ១៣២៧, ឆ្នាំ ១៩៥៩, (ម.៥២|៣១) ។

សតិសម្បជញ្ញគាថា : ព្រះបាឡាត់ សុន-ស៊ី ទ.ក. ៤
ទំព័រ ១១៨, ឆ្នាំ ១៩៥៦ (ម.៥២|២៨) ។

សត្តដ្ឋសូត្រ : ឧកញ៉ាភក្តីជា យ៉ុង ទ.ក. ៧-៨-៩,
ទំព័រ ១០៤, ឆ្នាំ ១៩៣៣. (ម.៥២|៦) ។

(នៅមានត)

# ជីវប្រវត្តិ

## របស់ខ្ញុំឈ្មោះ អៀង សាយ

(គ)

ខ្ញុំសន្យានឹងពួកយួនថា ខ្ញុំមិននិយាយតាមការពិត ខ្ញុំគិតឲ្យវារួចខ្លួនទាំងអស់គ្នា ។

ដោយខ្ញុំទៅនិយាយប្រាប់ពួកជប៉ុនថា ក្មេងវាប្រាប់ខ្ញុំថា កាបូបនោះដាក់ហោប៉ៅខាងក្រោយមិនបានចូលសិប់ នៅយប់ដែលស៊ីផឹករួច ដើរមកបានបន្តិច កាបូបនោះជ្រុះធ្លាក់នៅផ្លូវ មានយួនម្នាក់ពាក់អាវខ្មៅ ស្លៀកខោខ្មៅ ដើរជើងទទេ បំរុងទៅរកស៊ីផឹក វាជាន់ទៅលើកាបូប វារើសបើកមើលឃើញមានប្រាក់ពីររយរៀល វាដកយកប្រាក់ ហើយបោះកាបូបចោលទៅក្នុងគុម្ពផ្កា នៅមុខភោជនីយដ្ឋាននោះ វាត្រឡប់ទៅវិញ ឥឡូវនេះយួនដែលរើសបានប្រាក់ វាទៅផ្ទះវានៅឯព្រៃនគរ ឯណោះបាត់ទៅហើយ ។ ជប៉ុននាំគ្នាមករកមើល ឃើញកាបូបនោះ វាត្រេកអរខ្លាំងណាស់ ដោយបានឃើញឯកសាររបស់វា ។

ខ្ញុំចេះតែបែកគំនិត អំពីរឿងលេងកលថ្មីនៃក្អក រហូតដល់បានធ្វើឲ្យគេឃើញជាក្មេងកើតចេញពីផ្កាឈូក នាំឲ្យផ្អើលគេមកមើល បានប្រាក់ជាច្រើន រឿងក្មេងកើតពីផ្កាឈូកនោះអស្ចារ្យណាស់ មិនមែនដូចធ្វើសម័យឥឡូវនេះទេ គេចង់បន្លំឲ្យដូចរបស់ខ្ញុំធ្វើ តែធ្វើមិនដូច ។

កាលដែលធ្វើរួច តាំងឲ្យគេមើលនៅភ្នំពេញ ហើយចេញទៅគ្រប់ខេត្តក្រៅ ឲ្យបងប្អូនខ្ញុំនាំយកទៅតាំង ឲ្យគេមើលយកប្រាក់គ្រប់ខេត្តក្នុងស្រុកខ្មែរ ហើយទៅស្រុកយួនកូសាំងស៊ីននៅយូរខែ ទើបទៅដល់ហាណូយឯតុងកឹងទៀត បានប្រាក់ច្រើនដូចត្រូវឆ្នោតធំមួយ ។ ខ្ញុំមានរូបថតនិងឯកសារអំពីក្មេងកើតពីផ្កាឈូកនោះ ទុកមកដល់ពេលនេះ ។

បន្ទាប់អំពីរឿងដែលខ្ញុំលេងកលថ្មីនក្អក ខ្ញុំសរសេរអំពីរឿងដែលខ្ញុំចេះតែងពាក្យកាព្យឃ្លោង ។

នៅវត្តបាក់ក ដែលមានឈ្មោះត្រឹមត្រូវថាវត្តឧដុង្គមានជ័យ នៅជិតភ្នំស្រង់ គឺក្នុងស្រុកកំណើតរបស់ខ្ញុំ មានរូបគំនូររឿងពុទ្ធប្រវត្តិនៅផ្ទៃសាលាវត្តនោះ ដែលជាសំណាដៃរបស់លោកឪពុកខ្ញុំ ។ ខ្ញុំឃើញចំណងជើងជាពាក្យកាព្យ ខ្ញុំកត់ចម្លងយកមកតាំងពីខ្ញុំបានអាយុ១៨ ឆ្នាំ សេចក្តីថា :

សេរីកេហារប្រាជ្ញាវៀង　　　នាមដើមឈ្មោះអៀងជាងគំនូរ
គំនិតប្រឹងគិតប្រកបគូរ　　　ប្រគេនលោកគ្រូចៅអធិការ ។
គ្បិតព្រះទ័យព្រះទសពល　　　យោបល់ឆ្ងើយល់ដោយបញ្ញា
ខំស្អិតគិតស្អាងសាងសាលា　　　ជាការទុកតព្រះគុណថ្លៃ ។
ទើបច្រងតម្រាស់ត្រាស់ប្រើប្រាណ　　　មិនខានខំប្រឹងតាមព្រះទ័យ
ប្រតានរង្វាន់ឲ្យអាស្រ័យ　　　មួយថ្ងៃជាប្រាក់សាមសិបសេន

ដោយឃើញពាក្យកាព្យ ដែលមានពាក្យផ្ទួនចួនជាប់គ្នា មានឃ្លាជាពាក្យពីរពេះនោះ ខ្ញុំជាប់ចិត្តគិតពិនិត្យពាក្យកាព្យឃ្លោង ឲ្យតែឃើញពាក្យ ដែលមានកាព្យទាក់ទង ខ្ញុំឈ្លោកពិនិត្យគិតរករបៀបតាប់ចុងជួន ដោយព្យាយាមយូរមក ខ្ញុំរករបៀបតែងជាពាក្យកាព្យបានខ្លះ សូមយកពាក្យកាព្យជំនាន់នោះ ពីរ-បីមកជូនមើល ។ ដោយទៅធ្វើការក្នុងថ្ងៃភ្ជុំបិណ្ឌ នឹកតាស់ចិត្តនឹកដការសោណាព្យាបាល ខ្ញុំសរសេរពាក្យកាព្យមួយថា :

អស្ចារ្យចម្លែកប្លែកឆ្នាំនេះ      រាជការតែងបេះរេះសព្វគ្រប់
បុណ្យភ្ជុំតាំងមូលមិនឲ្យឈប់      គម្ពីរមកខ្ទប់សាលាដែក ។
ជូនតាគាត់មករកឯវត្ត      បាត់ទៅប្រាកដជាយំស្រែក
តាំងញាតិសណ្ដានច្រើនអនេក      ដែលចែកហានទៅឥឡូវមក ។
បើកូនចៅនៅតែធ្វើការ      អ្នកណាទឹងបានគិតរះរក
អន្សមនំគមរៀបដាក់ស្ពត      ដូវត្រូវមករកពីសា ។

ពាក្យកាព្យមួយទៀត ខ្ញុំឃើញជាងម្នាក់ធ្វើការជាមួយប្អូនខ្ញុំ មានគេនិយាយចំអកចំអន់លេងទីងជាងនោះ ខ្ញុំសរសេរពាក្យកាព្យ ១ ឲ្យគេអាន ឲ្យគេស្ដាប់តាំងអស់គ្នា មានសេចក្ដីថា :

ពួកជាងស៊ីម៉ងត៍មានឈ្មោះយី      បេះការខ្ទួចខ្ទីសល់ដោយជុំ
បេះបួកចូកក្រាប់កាច់ប្រមុំ      ឲ្យតែមានពុម្ពធ្វើបានគ្រប់ ។

ចេះភាយស៊ីមិនគិតផងដូចផេះ ចុកទៅនៅល្បះផុយដុប ៗ
បើផ្ញាក់ថ្នាក់បែកមានដែកទប់ យ៉ាយល់ការគ្រប់យប់រៀនគូរ ៗ
ស្រី ៗ ឃើញក្បាច់ញោចកណ្តៀវ ដែលយីព្រានព្រៀវផ្អើលមើលឈូរ
សរសើរគ្រប់មាត់ថាគាត់គូរ គំនូរល្អដាច់ដូចក្បាច់អាល ៗ

ដោយខ្ញុំជាប់គំនិតពីពាក្យកាព្យឃ្លោង មានឥស្សរជនជាន់ខ្ពស់មួយរូប ប្រើឲ្យខ្ញុំគូររូបមួយធំតាមរូបថតតូច ដល់ឃើញខ្ញុំគូរបានដូចរូបថតនោះ បានបញ្ចេញពាក្យសរសើរលើកទឹកចិត្តជាច្រើន ខ្ញុំទឹកចង់សើចទឹកពាក្យអស់នោះ ដែលជាពាក្យពយ ធម្មតាទេ តែខ្ញុំយកមកបន្ថែមបន្ទយតែងជាពាក្យកាព្យ មើលលេងថា ៖

ខែជាងអ្នកចេះចំណេះចប់ កុំជប់គិតព្រួយពីប្រាក់កាស
ឯងគួរពេលល្អិតកុំគិតផ្តាស ប្រាក់កាសអញឲ្យឯងពេញចិត្ត ៗ
ដូចកាលអញទៅនៅប៉ារីស មានជាងគេចេះបញ្ចេញមុត
គូរដូចរូបអញ ១ ពេញចិត្ត អាណិតគេណាស់អញឲ្យក្រែល ៗ
គ្រាន់តែមេដាយរាល់ទឹងប៉ោត ប្រាក់ហ្វ្រង់គ្រណាតចូកទឹងប៉ែល
រាល់ទឹងគ្រឡក្រប្រហែល អញឲ្យគេក្រែលដោយរាក្រ ៗ
ឯខ្លួនឯងនេះឯងកុំគិត លែងលិទ្ធប្រហុកហុតសម្ល
សុទ្ធតែនំប៉័ងនិងត្រីខ ម្ហូបបារាំងយ៉ាងល្អសមខ្ចិះ ៗ
តាំងព្រឹករាំងល្ងាចមកស៊ីចុះ ឯងចេះប៉ុណ្ណោះមិនសំគិះ

ឡានអញប្អូនដប់ប៉ែតជិះ ទាំងកុលាបម្ទិះបេះតាមចិត្ត ។
សួនច្បារដំណាំអញផ្កាផ្កា ទៅណាមកណាអញអាណិត
បេះទៅក្រងលេងកំសាន្តចិត្ត កុំគិតកោតខ្លាចអំណាចអញ ។
មួយទៀតស្រី ៗ ក្មេងក្នុងក្រៅ កូនចៅអ្នកណាឯងស្រឡាញ់
មើលឲ្យស្រឡះរូបប្រាប់អញ នឹងកាញ់គិតគូរដណ្តឹងឲ្យ ។
ឯគ្រឿងប្រពន្ធឯងកុំព្រួយ ឯខ្លួនឯងមួយមិនខ្វល់ខ្វាយ
អញជានាជួយប្រាក់កប់រយ អញរៀបការឲ្យកុំខ្លាចអត់ ។
ឯផ្ទះសម្បែងឯងមិនក្រ សង់ថ្មតឿឡើងតម្កើងកត់
ប្អូនជាន់ប្រាំជាន់មិនកំណត់ ឡើងម្តងក្រែងហត់មាត់ហប ៗ ។

ខ្ញុំមានសរសេរពាក្យច្រើនទៀត ជាចំនុកច្រៀងខ្លះ ជាសុភាសិតខ្លះ ជារឿងបែបសាស្ត្រាខ្លះ តែគេខ្ចីយកទៅមើលបំបាត់អស់ខ្លះ នៅសល់ខ្លះ គឺរឿង តាតូច និងមេកាព្យជាក្បួនច្បាប់ ។

ឯរឿងប្រលោមលោក ខ្ញុំស្រលាញ់អានរឿងអក្សរខ្មែរ និងអក្សរបារាំងជាច្រើន ខ្ញុំអានមើលពិនិត្យល្បិចកិច្ចកលដែលគេសរសេរ លុះតែបានយល់ បានសរសេរលេង សរសេរល្បងមើលច្រើនរឿងដែរ ។

តែមុនដំបូងខ្ញុំចាប់សរសេររឿងល្ខោន ជារឿងកំប្លែងខ្លី ៗ មានតែមួយឈុត ១ បន្ទាប់មក ខ្ញុំសរសេររឿងល្ខោន ជារឿងគួរឲ្យសើច ជារឿងកំសត់ និងជារឿងអប់រំផង ១ មានច្រើនឈុត ច្រើន

ធាក ដល់មកក្រោយ ទើបខ្ញុំសរសេររឿងប្រលោមលោក និងរឿងកំសាន្តចិត្តខ្លះ ៗ ជាច្រើន ។

បានជាខ្ញុំចាប់សរសេររឿងមុន ដោយខ្ញុំជាអ្នកនាំសិស្សហាត់លេងរឿងកាលពិធីចែករង្វាន់ ឬ បុណ្យផ្កា បុណ្យកឋិន ។

លើកបំណោះរឿងល្ខោន ដែលជារឿងវែងហើយល្អផងនោះគឺ :

១- រឿងសេនាក្លាហាន

២- រឿងរត់ចំពា

៣- រឿងកេរ្តិ៍មរតក

៤- រឿងសុបិននិមិត្ត

៥- រឿងព្រះរាជសម្ភារ

៦- រឿងវីរសកប្តី

៧- រឿងស្រីសុភាព

៨- រឿងជាងឈើប្រាជ្ញព្រោក ។

រឿងក្រោយនេះ បានទទួលរង្វាន់ក្នុងការប្រឡងអក្សរសាស្ត្រ អំពីដៃឯ.ឧ. ហ៊ុយ - កន្ធុល នៅទីព្រះនាំងភោជនីយ ចំពោះព្រះភក្ត្រព្រះករុណាព្រះបាទសម្តេច ព្រះនរោត្តម សីហនុ ។

ឯរឿងប្រលោមលោក បើរឿងដែលល្អ ១ គឺ :

១- រឿងសាវកការណ

២- រឿងស្រីប្ដូរផ្ដោះ

៣- រឿងផិតក្បត់

៤- រឿងគូព្រេងគូកម្ម

៥- រឿងអ្នកជាប់ពោទទៅជាគ

៦- រឿងផ្កាកែផ្កាកេយ

រឿងក្រោយនេះបានទទួលរង្វាន់ ក្នុងការប្រឡងអក្សរសាស្ត្រ អំពី ថ្ងៃ ៦.១. មាស - ណាល់ នៅមន្ទីរមហោស្រពក្រុង ចំពោះព្រះភក្ត្រ ព្រះបាទសម្ដេច ព្រះនរោត្តមសីហនុ និងចំពោះមុខលោក ឡរស៊ើ- ដង់តស៊ុយប៉េរយ៉េរ ។

បើត្រឡប់មកនិយាយអំពីចំណោះខាងវិចិត្រសិល្បៈវិញ កាលលោក ដេស្បាងាំងធ្វើជានាយកក្រសួងឃោសនាការ លោក គិម - ហាក់ ធ្វើ ជាកម្មនៅក្នុងក្រសួងនេះ មានបង្គាប់ទៅសាលាទស្សហកម្ម, សាលា របនា, ក្រសួងសុរិយោដី និងក្រសួងសាធារណការ ឲ្យរៀបតុបតែង ទូកញ្ចក់ ៣ ក្នុង ១ ក្រសួង ឲ្យគូរដាក់តពណ៌លើការស្ដើង ឬក្រដាស ក្រាស់ហើយកាត់ដាក់បញ្ឈរ ធ្វើជាទេសភាព ឲ្យមើលឃើញមុខក្រោយ ឆ្ងាយជិត គឺ « ឌីយ៉ូរ៉ាម៉ា » ធ្វើយ៉ាងម៉េចឲ្យបានគេឃើញតាមគោល បីគឺ :

១– ស្រុកខ្មែរពីដើមយ៉ាងម៉េច

២– ស្រុកខ្មែរបច្ចុប្បន្នយ៉ាងម៉េច

៣– ស្រុកខ្មែរអនាគតយ៉ាងណាទៅ ។

គេឲ្យធ្វើប្រឡងគ្នាយករង្វាន់ កាលនោះសាលាឧស្សាហកម្ម ដែលមានខ្ញុំជាអ្នកធ្វើតាមគោលការណ៍បីគឺ កាំបូតដូហ្វ្រើ, កាំបូតឌីយេរ, កាំបូតអឺម៉ាំង នោះបានទទួលរង្វាន់លេខ ១ ។

ម្យ៉ាងទៀត មានការប្រឡងគំនូរសំណាកប្រកាសផ្សាយដំណឹង អំពីពិព័រណ៍ ដែលនឹងមានតាំងនៅក្នុងព្រះកែវមរកត ។ កាលនោះ គេឲ្យរង្វាន់លេខ ១ ទៅសាលាចេនា, លេខ ២ ឲ្យមកខ្ញុំ តែដល់បានជាប្រកាសយកទៅបិទតាមពេញក្នុងក្រុងនិងខេត្តក្រៅ ទៅជាឃើញរូបគំនូរសំណាករបស់ខ្ញុំទៅវិញ ឯគំនូរសាលាចេនាដែលបានរង្វាន់លេខ ១ មិនឃើញ ដល់សើបសួរទៅលេចឮពាក្យថា មេប្រយោគយល់ដល់ពួកសាលាចេនា ក៏ឲ្យរង្វាន់លេខ ១ ទៅ ដល់យកគំនូរលេខ ១ ទៅឲ្យគេផ្ដិតពុម្ព គេធ្វើពុម្ពបោះ គេថាពាសពីពណ៌គ្មានរបៀបល្អធ្វើពុម្ពបាន គេចោលទៅ គេយករបស់ខ្ញុំដែលបានលេខ ២ មកធ្វើវិញ ដោយមានរបៀបរៀបពណ៌ល្អ ។

(នៅមានត)

អត្ថបទផ្នែកទំនៀមទម្លាប់

# ចូលឆ្នាំថ្មី

អ្នកស្រី ពេជ-សល់ រៀបរៀង

ខ្មែរនិយមចូលឆ្នាំថ្មីនៅក្នុងខែចេត្រ ដែលជាខែទី ៥ នៃប្រក្រតិទិនខ្មែរ ប៉ុន្តែគេនៅតែរាប់ខែមិគសិរ ជាខែទី ១ ដដែល ។ ការកំណត់ថ្ងៃ-ខែ ចូលឆ្នាំថ្មីនេះ កាលដើមឡើយ ព្រោះលោកបណ្ឌិតអ្នកប្រទេសទាំងឡាយក្នុងជម្ពូទ្វីប លោកកំណត់យកខែមិគសិរជាដើមឆ្នាំ ដោយហេតុក្នុងសម័យព្រេងនាយ លោកប្រើរដូវ ៣ តាមចន្ទគតិ ដោយច្រើនគឺ:

- ហេមន្តរដូវ ( រដូវត្រជាក់ )
- គិម្ហរដូវ ( រដូវក្តៅ )
- វស្សានរដូវ ( រដូវភ្លៀង )

រដូវត្រជាក់ ឬ ហេមន្តរដូវ លោកទុកជារដូវដើមឆ្នាំ ប្រៀបដូចជាវេលាព្រឹក ចាត់ទុកជាដើមថ្ងៃ ដែលមានអាកាសធាតុត្រជាក់ គួរជាទីពេញចិត្តនៃមនុស្សសត្វទូទៅ ។

រដូវក្តៅ លោកទុកជារដូវកណ្តាលឆ្នាំ ប្រៀបដូចជាវេលាថ្ងៃត្រង់ ដែលព្រះអាទិត្យបញ្ចេញចំហាយយ៉ាងខ្លាំង ។

រដូវភ្លៀងផ្គរ ប្រកបដោយអាកាសងងឹតស្រអាប់ លោកទុកជាវេលាចុងថ្ងៃ ប្រៀបដូចជាវេលាទៀបចូលរាត្រី ។

អាស្រ័យហេតុនេះ ទើបចាស់ព្រឹទ្ធាចារ្យ លោកកំណត់យកខែមិគសិរ ជាខែចូលឆ្នាំ ។

ឯការកំណត់ចូលឆ្នាំ ក្នុងខែមិគសិរនោះ មកអំពីជំនាន់ដើម គឺពីត្រឹមសម័យក្រុងនគរធំឡើងទៅ ប្រទេសកម្ពុជាយើង រាប់អានប្រើចន្ទគតិជាសំខាន់ ៗ ប៉ុន្តែអ្នកប្រាជ្ញជាន់មុន បានធ្វើសេចក្តីកត់សំគាល់ថា ចន្ទគតិ គឺដំណើរនៃព្រះចន្ទនោះ គឺកំណត់តាមហោរាសាស្ត្រ ដែលព្រះចន្ទត្រូវដើរមួយជុំពិភពលោកម្តង ។ ដើម្បីធ្វើដំណើរឲ្យបាន ១ ជុំពិភពលោកនេះ ព្រះចន្ទត្រូវចំណាយពេលអស់ ២៩ ថ្ងៃកន្លះជាងបន្តិច ដែលហៅថា ១ ខែ ហើយ ១២ ខែ បានជា ១ ឆ្នាំ ។ ប៉ុន្តែប្រសិនបើយើងនិយមប្រើតាមចន្ទគតិតែម្យ៉ាង លុះច្រើនពាន់ឆ្នាំទៅខាងមុខ យើងនឹងឃើញថា រដូវតាមចន្ទគតិ នឹងមិនទៀងទាត់តាមធម្មតាឡើយ គឺថា រដូវរងានឹងក្លាយទៅជារដូវក្តៅ ។ ក្លាយទៅជារដូវភ្លៀង ព្រោះគោលនៃរដូវទាំងឡាយ ដែលជាគ្រឿងសំគាល់ធម្មជាតិ ដូចជា រដូវឈើផ្កា ផ្លែ ភ្លៀង ខ្យល់ ជាដើម សុទ្ធតែត្រូវតាមសុរិយគតិទាំងអស់ ។ ដើម្បីចៀសវាងនូវការប្រែប្រួលដូចនេះហើយ ទើបនៅពេលដែលមនុស្សយើងមានសេចក្តីចេះដឹងវិសេសឡើង ក៏គិតប្រើរដូវតាមសុរិយគតិ អែបជាមួយនឹងចន្ទគតិផង នឹងប្រើសុរិយគតិសុទ្ធតែម្យ៉ាងក៏ពុំបាន ព្រោះក្នុងគោតមពុទ្ធកាលនេះ មានពិធីកិច្ចផ្សេង ៗ ក្នុងសាសនាច្រើនណាស់

ដែលទាក់ទងនឹងចន្ទគតិ ទើបគេនិយមប្រើអែបគ្នាយ៉ាងនេះ ហើយបើកាលណាព្រះចន្ទនិងព្រះអាទិត្យដើរឃ្លាតឆ្ងាយអំពីគ្នា ល្មមគប់បានជា ១ ខែហើយ ទើបគេគិតលើកអធិកមាសម្តង ដើម្បីឲ្យទាន់គ្នាវិញ (តាមទម្លាប់ ៤ ឆ្នាំ មានអធិកមាសម្តង) ។

ទើបតែជាខាងក្រោយ គឺក្រោយពីពេលដែលផ្តើមប្រើចុល្លសករាជមកនេះទេ ដែលខ្មែរយើងត្រឡប់ប្រើសុរិយគតិជាសំខាន់ ហើយកំណត់ចូលឆ្នាំក្នុងខែចេត្រ ដែលជាខែទី ៥ ជាប់រហូតមកដល់សព្វថ្ងៃនេះ ។ ប៉ុន្តែទោះជាមានលើកអធិកមាសឲ្យទាន់គ្នាយ៉ាងនេះក៏ដោយ ក៏ថ្ងៃចូលឆ្នាំខ្មែរ នៅតែពុំបានទៀងទាត់ដូចខាងអឺរ៉ុបដែរ ព្រោះជួនត្រូវខាងដើម ជួនត្រូវខាងចុង គ្រាន់តែមានកំណត់ទុកថា សង្ក្រាន្តនឹងមានក្នុងរវាង ១ ខែ គឺ ក្នុងរវាងពីថ្ងៃ ៤ កើតខែចេត្រ ទៅថ្ងៃ ៤ កើតខែពិសាខ ប៉ុណ្ណោះ ។ ដូច្នេះ ទើបយើងបានសំគាល់ឃើញថា នៅឆ្នាំខ្លះ ការកំណត់ពេលចូលឆ្នាំ ត្រូវធ្លាក់ទៅដល់ទៅខែពិសាខក៏មាន(១) ។

តាមសេចក្តីអធិប្បាយដូចខាងលើនេះ ឃើញថា ការដែលយើងធ្លាប់បានឮចាស់ទុំ លោកនិយាយថា ខ្មែរយើងសម័យបុរាណ គេនាំគ្នាធ្វើបុណ្យក្តី លេងល្បែងក្តី អស់ពេលពេញ ១ ខែចេត្រនោះ ជាការពិតណាស់ ព្រោះរយៈពេល ១ ខែចេត្រនេះ គេទុកជារដូវចូលឆ្នាំទាំងមូល មិនកំណត់យកតែថ្ងៃណាមួយ ដូចសព្វថ្ងៃនេះទេ ។

---

១– ឆ្នាំមមែនព្វស័ក ព.ស. ២៤៧០, ចូលឆ្នាំដល់ទៅ ៦ កើតខែពិសាខ ។

ក្នុងប្រទេសកម្ពុជាយើងសព្វថ្ងៃនេះ នៅតំបន់ខ្លះ ដូចជាជាំខ្សាន ប៉ៃលិនជាដើម មានទំនៀមមួយប្លែកអំពីតំបន់ឯទៀត ដែលគេតែងប្រារព្ធលេង នៅពេលចូលឆ្នាំខ្មែរ ក្រៅអំពីទំនៀមធ្វើបុណ្យជាកុសលចំពោះព្រះសង្ឃ ។

តាមសេចក្តីរៀបរាប់របស់លោក មាស - ហាំ និង លោក ប៊ុន ប៉ូរ ដែលធ្លាប់បានធ្វើកិច្ចការនៅតំបន់ជាំខ្សាននេះថា : ១៥ ថ្ងៃជាខាងក្រោយ គឺគិតអំពីថ្ងៃចូលឆ្នាំទៅ អ្នកស្រុកទាំងប្រុសទាំងស្រី ទាំងក្មេងទាំងចាស់ នាំគ្នាយកទឹកអប់ ផ្កាភ្ញី ទៅកាន់ទីវត្តអារាម ដើម្បីទៅធ្វើពិធីស្រង់ជម្រះព្រះពុទ្ធរូបនៅក្នុងព្រះវិហារ ដែលធូលីកាន់អស់ពេល ១ ឆ្នាំទៅហើយនោះ និងដើម្បីសុំសេចក្តីសុខសប្បាយអំពីកិច្ចនោះផង ។

ពេលត្រឡប់មកផ្ទះវិញ ពួកកំលោះនាំគ្នាតាមស្រោចទឹកក្រមុំ គឺគេលេងចាក់ទឹកលើគ្នាទៅវិញទៅមក ឥតប្រកាន់ជាស្រី ជាប្រុសឡើយ ។ ល្បែងស្រោចទឹកដែលអ្នកស្រុក ក្នុងតំបន់ជាំខ្សាន ទាំងប្រុសទាំងស្រីលេងនោះ ហាក់ដូចជាសប្បាយណាស់ ។ នៅពេលដែលគេនិយមលេងនោះ ពួកកំលោះនាំគ្នារែកទឹកនឹងគ្រុះ សំដៅទៅផ្ទះណាដែលមានកូនក្រមុំ បានដល់ហើយ ដណ្តឹងសួរឪពុកម្តាយគេថា " លោកពូ-អ៊ី នាងឈ្មោះ... (ឧ. ឈ្មោះនាង សាគំ) ទៅណាហើយ ? " ជួនកាលឪពុកម្តាយនាងក្រមុំនោះ កុហកថា " មិននៅទេ ទៅលេងឯនោះ

ហើយ ” តែទោះជាគ្រូគេឆ្លើយយ៉ាងនេះក៏ដោយ ក៏ពួកកំឡោះនោះនាំគ្នាឡើងទៅរើករកទាល់តែឃើញ ហើយនាំគ្នាយកទឹកជះ ទោះជាទឹកខ្ទាតទៅទទឹកអីវ៉ាន់ ឬមនុស្សដទៃទៀត ក៏ឥតគិតឡើយ ។ ជួនកាលពួកកំឡោះដែលរកទឹក ដើរទៅរកស្រោចគេនោះ ប្រទះនឹងក្រមុំដែលមានកិច្ចការ កំពុងធ្វើដំណើរតាមផ្លូវ ក៏ជះទឹកទៅលើទាល់តែទទឹកអស់ តែគេឥតមានប្រកាន់ខឹងអ្វីឡើយ ។

រឿងល្បែងបែបនេះ មិនមែនមានតែស្រី ។ ទេ ដែលទទួលអភ័ព្វ, គឺពួកស្រី ។ ក៏គេចេះដែរ គេនាំគ្នាដំចាំមើល ឲ្យតែពួកកំឡោះបែកហ្វូង ឬដើរគ្នាតិចហើយស្លៀកពាក់ល្អ ។ គេនាំគ្នាព្រួតចាប់ផ្ដួល ដងទឹកចាក់ចូលច្រមុះ ចូលត្រចៀក ទាល់តែសំពះអង្វរសុំចាញ់ ទើបគេឈប់ ។ ល្បែងចាក់ទឹកនេះ មិនមែនលេងត្រឹមតែអ្នកធ្លាប់ស្គាល់គ្នាប៉ុណ្ណោះទេ សូម្បីអ្នកមិនធ្លាប់ស្គាល់ ក៏លេងបាន ឲ្យតែចូលទៅដល់ក្នុងស្រុកគេ ។

តាមសេចក្ដីឲ្យការណ៍ របស់លោក ហង់ - សំហឿនថា បុណ្យចូលឆ្នាំថ្មីនៅប៉ៃលិន ក៏សប្បាយណាស់ដែរ, សប្បាយទាំងរូបលោកទាំងភ្ញៀវទេសចរពីក្រៅទាំងឡាយ ដោយគេលេងចាក់ទឹកគ្នា ដូចជានៅឯជាំក្សាន្តដែរ ។

កាលពីដើមឡើយ នៅផ្ទះកូខ្សាទីមួយ ។ គេតែងរៀបទឹកអប់ និង

គ្រឿងក្រអូបផ្សេង ៗ សម្រាប់បុណ្យចូលឆ្នាំ កាលបើមានភ្ញៀវចូលទៅ អ្នកផ្ទះយកគ្រឿងក្រអូបនោះទៅប្រោះព្រំលើខ្លួនភ្ញៀវ ប្រសិទ្ធិពរឲ្យមានជោគជ័យ សេចក្ដីសុខ សេចក្ដីចំរើនគ្រប់ប្រការ តែលុះដល់ក្រោយមក ទំនៀមនេះ ក៏ក្លាយទៅជាទំនៀមបាចទឹកដាក់គ្នាទៅវិញ គឺនៅមុខផ្ទះម្នាក់ ៗ សុទ្ធតែមានផ្ដិល ឬធុងទឹក ឲ្យតែអ្នកណាដើរកាត់មុខផ្ទះគេ មិនថា ស្រី - ប្រុស ឬកូនលោកណាទេ ទោះជាអ្នកណាក៏ដោយ បើស្លៀកពាក់ល្អ ៗ ផង គេរឹតតែចូលចិត្តលេងណាស់ទៅទៀត កំលោះដេញសាចទឹកលើក្រមុំ ក្រមុំដេញសាចទឹកលើកំលោះ បើក្រមុំណារត់ចូលផ្ទះ គេដេញសាចទឹកតាល់តែដល់ផ្ទះ សាចទឹកលើបានហើយ ទើបឈប់ ៗ ពុំឃើញមានលេងល្បែងអ្វីក្រៅពីល្បែងនេះទេ ។

ចាស់ទុំនិងក្មេងខ្លះ នាំគ្នាឡើងទៅលើភ្នំយ៉ាត ដើម្បីជម្រះចិត្តអកុសលចោល ហើយតម្រង់ចិត្តឲ្យបានល្អក្នុងឆ្នាំថ្មីតទៅ អ្នកខ្លះទៀត គេដើរទៅសំពះចាស់ទុំ ដើម្បីសុំពរឲ្យបានសេចក្ដីសុខ សេចក្ដីចំរើន និងប្រកបការងារឲ្យបានសម្រេចគ្រប់ប្រការ ។

នៅថ្ងៃបង្ហើយបុណ្យចូលឆ្នាំ គេនាំគ្នាទៅកាន់ទីវត្តទាំងប្រុសទាំងស្រី មានទាំងទឹកអប់ជាប់គ្រប់ដៃទៅផង ដើម្បីទៅធ្វើពិធីស្រង់ព្រះដូចនៅខេត្តនានាដែរ ៗ នៅពេលនោះ គេលេងល្បែងចាក់ទឹកធំណាស់

គេស្រង់ទាំងព្រះពុទ្ធរូប ទាំងចាក់ស្រោចគ្នាទៅវិញទៅមក ទាល់តែទទឹកស្រឡាបគ្រប់គ្នាគ្មានសល់ ទៅជាប្រឡកប៉ូកប៉ាកពេញទាំងវត្ត ៗ ពួកគេនិយាយថា មានស្រី ៗ ខ្លះ លាយទឹកល័ក្តបន្ទំ ដើម្បីចាក់លើប្រុស ៗ ដែលមានសំលៀកបំពាក់សផង ហើយនាំគ្នាហ៊ោកញ្ជៀវគ្រហឹមអឺងអាប់ គួរសប្បាយពេកណាស់ ។

---

# ផ្នែកកំណត់និងប្រវត្តិការណ៍

## សេចក្ដីរាយការណ៍

អំពីសកម្មភាព នៃពុទ្ធសាសនបណ្ឌិត្យ

ក្នុងត្រីមាសទី ៤ ឆ្នាំ ១៩៦៦

សេចក្ដីរាយការណ៍នេះ គឺធ្វើបន្ទាប់ពីសេចក្ដីរាយការណ៍ ៣ ត្រីមាសមុន ដែលបានធ្វើកាលពីថ្ងៃទី ៣០ កញ្ញា ១៩៦៦ (ផ្ញើជូនទៅក្រសួងធម្មការ តាមដីកាអម លេខ ១.៦៤០ ព.ប. ចុះថ្ងៃ ៣-១០-៦៦) ហើយដែលបានចុះក្នុងកម្ពុជសុរិយាលេខ ១-២ ឆ្នាំ ១៩៦៧ ។

១- ផ្នែករដ្ឋបាល :

ទោះបីខ្វះបុគ្គលិកមានសមត្ថភាពជាចាំបាច់គឺ : -អគ្គលេខាធិការរង ១ រូប, -នាយការិយាល័យរបៀប និង បុគ្គលិក ១ រូប, -នាយការិយាល័យនៃការផ្សាយ ១ រូប, ក៏វិជ្ជាឋានបានចាត់ចែងការ មានរបៀបរៀបរយចម្រើន ដោយការខិតខំទូកម៉ាំង របស់បុគ្គលិកទទួលកិច្ចការបណ្ដោះអាសន្ន គ្រប់ៗគ្នា ក្នុងក្រសួងនេះ ។

## សេចក្ដីស្នើសុំ:

វិជ្ជាឋានសុំទូលចំពោះក្រសួងធម្មការ សូមមេត្តា ៖

ក- ជួយរំលឹកចំពោះការសុំបុគ្គលិក (ពិសេសមានសហជីវិន លាង-ហ៊ីបអាន) គ្រូបង្រៀននៅសាលា អ៊ុង-ម៉េងគីក ជាដើម ដែល

ក្រសួងអប់រំជាតិ ទើបនឹងតបថា យល់ព្រមផ្តល់មកឲ្យតាមសុំនៅដំណាច់ឆ្នាំសិក្សា ១៩៦៦-៦៧ នេះ តាមលិខិតលេខ ៤៨២២ ប.ព. ចុះថ្ងៃ ២៦-១២-៦៦ ចម្លងផ្ញើរបស់ក្រសួងធម្មការ លេខ ៩-ប ចុះថ្ងៃ ៣-១-៦៧ ។

១- ចាត់ចែងយ៉ាងណាឲ្យបានកម្មករថែម ដើម្បីបំពេញការងារសំអាតអគារទាំងមូល ទីបរិវេណក្រសួងហូតដល់បរិវេណខាងមុខពុទ្ធិកវិទ្យាល័យព្រះសុរាម្រិតផង ។

សូមជម្រាបថា កម្មករ ទិន កាប៉ូពល់កៃ ៣ នាក់របស់វិជ្ជាឋាន គឺសព្វថ្ងៃ ត្រូវទទួលខុសត្រូវគ្រប់បែបយ៉ាង ខាងការសំអាតអគារក្រសួងធម្មការ វិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ ទីបរិវេណទាំងអស់ នៃក្រសួងធម្មការ ព្រមទាំងពុទ្ធិកវិទ្យាល័យថែមទៀត ។

២- ផ្នែករៀបចំសម្ភារៈ

វិជ្ជាឋាន បានចាត់ឲ្យធ្វើផ្លាកសញ្ញាថ្មី កែពី "អគ្គលេខាធិការដ្ឋាន" មកជា "នាយកដ្ឋាន" នៃពុទ្ធសាសនបណ្ឌិត្យវិញ; ធ្វើសញ្ញាផ្លាកឈ្មោះបុគ្គលិកទៅតាមមុខនាទីរបស់ខ្លួន សម្រាប់ដាក់នៅលើការិយាល័យម្នាក់ៗ; ធ្វើសួនច្បារ នៅមុខពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត បានសមសួនក្នុងពេលអនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃលើកទី ២៣; រៀបចំទីកន្លែងខាងត្បូងអគារ ដោយរៀបថ្មអន្ទ័យជុំវិញដើមអំពិលឲ្យបានស្អាតទូលាយ ដល់រថយន្តចតបានដោយស្រួល ។

# សេចក្ដីស្នើសុំ

ដើម្បីការពាររថយន្តពជការ កុំឲ្យត្រូវថ្ងៃ, ភ្លៀង, ខ្យល់, ខូចខាត, រឺផ្លាហានសុំក្រសួងធម្មការរៀបយ៉ាងណា សង់រោងមួយនៅខាងលិចអគារ គឺខាងកើតនៃអគារពុទ្ធិកវិទ្យាល័យ ដើម្បីធ្វើជាចំណតរថយន្ត (យើងមានហ្វីប្រស៊ីម៉ង់ ហើយទីងឈើខ្លះដែលជារោងរថយន្តចាស់នៅខាងត្បូងអគារពុទ្ធិកវិទ្យាល័យ) ។

## ៣– ផ្នែកចំណូល–ចំណាយ

## ក– ផ្នែកចំណាយ

ទី ១– ចំណាយខាងទឹក: គិតត្រឹមត្រីមាសទី ៣ ។ ឯត្រីមាសទី ៤ ផ្លាករទឹកពុំទាន់ទារថ្ងៃនៅឡើយទេ ។

### តារាងប្រៀបធៀប

ឆ្នាំកន្លងទៅ

| ត្រីមាស | ឆ្នាំ ១៩៦៥ | ឆ្នាំ ១៩៦៦ |
|---|---|---|
| ត្រីមាសទី ១ | ៧៥៧ ៛ ៦៥ | ៤១៩ ៛ ៨៥ |
| ត្រីមាសទី ២ | ៨០៥ ៛ ៥០ | ៤៣០ ៛ ៣៥ |
| ត្រីមាសទី ៣ | ២២៤ ៛ ៤០ | ១៩៨ ៛ ០០ |
| បូករួម . . . . | ១.៧៨៧ ៛ ៥៥ | ១.០៤៨ ៛ ២០ |

បញ្ជាក់: ក្នុងឆ្នាំនេះចំណាយថយជាងឆ្នាំទៅចំនួន ៧៣៩ ៛ ៣៥ ។ ការចំណេញបែបនេះមកពីបានសំចៃ ហើយមានភ្លៀងបរិបូណ៌ មិនសូវ

ប្រើប្រាស់ស្រោចស្រពជាតិទឹកផ្កាកូនស្ពួនបារាំងឡើយ ។

ទី ២- ចំណាយខាងក្លើង : ( គិតត្រឹមខែវិច្ឆិកា ) ។ ឯខែធ្នូ ពុំទាន់គាំវីជូនៅឡើយទេ ។

## តារាងប្រៀបធៀប

ឆ្នាំកន្លងទៅ

| ខែ | ឆ្នាំ ១៩៦៥ | ឆ្នាំ ១៩៦៦ |
|---|---|---|
| មករា | ៣៧២,០០ | ៦៣៩,០០ |
| កុម្ភៈ | ៧២៣,០០ | ៥៦៨,០០ |
| មីនា | ៤០៥,០០ | ៩៧៦,០០ |
| មេសា | ៧៧៤,០០ | ៩៧៩,០០ |
| ឧសភា | ១០១៤,០០ | ៧៧៩,០០ |
| មិថុនា | ១១២៣,០០ | ១១៦៩,០០ |
| កក្កដា | ៨៣២,០០ | ៦៤៦,០០ |
| សីហា | ១០៤៣,០០ | ៧៣២,០០ |
| កញ្ញា | ៧៦១,០០ | ១៤៨៣,០០ |
| តុលា | ៨៥៤,០០ | ១៣០០,០០ |
| វិច្ឆិកា | ៨៤៧,០០ | ១៥០៥,០០ |
| ធ្នូ | ៨៩៩,០០ | ២០៨៩,០០ |
| បូករួម | ៩.៦៥៥,០០ | ១៣.៨៥៩,០០ |

បញ្ជាក់: ក្នុងឆ្នាំនេះ ចំណាយប្រេងដាំងឆ្នាំទៅ ចំនួន ៤ ២០៤រ០០ ។ ការចាយប្រេងដាំងបន្តិចនេះ បណ្ដាលមកពីមានការបើកបំភ្លឺពេលយប់ ក្នុងទស្សនកិច្ចរបស់ភ្ញៀវជាតិ មាន ឯ.ឧ. ប្រធានាធិបតីបារាំង និងក្នុងពេលបុណ្យ ព្រមទាំងការប្រើ ទូទឹកកក និងម៉ាស៊ីនត្រជាក់ខាងធម្មការផង ។

សេចក្ដីសង្កេត: ចំណាយទឹកភ្លើងនេះ គឺពុំទាស់សាសនបណ្ណិត្យ ចេញសងសរុបចំពោះក្រសួងធម្មការទាំងមូលផង ពីព្រោះកុងទ័រទឹកភ្លើង ជាកម្មសិទ្ធិរបស់វិជ្ជាឋាន ដែលជាអ្នកទទួលបន្ទុកចាយរាយប្រាក់គ្រោង ចំណាយម្នាក់ឯង តាំងអំពីដើមរៀងដរាបមក ។

យោបល់រួម: បើគិតទៅនឹងប្រាក់គ្រោងចំណាយ របស់ក្រសួង ដែលមាន ២០.០០០រ០០ មួយឆ្នាំ ( ទោះបីថ្លៃទឹក ត្រីមាសទី ៤ និងថ្លៃភ្លើងខែធ្នូមិនទាន់គិតនៅឡើយក្ដី ) យើងនឹងទុកសំចៃសល់ប្រាក់ថវិកា គ្មានការខ្វះខាតអស់ប្រាក់គ្រោងឡើយ ( គឺសល់ប្រាក់គ្រោង ២០.០០០រ − ១៤.៩០៧ រ ២០ = ៥. ០៩២ រ ៨០ )

## ១_ ផ្នែកបំណុល

សូមបញ្ជាក់ថា បំណុលក្នុង ៣ ត្រីមាសមុនមាន: ១.៤២៨.២៤៣រ៨១ ដែលបានមកពីលក់សៀវភៅនានា ។

មកទល់ថ្ងៃទី ៣១ ធ្នូ ១៩៦៦ នេះ ចំណូលសរុបឡើងដល់ ១.៨២៣.៣៨៤៛១១ ។

បញ្ជាក់ : បើប្រៀបធៀបទៅនឹងចំណូលឆ្នាំ ១៩៦៥ ដែលមានដល់ទៅ ២.៤៤៤.២៧៤៛៦១ យើងឃើញថាឆ្នាំ ១៩៦៦ នេះ ចំណូលថយបន្តិច ។

ការថយចំណូលនេះ ហេតុទី ១ បណ្តាលមកអំពីក្រសួងធម្មការបានដកសៀវភៅ ១៦ មុខ របស់ធម្មសម្បត្តិចេញអំពីវិជ្ជាឋាននេះ ។ ហេតុទី ២ ថវិកាឆ្នាំទៅ គ្រាន់បោះសៀវភៅខ្វះៗ ពុំបានគ្រប់ចំនួនត្រូវការរបស់សាធារណជន ។ ហេតុទី ៣ គឺសៀវភៅបីមុខរបស់ពុទ្ធិកវិទ្យាល័យ ត្រូវបោះពុម្ពផ្សាយ ទាំងអស់មាន ២៤ មុខ ( បោះពុំទាន់ហើយគឺ កច្ចាយនរូបត្ថម្ភ ភាគ ១ និងធម្មបទដ្ឋកថា ភាគ ១ និង ២ ) ។ ហេតុទី ៤ គឺ មកពីបណ្ណាគារគ្រៅ បានលួចបម្លងយកសេចក្តីរៀងក្នុងសៀវភៅធម៌ជាដើមរបស់ក្រសួង ទៅបោះពុម្ពលក់ថោកដេញជើងក្រសួង, ប៉ុន្តែឥឡូវ យើងបានសម្រេចបង្គាប់ឲ្យប្រមូលដកហូត នូវសៀវភៅក្លែងបន្លំទាំងនេះហើយ ។ ហេតុទី ៥ មកពីយើងឲ្យកម្រៃភាគរយតិចពេក តែត្រឹម ១០ ភាគរយ ដល់ឈ្មួញជាវដុំយកទៅលក់គ្រៅ ( វិជ្ជាឋាន រង់ចាំតែព្រះរាជក្រឹត្យរៀបចំក្រសួង ដែលសព្វថ្ងៃនៅគណៈរដ្ឋមន្ត្រី ពុំទាន់ជំនុំអនុម័តនៅឡើយ នោះទើបសម្រួលច្បាប់

ចុះកម្រៃឲ្យបានសមសួនដល់ឈ្មួញខ្លះ ដើម្បីជាមធ្យោបាយជួយឲ្យសៀវ-ភៅយើងដាច់ច្រើន ) ។

**យោបល់** : ប៉ុន្តែចំណូលដែលចុះប៉ុណ្ណោះ ក៏គង់តែឃើញថា បើប្រៀបធៀបទៅនឹងគ្រោងថវិកា សម្រាប់បោះពុម្ពផ្សាយក្នុងឆ្នាំ ១៩៦៦ ចំនួនប្រាក់ ១.៨០០.០០០៛០០ នោះ វិជ្ជាហាន បានប្រើកេកម្រៃចំណេញជូនថវិកាជាតិចំនួន ៤៧.៣៨៤៛១១ ដែរ ។ គឺថាយើងគ្មានខាត បើប្រៀបធៀបទៅនឹងឆ្នាំមុន គឺឆ្នាំ ១៩៦៤ ចុះទៅ ។

**សេចក្ដីស្នើសុំ**: វិជ្ជាហាន ចង់សុំក្រសួងធម្មការ ឲ្យផ្ដល់សៀវភៅ ៤៤ មុខ ខាងពុទ្ធិកវិទ្យាល័យ មកឲ្យវិជ្ជាហានផ្ដាច់ ចាត់ចែងបោះដោយថវិកាខាងវិជ្ជាហានតែម្ដង ដើម្បីងាយស្រួលក្នុងកិច្ចការទទួលខុសត្រូវផង ។

សូមបញ្ជាក់ថាពីមុន ពុទ្ធិកវិទ្យាល័យ ឬក្រសួងធម្មការ គ្រោងថវិកាបោះពុម្ពសៀវភៅ ៤៤ មុខដែលសុំនេះ ដោយគ្មានសួរវិជ្ជាហានថា បោះប៉ុន្មាន ៗ ក្បាលទេ ។ លុះបោះហើយ ស្រាប់តែប្រគល់ចំនួនសៀវភៅ មកឲ្យវិជ្ជាហានដាក់ឃ្លាំង ហើយលក់យកប្រាក់ដាក់ថវិកាវិញ ។ លំបាកម្យ៉ាងទៀតគឺ កាលណាពុទ្ធិកវិទ្យាល័យ សុំធម្មការបោះពុម្ព គឺពុំមានសួរគណៈកម្មការអ្នកប្រាជ្ញ ( មានគណៈកម្មការព្រះត្រៃបិដកជាដើម) ទេ ហើយលុះបោះរួចទៅមានខុស ឧទាហរណ៍

ដូចជាសៀវភៅភិក្ខុបាតិមោក្ខ ដែលសម្តេចព្រះសង្ឃរាជផ្ញើមក ប្រាប់ថាខុសពេញពាសជាដើម ហើយវិជ្ជាឋាន ដែលគ្រាន់តែទទួលលក់នោះ ត្រូវទទួលទោសទាំងអស់ទៅវិញ ។

៤. ការបោះពុម្ពផ្សាយ

ដូចមានសេចក្តីរាយការណ៍ ចុះថ្ងៃ ៣០-៩ ៦៦ ផ្ញើមកក្រសួងធម្មការស្រាប់ ។

៥- ការធានាគាំទ្រចំពោះអង្គការនានា

ក្រសួងបានសម្រេចផ្ញើព្រះត្រៃបិដកពីភាគ ១ ដល់ ៩០ ( ៩០ ភាគ ) តាមសេចក្តីស្នើសុំរបស់ ឯ.ឧ. ហ៊ុយ-កន្ធុល ឯកអគ្គរាជទូតកម្ពុជាប្រចាំក្រុងម៉ូស្គូ ទៅតំកល់ទុកនៅវត្តមួយ ជាមជ្ឈមណ្ឌលពុទ្ធ-សាសនា នាក្រុងប៊ែរឡាំងខាងលិច ( លិខិតយល់ព្រមផ្តល់តាមសុំផ្ញើទៅធម្មការ លេខ ២០១៨.ពប ចុះថ្ងៃទី ៣១ ១២-៦៦ ) ។

៦- សេចក្តីសន្និដ្ឋាន

វិជ្ជាឋានដែលបានធ្វើកិច្ចការ ដូចរៀបរាប់ក្នុងរបាយការណ៍ពេញ១ឆ្នាំមកនេះ ក៏នៅតែយល់ថា បានលទ្ធផលបន្តិចប៉ុណ្ណោះ ។ នៅឆ្នាំ ១៩៦៧ នេះ វិជ្ជាឋាននឹងខិតខំបន្តសកម្មភាពឲ្យកាន់តែបានចំរើនផុះផាលតទៅទៀត ។

ភ្នំពេញ ថ្ងៃទី ៣១ ធ្នូ ១៩៦៦

នាយកនៃពុទ្ធសាសនបណ្ឌិត្យ

ហត្ថលេខា : ឈាង-ហ៊ាបអាន

# អនុសំវច្ឆរមហាសន្និបាតទី ២៣ នៃមន្ត្រីសង្ឃ

ញ.សឿង រៀបរៀង

ពិធីអនុសំវច្ឆរមហាសន្និបាតទី ២៣ នៃមន្ត្រីសង្ឃ សម្រាប់ឆ្នាំមមី អដ្ឋស័ក ព.ស. ២៥០៩ បានប្រព្រឹត្តទៅ ក្នុងបរិយាកាសដ៏រីករាយយ៉ាងក្រៃលែង ពីថ្ងៃសុក្រ ៤ រោចខែបុស្ស ព.ស. ២៥០៩ (៣០ ធ្នូ ១៩៦៦) ដល់ថ្ងៃពុធ ៩ រោច ខែ-ឆ្នាំដដែល ( ៤ មករា ១៩៦៧ ) នៅពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ( រួមទាំងពីរគណៈ ) ក្រោមព្រះរាជាធិបតី-ភាពដ៏ខ្ពង់ខ្ពស់នៃសម្តេចព្រះប្រមុខរដ្ឋ, នៅវត្តឧណ្ណាលោម ក្រោមព្រះរាជាធិបតីភាពនៃសម្តេចព្រះសង្ឃរាជគណៈមហានិកាយ និងនៅវត្តបទុម-វតី ក្រោមព្រះអធិបតីភាពនៃសម្តេចព្រះសង្ឃនាយក គណៈធម្មយុត្តិក-និកាយ ( តាមកម្មវិធីនៃគណៈទាំងពីរ ) ។

យើងសូមរៀបរាប់សង្ខេប ចំពោះតែពិធីក្នុងថ្ងៃសៅរ៍ ៥ រោច ខែបុស្ស ព.ស. ២៥០៩ ( ៣១-១២-៦៦ ) ដែលជាថ្ងៃប្រជុំធំ រួមព្រះសង្ឃទាំងពីរគណៈ ពេលម៉ោង ៤ កន្លះរសៀល នៅពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ក្រោមព្រះរាជាធិបតីភាពនៃសម្តេចព្រះប្រមុខរដ្ឋ ។ បន្ទាប់ពីព្រះសង្ឃស្វាធ្យាយធម៌ជយន្តោ ថ្វាយព្រះពរជ័យចំពោះសម្តេចនិង ព្រះអគ្គពុទ្ធសាសនូបត្ថម្ភករួចហើយមក, សហជីវិន គុយ-តៅ អនុរដ្ឋលេខា-ធិការក្រសួងធម្មការ បានថ្លែងសុន្ទរកថា រៀបរាប់អំពីសកម្មភាពនៃព្រះ

ពុទ្ធសាសនា, រួចហើយព្រះតេជព្រះគុណ ហោម - ស៊ឹម វិនយធរនៃមេគណខេត្តតាកែវ ជាតំណាងមន្ត្រីសង្ឃទាំងអស់ បានថ្លែងសុន្ទរកថាសង្ខេបមួយទៀត ( សុន្ទរកថាទាំងពីរនេះ យើងនឹងចុះផ្សាយក្នុងទំព័រខាងក្រោយ ) ។

បន្ទាប់ពីនេះ, សម្តេចព្រះប្រមុខរដ្ឋ ទ្រង់បានថ្លែងព្រះសន្ទកថាមួយជាកិច្ចប្រស័យ ចំពោះមន្ត្រីសង្ឃ, ព្រមទាំងព្រះសង្ឃទាំងអស់ ដែលបាននិមន្តមកយ៉ាងច្រើនកុះករណែនណាន់តាន់តាប់ ពាសពេញទីបរិវេណនៃពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ។ ជាដំបូង, ព្រះអង្គទ្រង់មានព្រះបន្ទូលអំពីការចំរើនលូតលាស់ជាអតិបរមា នៃវិស័យពុទ្ធសាសនា និងវិស័យដទៃទៀត ដោយសារព្រះសង្ឃទាំងអស់ មានសាមគ្គីធម៌ជួយដឹកនាំតាំងទ្រយ៉ាងពេញបន្ទុក ស្របទៅតាមគតិការសង្គមរាស្ត្រនិយម ដែលជាលទ្ធិ សង្គមនិយមអាស្រ័យពុទ្ធសាសនា ។ ចំពោះការលូតលាស់នេះ, ទ្រង់មានព្រះបន្ទូលថែមថា : តាមការពិនិត្យសង្កេតរបស់ជនបរទេស ឃើញថា នៅប្រទេសកម្ពុជា វិស័យទាំងឡាយ សឹងបានចំរុងចំរើនលូតលាស់យ៉ាងស្តុកស្តម្ភសម្បើមណាស់ លើកលែងតែសាសនាកាតូលិកចេញ ។ មានកាសែតកាតូលិកមួយបានផ្សាយថា នៅស្រុកឯទៀត ។ គេបានឃើញបណ្តាជនក្រីក្ររហោមរហាម ដើរសុំទានជាហេតុនាំឲ្យជនបរទេសធុញទ្រាន់ណាស់ ចំណែកនៅប្រទេសកម្ពុជា

គ្មានស្ពានគាំពុំនដាប់បែបនោះទេ – ភ្នំពេញជាទីក្រុងមួយស្អាតស្អំសក្តិសមស្រស់បំព្រង គួរឲ្យគោតសរសើរណាស់ ... ។ ចំពោះសាសនាវិញ ខ្មែរជឿកាន់ព្រះពុទ្ធសាសនាយ៉ាងខ្ជាប់ខ្ជួនមុតមាំណាស់, គេមិនអាចនឹងឃោសនាពន្យល់ខ្មែរឲ្យជឿសាសនាដទៃទៀត មានគ្រិស្តសាសនាជាដើម ដោយងាយៗបានទេ – ខ្មែរមិនស្គាល់គ្រិស្តសាសនាថាជាយ៉ាងណាៗទេ – ខ្មែរសំគាល់ថាគ្រិស្តសាសនា គឺជាសាសនារបស់ជនជាតិឥរ៉ុប ... ។ សម្តេចឪ ព្រះអង្គទ្រង់សរសើរហើយសរសើរទៀត ចំពោះសម្តេចព្រះពោធិវង្ស ដែលបានយកព្រះទ័យទុកដាក់យ៉ាងប្រិតប្រៀបជាទីបំផុត ក្នុងការរុះរើ-ស្ថាបនាជាថ្មីឡើងវិញ នូវអគារទាំងឡាយនៃពុទ្ធិកវិទ្យាល័យ, ជាពិសេសទៅទៀត ព្រះអង្គបានបរិណាបច្ច័យចំនួន ហុកសិបម៉ឺនរៀល (៦០០.០០០៛) សម្រាប់បង្ហើយការស្ថាបនានេះ ។

តពីនេះទៀត, សម្តេចឪ ទ្រង់មានព្រះបន្ទូលអំពីនយោបាយក្នុងប្រទេស និងក្រៅប្រទេសនៃកម្ពុជាអព្យាក្រិត យ៉ាងពិស្តារ ដែលគ្រប់ចំណុចទាំងអស់ សុទ្ធតែមានសារៈសំខាន់ ពីរោះក្បោះក្បាយ ព្រះសង្ឃនិងបណ្តាជនទាំងឡាយ បានចាប់អារម្មណ៍ ប្រុងស្តៀងស្តាប់យ៉ាងផ្ចិតផ្ចង់ដក់ជាប់ចិត្តឥតធុញទ្រាន់ ដរាបដល់ចប់ព្រះសន្ទកថានេះ នៅពេលម៉ោង ៧ យប់ ក្នុងបរិយាកាសដ៏សែនរីករាយយ៉ាងក្រៃលែង ។

សូមលោកអ្នកអាន មេត្តាអភ័យទោស ចំពោះការពុំអាចលើកយក ព្រះសង្កថាទាំងស្រុងរបស់សម្តេចនុ មកចុះផ្សាយក្នុងទំព័រនេះបាន ។

ឯសុន្ទរកថារបស់សហជីវិន គុយ-ពៅ និងព្រះវិនយធរ សោម-សឹម តំណាងមន្ត្រីសង្ឃ, យើងសូមចុះផ្សាយដូចតទៅនេះ ៖

## សុន្ទរកថា សហជីវិន គុយ-ពៅ

អនុរដ្ឋលេខាធិការក្រសួងធម្មការនិងសាសនសិក្សាធិការ

សូមព្រះតេជះគុណលើត្បូង

សូមព្រះពរទានក្រាបបង្គំទូល ក្រោមល្អងធូលីព្រះបាទ នៃសម្តេច សហជីវិន ព្រះប្រមុខរដ្ឋ ជាព្រះអគ្គពុទ្ធសាសនូបត្ថម្ភក៍

សូមទ្រង់ជ្រាប ។

នៅក្នុងពិធីអនុសំវច្ឆរមហាសន្និបាត នៃមន្ត្រីសង្ឃលើកទី ២៣ ប្រចាំឆ្នាំមមីអដ្ឋស័ក ព.ស. ២៥០៩ នេះ, ទូលព្រះបង្គំជាខ្ញុំ, ក្នុងនាម នៃក្រសួងធម្មការ និងសាសនសិក្សាធិការ និងក្នុងនាមពុទ្ធបរិស័ទទាំងអស់ ក្នុងប្រទេសកម្ពុជា សូមថ្វាយនូវកំណារព្រះមហាករុណាធិគុណ យ៉ាងរំភើប និងយ៉ាងកក់ក្តៅបំផុត ចំពោះព្រះរាជាធិបតីភាព ដែលល្អងធូលីព្រះបាទ បានទ្រង់សព្វព្រះរាជហឫទ័យ ប្រោសព្រះរាជទានដល់ពិធីសម្ពោធបើក មហាសន្និបាតនៃព្រះសង្ឃ ក្នុងឱកាសដ៏មហោឡារិកនេះ ដែលមាន ប្រជុំរៀងរាល់ឆ្នាំ ដើម្បីពិភាក្សាចំពោះបញ្ហាទៅខាងព្រះពុទ្ធសាសនា ។

## សូមទ្រង់ព្រះមេត្តាប្រោស

អនុសាវរីយ៍មហាសន្និបាតនៃមន្ត្រីសង្ឃនេះ បានកើតឡើងចំនួន ២៣ ឆ្នាំហើយ រាប់តាំងឆ្នាំនេះផង គឺជាលទ្ធផលដ៏វិសេសក្រៃលែងនៃការឧបត្ថម្ភរបស់រាជបល្ល័ង្ក ចំពោះព្រះពុទ្ធសាសនា ដែលជាសាសនាសុខចំរើនបំផុតក្នុងលោក ហើយជាពិសេស គឺសម្តេចជាអម្ចាស់ កាលដែលព្រះអង្គនៅកំពុងគ្រប់គ្រងរាជសម្បត្តិនោះ ទ្រង់បានបង្កបង្កើតឲ្យមានឡើង ។ ដូច្នេះ អាចសន្មតយ៉ាងខ្ញុំបានថា មហាសន្និបាតនៃព្រះសង្ឃនេះ មានអាយុកាល ២៣ ឆ្នាំហើយ ជាបុត្រផ្ទាល់របស់សម្តេចជាអម្ចាស់ ។ មិនតែប៉ុណ្ណោះ, សម្តេចជាអម្ចាស់ទ្រង់តែងស្តេចយាងមកជាព្រះរាជាធិបតីរៀងរាល់ឆ្នាំ រឹងរឹតតែបង្ហាញឲ្យឃើញថា ព្រះអង្គតែងសព្វព្រះរាជហឫទ័យជានិច្ច ចំពោះមហាសន្និបាតនេះ ។ ដូច្នេះហើយ កិច្ចការអ្វីដែលទាក់ទងនឹងព្រះពុទ្ធសាសនាក្តី ទាក់ទងនឹងកិច្ចការរដ្ឋក្តី ព្រះអង្គពុំដែលលាក់លៀមម្តងណាទេ ទ្រង់តែងតែថ្លែងជាឧឡារិក លាតត្រដាងនូវការទាំងអស់នេះ ថ្វាយ-ប្រគេនព្រះសង្ឃនៅក្នុងទីនេះជាដរាប ដូចជាព្រឹត្តិការណ៍ពីរ គឺ :

១- ព្រះអង្គទ្រង់សព្វព្រះរាជហឫទ័យប្រោសព្រះរាជទាន ថ្វាយព្រះឋានន្តរស័ក្តិទីសម្តេចព្រះសង្ឃរាជ ចំពោះសម្តេចព្រះសង្ឃនាយកទាំងពីរព្រះអង្គ ក៏នៅត្រង់កន្លែងនេះ ។

៦– ព្រះអង្គទ្រង់ថ្លែងនៅបញ្ជាក់អំពីគោលនយោបាយខ្មែរ ហេតុព្រះអង្គទ្រង់និពន្ធបានជាសៀវភៅមួយមានចំណងជើងថា នយោបាយសង្គមនិយមព្រះពុទ្ធសាសនានៃប្រទេសកម្ពុជា ក៏ផ្តើមឡើងនៅត្រង់ទីនេះដែរ ។

ហេតុការណ៍ទាំងនេះទៀត បញ្ជាក់ឲ្យឃើញថា ព្រះរាជបល្ល័ង្កខ្មែរ បានទំនុកបំរុងព្រះពុទ្ធសាសនា ជាដរាបរៀងមកជាប់ជាប្រពៃណីតាំងពីបុរាណកាល រហូតមកដល់បច្ចុប្បន្នកាល ក៏រឹងរឹតតែបន្ថែមកម្លាំងឧបត្ថម្ភឲ្យខ្លាំងក្លាឡើងទៀត ដូចជានៅពេលថ្មី ៗ នេះ ល្អងធូលីព្រះបាទ បានកសាងវត្តធំៗ ពីរទៀត គឺវត្តជោតញ្ញាណ ១ ឥន្ទញ្ញាណ ១ នៅក្រុងព្រះសីហនុ ដែលទើបសម្ពោធ ហើយប្រោសព្រះរាជទានដល់ព្រះសង្ឃ និងពុទ្ធសាសនិកជន ធ្វើសក្ការបូជាច្រើនរុងរឿង ជាកិត្យាភាពក្នុងព្រះពុទ្ធសាសនា ។ ដោយសារព្រះរាជហឫទ័យជ្រះថ្លាក្នុងព្រះពុទ្ធ-សាសនានេះ អនុសំវច្ឆរមហាសន្និបាតនៃមន្ត្រីសង្ឃរៀងរាល់ឆ្នាំ ដែលប្រព្រឹត្តទៅក្រោមព្រះរាជាធិបតីភាពនៃសម្តេចព្រះសង្ឃរាជទាំងពីរព្រះអង្គ ព្រះអធិបតីភាពនៃសម្តេចព្រះសង្ឃនាយកនោះ តែងតែបានលទ្ធផលល្អ ពិភាក្សាសម្រេចនូវបញ្ហាធំ តូចផ្សេង ៗ ដែលកើតមានក្នុងរយៈឆ្នាំដែលកន្លងទៅ និង រៀបចំសម្រាប់ឆ្នាំទៅមុខទៀត ។

សូមទ្រង់ព្រះមេត្តាប្រោស

ទូលព្រះបង្គំសូមព្រះរាជទាន ព្រះបរមរាជវរោកាស ដើម្បីក្រាបបង្គំថ្វាយអំពីកិច្ចការខ្លះ ដែលក្រសួងធម្មការបានបំពេញមក ក្នុងរយៈឆ្នាំនេះ :

១- ផ្នែកវិជ្ជាស្ថានស្រាវជ្រាវទំនៀមទម្លាប់ : កិច្ចការខាងការស្រាវជ្រាវទំនៀមទម្លាប់ និងប្រវត្តិផ្សេង ៗ ក៏ប្រមូលបានឯកសារសំខាន់ ៗ ពីគ្រប់ភូមិភាគក្នុងប្រទេសបានកើនចំនួនលើសពីឆ្នាំមុនដែរ ជាហេតុនាំឲ្យមានអ្នកប្រាជ្ញ អ្នកស្រាវជ្រាវក្នុងស្រុក និងបរទេសជាច្រើន ចេញចូលទាក់ទងជាមួយបណ្ណាល័យពុទ្ធសាសន–បណ្ឌិត្យ ដែលព្រះរាជបល្ល័ង្កបានបង្កើតឡើងរាប់ជាង ៤០ ឆ្នាំមកហើយ ។ មានមជ្ឈដ្ឋានបរទេសនានា គេទទួលស្គាល់ថា បណ្ណាល័យយើងនេះ ជាមជ្ឈមណ្ឌលខាងវប្បធម៌ជាតិយ៉ាងសំខាន់ផង ។ មិនតែប៉ុណ្ណោះ ក្រសួងបានអំពាវនាវឲ្យវត្តនានា បង្កើតបណ្ណាល័យប្រចាំវត្ត ដោយអនុគ្រោះឲ្យជាសៀវភៅបណ្ដាក់ ហើយនិងចុះតម្លៃយ៉ាងថោកថែមទៀតផង មកទល់នឹងពេលនេះ មានវត្តចំនួនជិតមួយពាន់ហើយ ដែលបានបង្កើតបណ្ណាល័យតាមសេចក្ដីអំពាវនាវ ។

២- ផ្នែកបោះពុម្ពផ្សាយ : ចំពោះកិច្ចការបោះពុម្ពផ្សាយក្បួនខ្នាតផ្សេង ៗ នៅឆ្នាំនេះ បានកើនច្រើនជាងឆ្នាំមុន ៗ គឺបោះពុម្ពហើយស្រេចបានចំនួនសៀវភៅ ១៦៤.៧១០ ក្បាល ចែកចេញជា ៥៤ ឈ្មោះផ្សេង ៗ គ្នា ។ ក្នុងចំនួននេះ មានខ្លះជាសៀវភៅចាស់ដែលបោះពុម្ពឡើងវិញ និងខ្លះទៀតជាសៀវភៅតែងថ្មី ៗ ឯព្រះត្រៃ-បិដក ក៏ចេញផ្សាយបាន ៩០ ភាគហើយ ក្នុងចំនួន ១១០ ភាគ

ដែលបានប្រែតម្រឹមតម្រង់ប្រសើរ ៗ

៣- ផ្នែកការសិក្សាខាងព្រះពុទ្ធសាសនាវិញ ក៏មានដំណើរល្អ តាំងខាងផ្នែកគន្ថធុរៈ និងវិបស្សនាធុរៈព្រមគ្នា ៗ ខាងផ្នែកគន្ថធុរៈ រាជរដ្ឋាភិបាល បានចាត់ចែងឲ្យមានសាលាធម្មវិន័យ ដែលបានបើកបង្រៀនហើយចំនួន ១.០៩៦ សាលា មានសិស្ស ១៥.៩៦១ រូប មានសាលាពុទ្ធិកបឋមសិក្សា ៦៦៧ មានសិស្ស ១០.៣៨៣ រូប ហើយសាលាបឋមសិក្សានេះ ត្រូវមានការកែទម្រង់ថ្មីសម្ដេចព្រះមហាក្សត្រិយានី ជាអម្ចាស់ជីវិតលើត្បូង និងសម្ដេចសហជីវិន បានទ្រង់ព្រះមេត្តាប្រោស តាមសេចក្ដីទូលសើរនៃសម្ដេចព្រះពោធិវង្ស ជាអគ្គាធិការនៃពុទ្ធិកសិក្សា ក្នុងព្រះរាជអាណាចក្រ ក៏បានប្រកបទៅដោយដំណើរល្អ ឥតអ្វីជាឧបសគ្គដែរ ៗ សព្វថ្ងៃ សាលាពុទ្ធិកបឋមសិក្សាបែបទម្រង់ថ្មី មានចំនួន ៦១ ចែកជា ៨៧ ថ្នាក់រៀន និងមានសមណសិស្សចំនួន ២.៩៥៩ រូប គឺទើបតែបង្កើតនៅគ្រប់ទីប្រជុំជនស្រុក ក្នុងខេត្តសំខាន់ ៗ នៅឡើយ ពុំទាន់បានដល់ខេត្តថ្មី ៗ នៅឡើយទេ ៗ ដូច្នេះ បានជាគ្រោងការក្នុងឆ្នាំថ្មីនេះ នឹងត្រូវបង្កើនថ្នាក់ បន្ថែមគ្រូសម្រាប់នៅទីថ្មី ៗ ទៀត ដើម្បីបំពេញកិច្ចត្រូវការ របស់បណ្ដាពុទ្ធបរិស័ទគ្រប់ដំបន់តាំងនោះ ៗ ព្រោះរបៀបកែទម្រង់ថ្មីនេះ ជាទិសដៅតែមួយនៃកិច្ចសិក្សាក្នុងពុទ្ធចក្រ ឲ្យស្របគ្នានៅនឹងការសិក្សាខាងអាណាចក្រ

ដែលសព្វថ្ងៃកំពុងតែមានវឌ្ឍនភាពជាអតិបរមា ក្រោមព្រះរាជកិច្ចដឹកនាំ នៃសម្តេចសហជីវិន ជាប្រធាននៃសង្គមរាស្ត្រនិយម ។ វត្ថុបំណងនេះ ក៏កើតឡើងពីព្រះរាជតម្រាស់ជាសាទៀននៃល្អងធូលីព្រះបាទ ដែលទ្រង់បានថ្លែងផ្តាំផ្ញើនៅទីនេះដែរថា : សមណនិស្សិត ក៏ជាអនាគតពលរដ្ឋយើងប្រពៃណាស់ សំរាប់បំរើប្រទេសជាតិទៅអនាគត ។ ព្រះរាជបន្ទូលសូរសីហនាទនេះ មានន័យទូលាយអនេកអនគ្ឃណាស់ ដែលទូលព្រះបង្គំទាំងអស់ខ្ញុំប្រតិបត្តិមិនឲ្យខានឡើយ ហេតុនេះ បានជាត្រូវសំរិតសំរាំងរើសគ្រូ ដើម្បីយកទៅបង្រៀនសាលាទាំងនេះ ឲ្យមានសមត្ថភាព និងគុណសម្បត្តិបរិបូណ៌ ដោយបើកការប្រឡងជ្រើសរើសយ៉ាងតឹងរ៉ឹង កាលពីឆ្នាំ ១៩៦៥ មុន និងកាលពីដើមឆ្នាំ ១៩៦៦ នេះមុន ហើយបានគ្រោងថា នឹងជ្រើសរើសសម្រាប់ឆ្នាំសិក្សាថ្មីតទៅទៀត ។

## សូមទ្រង់ព្រះមេត្តាប្រោស

ទូលព្រះបង្គំជាខ្ញុំ សូមព្រះបរមរាជានុញ្ញាត ថ្លែងក្នុងនាមព្រះរាជរដ្ឋាភិបាល នូវអំណរព្រះករុណាធិគុណ និង កតញ្ញូតាធម៌ដ៏លើសលប់ថ្វាយចំពោះសម្តេចព្រះសង្ឃរាជ, សម្តេចព្រះសង្ឃនាយក, សម្តេចព្រះពោធិវង្ស ដែលព្រះអង្គទ្រង់តែងតែប្រឹងប្រែងពេញព្រះកាយពល ឧបត្ថម្ភកិច្ចការគ្រប់បែប ក្នុងផ្លូវពុទ្ធចក្រឲ្យប្រកបដោយសេចក្តីចំរើនមហិមា

គ្រប់គ្រាគ្រប់កាល ពិសេសគឺព្រះអង្គទ្រង់ត្រិះរិះរកមធ្យោបាយល្អ ៗ ជួយប្រទានព្រះរាជយោបល់ដល់ក្រសួងធម្មការ ។ ទូលព្រះបង្គំជាខ្ញុំ - ខ្ញុំព្រះករុណា ព្រមទាំងពុទ្ធបរិស័ទទាំងអស់ ពុំអាចភ្លេចបានឡើយ ចំពោះព្រះគតិបណ្ឌិតទាំងនេះ ។

មួយចំណែកទៀត ទូលព្រះបង្គំជាខ្ញុំ សូមឆ្លៀតឱកាសដ៏ឧឡារិកនេះ ថ្វាយអំណរព្រះគុណចំពោះព្រះតេជព្រះគុណ ជាគណៈមហានុក្រម មេគណ អនុគណ និងចៅអធិការគ្រប់ព្រះអង្គ ដែលបានជ្រោមជ្រែងពេញសមត្ថភាព ឥតសំចៃកម្លាំង រួបរួមគ្នាធ្វើឲ្យកង់ពុទ្ធចក្រលឿនទៅមុខ ស្មើគ្នានឹងល្បឿននៃកង់អាណាចក្រដែរ ។ ឧទាហរណ៍ដូចជាកិច្ចជួយដល់រាជរដ្ឋាភិបាល ក្នុងវិស័យសង្គមកិច្ច វប្បធម៌ មានជាអាទិ៍ ការដាំដើមឈើ, ជីកអណ្ដូងទឹក, ស្ថាបនាមន្ទីរពេទ្យ, សាលារៀន ដោយបានចូលជួយជាសកម្មផង ជាទីប្រឹក្សានៃកិច្ចការអភិវឌ្ឍន៍សហគមន៍ផង និងកិច្ចការជាច្រើនទៀត ឲ្យបានសម្រេចឡើង នៅតាមទីក្រុង និងទីជនបទនានា ស្របទៅតាមព្រះមាគ៌ានយោបាយដ៏ខ្ពង់ខ្ពស់ នៃសម្ដេចសហជីវិន ព្រះប្រមុខរដ្ឋ ។

## សូមទ្រង់ព្រះមេត្តាប្រោស

នៅទីអវសាននេះ ទូលព្រះបង្គំជាខ្ញុំ សូមថ្វាយល្អងធូលីព្រះបាទជាថ្មីម្ដងទៀត នូវអំណរព្រះមហាករុណាទិគុណ និងកតញ្ញូតាដ៏

ជ្រាលជ្រៅ ចំពោះព្រះរាជវត្តមាននៃព្រះអង្គ និង សូមទូលបួងសួង ចំពោះគុណបុណ្យព្រះរតនត្រ័យ តេជានុភាពនៃព្រះពុទ្ធសាសនា និងវត្ថុស័ក្តិសិទ្ធិ ក្នុងសកលលោក ជួយអភិបាលថែរក្សាអង្គសម្តេចព្រះមហាក្សត្រិយានី ជាអម្ចាស់ជីវិតលើត្បូង និងសម្តេចព្រះប្រមុខរដ្ឋ សូមព្រះអង្គបានប្រកបដោយព្រះបរមសុខសួស្តី ឈ្នះមារសត្រូវគ្រប់ទិសទី និងមានព្រះជន្មាយុយឺនយូរ ដើម្បីជាម្លប់ដ៏សុខសាន្តនៃប្រជាពលរដ្ឋខ្មែរជាកូនចៅព្រះអង្គដរាបតទៅ ។

ជយោ ! ព្រះរាជបល្ល័ង្ក

ជយោ ! សម្តេចព្រះអគ្គពុទ្ធសាសនូបត្ថម្ភក៍

ជយោ ! សង្គមនិយមព្រះពុទ្ធសាសនា

សូមព្រះតេជះតំកល់លើត្បូង

---

# សុន្ទរកថា

ព្រះវិនយធរ សោម សឹម តំណាងមន្ត្រីសង្ឃ

សូមថ្វាយព្រះពរសម្តេចព្រះប្រមុខរដ្ឋ អគ្គពុទ្ធសាសនូបត្ថម្ភក៍

សូមទ្រង់ជ្រាប ។

ក្នុងនាមនៃមន្ត្រីសង្ឃគ្រប់ឋានៈ ក្នុងព្រះរាជធានីភ្នំពេញ និងក្នុងខេត្តក្រៅ ដែលស្ថិតនៅក្រោមព្រះឱវាទ នៃសម្តេចព្រះសង្ឃរាជ និងសម្តេចព្រះសង្ឃនាយក ទាំងពីរព្រះអង្គ ហើយដែលបាននិមន្តមកជួប

ក្នុងមហាសន្និបាតនេះ អាត្មាភាព សូមថ្វាយព្រះពរ ថ្លែងនូវអំណរដ៏ក្រៃលែង ចំពោះព្រះមហាករុណាទិគុណដ៏ខ្ពង់ខ្ពស់ នៃសម្តេចព្រះប្រមុខរដ្ឋ អគ្គពុទ្ធសាសនូបត្ថម្ភក៏ ដែលទ្រង់សព្វព្រះរាជហឫទ័យ ស្តេចយាងមកជាព្រះរាជាធិបតី ក្នុងពិធីអនុស្សាវរីយ៍មហាសន្និបាតទី ២៣ នៃមន្ត្រីសង្ឃនេះ ។

សូមថ្វាយព្រះពរ

អម្បាញ់មិញនេះ លោកអ្នកឧកញ៉ាអនុរដ្ឋលេខាធិការក្រសួងធម្មការ បានថ្លែងសេចក្តីថ្វាយពតិមាន អំពីមហាសន្និបាតនេះ ដែលមានសេចក្តីជាប់ទាក់ទងចំពោះព្រះមហាក្សត្រ ចំពោះព្រះពុទ្ធសាសនា ចំពោះព្រះសង្ឃ និង ចំពោះប្រទេសជាតិរួចហើយ ។

ឥឡូវនេះ អាត្មាភាព ជាតំណាងមន្ត្រីសង្ឃទាំងអស់ សូមព្រះរាជទានព្រះរាជឱកាស ថ្វាយពតិមាន បន្ថែមយ៉ាងសង្ខេប អំពីព្រះពុទ្ធសាសនា ក្នុងប្រទេសកម្ពុជា សម័យបច្ចុប្បន្នដូចតទៅនេះ ៖

សូមថ្វាយព្រះពរ

សម័យបច្ចុប្បន្ននេះ ទោះបីជនរួមជាតិ ជា ឧបាសក ទាយក ពុទ្ធសាសនិកនៅតាមព្រំដែន បានទទួលរងគ្រោះថ្នាក់មួយផងមួយកាល ដោយការឈ្លានពានអំពីបរទេសជិតខាង, ក៏អាចសន្និដ្ឋានបានថា ពុទ្ធ-សាសនិកជន ទាំងគ្រហស្ថ ទាំងបព្វជិត ក្នុងប្រទេសកម្ពុជាទាំង

មុល បានប្រកបដោយសេចក្ដីសុខសាន្ត ស្ទើរតែឥតមានទុក្ខព្រួយ ប្រសើរវិសេសជាងពុទ្ធសាសនិកជន នៅប្រទេសជិតខាងជុំវិញកម្ពុជរដ្ឋយើង ព្រោះថា ដូចជាកិត្តិយស ដែលយើងធ្លាប់បានទទួលរៀងមក, ប្រទេសខ្មែរយើង ជាកោះសន្តិភាព នៅក្នុងសមុទ្រនៃភ្លើងសង្គ្រាម ។

ដោយអាស្រ័យនូវសេចក្ដីសុខសាន្តនេះ ព្រះសង្ឃទាំងឡាយ សឹងមានឱកាសគ្រប់គ្រាន់ ក្នុងដំណើរបំពេញគន្ថធុរៈ គឺការសិក្សាធម៌វិន័យព្រះពុទ្ធសាសនា និងវិបស្សនាធុរៈ គឺការដុសខាត់ សម្រិតសម្រាំងចិត្តគំនិតឲ្យបានថ្លៃថ្លា និងការកសាងបង្កើតសម្បត្តិថ្មី ៗ ក្នុងព្រះពុទ្ធសាស-នា ព្រមទាំងជួយបំពេញសង្គមកិច្ច ចំពោះត្រង់ខណា ដែលមិនពាស់ខុសនឹងវិនយបញ្ញត្តិ ។

ព្រះសង្ឃទាំងអស់ បានដឹងច្បាស់ណាស់ថា ប្រទេសកម្ពុជា ដែលប្រកបដោយឯករាជ្យ, អព្យាក្រឹត្យ និងសេចក្ដីសុខ · ចម្រើន មានសមិទ្ធិកើនចំនួនជានិច្ចកាលថៃ ទាំងព្រះពុទ្ធសាសនា ក៏មានការលូតលាស់ចម្រើនជាលំដាប់មកយ៉ាងនេះ ប្រាកដជាដោយសារព្រះបញ្ញា-ញាណដ៏វាងវៃ និងព្រះនយោបាយដ៏ភ្លឺថ្លា ព្រមទាំងព្រះគតិបណ្ឌិតដ៏-ឆ្នើម នៃសម្ដេចព្រះប្រមុខរដ្ឋជាអម្ចាស់ ដែលជាព្រះឯកអគ្គមគ្គុទ្ទេសក៍ដ៏ប្រសើរបំផុត ។

ព្រះសង្ឃទាំងអស់ តែងមានកតញ្ញូតាធម៌ដ៏ខ្ពង់ខ្ពស់ ចំពោះសម្ដេច

ជាអម្ចាស់ ឥតមានភ្លេចព្រះឧបការគុណដ៏លើសលុបរបស់ព្រះអង្គ ដែលទ្រង់បានកសាងសុខសន្តិភាព ព្រះរាជទានដល់ប្រជាពលរដ្ឋទូទៅ ដោយនយោបាយសង្គមនិយមព្រះពុទ្ធសាសនា ដែលជានយោបាយឯកតែមួយសម្រាប់មាតុភូមិជាទីស្រឡាញ់ គឺប្រទេសកម្ពុជា ព្រមទាំងសម្រាប់សកលពិភពលោកផង ។

សូមថ្វាយព្រះពរ

មន្ត្រីសង្ឃទាំងអស់ នៅចាំជាក់ថា ទិវាខួបនៃមហាសន្និបាតនេះ ដែលផ្តល់ឱកាសមហាប្រសើរ ឲ្យបានជួបព្រះភក្ត្រជាទីស្នេហា ជាទីនឹករលឹក នៃសម្តេចព្រះអគ្គពុទ្ធសាសនូបត្ថម្ភកជាអម្ចាស់, កាលដើមឡើយក្នុងសម័យអាណាព្យាបាលបារាំង, ជាបរិវេណនៃសាលាបាលីជាន់ខ្ពស់ៗ ចាប់តាំងពីសម័យដែលប្រទេសកម្ពុជា ត្រឡប់បានឯករាជ្យមក, ក្រោមព្រះរាជូបត្ថម្ភនៃព្រះបរមមហាក្សត្រ, ដោយសារព្រះរាជសទ្ធាជ្រះថ្លាដ៏មោះមុត និង ព្រះបំណងដ៏ឧត្តម ដើម្បីលើកឋានៈបំណេះវិជ្ជានៃព្រះសង្ឃ សាលាលីជាន់ខ្ពស់ ក៏បានប្រែនាមបញ្ញត្តិជា ពុទ្ធិកវិទ្យាល័យព្រះសុរ-ម្រឹត ដោយមានសកលវិទ្យាល័យព្រះសីហនុរាជ បានចាប់សម្ពោធឡើង ដើម្បីនាំដំណើរនៃពុទ្ធិកសិក្សា ឲ្យបានទៅដល់ទីបំផុត ។ មិនត្រឹមតែការកែប្រែនាមបញ្ញត្តិ និងឋានៈនៃការសិក្សាប៉ុណ្ណោះទេ ទោះទាំងរូបរាងដែលមានសភាពទ្រុឌទ្រោមចាស់គ្រាំគ្រា ក៏សម្តេចព្រះប្រមុខរដ្ឋ

ជាអម្ចាស់ ទ្រង់មានព្រះបញ្ញា ឲ្យកែប្រែ ឲ្យមានសម្រស់ និងសភាព ថ្មោងថ្មីវិញដែរ ។ ការកែប្រែទាំងខាងគុណសម្បទ ទាំងខាងរូបសម្ប័ទនេះ មន្ត្រីសង្ឃគ្រប់រូប និងពុទ្ធបរិស័ទជាគ្រហស្ថគ្រប់គ្នា បានឃើញប្រត្យក្ស ថ្ងៃហើយថ្ងៃទៀតរៀងរាល់ឆ្នាំ ។ ភិក្ខុសង្ឃខ្មែរ តែងបានទទួលភាពត្រជាក់ត្រជុំ ដោយសារទឹកព្រះហឫទ័យដ៏រងថ្វា នៃសម្តេចព្រះប្រមុខរដ្ឋជាអម្ចាស់ជាទីស្នេហាតែមួយព្រះអង្គ ។ មន្ត្រីសង្ឃមានសង្ឃឹមមាំ លើកិច្ចទំនុកបម្រុងតទៅអនាគត នៃព្រះរាជរដ្ឋាភិបាល ថា ការសិក្សាក្នុងព្រះពុទ្ធសាសនា នឹងមានដំណើរទៅកាន់វឌ្ឍនភាពជាលំដាប់ ។

ជាទីបញ្ចប់នេះ, អាត្មាភាព, ក្នុងនាមនៃព្រះសង្ឃទាំងអស់, សូមថ្វាយព្រះពរបវរសួស្តី ជោគជ័យ មហាមង្គល វិបុលសុខគ្រប់ប្រការ ចំពោះសម្តេចព្រះមហាក្សត្រិយានី ជាអម្ចាស់ជីវិត, ចំពោះសម្តេចព្រះប្រមុខរដ្ឋ ព្រះអគ្គមគ្គុទ្ទេសក៍ :

- សូមព្រះអង្គបានប្រកបដោយព្រះជន្មាយុយឺនយូរ ជាងរយវស្សា មានព្រះសុខភាពដ៏បរិបូណ៌ !
- មារសត្រូវគ្រប់ទិសទី កុំគប្បីយាយីបៀតបៀនព្រះអង្គបានឡើយ!

សូមថ្វាយព្រះពរ !

៤

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

ឆ្នាំទី ៣៩ ខែ មេសា

ព.ស. ២៥០៩ គ.ស. ១៩៦៧

៨

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ

ឆ្នាំទី ៣៩ ខែ មេសា

ព.ស. ២៥០៩ គ.ស. ១៩៦៧

# សព្ទសាធុការពរ

ក្នុងឆ្នាំថ្មី, មមែរនព្វស័ក ព.ស. ២៥១០ នេះ ពុទ្ធសាសនបណ្ឌិត្យ សូមលំឱនកាយប្រសិទ្ធិពរជ័យថ្វាយដោយគោរពចំពោះ៖

– សម្ដេចព្រះមហាក្សត្រិយានី ជាអម្ចាស់ជីវិតលើត្បូង និង សម្ដេចព្រះប្រមុខរដ្ឋ សូមទ្រង់បានប្រកបដោយព្រះបរមសុខគ្រប់ប្រការ ព្រមទាំងមានព្រះជន្មាយុយឺនយូរ !

– សម្ដេចព្រះសង្ឃរាជ និង សម្ដេចព្រះសង្ឃនាយក សូមព្រះអង្គមានព្រះសុខភាពបរិបូណ៌រឹងប៉ឹងមុតមាំ មានព្រះជន្ម-វស្សាវែង !

ព្រមទាំង

សូមប្រគេន-ជូនសព្ទសាធុការពរចំពោះពុទ្ធបរិស័ទទូទៅ ទាំងបព្វជិត ទាំងគ្រហស្ថ, សូមបានចម្រុងចំរើនកើនកប ដោយ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាត !

ÉCOLE F...
F.682
BIBLIOTHÈQUE
P.P.
DIRECTEMENT...

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និង អក្សរសាស្ត្រ
ចេញរាល់ខែ ពីពុទ្ធសាសនបណ្ឌិត្យ

បញ្ជីរឿង

*ផ្នែកសាសនា* — ទំព័រ

១– បញ្ហាព្យាករណ៍ពីពុទ្ធសាសនា លោក សម-ថាំង ប្រែ-រៀបរៀង (ត) . . . ៣៤៧
២– ម៉ែចក៏ចាំបួស ម៉ែចក៏ចាំសឹក សហជីវិន ផល-ទិត រៀបរៀង . . . . . . ៣៥៧

*ផ្នែកអក្សរសាស្ត្រ*

៣– ពិចារណាដើម្បីយល់តក្កវិជ្ជា លោក ហ៊ុន គីមសៀ រៀបរៀង (ត) . . . ៣៧៥
៤– វចនានុក្រម សំស្ក្រឹត-ខ្មែរ ព្រះមហា ប៉ាង–ខាត់ រៀបរៀង (ត) . . . . . ៣៨៥
៥– ព្រះរាជនិពន្ធរាមកេរ្តិ៍ លោក ឱ. ពាម ស្រាវជ្រាវ (ត) . . . . . . ៣៨៩
៦– ឯកសារ សាស្ត្រស្វ័ការីតនិងព្រាំង លោក ញ៉ុក-ថែម រៀបរៀង (ត) . . . ៣៩៧
៧– រឿងសាមកុក អ្នកនកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង (ត) . . . . . ៤០១
៨– ឯកសារកម្ពុជសុរិយា លោក ឱ.ពាម ប្រមូលរៀបរៀង (ត) . . . . . . ៤១៩
៩– ជីវប្រវត្តិរបស់ខ្ញុំ ឈ្មោះ អៀង-សាយ (ត) . . . . . . . . . . ៤១៧
១០– សិរីនៃកបិលមហាព្រហ្ម សហជីវិន ផល-ទិត នៅពុទ្ធសាសនបណ្ឌិត្យ រៀបរៀង . ៤២៥

*ផ្នែកកំណាត់ និង ប្រវត្តិការណ៍*

១១– អនិច្ចធម្មនៃព្រះមហាវីរវង្សាចារ្យ វ៉ាន់-សាឌុម . . . . . . – ៤៣១
– សុន្ទរកថា ព្រះសមុហ៍ពុធាចារ្យ ពុធ-ប៉ុណ្ណ . . . . . ៤៣៣
– សុន្ទរកថា សហជីវិន គុយ-ពៅ អនុរដ្ឋលេខាធិការក្រសួងធម្មការ. . . . ៤៣៧
១២ – សេចក្ដីរាយការណ៍ អំពីសកម្មភាពនៃពុទ្ធសាសនបណ្ឌិត្យ . . . . ៤៤៦
១៣– ពរសព្វសាធុការ . . . . . . . . . . . . ៤៥១

មួយឆ្នាំមាន ១២ សៀវភៅ តម្លៃជាវ ២៣០រ០០ ។

# ផ្នែកសាសនា

ពាក្យឃាត់មិនឲ្យ ធ្វើការអាក្រក់
ជាការលាមក, ឲ្យធ្វើល្អទៅ,
ឲ្យជ្រះថ្លាចិត្ត កុំឲ្យហ្មងសៅ,
បីនេះលោកហៅ ពុទ្ធសាសនា ។

ប.ព.

## បញ្ហាព្យាករណ៍ពីពុទ្ធសាសនា

(ត)

លោក សប-ថាំង ប្រែ - រៀបរៀង

៨- គម្ពីរមហាវង្ស ដែលជារឿងបុរាណបានពណ៌នាបញ្ជាក់ដោយពិស្តារអំពីប្រវត្តិពង្សាវតារនៅលង្កាទ្វីប ក្នុងជំនាន់ពុទ្ធកាល រវាងរាជ្យព្រះវិជយរាជា មុនគ្រិស្តសករាជ ៥៤៣ ឆ្នាំ ក្នុងពេលដែលព្រះសម្មាសម្ពុទ្ធទ្រង់គង់ព្រះជន្មមាននៅឡើយ ។ គម្ពីរនេះ មានសំដែងអំពីរឿងព្រះបរមគ្រូជាច្រើនអន្លើ និងអំពីព្រះបាទអសោក ទូរអស់ព្រះចៅគ្រប់គ្រងផែនដីទាំងពួង ដែលមានរឿងរ៉ាវពាក់ព័ន្ធក្នុងព្រះពុទ្ធសាសនា ។

ប្រ. តាមគេសំគាល់ថា ព្រះបរមគ្រូមានព្រះសរីរៈកាយ ដូចជាយក្ស កំពស់ ១៨ ហត្ថ, រឿងនេះមានក្នុងពង្សាវតារឬទេ ?

វិ. គ្មានអ្វីជាគ្រឿងសំគាល់ទេ យើងគ្រាន់តែដឹងតាមគម្ពីរថា ព្រះ

ព្រះកគ្រុព្រះអង្គ សឹងប្រកបដោយអទ្ភុតលក្ខណៈ ដែលគេឃើញ ហើយនិយាយតាមគ្នា ៗ មកថា ដូចព្រះពុទ្ធអំពីបុរាណ ៗ

ប្ញ. អ្នកអាចនឹងពណ៌នាតាមលំនាំ ដែលមានក្នុងគម្ពីរផ្សេង ៗ ថា ព្រះអង្គប្រកបដោយព្រះរូបលក្ខណៈដូចមនុស្សសាមញ្ញឬទេ ?

វិ. អាច, ព្រោះមានសំដែងក្នុងគម្ពីរអង្គុត្តរនិកាយស្រាប់ថា មានស្ត្រីម្នាក់ ដែលតែងតែធ្វើទានប្រគេនព្រះមហាកស្សបៈ ; មានកាលមួយនោះ នាងបានយកចង្ហាន់ ទៅបូជាព្រះបរមសម្មាសម្ពុទ្ធវិញ ដោយការគោរពប្រាថ្នាថាតែព្រះមហាកស្សបៈដែលជាសាវ័ករបស់ព្រះអង្គ ហើយប្រសិនបើព្រះអង្គមានព្រះកាយដូចជាយក្ស នឹងធ្វើដូច្នេះ ពុំបានឡើយ ព្រោះមហាកស្សបៈ មានសរីរៈកាយជាមនុស្សធម្មតាទេ ៗ

ប្ញ. ព្រះកិត្តិនាមជាទីគោរពរបស់ព្រះពុទ្ធជាម្ចាស់មានដូចម្តេចខ្លះ ?

វិ. ព្រះកិត្តិនាមព្រះសក្យមុនី មានច្រើនគឺ

សាក្យ, សិង្ហ, សុគត, សត្ថា, ជិន, ភគវ័ត, លោកនាថ, សព្វញ្ញូ, ធម្មរាជា, តថាគត ជាដើម ៗ

វគ្គទី ២

## អំពីព្រះធម៌ឬច្បាប់ព្រះពុទ្ធសាសនា

ប្ញ. ពាក្យថាពុទ្ធៈ បានសេចក្តីដូចម្តេច ?

វិ. បានសេចក្តីថា អ្នកត្រាស់ដឹង ឬអ្នកដែលបានសម្រេចនូវព្រះអនុត្តរសម្មាសម្ពោធិញាណ ៗ

បុ. អ្នកបានពោលថា ក្នុងកាលមុននៃព្រះបរមគ្រូយើងនេះ មាន ព្រះពុទ្ធអំពីបុរាណមកដែរ តើមែនឬទេ ?

វិ. មែន, យើងស្ដាប់ឮ តាមបវេណីអំពីបុរាណមក, ព្រះពុទ្ធនឹងត្រាស់ដឹងម្ដង ៗ ក្នុងពេលដែលមនុស្សសត្វដល់នូវសេចក្ដីលំបាក និងងងឹតអន្ធការ ដែលបណ្ដាលមកអំពីអវិជ្ជាគ្របសង្កត់ ហើយត្រូវការរកផ្លូវខុសត្រូវ ដែលជាករណីយកិច្ចរបស់ព្រះពុទ្ធគ្រប់ព្រះអង្គទ្រង់ត្រាស់ដឹង ហើយប្រៀនប្រដៅពន្យល់ប្រាប់ផ្លូវល្អផ្លូវត្រូវ ។

បុ. ព្រះពុទ្ធទីមួយ ៗ ទ្រង់បានកសាងបារមីធម៌ដូចម្ដេច ?

វិ. ជនណាមួយដែលបានជួបប្រទះហើយ ស្ដាប់ព្រះធម៌ទេសនា អំពីសំណាក់ព្រះពុទ្ធអង្គណាមួយក្នុងលោកនេះ បានតាំងបេក្ខជាខ្លួនថា ឲ្យបានជាពុទ្ធភូមិក្នុងកាលជាអនាគត, បើជននោះ បានបំពេញបារមីល្មមគួរដល់ការត្រាស់ដឹងហើយ ក៏បានត្រាស់ជាព្រះពុទ្ធមួយព្រះអង្គ ដើម្បីយឹតយោងដឹកនាំមនុស្សសត្វក្នុងត្រៃលោកឲ្យរួចផុតអំពីជាតិកំណើត ។

បុ. អ្នកដែលមានបំណងចង់បានត្រាស់ជាព្រះពុទ្ធ ត្រូវកសាងដូចម្ដេច ?

វិ. ត្រូវខំកសាងក្នុងបច្ចុប្បន្នជាតិនិងអនាគតជាតិ ដើម្បីផ្ដាច់បង់នូវតណ្ហា, ធ្វើចិត្តឲ្យបានសុចរិត ដោយហាត់ពត់ហ្វឹកហ្វឺន ហើយខំប្រឹងសិក្សាចំណេះវិជ្ជាជាន់ខ្ពស់ ឲ្យបានចំរើនកើនឡើងជាលំដាប់ ជា

មនុស្សស្រគត់ស្រគំ មានចរិយាធម៌ខ្ពង់ខ្ពស់ និងមានចិត្តស្ងប់ចុះកង់វត្ត ប្រតិបត្តិដែលជាផ្លូវមគ្គញាណ, លុះដល់កំណត់ទីបំផុតជាតិ ក៏នឹងបានជាមនុស្សវិសេស, ត្រាស់ដឹង ដល់នូវសម្មោធិញ្ញាណ ជាសាស្ដានៃមនុស្សសត្វទាំងឡាយ ។

ប្រ. ក្នុងពេលដែលព្រះអង្គកំពុងកសាងខ្លួនកាត់កាលវដ្តសង្សារទ្រង់មានព្រះនាមជាដូចម្ដេច ?

ឆ្លើ. ទ្រង់មានព្រះនាមថា ព្រះពោធិសត្វ, ហេតុនេះហើយបានជាព្រះពុទ្ធសាសនិកជនហៅ គោតម ទ្រង់មានព្រះនាមថា ពោធិសត្វ ទៅទល់ទីពេលដែលទ្រង់បានសំរេចសម្មោធិញ្ញាណ ត្រាស់ដឹងជាព្រះពុទ្ធនៅនាក្រោមដើមពោធិព្រឹក្ស ។

ប្រ. គេអាចដឹងរឿងរ៉ាវនៃព្រះអង្គ ក្នុងកាលដែលទ្រង់នៅជាព្រះពោធិសត្វនៅឡើយឬទេ ?

ឆ្លើ. ក្នុងគម្ពីរជាតកដ្ឋកថា មានសំដែងអំពីរឿងរ៉ាវដែលព្រះអង្គអន្ទោលយកកំណើតជាច្រើនអទ្ទី ។

ប្រ. រឿងរ៉ាវទាំងនេះ បង្ហាញនូវដូចម្ដេចខ្លះ ?

ឆ្លើ. ថា មានបុរសម្នាក់ បានត្រាច់រង្គាត់ក្នុងវដ្តសង្សារជាច្រើនជាតិ កសាងខ្លួនបារមីដោយការកំចាត់បង់នូវកិលេសតណ្ហា និងការបំពេញនូវគុណធម៌ទាំងពួង ។

ប្រ. គេអាចកំណត់ចំនួនជាតិកំណើត ដែលព្រះពោធិសត្វមួយៗ ត្រូវកសាងមុននឹងបានសំរេចជាព្រះពុទ្ធនោះ បានឬទេ ?

វិ. ទេ, រឿងនេះ ស្រេចហើយតែបុព្វចរិត និងភាពនៃការកសាង ដែលព្រះពោធិសត្វមួយ ៗ តាំងប្តេជ្ញា ឲ្យបានជាពុទ្ធភូមិ ហើយនិងហេតុដទៃ ៗ ទៀត ។

ប្រ. ព្រះពោធិសត្វទាំងឡាយ មានប៉ុន្មានយ៉ាង ?

វិ. ព្រះពោធិសត្វដែលនឹងបានត្រាស់ជាព្រះពុទ្ធក្នុងអនាគត ចែកជា ៣ យ៉ាង ។

ប្រ. ចូរអ្នករៀបរាប់មកមើល ?

វិ. បញ្ញាធិក ឬឧគ្ឃដិតញ្ញូ "អ្នកត្រាស់ដឹងយឺនយូរជាងគេបង្អស់" សទ្ធាធិក ឬវិបចិតញ្ញូ "អ្នកត្រាស់ដឹងដោយយឺតយូរមធ្យម" វិរិយាធិក ឬនេយ្យ "អ្នកត្រាស់ដឹងដោយស្រួកទ", ព្រះពោធិសត្វជាបញ្ញាធិកច្រើនប្រើបញ្ញា, ព្រះពោធិសត្វជាសទ្ធាធិក ប្រកបដោយជំនឿ, ព្រះពោធិសត្វជាវិរិយាធិក ប្រកបដោយទូវក្តីព្យាយាមយ៉ាងមាំ ។ ព្រះពោធិសត្វទីមួយ ដែលប្រកបដោយបញ្ញា ពុំសូវស្រួកទក្នុងការត្រាស់ដឹងទេ, ព្រះពោធិសត្វទីពីរ ដែលប្រកបដោយជំនឿ ពុំសូវអើពើនឹងរកផ្លូវជាមគ្គញាណឡើយ, ព្រះពោធិសត្វទីបី គិតតែកសាងអំពើល្អជានិច្ចកាលបង្អង់ ពុំមានគិតដល់សេចក្តីនឿយលំបាកឡើយ ។

ប្ញ. កាលដែលព្រះពោធិសត្វនៃយើងបានសម្រេចនូវអនុត្តរសម្មាសម្ពោធិញ្ញាណហើយ ទ្រង់បានសំដែងថា សត្វសត្វទាំងអស់ បានទទួលទុក្ខវេទនាមកអំពីអ្វី ?

វិ. មកអំពីអវិជ្ជា ។

ប្ញ. ចុះអ្វីដែលជាឱសថ ?

វិ. បញ្ញាជាគ្រឿងកំចាត់បង់នូវសេចក្តីងងឹត ដើម្បីឲ្យបានត្រាស់ដឹង ជាឱសថ សំរាប់រំងាប់នូវអវិជ្ជា ។

ប្ញ. ហេតុម្តេចបានជាអវិជ្ជាជាបច្ច័យនាំឲ្យកើតទុក្ខលំបាក?

វិ. ព្រោះអវិជ្ជាជាគ្រឿងនាំឲ្យជំពាក់ចិត្តនឹងរបស់ដែលគ្មានខ្លឹមសារ នាំឲ្យក្រោធវង្វេងយល់ខុសនូវវត្ថុទាំងពួងដែលមិនទៀងពិត ថាជារបស់ទៀងពិតប្រាកដ ញុំាងជីវិតឲ្យកន្លងទៅដោយការស្វែងរកវត្ថុ ដែលគ្មានតម្លៃគ្មានប្រយោជន៍ ហើយបោះបង់បោលវត្ថុដែលមានតម្លៃមានប្រយោជន៍ដ៏ឧត្តមក្រៃលែងនោះវិញ ។

ប្ញ. ប្រយោជន៍ដ៏ឧត្តមនោះ បានដល់អ្វីខ្លះ ?

វិ. កិរិយាដឹងស្គាល់អាថ៌កំបាំងនៃជាតិកំណើត នៃកពាទង់ពេសនា របស់មនុស្ស ហើយនិងការរកឃើញជាតិកត ដែលជាបច្ច័យនៃសង្ខារ ដើម្បីធ្វើអ្នកដទៃទាំងខ្លួនឯង ឲ្យបានសេចក្តីសុខចំរើន ឲ្យផុតពីទុក្ខតាមសភាវៈធម្មតា ចាត់ថាជាប្រយោជន៍ដ៏ឧត្តមយ៉ាងក្រៃលែង ។

ប្ញ. តើទីណាដែលកំចាត់បង់នូវសេចក្ដីលំបាកខ្លាំង ហើយចៀសវាងនូវសេចក្ដីសោយសោកបាន ?

វិ. ការដឹងច្បាស់នូវអរិយសច្ចទាំងបួន ដែលព្រះបរមគ្រូសំដែងទុកមក ពប់ថាជាទីសំរាប់កំចាត់បង់នូវសេចក្ដីលំបាកខ្លាំង ហើយចៀសវាងទុក្ខបាន ?

ប្ញ. ចូររៀបរាប់មកមើល ?

វិ. ១)- សេចក្ដីទុក្ខលំបាក កើតពីការអន្ទោលយកជាតិ វិលស្លាប់វិលកើត ៗ ក្នុងកពក្ដូចកពង់ ហៅថា " ទុក្ខអរិយសច្ច ",

២)- ហេតុដែលនាំឲ្យកើតទុក្ខគឺសេចក្ដីប្រាថ្នាដែលចេះតែចំរើនធំឡើង ៗ ឥតមានកំណត់ ហើយចេញបានសម្រេចតាមបំណង ហៅថា " សមុទយសច្ច ",

៣)- ការរំលត់នូវតណ្ហា ហៅថា " និរោធសច្ច ",

៤)- ផ្លូវប្រតិបត្តិដំណើរ ឲ្យដល់នូវការរំលត់បង់នូវតណ្ហា ហៅថា " មគ្គសច្ច " ។

ប្ញ. ចូរអ្នករៀបរាប់ហេតុដែលនាំមកនូវទុក្ខនោះមកមើល ?

វិ. ការកើត, សេចក្ដីចាស់គ្រាំគ្រា, ជម្ងឺដម្កាត់, សេចក្ដីស្លាប់, ការប្រាសព្រាត់ ចាកសត្វនិងសង្ខារ ដែលជាទីស្រឡាញ់, ការជួបប្រទះនូវសត្វនិងសង្ខារ ដែលជាទីស្អប់ខ្ពើម, សេចក្ដីប្រាថ្នានូវរបស់ដែលមិនអាចនឹងសម្រេចបានជាដើម, នេះឯង ជាហេតុនាំមកនូវទុក្ខ ។

ប្រ. ហេតុទាំងនេះ មានប្លែកគ្នាទៅតាមបុគ្គលដែរឬទេ ?

វិ. ប្លែក, ព្រោះមនុស្សគ្រប់រូបតែងទទួលទុក្ខមានកំរិតផ្សេង ៗ ពីគ្នា ។

ប្រ. ត្រូវធ្វើដូចម្តេច ដើម្បីនឹងចេញចាកទុក្ខដែលកើតអំពីសេចក្តីប្រាថ្នាពុំចេះឆ្អែតឆ្អន់ និងសេចក្តីត្រូវការ ដែលកើតមកអំពីអវិជ្ជា ?

វិ. ត្រូវរំងាប់បង់ឲ្យជ្រះស្រឡះ ត្រូវកំចាត់បង់នូវតណ្ហានិងសេចក្តីរីករាយ ដែលជាហេតុនៃកងទុក្ខ ដែលហៅថា មគ្គសច្ច ។

ប្រ. ត្រូវធ្វើដូចម្តេច ទើបឈ្មោះថា ដល់នូវមគ្គសច្ចនោះ ?

វិ. ត្រូវប្រតិបត្តិតាមគន្លងនៃមគ្គទាំង ៨ ប្រការ ដែលព្រះពុទ្ធជាម្ចាស់បានត្រាស់ដឹងនិងសំដែងហើយនោះ ។

ប្រ. ពាក្យថា អដ្ឋង្គិកមគ្គ បានសេចក្តីដូចម្តេច? បានដល់អ្វីខ្លះ?

វិ. បានដល់ផ្លូវទាំង ៨ ប្រការ ដែលលោកហៅថា អង្គ គឺ ១ សេចក្តីយល់ត្រូវ, ២ ការត្រិះរិះត្រូវ, ៣ សំដីត្រូវ, ៤ ការងារត្រូវ, ៥ ការចិញ្ចឹមជីវិតត្រូវ, ៦ សេចក្តីព្យាយាមត្រូវ, ៧ ការនឹករលឹកត្រូវ ៨ កិរិយាតាំងកល់ចិត្តត្រូវ ។ បុគ្គលដែលបានប្រតិបត្តិតាមអង្គទាំងនេះ នឹងអាចរលាស់ខ្លួនចាកទុក្ខ ហើយបានដល់ឋានក្សេមក្សាន្តដោយពិត ។

ប្រ. បើនឹងប្រើពាក្យដទៃជំនួសពាក្យថា "ក្សេម" នេះបានឬទេ ?

វិ. បាន, នឹងហៅថា រួចចាកចំណង ក៏បាន ។

ប្រ. រូបតាកចំណងអ្វី ?

វិ. រូបតាកទុក្ខលំបាកនៅក្នុងលោក តាកការវិលកើតវិលស្លាប់ ដោយអំណាចអវិជ្ជា និងតណ្ហាដ៏លាមក ។

ប្រ. កាលបើបុគ្គលណាមួយបានរួចផុត តាកបំណង ប្អូនទូង់នេះ តើនឹងបានដល់នូវអ្វី ?

វិ. នឹងបានដល់នូវព្រះនិព្វាន ។

ប្រ. និព្វានជាអ្វី ?

វិ. ជាសភាវៈដ៏ស្ងប់ស្ងាត់វិសេស ជាទីក្សេម លែងមានការប្រែប្រួលផ្លាស់ប្តូរ ជាសភាវៈទៀងទាត់ គ្មានតណ្ហាគឺសេចក្តីប្រាថ្នា គ្មានការប្រឡូកប្រឡំដោយសុខនិងទុក្ខ និងគ្មានទុក្ខលំបាក គ្មានចុតិនិងបដិសន្ធិទេ ។ មុននឹងដល់និព្វាន បុគ្គលតែងតែវិលកើតវិលស្លាប់គ្មានឈប់ឈរ; លុះបានដល់ព្រះនិព្វានហើយ ទើបឈប់មានកំណើតតទៅទៀត ។

ប្រ. គេឃើញក្នុងសៀវភៅណាដែលពន្យល់ដោយពិស្តារ ពីព្រះនិព្វាន និងបញ្ញត្តិនាមទាំងពួងដែលបញ្ជាក់សេចក្តីអំពីព្រះនិព្វាននោះ ?

វិ. នៅក្នុងសៀវភៅវចនានុក្រមភាសាបាលីរបស់លោកស្ហ៊ូលឌែស (Childers) គេឃើញមានពន្យល់ពាក្យ " និព្វាន " យ៉ាងពិស្តារ ។

ប្រ. ជនចំពួកខ្លះគិតស្មានថា ព្រះនិព្វាន ជាឋាននៅលើមេឃ ជា

ឋានសួគ៌, តើព្រះពុទ្ធសាសនាមានពន្យល់ដូច្នេះឬ ?

វិ. ពុំដូច្នេះទេ, ព្រោះកាលកូដទន្តព្រាហ្មណ៍ក្រាបទូលសួរព្រះអរហន្ត អំពីទីនៃព្រះនិព្វាន ព្រះអរហន្តតបវិញថា "ព្រះនិព្វាន ស្ថិតនៅត្រង់កន្លែង ដែលជាទីតាំងនៃសេចក្ដីប្រតិបត្តិត្រឹមត្រូវតាមធម៌វិន័យ" ។

ប្ុ. ហេតុម្ដេចបានជាមនុស្សយើងត្រូវកើតទៀត ?

វិ. មកពីសេចក្ដីប្រាថ្នាពុំចេះអស់ (តណ្ហា ចំពោះវត្ថុដែលមាននៅក្នុងលោកនេះ និងសេចក្ដីប្រាថ្នាក្នុងភពនានា) នេះហើយជាធម្មជាតិមួយ មានរិទ្ធិអំណាចខ្លាំងណាស់ អាចដឹកនាំសត្វឲ្យចាប់បដិសន្ធិកើតនៅក្នុងត្រៃលោកតទៅទៀតបាន ។

ប្ុ. សេចក្ដីប្រាថ្នាដែលពុំបានសម្រេច អាចឲ្យផលណាមួយក្នុងបដិសន្ធិរបស់សត្វនោះឬទេ ?

វិ. អាចឲ្យផលបានដូចជាកុសលនិងអកុសលនៃយើងដែរ ។

ប្ុ. កុសលនិងអកុសល អាចឲ្យផលក្នុងបដិសន្ធិកាលរបស់យើងឲ្យមានភាព លក្ខណៈ និងរូបរាងល្អអាក្រក់ បានឬទេ ?

វិ. បាន តាមធម្មតា ផលជាកុសលអាចនាំសត្វឲ្យចាប់បដិសន្ធិនៅក្នុងទីខ្ពង់ខ្ពស់ជាទីរីករាយសប្បាយ, ចំណែកខាងអកុសលវិញ តែងនាំសត្វឲ្យចាប់បដិសន្ធិនៅក្នុងទីថោក-ទាប និងទីទុក្ខលំបាក ។

(នៅមានត)

# ម៉េចក៏ចាំបួស ម៉េចក៏ចាំសឹក

សបៈដីន ផល-ទិត នៅពុទ្ធសាសនបណ្ឌិត្យ

(៥-៣-៦៤)

មុននឹងដើរត្រូវតាមផ្លូវត្រង់ ត្រូវចេះវះបង់ស្លឹកហុស
បើឃើញត្រង់ណាជាផ្លូវខុស ប្រាជ្ញប្រាណជាតិមនុស្សកុំប្រព្រឹត្ត ។
ផ្លែស្លែងវែងពុលជាទោសកាច តែមានគុណអាចកែជីវិត
ស្តៅ-ម្រះ ក្រាស់ដោយជាតិល្វីងពិត តែគង់មានឫទ្ធិកែរោគបាន ។
ភ្លើងក្តៅហៅកាចកំណាចក្រៃ តែជាតម្លៃនៃបង្ក្រាន
ជាតិស្រាស្រវឹងរឹងស៊ីប្រាណ តែគង់ផ្សំបានជាឱសថ ។
កាំបិតពិតជាគ្រឿងប្រហារ តែអាចប្រើការកាប់អុសដុត
ជាតិបរមាណូមានទោសផុត តែមានគុណសុទ្ធផុតដូចគ្នា ។
រីឯពាក្យថ្កោលថោលដេញស្ងួរ ទោះបីគ្មានគួរជួរម្តងម្តា
ក៏គង់មានគុណច្រើនមហិមា មកជាមួយគ្នាអចិន្ត្រៃយ៍ ។
រឿងបួសរួសសឹកការជាឫកខ្មែរ មិនសមខ្វះដែរតែប្រពៃ
ព្រោះបួសជាបុណ្យគុណច្រើនក្រៃ ជួយគ្រាប់ទិសស្រយ សាងសុចរិត ។
អ្នកដែលបានបួសជាផ្នួសពេញ ដល់សឹកមកវិញហៅបណ្ឌិត
ហៅក្លាយមកទៀតថាអន្ទិត នេះពិតជាឈ្មោះខ្ពស់ពណ្ណរាយ ។
សម័យអង្គរដ៏ថ្កើងថ្កាន អន្ទិតធ្លាប់បានឋានទូលាប
ជាគ្រូអាចារ្យ ជាចៅហ្វាយ ធ្វើការតាំងឡាយថ្វាយក្សត្រា ។

ផ្ការផ្គាប់អានក្នុងឋានខ្ពស់ លើកសិង្ហកិត្តិយសខ្ពស់ថ្លៃថ្លា
ផ្ការពស្ត្រចាស់ស្រុកខ្មែរគ្រប់គ្នា រាប់ថាឈ្មោះហ្នឹងសឹងពិសិដ្ឋ ។
ហេតុកំណាន់ប្រកាន់ថា គេម្ទោះស្តុកណា គ្មានគំនិត
មិនបានទាមថាជាអច្ឆិត នោះពិតជាគេមិនឲ្យកូន ។
នៅក្នុងសម័យនៃសង្គ្រាម ហូរឈាមចេញតាកអង្គតាជូន
អក្សរសាស្រ្តខ្មែរស្ទើរសាបសូន្យ តើគូនទេវតាណាមកជួយ ។
មិនតែអ្នកបួសនោះប្អី ដែលសាងស្នាដៃលើកស្ទួយ
ទល់ទប់ឧបស័គ្គរក់ទុក្ខព្រួយ ប្រឹងជួយស្ទួយទូលមូលរក្សា ។
ខ្មែរជាជាតិតូចតែដូចពេជ្រ ទោះក្រីក្រម្តេចក៏ហានក្លា
ចេះមានសរសេរតួអក្ខរ ស្ទើរតែគ្រប់គ្នាក្នុងមណ្ឌល ។
ការនេះពេញជាមិនចាញ់ដៃ ជនជាតិដទៃនាសាកល
ខ្មែរជាជាតិតូចតែដួចដល់ ចិត្តវែងនឹងថ្កល់យល់កាលវែង ។
ព្រោះបានមានមិត្រចិត្តត្រង់ហួស គឺការកាន់ផ្នួសបួសហ្នឹងឯង
ដែលពាំនាំខ្មែរឲ្យបែរស្វែង ប្រឹងប្រែងក្រែងបាត់ខ្វាត់វាសនា ។
អ្នកបួសស្ពាយបាត្រដើរបិណ្ឌបាត ក៏គ្មានអន្តរាយដល់ជនណា
លោកមិនដែលញ៉ាំងអ្នកជ្រះថ្លា ឲ្យខូចសទ្ធាប្តូរធនធាន ។
ព្រោះពុទ្ធសាសនាថ្លាឧត្តម ប្រកាន់និយមរឿងឲ្យទាន
ប៉ុន្តែមិនឲ្យអន្តរធាន បាត់បង់សន្តានខាងស្រង់សត្វ ។

ទោះបីសុំគេមកគោក្ដា  ក៏គ្មានអាជ្ញាទៅអារកាត់
ពួកអ្នកឲ្យទានឥតមានខ្វាត់  សទ្ធា-សម្បត្តិនៅធម្មតា ។
ប្រៀបដូចសត្វឃ្មុំសំបុក  ហើរត្រាច់គ្រប់មែកព្រឹក្សា
ខ្វាត់ខ្វែងស្វែងត្រឹបទឹកដមផ្កា  យកទៅសង់ជាផ្ទុកឃ្មុំបាន ។
បុប្ផាផ្កាណាយផ្សាយក្លិនក្លែប  ដែលត្រូវឃ្មុំក្រេបទឹកដមប្រាណ
ក៏ឥតស្រពោនស្វិតរំខាន  តាំងនៅតាមឋានដូចប្រក្រតី ។
ទាំងក្លិនទាំងពណ៌ក៏នៅស្រស់  ដូចដើមតាំងអស់ឥតប្រែអ្វី
អាចបុះចលចេញក្តិបផ្លែខ្ចី  កើនពូជប្រក្រតីឥតបង់ខាត ។
ឯឃ្មុំក៏ផឹកទឹកដមផ្កា  យកទៅសាងជាផ្ទុកដ៏ហ្មត
ចិញ្ចឹមកូនចៅផៅរួមជាតិ  ដោយឥតមានខាតទៅខាងណា ។
គឺផ្កាក៏ឥតវិបរិតខូច  នៅកើតកពូជជាធម្មតា
រីឃ្មុំផ្សំពីទឹកដមផ្កា  ក៏បានកើតជាប្រយោជន៍ធំ ។
រឿងនេះប្រៀបបានទីអ្នកបួស  កាន់ផ្គត់បទផ្នួសគេឧត្ដម
ប្រឹងប្រែងស្វែងរកគុណដ៏ធំ  ដូចជាសត្វឃ្មុំអ៊ីចឹងឯង ។
អ្នកឲ្យឥតខូចភោគសម្បត្តិ  ឥតខ្វាត់សទ្ធាចិត្តបាត់បែង
អ្នកបួសបានហើយក៏ប្រឹងប្រែង  ប្រព្រឹត្តខ្លួនឯងស្វែងរកគុណ ។
ក្រៅពីខ្លួនលោកយោគដល់ញាតិ  ផ្សព្វផ្សាយដល់ជាតិឥតខាតស៊ុន
ខ្មែរយើងថ្កើងថ្កានមានកិត្តិគុណ  ដោយបុណ្យអ្នកបួសជួយទ្រទ្រង់ ។

រមែងមកគឺមួយ ជួបជាក់ច្បាស់ វាងអក្សរសាស្ត្រឲ្យគង់វង្ស
ពីរជួយអប់រំផ្សំចម្រើន ឲ្យខ្មែរខ្ពស់ខ្ពង់ខាងចរិយា ។
បីជួយឲ្យបានជាមណ្ឌល ផ្ដួចផ្ដល់ទំនុកអ្នកមាក
កូនខ្មែរខ្សត់ក្រយ៉ាងម្ដេចម្ដា ទៅនៅសិក្សាបានទាំងអស់ ។
បួនជួយឲ្យជាតិចេះបង្ផ្ដុំ រមែងជាសង្គមជុំគ្នារស់
ឲ្យចេះធ្វើទានទ្រព្យរបស់ មានចិត្តសប្បុរសសង្គ្រោះខ្សត់ ។
សង្គ្រោះអ្នកបួសជាអាចារ្យ សង្គ្រោះកុមារដែលនៅវត្ត
សង្គ្រោះពលករដែលក្រខ្សត់ សង្គ្រោះជនបទដែលអត់បាយ ។
ព្រោះតែការបួសនេះសំខាន់ ទើបខ្មែរប្រកាន់មិនដំណាយ
ផ្ដាំត-កូនចៅចៅវែងឆ្ងាយ ត្រូវតែប្រឹងកាយបួសកុំខាន ។
បើមិនបួសយូរបួរបព្វជ្ជា ត្រឹមបញ្ចវស្សាសឹកក៏បាន
តែកុំខ្សោះណាឲ្យថ្មោះខាន មុខជាលែងបានប្រពន្ធល្អ ។
ទំនៀមនេះឯងគេតែងគិត ដើម្បីទាញចិត្តមនុស្សឲ្យស
មួយគឺឲ្យមនុស្សទាំងមានក្រ ទោះរៀនច្បាប់ល្អឲ្យស្គាល់ច្បាស់ ។
—ពីរគឺឲ្យខ្មែរស្រែចំការ ចេះសរសេរចារអក្សរសាស្ត្រ
បើទុកជារៀនមិនជាក់ច្បាស់ អន់ណាស់អានបានសរសេរបាន ។
ការបួសកើតបុណ្យមានគុណខ្ពស់ រៀបរាប់មិនអស់ហួសប្រមាណ
ទ្រទ្រង់ជាតិយើងឡើងថ្កើងថ្កាន កុំភ្លឹកនឹកស្មានថាជោគជាប ។

ជនណាទៀតណាយកាយកើតស្រាប់ មិនបង់នៅជាប់អំពើបាប

ជននោះបួសស្ងួនលែងប្រភាព រៀនការរហូតអស់ជីវិ ។

ជនណាមិនទាន់ទ្រាំដិនណាយ នៅឃើញសប្បាយក្នុងកាមខ្លាំង

ជននោះបួសតែមួយភាំង កំតាំងសឹកមករកកាមវិញ ។

ការបួសដើម្បីភ្ជាប់វិស័យ ខានល្អប្រពៃឲ្យពេញលេញ

តែកុំខាតពេញឥតចំណេញ ត្រូវចេញក្រហានខានសិក្សា ។

រៀនភាំងផ្លូវធម៌តាំងផ្លូវលោក ចេះដឹងគរគោកតែគ្រប់គ្នា

សឹកមកជួយជាតិជួយសាសនា ដូចគេកល់គ្នាអ៊ីចឹងដែរ ។

មិនបង់បាយជាតិញាតិសន្តាន បំណាច់ខ្លួនប្រាណកើតជាខ្មែរ

បានជួយជាតិសាសន៍ដូចគេដែរ មិនបែរជាស្អប់ចំលាប់ឪ ។

ឥឡូវការបួសហួសសម័យ កាលពេលសព្វថ្ងៃលោកតម្រូវ

មិនចាំបាច់បួសឲ្យហួសផ្លូវ គេត្រូវនៅជាយុវជន ។

គេក្រេបវិជ្ជាតាមចិត្តចង់ ចេះជាងលោកសង្ឃក្នុងបច្ចុប្បន្ន

ចាំបួសធ្វើអីឲ្យតែអន់ នាំគេរិះគន់ទ្រាំភល់គ្នា ។

ពីដើមស្រុកទេសយើងលិចលង់ បានជាពឹងសង្ឃខាងសិក្សា

យើងបួសដើម្បីរៀនអក្ខរ ទ្រទ្រង់ភាសាជាតិឲ្យរស់ ។

ឥឡូវរីកកើនចំរើនណាស់ ខានអក្សរសាស្ត្ររៀនមិនអស់

មានតាំងតម្រិះចំណេះខ្ពស់ ចាំបួសឲ្យអស់កម្លាំងអី ។

ជំណើរសម័យមានថ្ងៃយប់ វិលឥតឈរឈប់ជាប្រក្រតី
តើយើងជាជាតិជាប់ឈ្មោះល្បី កើតនៅលើដីកម្ពុជា ។
ម្ដេចក៏មិនប្រែកែសម្រួល សម្រួលឲ្យស្រួលតាមវេលា
ជាសប្ដូរទម្លាប់ឲ្យគាប់ជា តាមពេលៈវេលាព្រមគ្នានៅ ? ។
សំដីនេះមិញពេញជាសម តែបួលប្រឡំពុំទាន់ជ្រៅ
ព្រោះឃើញតែគោលដែលដើរនៅ ឯឋានបរិតនៅពុំសូវគិត ។
សម័យថ្មីនេះរៀនការបួស ទីដ៏ជាក់ហួសក៏ពុំពិត
ព្រោះមួយក្រស្ដីខ្វះនៅពេញចិត្ត ពីរពួកអទ្ធិតក៏មានផ្លូវ ។
បានរៀនបានសូត្រហួតអស់ ដូចពួកគ្រហស្ថពេលឥឡូវ
ធៀតពេលប្រព្រឹត្តគិតរកត្រូវ ដឹកនាំម៉ែឪទៅរកសុខ ។
ទីបីដូចយើងប្រាប់ខាងដើម អំពីដង្ហើមកូនអ្នកស្រុក
ជាអ្នកក្រខ្សត់អត់គ្រប់មុខ ក៏ជាបន្ទុកការបួសដែរ ។
បើនឹងបញ្ជាក់ឲ្យយល់ឆាយ យើងនឹងអធិប្បាយបើកបកកើត
អំពីស្នាដៃអ្នកបួសខ្មែរ ដែលបែរបែកផលជាច្រើនយ៉ាង ។
ការបួសប្រៀបបាននឹងគល់ឈើ ដែលលូតលើចេញមែកធាង
ជាទីបុិចផ្កាផ្លែប្រងប្រាង ជាគ្រឿងសំណាងអ្នកបេះផ ។
គល់ពិតតែមួយតែជួយទ្រ ឲ្យល្អមែកធាងសន្ធឹកខ្ពី
បើកាប់គល់ប៉ាច់ផ្ដាច់ពីដី មែកធាងអាងអីមិនរលំ ។

នៅពេលសព្វថ្ងៃសម័យណាស់ តែផ្លាស់មិនផុតពីភាសទុំ
ដូចក្មេងជាតិខ្មែរទាំងតូចធំ នៅតែទៅផ្ដុំសុំដេកវត្ត ។
អ្នកស្រុកចំណាយតាមធនធាន ច្រើនសែនច្រើនលានគ្មានកំណត់
សាងកុដិសាលាពេញគ្រប់វត្ត តើពិតប្រាកដមកពីអ្វី ។
គឺមកពីចិត្តគេជ្រះថ្លា នឹងពុទ្ធសាសនាព្រះជិនស្រី
ដែលមានអ្នកបួសជាសាក្សី ទើបគេឃ្មាតខ្មីគ្មានគិតស្តាយ ។
ដល់កើតជាហានទីលំនៅ លាភនេះផ្ចាក់ទៅក្មេងទាំងឡាយ
នៅបួសនៅរៀនតាមសប្បាយ បន្ធូរប្រាក់ម្ដាយឪពុកបាន ។
បើអស់លោកសង្ឃពីវត្តក៏ តើកុដិសាលាម្ដេចនឹងមាន
ក្មេងខ្មែរក្រីក្រអន្តរធាន រកទីតាំងប្រាណពុំបានពិត ។
មិនត្រឹមប៉ុណ្ណោះអស់ព្រះសង្ឃ ព្រះទ័យស្រោចស្រង់ក្នុងអាណិត
ដឹកនាំបាសកឲ្យដក់ចិត្ត ជួយគិតពីការសិក្សាជាតិ ។
អ្នកស្រុកជឿបុណ្យស៊ិនចំណាយ វៃប្រាក់កាសតាយដោយចិត្តស្អាត
សាងសាលារៀនមានព្រោងព្រាត គ្មានខាតថវិកាពជការសោះ ។
គ្រប់វត្តសុទ្ធសឹងប្រឹងប្រឹតប្រៀន សាងសាលារៀនគ្មានចន្លោះ
គ្រប់ភូមិកុះករពោះកៀនកោះ សាលាដូចហោះទៅតំកល់ ។
បើគ្មានព្រះសង្ឃអ្នកដឹកនាំ ឲ្យមនុស្សជឿម៉ាំក្នុងមគ្គផល
តើងាយអ្នកណានឹងគិតរបល់ ជួយផ្ដល់កជការបានប៉ុណ្ណឹង ។

សម្ដេចបិតាជាអម្ចាស់ ក៏ទ្រង់បានត្រាស់ច្បាស់ឲ្យដឹង
ជាញឹកញយណាស់ពីរឿងហ្នឹង ឲ្យជាតិយើងដឹងសព្វគ្រប់ហើយ ៗ
ដូច្នេះការបួសគ្មានចង្រៃ គ្មានហួសសម័យឯណាឡើយ
ព្រោះមានជនខ្លះធ្វើព្រងើយ ប្រែខ្វង់ធ្ងន់ធ្ងើយថាថោកទាប ៗ
បានបួសព្រោះតែបានលះចិត្ត ដែលធ្លាប់ឆ្នើងគិតប្រកាន់ភាព
ដើម្បីឲ្យបានបាត់ពីបាប ម្ដេចខ្លាចថោកទាបមកដល់កាយ ៗ
គេប្រឹងប្រព្រឹត្តចិត្តឲ្យស្អាត ព្រឹកឡើងកាន់បាត្រដើរបិណ្ឌបាយ
ស្លៀកពាក់ក៏អន់មិនឆើតឆាយ កោរសក់អត់បាយឆ្ងាយពីផ្ទះ ៗ
ច្បាប់បួសអីចឹងតឹងតែង ឲ្យមនុស្សលះលែងចិត្តមានះ
ចេះទន់ទានទាបក្រាបសំពះ សមនឹងឃ្លាល្បះភាសិតថា ៗ
“ ទាសៈទម្លាយបង់មានៈ ជរៈទម្លាយរូបសោភា
ថ្លែងរឿងព្រះពុទ្ធផុតវេក យាចកៈឈ្មោះថាថោកទាបពិត ” ៗ
ដូច្នេះអ្នកបួសហួសពីទាប ព្រោះភាពពឹងគេសាងជីវិត
តែបើមើលពង់ត្រង់ផ្លូវចិត្ត នោះពិតជាថ្លៃឥតគូស្មើ ៗ
ព្រោះអីព្រះសង្ឃដែលទ្រង់សីល មិនមែនខូចខិលប្លិលធ្វើ
របៀបសុំទៀតក៏ថ្នាក់លើ ដូចយើងស្រាយរើទានលើស្រាច់ ៗ
មិនមែនដូចសូមដើរសូមទាន ដែលដាក់ទុកប្រាណថាអភ័ព្វ
សុំគេតាមចិត្តឥតទម្លាប់ គេស្អប់គេខ្ពើមឆ្អើមគ្រប់គ្នា ៗ

ព្រោះខ្ជិលកសាងអាងតែសុំ    មារយាទធ្វើយព្រួយកំព្រា
រៀបរាប់ឲ្យតែគេមេត្តា    គ្រង់គុណល្អជាគ្មានធ្វើសោះ ៗ
រីឯព្រះសង្ឃខ្ទង់ជាងហ្នឹង    មិនធ្វើអីចឹងឲ្យអាប់ឈ្មោះ
ហើយតាំងចរិយាក៏គ្មានមោះ    ល្មមដោះពាក្យគេនិន្ទាបាន ៗ
ធ្វើខ្លួនជូនគេជាស្រែបុណ្យ    ប្រព្រឹត្តសាងគុណតាប់កល្យាណ
ជួយថែរសង្គ្រោះញាតិសន្តាន    ជួយជាតិដូចបានថ្លែងមកហើយ ៗ
ខ្វះមិនទាន់ខ្ពាំងតាំងចិត្តហួស    ព្រាន់ទឹងការបួសយ៉ាងហ្នឹងឡើយ
មានតែស្តើងស្តួចដែលល្ហួចធ្វើយ    ព្រោះគេដល់ត្រើយសើយគួរដាក់ ៗ
ឯសាលារៀនមានច្រើនពិត    តែស្រេចទឹងចិត្តដែលគេស្ទ្រគ
មិនបួសក៏រៀនគ្មានឧបស័គ្គ    ឡើងថ្នាក់ទៅលើប្រសើរក្រៃ ៗ
តែបើគេចង់ទ្រង់ចីពរ    ដើម្បីកាន់ធម៌ប្រពៃ
បួសចុះប្រុសប្រាជ្ញកុំខ្លាចភ័យ    រាគ្មានទោសពៃរ៍ទៅអ្វីទេ ៗ
រាជការសង្គមបានទំរៀប    របៀបសិក្សាជាហូរហែ
ចែកជាពីរផ្លូវឥតផ្លាស់ប្រែ    ស្រេចតែកូនចៅទៅសិក្សា ៗ
របៀបមួយផ្នែកបែកបច្ចុប្បន្ន    សម្រាប់យុវជនពុំបព្វជ្ជា
មួយទៀតហៅពុទ្ធិកសិក្សា    សម្រាប់ជនណាជាបព្វជិត ៗ
ដូច្នេះការរៀនមានពីរផ្លូវ    សុទ្ធតែត្រឹមត្រូវគ្មានរវិត
ចង់រៀនខាងណាស្រេចលើចិត្ត    កុំគិតជាល្បែងប្រជែងគ្នា ៗ

កុំញុះអ្នកបួសឲ្យហួសខុស ផុតពីឋានមនុស្សទៅសួគ៌
អ្នកបួសមិនមែនជាតិទេវតា គឺជាតិខ្មែរដូចគ្នាដែរ ៗ
ហើយជាយុវជនបន្តវង្ស មានពូជមានពង្សពីឈាមខ្មែរ
ដូចជាយុវជនទាំងពួងដែរ មិនមែនក្លាយបែរខ្មែរពីប្រាណ ៗ
ប៉ុន្តែអ្នកបួសហួសពីគេ ត្រង់បែកចិត្តទៅជាពីរស្ថាន
គឺមួយស្វែងរកសួគ៌និព្វាន ពីរកសាងប្រាណក្នុងបច្ចុប្បន្ន ៗ
មុននឹងទៅសួគ៌គួរតែសាក បែរងាកសាងខ្លួនឲ្យគ្រប់គ្រាន់
មិននែនឡើងសួគ៌ដូចឯផ្សែង ទាំងពេលបច្ចុប្បន្នអ៊ីចឹងទេ ៗ
មួយទៀតការបួសហើយវិលសឹក តាមយើងរិះគិតរកពាក្យកែ
ឃើញថាជាគុណគួរកុំប្រែ ត្រូវទុកហូរហែឲ្យវែងឆ្ងាយ ៗ
ព្រោះបួសហើយសឹកបុកនេះថ្ងៃ ឲ្យទាន់សម័យដែលប្រែក្លាយ
– ទីមួយឲ្យកូនខ្មែរទាំងឡាយ ជាប់ចិត្តស្និទ្ធកាយតាមដូនតា ៗ
ឲ្យសមនឹងពាក្យដ៏សំខាន់ ដែលថាខ្មែរកាន់ពុទ្ធសាសនា
កុំកាន់តែមាត់ចិត្តសាវ៉ា កាន់គ្រាន់ឃោសនាយកបុណ្យស័ក្តិៗ
សម្តេចឪយើងដែលទ្រង់ធម៌ ជាឧទាហរណ៍ដ៏ជាក់លាក់
គឺទ្រង់កាន់វង្សជាខ្មែរម្នាក់ ព្រះទ័យស្មោះស្ម័គ្រទំនៀមជាតិ ៗ
ទ្រង់កាន់ព្រះផ្នួសបួសជាសង្ឃ តាមបែបព្រះវង្សពង្សនរនាថ
សមជាក្សត្រខ្មែរឥតប្រែឃ្លាត អ្នកជាតិនិយមពុទ្ធសាសនា ៗ

— ទីពីរទៀតខ្មែរប្រកាន់ខ្ជាប់ នូវបទទម្លាប់ដ៏ថ្លៃថ្លា
ដែលឲ្យយើងចេះសង្គ្រោះគ្នា ដូចបានពណ៌នាខាងដើមហើយ ៗ
ព្រោះតែបើយើងលែងបួសវិញ ក៏គ្មានចំណេញប៉ុន្មានឡើយ
យូរទៅអ្នកបួសកាន់តែស្បើយ ដល់ហើយក៏បាត់រលត់បង់ ៗ
ដល់ផុតអ្នកបួសជំនួសព្រះ គ្រហស្ថអ្នកលះទ្រព្យស្រោចស្រង់
ជាប់សូន្យដូចគ្នាជាពិតត្រង់ ព្រោះគ្មានព្រះសង្ឃជាសាក្សី ៗ
រលាយអស់វត្តរលត់ឈឹង កូនខ្មែរធ្លាប់ពឹងគេបានអ្វី
វាទឹងធ្លាក់ចុះសាជាថ្មី ដល់ម្ចាស់ផែនដីក្នុងការស្រោយ ៗ
បើនាំគ្នាបួសឲ្យបន្ទាប់ បន្តគ្នាជាប់ខ្សែស្រឡាយ
សាសនាពិតជាមិនអន្តរាយ អាចតាំងទៅឆ្ងាយអង្វែងបាន ៗ
ហើយបើយើងប្រឹងឲ្យព្រមគ្នា លើកស្ទួយសាសនាឲ្យថ្កើងថ្កាន
ខ្ពង់ខ្ពស់ជាងនេះទៅទៀតបាន យើងហ៊ានថាធូរដល់សង្គម ៗ
ព្រោះមនុស្សជឿបុណ្យគុណមគ្គផល រឹតតែជួយផ្តល់ការឧបត្ថម្ភ
ខាងកិច្ចសិក្សាការអប់រំ មួយភាគយ៉ាងធំសមគួរខ្លះ ៗ
ជាតិអាចសំចៃលៃថវិកា ពីសាងសាលាពីសាងផ្ទះ
ពីការផ្គត់ផ្គង់កូនចៅខ្លះ ទុកយកទៅប៉ះការខ្វះខាត ៗ
ទៅក្នុងវិស័យដទៃផ្សេង ចម្រើនក្រៃលែងដល់រដ្ឋជាតិ
ប្រសិនជាលុបទម្លាប់ស្អាត នេះទៅតើជាតិចំណេញអី ៗ

បើនឹងនិយាយថាការបួស នេះនាំឲ្យហួសសម័យថ្មី
ខាតពេលដែលត្រូវសាងផែនដី សាងជាតិឃ្លាតខ្វីឡើងក្រៃលែង ។
ថានេះរឹះត្រូវតែនៅខុស មិនគិតវ័យមនុស្សឲ្យជាក់ស្តែង
តើអ្នកណាហ្ន៎ ! នៅកំហែង ឲ្យក្មេងទៅស្មើរធ្វើការងារ ។
គេចែកផ្នែកមនុស្សទាំងប្រុសស្រី តាមវ័យទាំងបីមកយូរយារ
ទីមួយគឺវ័យនៃកុមារ ជាវ័យត្រូវការសិក្សាមុន ។
ពីរគឺវ័យហៅកណ្តាល ជាកាលត្រូវមនុស្សរកសាងទុន
ទីបីជាវ័យកសាងគុណ ធ្វើបុណ្យធ្វើទានសីលភាវនា ។
អ្នកបួសច្រើនក្មេងស្ទើររៀនសូត្រ តាំងចិត្តសូត្របួសតាមដូនតា
បួសហើយចាប់ផ្តើមការសិក្សា ល្មមវ័យកាលណាក៏សឹកវិញ ។
មកលែងប្រតិដ្ឋផលិតផល ជួយជាតិជិតដល់យ៉ាងពេញលេញ
ប្រកបរបររកចំណេញ បំពេញមុខងារជាពលរដ្ឋ ។
រីឯយុវជនមិនបានបួស ក៏មិនជ្រុលជ្រួសហួសបែបបទ
ទោះបីមិនចូលជាសិស្សវត្ត ក៏គង់ចូលបទសិក្សាដែរ ។
មិនដែលមើលស្គាល់ត្រូវខុស ណាមួយប្រទុស្តប្រទេចដែរ
ដល់ក្មេងក្នុងវ័យសិក្សាដែរ ឲ្យបែរត្រឡប់ឈប់រៀនឡើយ ។
គ្មានការបង្ខំដំចង្អិត . មានតែលោមចិត្តជាកូនអើយ
ចាំរៀនសូត្រទៅកុំព្រងើយ ខ្លួននាងធំហើយត្រូវចេះខ្មាស ។

ចាន់នាងនៅក្មេងវ័យវែងឆ្ងាយ    កុំឲ្យទឹកស្អាយដល់ទៅចាស់
តែមានគ្រួសារការច្រើនណាស់    គ្មានពេលណាផ្លាស់វិលវិញទេ ។
ដូច្នេះជាបួសនាំឲ្យខាត    ឲ្យខូចការជាតិដូចពាក្យកែ
យើងហ៊ានឆ្លើយថាមិនពិតទេ    ដូចពោលហូរហៃមកនេះឯង ។
មួយទៀតបើបួស ផលហួសវ័យ    ព្រោះវៃមិនទាន់ក្នុងកាលក្មេង
រឿងនេះក៏គ្មានចំឡែកផ្សេង    វាតែងតែមានជាធម្មតា ។
ពោះមិនអ្នកបួសក៏ហួសដែរ    ព្រោះខ្មែរឪហាតជាតិសក្យ
ខ្វះរៀនពីវ័យកុមារ    ដល់ចាស់វស្សាក៏មិនឈប់ ។
– ទីបីប្រយោជន៍ខាងអប់រំ    លើកស្ទួយសង្គមខាងសេពគប់
ព្រោះអីការបួសជាទំនប់    ជួយទប់កូនខ្មែរឲ្យកែខ្លួន ។
ជួយផ្ដល់សំណាងខាងទិសស្រ័យ    ឲ្យស្គាល់ទោសពៃរ៍អបាយបួន
បេះការវិន័យយ៉ាងម៉ាំមួន    បេះហាត់ពត់ខ្លួនខាងចរិយា ។
ផ្នែកនេះជាភាគមួយយ៉ាងធំ    ខាងផ្ដល់សង្គមឲ្យថ្លៃថ្លា
កូនខ្មែរដែលបានចូលបព្វជ្ជា    សាសនាអប់រំសមគ្រប់កាយ ។
ឲ្យចេះគោរពច្បាប់ខុសត្រូវ    ស្គាល់គុណម៉ែឪគ្រូបាធ្យាយ
ស្គាល់តូចស្គាល់ធំផងទាំងឡាយ    ស្គាល់ញាតិជិតឆ្ងាយមិនវិបត្តិ ។
ស្នេហាជាតិសាសន៍រាជបល្ល័ង្ក    រួបរួមកំលាំងថែមប្រម៉ាត់
គាំពាររក្សាព្រះមហាក្សត្រ    មិនឲ្យសូន្យបាត់ពីសាវតារ ។

ឲ្យបេះដូងញាប់ចិត្តប្រតិដ្ឋផល ជីកស្រះលើកថ្នល់ផលសាធារណ៍
សាងកុដិសាលាព្រះវិហារ ជួយថែរក្សាការប្រមុខរដ្ឋ ។
ដល់សឹកមកវិញចិត្តប្រពៃ ព្រោះជាប់និស្ស័យដែលហាត់ពត់
មានចិត្តស្លូតត្រង់ក្នុងកម្មបថ ប្រាកដជាប់តាមផ្លូវសាសនា ។
បើមិនបានច្រើនគង់កើនខ្លះ មិនមែនស្រឡះបង់អាសា
តាមភ័ព្វនិស្ស័យព្រេងវាសនា តាមបែបដូនតាជាប់តទៅ ។

ដូច្នេះបួសសឹកបុកពិសេស ជួយជាតិប្រទេសជាច្រើនផ្លូវ
បើកាន់សាសនាតាមម៉ែឪ នោះត្រូវតែទៀតបួសកុំខាន ។
បើមិនបួសយូរបួរតាមសូត្រ ផ្លាស់គ្នាម្ដងម្នាក់ឡើងគ្រប់ប្រាណ
ព្រោះមិនជាធ្ងន់ខ្លួនប៉ុន្មាន ហើយឲ្យយើងបានស្គាល់ច្បាស់លាស់ ។
នូវច្បាប់វិន័យពុទ្ធសាសនា នូវច្បាប់ចរិយាខាងធម្មសាស្ត្រ
នូវគោលគំនិតព្រះជាម្ចាស់ នូវភាពកម្រាស់ជម្រៅធម៌ ។
តើធម៌ព្រះពុទ្ធផុតសម័យ ឬឲ្យទោសទៅលំអក់ពណ៌
ដល់ជាតិប្រជាពលនិករ ឬក៏ជាធម៌ដឹកនាំសត្វ ។

យើងសូមបញ្ជាក់មួយវគ្គទៀត ដោយធៀបជ្រើសយកពាក្យមកស្អាត
ចំពោះបញ្ហាការប្រតិបត្តិ តាមខ្សែបន្ទាត់ពុទ្ធសាសនា ។
អ្នកខ្លះបួសហើយលាត់សើយវិល រប៉ូចរប៉ុលវិលសិក្ខា
ត្រូវបានទោសពោរជោរហ៊ុហា មានពាក្យគេថា គ្រប់ទិសទី ។

ឲ្យបួសយ៉ាងហ្មឹងបាត់តម្លៃ　　នាំតែហិនហៃប្រពៃណី
ដូចដែករីងរែះត្រូវច្រែះស៊ី　　ល្អួចឈឺចំលុះឲ្យធ្លុះធ្លាយ ។
　　សំដីទាំងនេះយើងរិះគិត　　ក៏ឃើញថាពិតឥតប្រែក្លាយ
តែបើរៀបចំតាមបរិយាយ　　យើងអាចដោះស្រាយយ៉ាងនេះថា -
　　សាសនាព្រះពុទ្ធបរិសុទ្ធថ្លៃ　　ជាទីអាស្រ័យជនគ្រប់គ្នា
គ្មានរើសមុខមាត់ចិត្តយ៉ាងណា　　ឲ្យតែជ្រះថ្លាក៏បួសបាន ។
ព្រោះជាសាសនាប្រសើរក្តាត់　　របស់មនុស្សសត្វគ្រប់គ្រប់ប្រាណ
ជនណាជ្រះថ្លាក្នុងសន្តាន　　ក៏អាចបួសបានដូចដូចគ្នា ។
តែបើបួសហើយល្មើយគំនិត　　ប្រព្រឹត្តល្មើសច្បាប់នៃសាសនា
ព្រះពុទ្ធជាម្ចាស់លោកត្រាស់ថា　　លោកគ្មានធានាជននោះឡើយ ។
បើគេដាំក្រូចបានផលក្រូច　　បើគេសាងខូចអាក្រក់ហើយ
មិនអាចចៀសពីផលនេះឡើយ　　នេះជាពាក្យឆ្លើយល្អមគ្រប់គ្រាន់ ។
មួយទៀតបើយើងនឹងដោះស្រាយ　　ឲ្យឃើញវែងឆ្ងាយខាងបច្ចុប្បន្ន
យើងអាចប្រៀបធៀបឲ្យជាក់ស្ដែង　　ចែកជាថ្នាក់ជាន់តាមតម្លៃ ។
អ្នកបួសពួកខ្លះក្រាស់ដោយបាប　　ប្រព្រឹត្តថោកទាបខុសវិន័យ
ពិតមែន, ប៉ុន្តែបើប៉ាន់ថ្លៃ　　ប្រៀបមើលតម្លៃទោសនិងគុណ ។
គង់ឃើញថាគោលការប្រព្រឹត្ត　　ផ្ទុលខាងសុចរិតច្រើនជាងមុន
គឺមានការធ្វើអំពើបុណ្យ　　និងគុណបវរល្អច្រើនណាស់ ។

រីឯការទ្រុស្តខុសចរិយា　ពានត្រសិក្ខាដោយឥតខ្លាស
វាជាការតូចស្តួចស្តើងណាស់　យកមកប្រកាសក៏មិនសម ។
មួយទៀតច្បាប់សង្ឃអង្គល្អិតខ្ពស់　ជាងច្បាប់គ្រហស្ថខាងអប់រំ
ហើយច្បាប់នេះទៀតជ្រៀតក្រឹត្យក្រម　មានតូចមានធំជាច្រើនស្ថាន ។
ចំណែកអ្នកបួសដែលជ្រះចិត្ត　ជ្រុលខាងប្រព្រឹត្តចិត្តបំពាន
បំពានក្រឹត្យក្រមធំប្រធាន　ក៏លោកមិនហ៊ានបំពានដែរ ។
ជ្រុលជ្រួសជ្រោះធ្លោយដោយនិស្ស័យ　ត្រឹមតែទោសពៅគួរស្តីដេរ
ត្រង់ហ៊ានជាខ្លាំងនឹងច្បាប់ខ្មែរ　យើងឃើញហើយដែរកម្រណាស់ ។
កំហុសតិចតួចស្តួចស្តើងហ្នឹង　បើគៃលៃថ្លឹងគង់ឃើញច្បាស់
វានៅតែត្រង់ត្រូវល្អណាស់　ជាងគ្រហាវសផងទាំងឡាយ ។
គ្រហស្ថអស់ត្រឹមច្បាប់ផែនដី　ក្រៅនេះសេរីមានទូលាយ
ចង់ធ្វើយ៉ាងម៉េចហៅសប្បាយ　ក៏គ្មានគិតកាយក្រែងអាបត្តិ ។
រឿងស្រីរឿងស្រាបាក់ច្រៀង　ស្តាប់សូរស័ព្ទសៀងច្រៀងប្រតិព័ទ្ធ
ស្រែកហ៊ោកញ្ច្រៀវពុំក្រែងមាត់　ដើរលាត់ដើរសើយតាមចិត្តចង់ ។
ដើរលែងលំហែក្បែរមុខរាំង　ក្រៀបក្រាលើតាំងកៅអីបង់
មើលកុនមើលល្ខោនឡកកំរង់　ធៀតដើរចែចង់ផ្លូវស្នេហា ។
មានប្តីប្រពន្ធរួមស្នេហ៍ស្និទ្ធ　ផ្តេកផ្តិតផ្លូវកាមតាមប្រាថ្នា
ជិះកង់ជិះឡានស្រែកឡូឡា　ចង់ធ្វើយ៉ាងណាក៏គ្មានភ័យ ។

គ្មានគិតគិតភ្ញាក់នឹកនាំក្រែង    អាបត្តិអាប្រែងច្បាប់វិន័យ
ឯលោកសង្ឃវិញគ្មានទិសស្រ័យ    លោកគ្មានអស់ដៃអីដល់ម៉ឹង ៗ
បើធៀបប្រៀបប្រឹតចិត្តជាបុណ្យ    ផញ្ចឹងទោសគុណទប់ទល់ថ្លឹង
រវែកដូចវែងថ្លឹងអីចឹង    ពណ៌នាបុណ្ណឹងជាទំនង ៗ
ប៉ុន្តែសូមមិត្រម្រួមសាសនា    យល់ឲ្យច្បាស់ថាការខុសឆ្គង
របស់អ្នកបួសទាំងនោះផង    ទោះជាសៅហ្មងតូចក៏ដោយ ៗ
ក៏ច្បាប់វិន័យកាត់ក្រីទោស    មិនដែលសន្តោសអនុគ្រោះឲ្យ
លោកដែលប្រព្រឹត្តចិត្តធ្លោះធ្លោយ    ត្រូវប្រែកែក្រោយឲ្យស័ក្តិសម ៗ
ពីព្រោះករណីយកិច្ចលោកសង្ឃ    ដោយត្រង់គឺដៅការអប់រំ
ឲ្យល្អចរិយាជាប្រថម    ទើបគេមកខំប្រឹងអត់បាយ ៗ
ចុះបើមកបួសជ្រួសបណ្តោយ    បណ្តែតចិត្តឲ្យទៅកឃមាយ
ធ្វើតាមតែចិត្តគិតសប្បាយ    យកតាមតម្រាយត្រឹមហាក់ស ៗ
ការបួសចិញ្ចឹមចិត្តដូច្នេះ    ពិតជាគ្មានខ្វះគួរឲ្យខ្មាស
បួសតាំងពីក្មេងវែងដល់ចាស់    គ្មានផ្លាស់ចរិយាមារយាទព្រាណ ៗ
ការបួសនោះទៀតក៏គ្មានន័យ    មានតែទោសពៃរ៍អន្តរធាន
ការខ្វះក៏ភាគជាតិក៏ខាន    បង់បាយមិនបានប្រយោជន៍អ្វី ៗ
អ្នកបួសលោកដឹងខ្លួនយ៉ាងនេះ    បានជាលោកបេះតាំងស្មារតី
ប្រព្រឹត្តអប់រំតាំងតាស់ថ្មី    ឃើញគួរគប្បីមិនសូវឆ្គង ៗ

អ្នកស្រែធ្វើស្រូវរដូវកាល ស្ទុះស្ទាស្រើបស្រាលដោយបំណង
ចង់បានផលច្រើនជាងមិត្រផង ដោយនូវគន្លងផ្លូវសុចរិត ។
រីឯអ្នកបួសក៏ដូច្នោះ ប្រឹងប្រែងក្រោយដោះខាងផ្លូវចិត្ត
យកជ័យជំនះឈ្នះអស់មិត្រ ដោយការប្រព្រឹត្តិអប់រំប្រាណ ។
អស់មិត្រទាំងឡាយរួមសាសនា មានចិត្តជ្រះថ្លាដែលបានអាន
សូមមិត្រមេត្តាកុំខាន នឹកស្មានថាខ្ញុំក្រុមទៅក្រោយ ។
ខ្ញុំក្រុងចង់ជាបទបរិយាយ នេះគឺដោះស្រាយការថ្លោះធ្លោយ
ដែលអស់យុវជនជំនាន់ក្រោយ បណ្ដោយតាមចិត្តបំបិទគុណ ។
មិនបើកឲ្យឃើញភាគផលល្អ ដែលកកើតពីស្រែបុណ្យ
ជាដែនជំរកមកពីមុន ជាគុណជួយកែកូនខ្មែរអើយ ! ។

—ចប់—

ផ្ដាញ់កាបដោយការធ្វើកាបតប
ផ្ដាញ់អបដោយអាបធ្វើអប ត
ផ្ដាញ់ល្អដោយល្អិតធ្វើចិត្តល្អ
ផ្ដាញ់ក្រដោយតស៊ូធ្វើខ្ជត់

—— ៥ - ៩ ——

## ផ្នែកអក្សរសាស្ត្រ

អក្សរសាស្ត្រខ្មែរ ខ្មែរគួរថែថ្នម
ឲ្យបានខ្ជាប់ខ្ជួន គង់វង្សគត់មត់
ព្រោះអក្សរជាតិ ពោលជាតិប្រាកដ
អក្សររលត់ ជាតិក៏រលាយ

ប.ព.

# ពិចារណាដើម្បីយល់តក្កវិជ្ជា

(គ)

លោក ហ៊ុន គិមសៀ រៀបរៀង

យើងទាំងអស់គ្នាពិនិត្យតាមឧទាហរណ៍នេះ ក៏អាចយល់បានភ្លាមថា នេះហើយមកអំពីការសួរគ្មានវិធាន សួរប្រឡូកប្រឡល់ អាងតែខ្លួនធ្វើទុកបេះតែសួរមិនគិតគូរ ទាល់តែជាប់ទឹងសំនួររបស់ខ្លួនវិញ ។ និយាយសង្ខេបមកវិញគឺថា យើងទាំងអស់គ្នាសុទ្ធតែទទួលយល់ព្រមថា មានវិធានមែនក្នុងការរៀបចំគំនិត ដើម្បីនិយាយឲ្យបានត្រឹមត្រូវនឹងជាក់លាក់ ពីព្រោះថាសំដីជារូបភាពនៃគំនិត បើគំនិតសាំញ៉ាំប្រឡូកប្រឡល់គ្មានក្បាលកន្ទុយ . . . តើសំដីយើងមានសណ្ដាប់ធ្នាប់គ្រោះគ្រាយទៅម្ដេចកើត ? ការនិយាយចេញទៅ គេស្ដាប់មិនបាននេះហើយ ដែលអ្នកប្រាជ្ញបណ្ឌិត គេចងក្រងទៅជាក្បួនសម្រាប់សិក្សាដែលយើងហៅថា តក្កវិជ្ជា គឺជាវិជ្ជារៀបចំគំនិត ទុកដាក់សំដីដើម្បីនិយាយឲ្យបានជ័យជំនះ ។

# វិធានកើតពីណាមក ?

ខាងលើ យើងបានអធិប្បាយរួចមកហើយ ក្នុងការនិយាយទាក់ទងគ្នា មនុស្សយើងគេប្រើសំដី ។ និយាយដល់សំដី, មានតក្កវិទូម្នាក់មានយោបល់ថា : " សំដីជាឧបករណ៍នាំឲ្យមនុស្សយោគយល់គ្នាបាន ", " ការវិវត្តន៍ជឿនលឿនគ្រប់ផ្នែក ជាពិសេសគឺខាងផ្នែកគំនិតបញ្ញារបស់មនុស្សមួយភាគធំដែលរស់នៅក្នុងសង្គម ក៏អាស្រ័យមកតែអំពីសំដីគំនិតដែលគិតតែទទេ ៗ ប្រាសចាកសំដី ប្រាសចាកសម្ភារៈ គឺមិនអាចទុកជាធរមានបានទេ " ។

បើយើងធ្វើការពិចារណាចំពោះការទាក់ទងយ៉ាងជាក់ស្ដែងខាងលើនេះ, យើងទាំងអស់គ្នាយល់ថា : សំដីជាសំបកខាងក្រៅ ទុកដូចជារូបភាព សតិអារម្មណ៍ ( គំនិត ) នៅខាងក្នុង ទុកដូចជាអត្ថរស ឬខ្លឹមសារនៃសំដី ។ គឺចាប់ពីត្រង់នេះទៅហើយដែលនាំឲ្យកើតជាបញ្ហាមានរូបភាព ( សំដី ) និង អត្ថរស ( គំនិត ) ហើយតក្កវិជ្ជារូបភាព ក៏ជាវិជ្ជាសិក្សាអំពីរូបភាពនិងវិធានប្រើរូបភាពពោលគឺសំដី ដែលលាតត្រដាងនូវគំនិតខាងក្នុង ឲ្យចេញមកក្រៅនោះ ។ តាមធម្មតា រវាងរូបភាព និងអត្ថរសច្រើនមានការផ្ទុយគ្នា គឺថា សំដីនិយាយដែលចេញមកក្រៅ ជួនកាលមិនអាចបកស្រាយនូវគោលគំនិតខាងក្នុងឲ្យបានក្បោះក្បាយត្រឹមត្រូវទេ ពីព្រោះតែយើងមិនយល់វិធានសម្រាប់ប្រើសំដី ហេតុ

នេះហើយបានត្រូវមានតក្កវិជ្ជារូបភាពពន្យល់ឲ្យយើងយល់នូវ “វិធាន” ក្នុងការប្រើរូបភាពពោលគឺសំដីនោះឲ្យបានជាក់លាក់ហ្មត់ចត់ មានសមត្ថភាពអាចបកស្រាយពន្យល់នូវគំនិតខាងក្នុង ឲ្យបានត្រឹមត្រូវ ។ មនុស្សមានគំនិតល្អ, តែបើសំដី មិនអាចបកស្រាយបានគំនិតល្អនោះទេ អ្នកដទៃក៏គេមិនអាចយល់នូវលក្ខណៈល្អបានរបស់យើងបានដែរ, ហេតុនេះ តក្កវិជ្ជារូបភាព មានភារៈទទួលខុសត្រូវនៅក្នុងវិស័យនេះឯង ។

## តើរូបភាពនិងវិធានត្រិះរិះនៃតក្កសាស្ត្ររូបភាព វាយ៉ាងណាខ្លះ?

តក្កសាស្ត្ររូបភាពមានសមត្ថភាពសិក្សា, ពិចារណានូវរូបភាព និង វិធានតុបតែងគំនិត ដើម្បីលាតត្រដាងសតិអារម្មណ៍ឬបំណងរបស់ខ្លួនឲ្យបានជាក់លាក់យ៉ាងទៀងទាត់ ។ ដូច្នេះ, តក្កសាស្ត្ររូបភាព មិនសូវជាសំគីដល់អត្ថរសនៃបញ្ហាប៉ុន្មានទេ, សំគាល់ពិចារណាតែអំពីវិធាននៃការលាតត្រដាងពោលគឺការលេងសំដីច្រើនជាង បានសេចក្តីថា : តក្កសាស្ត្ររូបភាព ពុំមែនមិនដឹងដល់អត្ថរសនៃបញ្ហាអ្វីបន្តិចបន្តួចនោះទេ, ប៉ុន្តែភារៈរបស់វា ត្រូវត្រិះរិះខាងរបៀបប្រើសំដី ខាងការលេងវោហារឲ្យបានសមរម្យនិងត្រឹមត្រូវ ច្រើនជាង ។

និយាយថា តក្កសាស្ត្ររូបភាព ដែលមានដំណើរ ឬ ទិន្នាការ តែខាងប្រើសំដីនោះ តើមានន័យយ៉ាងដូចម្តេច ?

ដើម្បីឲ្យងាយយល់ យើងសុំជូនឧទាហរណ៍ខ្លះ ។ នៅក្នុងវិស័យ

អក្សរសិល្ប៍ (Domaine litteraire) មកបញ្ជាក់ដូចត ៗ ៖

វណ្ណកម្មអក្សរសិល្ប៍ (Œuvres littéraires) មានអត្ថរសនិងរូបភាពរបស់វា ។ អត្ថរស មានកប់រយកប់ពាន់ ប៉ុន្តែវាសំដែងចេញលេចឡើងដោយរូបភាព ជា កំណាព្យ, ជាល្ខោន, ជាប្រលោមលោក, ឬ ជារូបភាពផ្សេង ៗ ។ល។ បានសេចក្តីថា : តក្កសាស្ត្ររូបភាពត្រូវទទួលខុសត្រូវចំពោះវិធីតែង, របៀបចងក្រងកំណាព្យ, របៀបនិពន្ធ.... ចំណែកឯអត្ថរស វាមានខុសមានត្រូវ អនុលោមទៅតាមទស្សនៈនៃអ្នកនិពន្ធនោះ តក្កសាស្ត្ររូបភាពមិនសូវទទួលខុសត្រូវប៉ុន្មានទេ ទុកឲ្យវិទ្យាសាស្ត្រដែលមានសមត្ថកិច្ច ឬមុខងារនាទីដូចជាទស្សនវិជ្ជា (Philosophie) តៅវិនិច្ឆ័យទៅចុះ ។

ដើម្បីឲ្យងាយយល់, យើងសុំលើកយកឧទាហរណ៍ មនុស្សខ្លាក់ ៤ នាក់ ដែលគ្នាអំពីរូបដំរី មកពិចារណា :

ក— ១— ដំរីដូចឈើង

 ២- ដំរីដូចសសរផ្ទះ

ការីនាក់ទៀតត្រឡប់ ជានិយាយថា :

ខ - ១- ដំរីដូចសសរផ្ទះ

 ២— ដំរីមិនដូចសសរផ្ទះទេ

ក្នុងករណីទាំងពីរខាងលើនេះ តើមិត្តយល់ថា វាមានរយោចល់

ខុសគ្នាយ៉ាងណា ? តើយើងអាចយកក្បួនតក្កសាស្ត្រ ទៅប្រើក្នុងការនិយាយ ជាមួយមនុស្សម្នាក់ៗនោះរបៀបណា ក្នុងពេលដែលយើងមិនស្គាល់សត្វដំរីដូចគ្នា ។

ការពិត ក្នុងករណីដែលយើងមិនស្គាល់សត្វដំរីដូចគ្នានោះ យើងពុំអាចយករបៀបតក្កសាស្ត្របុរាណទៅប្រកែកការកាត់ អំពីរូបរាងដំរី ថាជាយ៉ាងនេះឬយ៉ាងនោះបានទេ ប៉ុន្តែមនុស្សម្នាក់ពីរនាក់ឆ្លើយក្នុងករណី " ៣ " តក្កសាស្ត្របុរាណអាចយល់បានថា : ចម្លើយនោះខុសទាំងពីរនាក់ ពីព្រោះឆ្លើយក្នុងវិធ្ធីចង្អៀត ។ ចំណែកឯក្នុងករណី " ១ " វិញ គឺតក្កសាស្ត្របុរាណអាចយល់បានថាមានមួយត្រូវ មួយខុស ពីព្រោះចម្លើយថា " ដំរីមិនដូចសសរផ្ទះទេ " វាខ្ចូណាយជាងវាឆ្ងាយត្រូវជាង ។ ការពិត ដំរីរាងដូចអី ក៏ដូចទៅ ឲ្យតែខុសពីសសរផ្ទះអាចត្រូវនឹងច មួយយើងបាន ពីព្រោះចម្លើយយើង មិនបានបញ្ជាក់អះអាងជាដូចនេះឬដូចនោះ . . . ។ល។

ចំពោះករណីទី ២ ទៅ បើមានគំនិតផ្ទុយគ្នាបែបដូច " ១ " ខាងលើ, តក្កសាស្ត្របុរាណបើកច្បាប់ឲ្យយើងឆ្លើយតែត្រឹម " មានមួយខុស មួយត្រូវ " ប៉ុណ្ណោះទេ តែត្រង់បញ្ជាក់ថា : អ្នកណាមួយខុស អ្នកណាមួយត្រូវគឺតក្កសាស្ត្រមិនឲ្យបញ្ជាក់ទេ ។ ( ប្រការនេះនឹងនិយាយច្បាស់ក្នុងជំពូកក្រោយ ) ។

## វិធានសំខាន់ ៗ នៃតក្កសាស្ត្ររូបភាព

តក្កសាស្ត្ររូបភាពបង្កើនទំលាតត្រដាងឡើង នូវរូបភាព, នូវវិធីប្រើសំដី, នូវវិធានត្រិះរិះនៃគំនិត . . . ហេតុដូច្នេះ បន្ទាប់នេះ យើងនឹងសិក្សាម្តងមួយ ៗ នូវប្រការសំខាន់ ៗ នៃតក្កសាស្ត្រ ។

តក្កសាស្ត្ររូបភាពបានអះអាងថា : គំនិតណាមួយដែលសមហេតុ ហើយត្រឹមត្រូវ គឺជាគំនិតដែលគ្មានការផ្ទុយ សំដីជាក់លាក់, ត្រូវតែ ក្បោយ, មានហេតុផល, ហើយមានឯកភាព . . . ។ ផ្ទុយទៅវិញ, បើគំនិត ឬពាក្យសំដីណាដែលមានការខ្វែងយោបល់ខាងក្នុង, និយាយ ចាប់ចុងព្រយុងដើម មិនច្បាស់លាស់ . . . មិនអាចនាំជ័យជំនះ ឬ នាំ ការបេះដឹង ឬ កំពន្យល់បញ្ហាណាមួយបានលទ្ធផលទេ ពីព្រោះគំនិត យើងខុស, វិធីប្រើសំដីកមិនច្បាស់ ស្រពិចស្រពិលនាំឲ្យគេច្រឡំ . . . ។ល។ ពីព្រោះតែសេចក្តីត្រូវការឲ្យបានច្បាស់លាស់នៃគំនិតរបស់ យើង ក្នុងការប្រើសំដីនេះហើយ, បានជាតក្កសាស្ត្ររូបភាព បាន បង្កើនឡើងជាវិធាន ៤ យ៉ាង ដែលគេហៅថា វិធានជាមូលដ្ឋាន នៃតក្កវិជ្ជា គឺមាន:

១ - វិធានឯកភាព (Le principe d'identité)

២ - វិធានផ្ទុយ ( Le principe de contradiction )

( អាចហៅថាវិធានមិនផ្ទុយក៏បាន )

៣- វិធានចាត់ចោលភាគទីបី ឬវិធានកណ្ដាល

– Le principe du milieu ou tiers exclu

៤- វិធានគានហេតុផលឬ វិធានមានហេតុផលគ្រប់គ្រាន់

– Le principe des Raisonnements biens complets

ហើយម្យ៉ាងទៀត តក្កសាស្ត្របុរាណ នៅមានពិចារណាដល់អត្តរូប (Forme) នៃការត្រិះរិះទៀត ដូចជា :

ការយល់ Concept

ការវិនិច្ឆ័យ Jugement

ការសន្និដ្ឋាន Déduction

នៅចុងក្រោយបង្អស់ តក្កសាស្ត្របុរាណនិយាយដល់បញ្ហាភស្តុតាងបញ្ជាក់ ។

មនុស្សយើងទាំងអស់គ្នា គ្មានអ្នកណាកើតឡើងហើយស្រាប់តែចេះពូកែតែម្ដងនោះទេ ការចេះដឹងតែងកើតមកពីការរៀនសូត្រដោយស្វិតស្វាញម្ដងបន្តិច ៗ ។ ហេតុនេះ រឿងតក្កវិជ្ជា ចំពោះមិត្តខ្លះដែលមិនបានធ្លាប់ត្រចៀកនឹងវិជ្ជានេះ មិនអាចគេចផុតពីការពិបាកស្ដាប់ទេ ប៉ុន្តែយើងខ្ញុំជឿថា : បើមិត្រទ្រាំលំបាក អានម្ដងបន្តិច ៗ នឹងប្រឹងពិចារណាឱ្យយល់បាន យើងជឿថាវិជ្ជានេះនឹងមានប្រយោជន៍ច្រើនដល់ការនិយាយស្ដីរបស់មិត្តក្នុងអនាគត ។

## ជំពូកទី–២

## ពិចារណាគឺជាអ្វី?

### ពិចារណាគឺជាចលនានៃខួរក្បាលដើម្បីការចេះដឹង

យើងទាំងអស់គ្នាកំពុងតែសិក្សាតក្កសាស្ត្រ, តក្កសាស្ត្រគឺជាវិទ្យាសាស្ត្រនៃការពិចារណា; ដូច្នេះ យើងទាំងអស់គ្នា គួរបានយល់អំពីការពិចារណាតើវាជាអ្វីសិន ជាមុនដែរ ។

### ពិចារណាគឺជាអ្វី?

ខ្ញុំបានឃើញសិស្សខ្លះអង្គុយសម្លឹងមើលដំបូលថ្នាក់, សិស្សខ្លះចងចិញ្ចើម, ប្របាច់ថ្ពាស, មានសិស្សខ្លះទៀតខាំដងប៉ាកកាលេង ៗល។ បើកាលណាយើងសួរគេ គេនឹងឆ្លើយប្រាប់យើងថា: គេកំពុងតែពិចារណា គេពិចារណាមិនទាន់ឃើញ (ខ្ញុំសុំប្រើពាក្យគិតជំនួសពិចារណា) ។

កាលណាយើងគិតអ្វីមួយមិនឃើញវាហាក់ដូចជាខួរក្បាលយើងគ្មានចលនា គឺជាខួរក្បាលយើងវានៅស្ងៀមមួយកន្លែង ។ វាមិនខុសគ្នានឹងម៉ាស៊ីនឡានខូច បើចង់ឲ្យវាទៅមុខទៀត មនុស្សត្រូវតែរុញវា ។ កាលណាគិតមិនឃើញ មនុស្សយើងខំប្រឹងគិត : ដៃស្ទាបក្បាល ប្របាច់ថ្ពាស . . . ហាក់ដូចជារុញច្រានខួរក្បាលយើងឲ្យវាលឿនទៅមុខមួយគ្រឹត បើយើងពិនិត្យមើលរូបភាពខាងក្រោមយើងនឹងឃើញថា : ការគិតគឺជាចលនានៃខួរក្បាល ។

បើមិត្តណាធ្លាប់បានយល់វិជ្ជាបដិច្ចសមុប្បាទ ( Dialectique ) ខ្លះ ៗ ពីមុនមកហើយ គេមុខជានឹងយល់ថា បាតុភូតទាំងអស់សុទ្ធតែជាសភាវៈចលនា ។ គំនិត គឺជាបាតុភូតធម្មជាតិ ហេតុដូច្នេះគំនិត ក៏មិនមែនជាចលនាឯណាបាន ? ។

តែនិយាយដល់ចលនាៈហើយ គឺយើងត្រូវនិយាយដល់សម្ភារៈហើយ ពីព្រោះសម្ភារៈទើបក៏មានចលនា ។

ក្នុងរឿងគំនិត Pensée នេះ យើងខ្ញុំនឹកទៅដល់ឃ្លាមួយដែលគេច្រើនតែនិយាយថា : " ខ្ញុំគិតល្អិតម៉ត់អស់ហើយ " ។ ពាក្យថាល្អិតម៉ត់ នាំឲ្យខ្ញុំនឹកឃើញទៅដល់រឿងកិនម្សៅ គឺថាកិនអង្ករឲ្យល្អិតម៉ត់ទៅជាម្សៅ ។

និយាយមកដល់រឿងកិនម្សៅនេះ ខ្ញុំសុំទោសមិត្តអ្នកអានបើករង្វង់ក្រចកមួយ ។ គឺថា : មិត្តក៏ធ្លាប់បានអានសៀវភៅតក្កសាស្ត្រជាអក្សរបរទេស អ្នកនិពន្ធជាតិណាមួយ បើគេសរសេរគឺគេបម្រើផលប្រយោជន៍ខាងគំនិតរបស់ជាតិគេ គេយកឧទាហរណ៍ណាដែលមានលក្ខណៈស្របទៅតាមសមត្ថភាពនៃប្រជាជនស្រុកគេ ពោលគឺលក្ខណៈនៅក្នុងស្រុកដូច្នេះ ក្នុងករណីពន្យល់រឿងចលនា យើងខ្ញុំសុំយកឧទាហរណ៍ជាក់ស្តែង ដែលប្រជាជនយើងភាគច្រើនធ្លាប់បានប្រទះកន្លងមក ដើម្បីឲ្យងាយយល់ដូចជារឿងកិនម្សៅនេះ ។

គំនិតម្យ៉ាងគឺជាចលនាមួយ គឺចលនារបស់ក្បាលគំនិតអន្តរទៀតល្អិតម៉ត់ទៅជាម្យ៉ាង ហេតុនេះបើយើងប្រៀបធៀបទៅនឹងការគិតគឺយ៉ាងដូច្នេះ ៖ គិតគឺជាចលនានៃខួរក្បាល ( ខួរក្បាលជាសម្ភារៈ ) ដែលយើងទុកដូចជាក្បាលនៅខាងលើ ។

ចង់គំនិតម្យ៉ាងត្រូវមានអង្គរយកទៅគំនិតនឹងក្បាល ហេតុនេះ ចង់គិតមនុស្សក៏ត្រូវមានបញ្ហា, ចំណាំ . . . ដើម្បីគិតអំពីដែរ ខួរក្បាលមនុស្សមិនអាចគិតទទេ ៗ បានទេ ។ រឿងរ៉ាវ, ចំណាំ, បញ្ហាទាំងអស់នេះ គឺជាសម្ភារៈ ដែលវិញ្ញាណរបស់យើងទទួលបានមកធ្វើឧបករណ៍សម្រាប់ឲ្យខួរក្បាលគិត ។ និយាយសង្ខេបមកវិញបានសេចក្តីថា ៖ គិតគឺជាចលនានៃខួរក្បាលផ្អែកទៅលើសម្ភារៈខាងក្រៅជាមូលដ្ឋាន ដើម្បីធ្វើយ៉ាងណាឲ្យមនុស្សយល់បានទូទៅបាតុភូតទាំងអស់នៅក្នុងប្រព័ន្ធទាំងមូល ។

ប្រការនេះសំខាន់ណាស់ សព្វថ្ងៃនៅលើសាកលលោកទាំងមូលក៏មានការបែកប្រណាំងគ្នាមិនចេះចប់មិនចេះអស់ពីរឿងសម្ភារៈ និងគំនិតនេះដែរ ដែលគេហៅថាពួក Matérialisme dialectique និងពួក Idéalisme métaphysique ( ពួកសម្ភារៈនិយមបដិច្ចសមុប្បាទ និងពួកគំនិតនិយមបរមត្ថសាស្ត្រ ) ។

(នៅមានត)

# វចនានុក្រមសំស្ក្រឹត-ខ្មែរ

(ត)

*ព្រះមហា ចាំង-ខាត់ រៀបរៀង*

---

-សានុ ក្រ.វិ. ព្ធដ៏ធំរវៃភ្នំ ។ -សារ គុ. ដែលមានសារៈព្ធដ៏ខាងក្នុង ។ នបុ. ភាពខាងក្នុង; ពល. ខាងក្នុង, ទ្រព្យដែលកប់ទុក, បម្រុក ។ -សុខ គុ. ដែលមានសេចក្តីសុខព្ធដ៏ខាងក្នុង ។ -ស្ថ គុ. ដែលឋិតនៅខាងក្នុង ។ -ស្បឝ៌ គុ ដែលប៉ះពាល់ព្ធដ៏ខាងក្នុង ។ -ស្វេរ គុ. ដែលស៊ើបព្ធដ៏ខាងក្នុង ។ -អន្តឝ្ចរ គុ. ដែលកម្រើកខាងក្នុង, ដែលនៅក្នុង ។ -អន្តស្តាប ពុ. ភ្លើងខាងក្នុង, គុ. ដែលឆេះព្ធដ៏ខាងក្នុង ។ អន្តស្តុហ៍ គុ. ដែលមានដំណក់ទឹកព្ធដ៏ខាងក្នុង ។ --អន្តស្តោយ គុ. ដែលមានទឹកព្ធដ៏ខាងក្នុង ។

អន្តរ គុ ដែលនៅខាងក្នុង, ដែលនៅជិតខាង, ជិតៗ, ស្និទ្ធស្នាល ។

នបុំ ខាងក្នុង, ទីចន្លោះ, រន្ធ, ។ ចម្រក, ទីចន្លោះ ។ កាល, សម័យ, ភាគ ។ សមាជិកកណ្តាល ។ ១, សេចក្តី ។ ចម្ងាយ, ភាពឆ្ងាយ, ភាពទីទៃពីគ្នា ។ អាការពិសេស, ឱកាស, ទោសជាចន្លោះ, ការដោធា ។ —គត គុ. ដែលនៅចន្លោះ, ដែលនៅឆ្ងាយ , —ចារិន គុ. ដែលត្រេចទៅឆ្ងាយ ។ —ជ្ញ គុ. ដែលដឹងទៅខាងក្នុង, ដែលដឹងច្បាស់ ។ —ទ្ទស្សិ ដែលឃើញនូវកណ្តាល ។ —បតិត គុ. ដែលធ្លាក់ក្នុងចន្លោះ, ដែលបាត់, ដែលមិនមាន ។ —បុរុឞ បុំ. (បុរសខាងក្នុង) —អាត្មធិ ព្រលឹង ។ —ប្រភវ (ដែលកើតក្នុងចន្លោះ) បុំ. វណ្ណៈលាយគ្នា ។ —ប្រេក្សិន គុ. ដែលមើលឃើញទោសជាចន្លោះ ។ —ស្ថ គុ. ដែលឋិតនៅជាចន្លោះ, បុំ សាក្សី ។

អន្តរាន្វេសិន គុ. ដែលស្វែងរកទោសជាចន្លោះ, ដែលចាំឧកាសជាទំនង ។ —អន្តរាគមន នបុំ. កិរិយាឆ្លង ។

−អន្តរាទិស ស្ត្រី. ទិសជាចន្លោះ ។ −អន្តរាវេទិ ស្ត្រី របៀង, ជញ្ជាំងខាន់ ។ −អន្តរេចរ គុ. ដែលចរនៅក្នុងផ្ទះ ។

អន្តរាល នប៉ុ. ពេលជាចន្លោះ, ខាងក្នុង ។ គុ. ដែលនៅជាចន្លោះ អន្តរាលេ ក្នុងពេលកំពុងដើរ ។

អន្តរ-តិ ធាតុ ទៅក្នុងចន្លោះ, លាក់, ញែក ។

អន្តរិក្ស នប៉ុ. អន្តរិក្ស ទីចន្លោះឰដ៏អាកាស, អាកាស, មេឃ ។ −ក្សិត គុ. ដែលនៅលើអាកាស ។ −លោក ប៉ុ. អន្តលោក មេឃ, ។ −សទ៍ គុ. ដែលនៅលើមេឃ ។ −អន្តរីក្សគ គុ. ដែលទៅតាមអាកាស, ប៉ុ. បក្សី ។

អន្តរីយ នប៉ុ. អន្តរីយ អាវទ្រនាប់ ។

អន្តជ៌្វល ធាតុ ឆេះខាងក្នុង, ភ្លឺខាងក្នុង ។

អន្តទ៌ហ ធាតុ ឆេះខាងក្នុង ។

អន្តធ៌ា ធាតុ លាក់, ទុក, លាក់ទុក, បំបាត់ ។

អន្តភិត្តិ ជាតុ ធ្វើការផ្សាត់ ។

អន្តភិប្ប ជាតុ ជ្រាបចូល, នៅខាងក្នុង ។

អន្តភ្រិម្ប ជាតុ ធ្វើឲ្យទន់ខ្សោយ ។

អន្តរ្វត្នី ស្ត្រី. ស្ត្រីមានគភ៌ ។

អន្តរ្វិស ជាតុ នៅខាងក្នុង ។

អន្តវន្ត គុ. ដែលមានទីបំផុត, ដែលកន្លងទៅ ។

អន្តស្ផុរ ជាតុ គ្រប់ពេញទាំងខាងក្នុង ។

អន្តិ អាយត. នៅជិត, ផ្ទុយ ។

អន្តិក ដែលទៅដល់ទីបំផុត ។ នបុ. ការនៅជិត ។

អន្តិម គុ អ្នកចុងបំផុត ។

អន្ត្យ គុ ដែលចុងបំផុត. វណ្ណៈចុងក្រោយ ។ -កម៌ន៑ នបុ. អន្តកម្ម ការរំលាយសព ។ -ជ គុ. បុ. អ្នកកើតក្នុងវណ្ណៈក្រោយបំផុត, -ជន្មន៑ -យោនិ ដូចគ្នា ។

(នៅមានត)

# ព្រះរាជនិពន្ធរាមកេរ្តិ៍

ភាគ ១២

(ក)

ពោលក ទីក-តាម

ស្រាវជ្រាវ និង រៀបរៀង

និយាយតាំងតែពីព្រះបាទទសរថ ក្រោយដែលបានតែងពិធីអាពាហ៍ពិពាហ៍ព្រះរាមរួចហើយ ក៏លើករេហ៍ពលវិលត្រឡប់ទៅនគរវិញ ប្រទះជួបនឹងរាមេសូរ ច្បាំងគ្នានឹងរាមេសូរ ។ ចាញ់ រហូតដល់ទូភីនិងទូកា ។ ស្លាប់ ទូភីទៅច្បាំងនឹងពាលី ។ សម្លាប់ទូភីស្លាប់ ។

*កាលនោះ ព្រះរាមសុរិវង្ស បានស្តាប់ពាក្យអសុរាសូរហើយ ទើបព្រះអង្គឆ្លើយតបទៅវិញថា រីខ្លួនឯងនេះ ចង់ដណ្តើមយកនាង ហើយមកអួតអាងថា មានបុណ្យានុភាពខ្លាំងក្រៃ ឯងមិនទាន់ដឹងគេដៃអញនេះ គឺព្រះនារាយណ៍បែងភាគ ចុះមកកើតជាព្រះរាមា នឹងប្រហារផ្ចាញ់ពួកពាលកុម្ភ័ណ្ឌ ដែលមានចិត្តទុច្ចរិតឫស្យា ឯងនេះឈ្មោះអ្វី បានជាអហង្ការក្លាហាន មិនដឹងប្រាណនឹងក្ស័យសូន្យអស់ហើយ ។ កាលនោះ រាមសូរអសុរក្លាហាន បានស្តាប់វាចាហើយ ក៏ក្តៅក្តួលខ្លួលឆេះក្នុងវិញ្ញាណញ័រអស់អង្គកាយា ហើយក៏ទះហត្ថាលាន់ឮផ្ទុងផាំងកាំងក្រពារ ហើយឆ្លើយតបទៅវិញថា រីខ្លួនអញនេះ ឈ្មោះរាមសូរទេវេស មានរិទ្ធិតេជៈដៃក្រៃពេកណាស់ ខ្លួនឯងជាមនុស្សប៉ុនសុចសត្វ ហេតុដូចម្តេចក៏ហ៊ានអួតថានារាយណ៍បែងភាគចុះមក ឯងនេះ ប្រៀបគណនាបីដូច*

ជាសត្វអំពិលអំពែក មកអួតពន្លឺឲ្យក្តៅស្មើនឹងព្រះសុរិយា ហើយនៃមនុស្ស ឯងកុំអាលអួត អម្បាលតែអង្គព្រះអរជុនគា មានរឿងព្រៃក្រែ ក៏គង់ក្ស័យរលត់មិនដៃអញ ឯងនេះ បើទុកជាព្រហ្ម ក៏ដីរ៉ាឯងគង់តែនឹងក្ស័យរលត់ផុតសង្ខារ ថាហើយ ក៏គន្ទ្រំបាទាក់ក្រោកតាំងប្រឹថពីគ្រវីក្រឡឹងតូចថៅពេជ្រ គេចវិញខ្ញាល់ ដូចកង្ហាល់កង្ហាវដែក សម្តែងឫទ្ធិតាំងព្រះសុរិយាអរុណោទ័យ មិនឃើញនៃខ្ទួនអស្សុក អាកាសវេហាស៍ក៏បណ្ដាលលាន់ឮគ្រឹកគ្រែង កក្រើកតាំងព្រៃព្រឹក្សាជាកោលាហល រន្ធះអស់ទឹកបន្ទឺស័ព្ទអឺតូអស់តាំងទសទិសា ។ កាលនោះ តាំងបីមហេសីអគ្គជាយា តាំងអគ្គអគ្គរេតសីតា ទូវអស់ហ្វូងកំណាន់ស្រីស្រីង្គារហោជាពលាករ បានឮស្នូរស័ព្ទសម្លេងគគ្រឹកគគ្រេងកក្រើកតាំងព្រៃព្រឹក្សាពនាវ៉ន ងងឹតបិទបាំងពន្លាក់មាគ៌ាស្ថាន អាកាសវេហាស៍ក៏ខ្មៅខ្មួលជង្គោលជង្គុំ ងងឹតទាល់មើលមិនឃើញគ្នា ដូចរាត្រីយប់ ព្រះនាងតាំងបី ក៏ភ័យភិតស្មើនឹងក្ស័យជីវិត ហើយស្រែកអឺងកង់រំពងតាំងព្រៃព្រឹក្សា ព្រះអង្គក៏ប្រាប់ថា មានពួកកុម្ភ័ណ្ឌមកតតាំងច្បាំងជាញជ័យ ទើបក្សត្រថ្ងៃមានព្រះរាជទៅនឹងព្រះរាជមហេសីតាំងបីថា ម្នាលនាងតាំងបី កុំនាងមានសេចក្តីស្លុតរន្ធត់ឡើយ ថ្ងៃអើយ ចូរនាងរង់ចាំមើលរិទ្ធិព្រះពរកូនសម្លាញ់យើងសិន ។

កាលនោះ ព្រះនាគយណ៍ហារីវង្សទ្រង់ចក្រនោះ លុះឃើញខាង

សីតាយោមិត្តភ័យភិតតក្កមាដូច្នោះហើយ ទើបព្រះអង្គថ្មមតុបត្រសោប
អង្គនាងសីតា ថាម្នាលអនុជ អ្នកកុំភ័យខ្លាចថ្វីអាយក្សា កុំថាដង់ងឹតមេឃ
ដីឡើយ ហើយបង្គឹងធ្នូប្រហារដីតេរឡក្សយប្រល័យផង់ហោង ៗ
ថាហើយព្រះអង្គទ្រង់ចាប់យកសរពាលចន្ទ ហើយក៏ក្រាកឈរឡើង
តម្រឹងធ្នូជ័យព្រះអង្គ ដ៏ល្អហាក់ដូចនៃអង្គព្រះកោសិយ៍ ចក្រីថ្លែងទៅ
ហោង ៗ រីស័ព្ទសន្ធឹកក៏លាន់ឮគគ្រឹកគឹកកង់រំពងទាំងអាកាសពសុធា
ក៏ញាប់ញ័រខ្ទារខ្ទរ រីទ្ធិអំណាចសរនោះ បណ្ដាលក្ដីស្មានដូចដួងអរុ-
ណោទ័យ ព្រះអង្គក្រឡេកមើលទៅវៃ ឃើញអសុរកមសូរ ៗ

កាលនោះ រីកមសូរនោះ លុះឃើញសិល្បមនុស្សថ្លែងមកដោយ
រិទ្ធិក្លាហានដូច្នោះ ក៏ទឹកក្រោធក្រេវក្រៃ ក៏ស្រែកគម្រាម ឮសព្ទ
សម្រេនដូចផ្គរលាន់ ហើយកុម្ភណ្ឌក៏ចាប់យកសិល្បជ័យវៃថ្លែងទៅដោយ
ចុគ្គាហោង ៗ រីស័ព្ទសន្ធឹកសរអសុរនោះ ក៏លាន់ឮសន្ធឹក ស្មើរ
នឹងក្ដុកផ្ទាប់ក្រឡាប់មហាប្រឹថពី ក៏ក្រើករំពើតដល់ឋានតុសិតា រីសរ
សក្កាអសុរនោះ ក៏ទៅប្រទក្សិណទានកដរថ មិនអាចនឹងចូលទៅជិតអង្គ
ព្រះចក្រាឡើយ ៗ កាលនោះ ព្រះភមាធិបតី ឃើញកមសូរ
យក្សាថ្លែងសរមកតគាំងច្បាំងនឹងព្រះអង្គដូច្នោះហើយ ទើបព្រះអង្គចាប់
យកព្រះវៃសង់សរអគ្គិសទីវត ហើយសម្ដែងថ្លែងទៅបំផ្លាញសរអសុរ
ព្រះអង្គទ្រង់តម្រង់ថ្លែងទៅ ក៏ឮលាន់ក្រើកទាំងត្រៃលោកា ៗ រីសរថ្មុ

នោះ ក៏ត្រឡប់កើតជាកង់ចក្រកែវភ្លឺផ្លេក ហើយក៏តម្រង់ត្រង់ទៅបំផ្លាញ សរយក្សាក៏ខ្ទេចខ្ទីដូចផង់ធូលីមួយរំពេច ដូចព្រិចភ្នែក ដោយតេជានុភាព ព្រះហត្ថា ៤ ។ កាលនោះ កមស្សូរអសុរ៍កើតក្រេវក្រោធជាខ្លាំងណាស់ ដូចភ្លើងប្រល័យកល្ប ហើយក៏ចាប់យកតួះថៅពេជ្រធ្វើគ្នា គ្រវែងពោល ទៅ លាន់ឮសន្ធឹកសន្ធាប់លើវេហាស៍ ដូចភ្លៀងធំ ងងឹតអ័ព្ទអស់ ទាំងសែនអរុណោទ័យ រីតួះថៅពេជ្រនោះក៏ដេញសរព្រះចក្រ ។ កាល នោះ រីព្រះកមាធិបតី ឃើញតួះថៅពេជ្រអសុរីមានឫទ្ធានុភាពមហិមា ទើបព្រះអង្គយកសរផ្កាផ្កាញរក ដ៏មានឫទ្ធិអំណាចសក្តាក្រៃ ហើយក្ប- ទ័យក៏បំណាន់មើលមិនព្រិចនេត្រា ព្រះយ៉ាតហ្មាទកស័ខ្ម ក៏ផ្លុងទៅ ដោយឫទ្ធិបោះ ។ លាន់ឮកក្រើកទាំងគិរីសុមេរុសត្តបរិភណ្ឌសីទន្តរ ហេតុទូទាំងពិភពលោក ដល់ទៅព្រហ្មអកនិដ្ឋ ងងឹតអន្ធការអ័ព្ទអស់ ទាំងទសទិសា រីសរផ្កាក៏ផ្កាញក្លូថៅពេជ្រអសុរា ។ កាលគ្រានោះ កមស្សូរសិទ្ធិស័ក្តិយក្សឃើញតួះថៅពេជ្របាញ់ឫទ្ធិសរព្រះកមា ក៏សែន ក្រោធ នេត្រាទាំងពីរក្រឡេកក្រឡៅជាលក្រហមប្រាលដូចផ្លូវអរុណោ ទ័យ គគ្រិំធ្មេញ ក៏ស្រែកសម្រែកសន្ធាប់ខ្លាំងក្រៃ អសុរក៏សម្តែង អំណាចញាប់ញ័រទាំងផែនដី ស្ទុះវៃចូលទៅចាប់ចុងចន្ទោលព្រះកជរថ របស់ព្រះកមា ដោយហត្ថាទាំង ៤ ហោង ។

កាលនោះ ព្រះសុរិវង្សអង្គនាករណ៍រិទ្ធី ត្រៀវត្រៀមសរធ្នូរដ៏យ

រស្មីភ្លឺដូចភ្លើងព្រាតព្រាយ ហើយស្ដេចក៏ក្រោយចុះពីរាជរថ ចូលក
ដៃនឹងអសុរប្រទាប់ចំបាប់គ្នាវិលវល់ទៅវិញទៅមក ប៉ុនប៉ងបំណងក្នុងចិត្ត
ទាំងសងខាងទំងផ្ដួលផ្ដាច់ជីវិតឲ្យសម្រេចគ្នាហោង ។ កាលនោះ ពមសូរ
អសុររិទ្ធិក្លាហាន ចូលរុករានមិនមានគិតជីវិតជីកអាត្មាសោះឡើយ ហើយ
សុទ្ធសឹងតែក្លាពលាខ្លាំង ចូលតតាំងច្បាំងគ្នា មួយកាប់មួយការអាវុធ
ទាំងសងខាង ក្រឡាប់ក្រឡាសវិលវល់វិលវល់ទៅវិញទៅមក ។ គ្រានោះ
ព្រះរាមាធិបតីចក្រីក៏កប់រងទំនងអសុរ ការមិនឲ្យត្រូវព្រះអង្គឡើយ ហើយ
ព្រះអង្គក៏ចាប់ដៃអសុរបាន ព្រះអង្គក៏លើកជើងស្ដាំជាន់លើដង្គង់ជើងឆ្វេង
របស់អសុរ ។ គ្រានោះ ពមសូរយក្សាក្នុងចិត្តនោះប្រាថ្នានឹងផ្ដាច់
ជីវិត ព្រះទ្រង់រំទួលក៏ត្រវិជ្ជជ័យ ពាយសំពង់ទៅត្រូវអង្គអសុរ ។ ពម-
សូរយក្សានោះ លុះត្រូវកាយក៏ឈឺស្បើរទឹងក្បែយប្រល័យជន្មា ទឹង
ទ្រាំពុំបាន ក៏យំស្រែកថា ឱអង្គអញអើយ សែនស្ដាយកម្លាំងរិទ្ធី
នោះចាំងវសចំសានុទិស ក៏អញធ្លាប់បង្ក្រាបប្រាបបាន គួរឬមកចាញ់
ឫទ្ធិមនុស្សសាមាន្យប៉ុនសុចសត្វ អសុរក៏តូចចិត្តក្រៃ ទឹងល្បីកេរ្តិ៍
ឈ្មោះទូទៅដល់កល្បកប្បអាប់សិរី ខាសអស់ទេព្រក្សត្រការគ្នាព្រៃ ទាំង
ទេវៈស្តួតាល័យគ្រប់ស្ថានពស៊ី អសុរខ្លួញរៀបរាប់ភ្លាង ក៏ក្រឡេកភ្នែក
មើលទៅព្រះចក្រី អសុរក៏ឃើញដៃ ៤ កាន់ចក្រគទាពេជ្រពណ្ណកយ
អសុរក៏ដឹងថា ជាអង្គព្រះនារាយណ៍ទ្រង់រិទ្ធិឫទ្ធេះហើយ ក៏ស្ទុះក្រោក

ចូលទៅក្រាបក្រោមព្រះបាទា រៀបទូលអង្វរសុំទោសព្រះរូ
ទ្រង់ព្រះករុណាមេត្តាប្រោសសន្តោសទុកជីវិត ដ្បិតខ្ញុំព្រះ·
នេះ ឃើញខុសពិតជីវិតគួរក្ស័យ ព្រោះមិនស្គាល់ព្រះអង្គឡើយ ហោ·
ហ៊ានទទឹងរឹងបង់ច្បាំងនឹងព្រះអង្គ សូមព្រះរាជទានជីវិតក្នុងជាន់គ្រានេះ
ម្តងឲ្យបានរស់នៅបម្រើបាទតទៅ ។

កាលនោះ ព្រះនារាយណ៍រាម បានស្តាប់ឃុនមារអសុរ៍ ទូញ
ពណ៌នាសូមជីវិតដូច្នោះហើយ ព្រះអង្គទ្រង់សើចញញឹម ៗ ទើប
មានព្រះរាជឱង្ការថា ម្នាលរាមសូរអសុរ ខ្លួននេះ ដ៏ទ្រង់សក្តាវរឫទ្ធិ
ជាកន្ទ្រោងលោកធាត្រី អង្គអញអវតារចុះមកបង្ក្រាបយុគ ដើម្បីប្រាថ្នា
នឹងឲ្យលោកជាសុខក្សេមក្សាន្ត រំលត់ទុក្ខសោកឲ្យបានត្រជាក់ទាំង
ផែនក្រោម ជាទីពំនាក់នៃត្រៃលោក ។ ឥឡូវនេះអ្នកដ៏ខ្លួនធ្វើខុសមែន
ពិត ជីវិតនោះ ណ្ហើយចុះ អញលើកឲ្យតាំងតែពីថ្ងៃនេះតទៅ ចូរ
តាំងចិត្តប្រព្រឹត្តនៅក្នុងសត្យក្នុងធម៌ ។ កាលនោះ រាមសូរអសុរ
បានស្តាប់ព្រះឱង្ការព្រះទ្រង់ត្រាស់ហើយ អសុរក៏ក្រាបក្រោមព្រះបាទា
រៀបទូលតបទៅវិញថា ដែលព្រះអង្គទ្រង់ព្រះមេត្តាការុណ្យព្រះគុណ
នោះជាទីបំផុត ទូលព្រះបង្គំជាខ្ញុំគ្មានវត្ថុអ្វីនឹងតបស្នងនូវព្រះបាទព្រះ
បារមី មានតែសេចក្តីមួយនេះ គឺអង្គព្រះសយម្ពូញាណ ព្រះរាជ
ទានអង្គត្រៃមេឃយក្ស ដ៏ជាអយ្យកាធិបតី ខ្ញុំព្រះករុណានេះ បាន

គង់ណាពង្សមក សូមថ្វាយក្រុងធូលីព្រះបាទចមលោកនាថ ទើបបាន បង្ក្រាបប្រាបពួកពាលពាលាបច្ចាមិត្រ ដើរចិត្តជាសត្រូវក្បត់ក្នុងលោ-កាហោង ។

កាលនោះ ព្រះទ្រង់តពលុបលើសលោកា ទទួលយកសរពីដៃ អសុរ ព្រះភ្នែកហ្ម៉ាក់សែកសេលាមខក្សៀកត្រពេក ។ ឯកមស្ពូរអសុរ លុះថ្វាយសរសិល្បហើយ ក៏ក្រាបថ្វាយបង្គំលាទៅវិញហោង ។

កាលនោះ រីអគ្គីអវតារធិបតី ចក្រក៏មានព្រះវាចាថា ម្នាលព្រះពិរុណ រីសរសិល្បនេះ យើងសូមផ្ញើទុកនឹងអ្នកផង បើយើងធ្វើការទៅមុខនោះ ទញ់ខាលគំនិតកាលណា សឹមយើងមកយកពីអ្នកវិញហោង ។ ថាហើយព្រះអគ្គីក៏ហោះហោលទៅលើអាកាស ។ ហេតុតែគេជាទុកាកអគ្គព្រះចក្រាក៏កក្រើកអំពីកទាំងទសទិសហោ ។ រីអគ្គព្រះពិរុណទេពក៏ទទួលទុកដោយសោមនស្សហោង ។

កាលគ្រានោះ រីអសុរហ្វូងទេពគ្រប់ក្រសីនោះ កុះឃើញកាមស្វូរអសុរ ចាញ់ធ្វើបារមីព្រះកាមេសហើយ ទៅវេសគ្រប់ស្នាខក៏អស្សោទរ ទះដៃឲ្យពរ ទៅខ្លះក៏ថា ពួកអសុរមារ ក្នុងគ្រានេះ ទីនវិនាសល្អិតខ្ទេចខ្ទី ដោយឫទ្ធិព្រះចមតៃតែង ៤ , ទៅខ្លះ ក៏បាចសាចនូវមាលាផ្កាភ្ញីមាស នូវផ្ញើមន្ទារាំពាកេស ហើយក៏ស្រែកនូវសព្ទសម្រែកឲ្យជ័យសិរីស្ដាគាបួរបម្រើន ។ ហោង ។

កាលនោះ ព្រះបាទខេមរដ្ឋាធិបតី ទាំង ៣ សម្តេចព្រ
ទ្ធអស់ពលយោធាទាំងពួងនោះ ឃើញព្រះកុមារមានជ័យជំនះឈ្នះក្រុង
ទេវទត្តក៏បាចសាចបុប្ផាទិព្វដេរដាសព្រះធរណី រំភើបមាណពនោះ ក្រសួប
អបក្រឡប់ពេញទាំងព្រៃព្រឹក្សា អ្នកខ្លះក៏ទាប់រើសយកមកបើប ហើយ
សៀតត្រចៀកដោយសោមនស្សរីករាយ ៗ អែន្តព្រះបិតុរង្គ ទ្រង់ឲ្យ
ត្រៀបជ័យ លើកយោធាទៅហោង ៗ លុះស្តេចយាងតាមផ្លូវព្រែក
ជ្រៅជ្រលងស្ទឹងបឹងបួរប្រែកព្រៃហិមពាន្ត ក៏ឈប់ដាក់យោធា ដោយ
យេះដំណាក់រៀង ១ កន្លែង លុះដល់អយុធ្យាធានីហើយ ទើប
ព្រះអង្គឲ្យបញ្ឈប់រេហ៍ពលសកលយោធា នៅនាកើយកែវមរកត ៗ ទាំង
៩ ក្បូនសុរិយវង្សពង្សា ក៏ស្តេចយាត្រាទៅកាន់ប្រាសាទកែវមរកតនា ដល់
ហើយក៏ដាក់អង្គគង់លើបល្ល័ង្កអាសន៍ ព្រះអង្គល្អដូចទេវកដកោសីយ៍ នា
កណ្តាលទៅមុខសុរិវង្ស ខ្ទឹមន្តសុណិសា ព្រះស្នំក្រមការកំណាន់ទាំង
ពួងជេរដាសដិតប្រកិតជំនិត ទើបព្រះអង្គទ្រង់ប្រទានទាំងទ្រព្យសម្បត្តិ
ជាតស្តាន ឲ្យព្រះរាជបុត្រា ទាំងស្រីស្រីង្គារដាបរិវារ ទាំងសេនាអាមាត្យ
មុខមន្ត្រី សព្វការកេវវីតម្រួតត្រួតត្រាមហាតលិតគ្រប់គ្រាន់ហើយ ទើប
ព្រះអង្គទ្រង់បង្គាប់ទៅនឹងព្រះពារុទព្រះសុតទ្រុងថា ម្នាលកូនអ្នកដ៏មានបុណ្យ
អានុភាពក្រៃដូចក្នុងប្រល័យកល្ប ចូលអ្នកត្រឡប់ទៅគប់ស្នងទ្នងព្រះ
បាទសម្តេចព្រះអយ្យកាធិរាជដូចដើម នឹងបានបម្រុងរក្សាអាណាប្រជាជន
ឲ្យអ្នកបានសេចក្តីសុខសុវត្ថិភាពសាពរហោង (នៅមានត)

# ឯកសារ សាស្ត្រាស្លឹករឹត និង ក្រាំង

*ដែលមាននៅវិជ្ជាស្ថាននៃពុទ្ធសាសនបណ្ឌិត្យ*

លោក ញ៉ុក-ថែម រៀបរៀង

(ក)

ចំណងជើង " សាស្ត្រា ច្បាប់កូនគម្ពីរ "

អ្នកនិពន្ធ រកពុំទាន់ឃើញ ។

កាលបរិច្ឆេទ គ្មានបញ្ជាក់ក្នុងអត្ថបទ ។

របៀបនិពន្ធ ពាក្យកាព្យ : បទកាកគតិ ។

ប្រភេទរឿង ច្បាប់អាពុកទូន្មានកូនឥទ្ធិពលពុទ្ធនិយមនិងរាជនិយម ។

លក្ខណៈឯកសារ សាស្ត្រាស្លឹករឹត ១ ខ្សែ មាន ៣ សន្លឹក ។

ឯកសារនេះ ពុទ្ធសាសនបណ្ឌិត្យ បានមកអំពីវត្ត
កាយកេនឬកាយវ៉ូន កំពង់ឆ្នាំងដែរ ចុះលេខ ៦៤៤ ។

អត្ថបទផ្តើម កូនអើយគម្ពីរ មានព្រះបាលី គាថាចេះហោង លោក
ទុកជាច្បាប់ សម្រាប់អ្នកផង ឲ្យរៀនត្រងត្រង់រៀនសាស្ត្រា ។
បរមេយ្យា នសម្បន្នោ គុណវិជ្ជា វិសាលិកុ - លំសុគក់
ឥតកំសា នលោកន្តិ ។ នរអ្នកណា . . . ។ល។

អត្ថបទបញ្ចប់ ព្រះពោធិសត្វ ខ្ញុំបាទបុត្រគេ បរិបូណ៌ស្រេចហើយ

ផ្គត់ផ្គង់មហាក្សត្រ ប្រណិបតន៍ជាក្រោយ មិនឲ្យឃ្លាតឡើយ

ទីនច្បាប់ធម៌ថ្ងៃ (១) ។

+ + +

បំណងជើង " សាស្ត្រា ច្បាប់ស្វះស្វែង "

អ្នកនិពន្ធ រកពុំទាន់ឃើញ ។

កាលបរិច្ឆេទ គ្មានបញ្ជាក់ក្នុងអត្ថបទ ។

របៀបនិពន្ធ ពាក្យកាព្យបទកាកគតិ ។

ប្រភពរឿង ច្បាប់ខ្ញុំបានសាមណេរនិងសិស្ស តាមប្រពៃណីខ្មែរ

ពីព្រេងនាយ ។

លក្ខណៈឯកសារ សាស្ត្រាស្លឹករឹត ១ ខ្សែមាន ៤ សន្លឹក ។

ឯកសារនេះ ពុទ្ធសាសនបណ្ឌិត្យ បានមកអំពីវត្ត

បទុមរតនៈ ខេត្តកំពង់ចាម ចុះលេខឯកសារ ៦៤០ ។

---

១) តទៅទៀត មានវិបត្តិទាំងជើងកាព្យទាំងអត្ថន័យ ។ ប្រហែលអ្នកចារ ចារបន្ថែម ដោយខ្លួនឯងទេដឹង? ល្បះបន្តទៅទៀតដូច្នេះ ៖

ពួកអ្នកកាន់កាន់ កំណត់សព្វថ្ងៃ ទាំង ១១ គ្រាន់គ្រប់ប្រពៃ រក្សាសីលថ្ងៃ ត្រូវធំវិញណា ។ យើងយួរលង់លុះ ម្ដងផង្គា សឹងទៅកើតឋាន ពិមានសួគ៌ា បរិបូរប្រុះប្រា-កដកបទៀងហោង ។

អត្ថបទផ្ដើម : ហៃអ្នកស្ទះស្ទួន លះពីតម្កើង ហែនល្អក់ក្ទះករ ស្ទ្រាក

មកបួស ព្ទទអង្គបារ ប្រាជ្ញាក្ទះករ ដឹងធម៌ពីណា ។ ហេតុ

បានពីគ្រូ ប្រដៅនៃផ្លូវ ដោយទូរសត្យា កុំអាងអួតបេះ ចំណេះ

អាត្មា ផុលពីបិត្តា ឯងថាលើសគ្រែ . . . ។ល។

អត្ថបទបញ្ចប់ : គួរតែលើក សត្វថ្ងៃញឹកៗ ជាប្រក្រតីហោង

ឲ្យខំសង្វាត ទូហាតស្រវាន ឲ្យបេះចាំចង់ តាមច្បាប់បុរាណ ។

ច្បាប់នេះឧត្តម ឲ្យកូនចៅចាំ មើលហើយឲ្យចាំ (?) បណ្ដាំ

ពាក្យព្រេង ដឹងតែកាគគ្រែនបាប ផកបតៅហោង (?)

បរិបូរហ្ចក់មី (?) សូរចេចប់ហោង (១) ។

+ + +

បំណងជើង "[illegible]"

អ្នកនិពន្ធ រកពុំបានឃើញ ។

កាលបរិច្ឆេទ គ្មានបញ្ជាក់ ក្នុងអត្ថបទ ។ ប្រហែលខាងចុង សតវត្សទី ១៩ ឬ ខាងដើមសតវត្សទី ២០ នេះឯង ។

---

១) – ពីល្បះខាងចុងនេះ រិបត្តិដោយដើងភ្យេ តគចាប់ចុងផ្លូងនឹងប្បាខាងលើ ។

របៀបនិពន្ធ ពាក្យ៧ បទបន្ទោលកាក និង ព្រហ្មគីត ។

ប្រភពរឿង មនោគតិរបស់អ្នកនិពន្ធ អំពីដំណើរដុចនិងត្រី ។

លក្ខណៈឯកសារ សាស្ត្រាស្លឹករឹត ១ ផ្សែ មាន ៩ សន្លឹកកន្លះ ។

ឯកសារនេះ ពុទ្ធសាសនបណ្ឌិត្យ បានមកអំពី

វត្តបទុមវតេ: ខេត្តកំពង់ចាម ចុះលេខ ៦៤០ ។

អត្ថបទផ្ដើម: នេះបទបន្ទោលកាក ។ ថ្លែងដោយទំនង ដំណើរត្រី

ផងយាត្រា តើបនឹងដុចណា ត្រីស្រែកថារើយចៀសចេញ ។

ដុចថាអើអើ បងអ្នកនេះតើម្ដេចមិញ កំមកប្រើអញ ចៀស

ចេញឲ្យអ្នកជាប្រៀង ។ . . . . ។ល។ . . . .

អត្ថបទបញ្ចប់: ប្អូនឹងប្រពន្ធ រវើងក្តៅលើសលន់ញ័រប្រាណ ក្តៅខប់

ពុំបាន ដេកថ្ងូរទ្រើងទ្រលក់គ្នា ។ កាបែកចាំងផ្ទាំង ហើយកាំ

ឈើចាំងអាត្មា អត់ចាំងអាហារ ពុំបានធីត្រីនោះសោះ ។ ដំណើរ

ដុចត្រី មែនមានអំពីព្រេងនោះ គ្រាន់គ្រប់តែម៉្លោះ បរិបូណ៌

សូមបេហើយហោង ។

( នៅមានត )

# រឿងសាមកុក

ឧកញ៉ាវិបុលរាជសេនា

នូ-កាង

ប្រែ-រៀបរៀង

(គ)

| |
|---|
| រឿងសាមកុកទុកជាយុទ្ធសាស្ត្រ អ្នកភាងវៃឆ្លាតបើបានអាន<br>នឹងចេះឧបាយកលបំណាន ទាំងមានសន្តានស្នេហាជាតិ<br>យូរ—អ៊ុន |

បើកាលណានាងទីនសែនឲ្យយើងនោះ ត្រូវឲ្យមានភ្លេងមហោរីង ពិណពាទ្យឲ្យគ្រប់ទិវារាត្រី ហើយនាងត្រូវបង្គាប់ក្មាក់ងាររមេការឲ្យកសាង ទីបុ៉ានា (គឺអនុស្សាវរីយ៍) បញ្ចុះសពយើងនៅទីព្រះលានក្រៅក្រុងឲ្យបាន ៧២ អន្ទីឡដូច ៗ គ្នា ដើម្បីកុំឲ្យមនុស្សនានាចាំសំគាល់បានថាសពយើង នោះបញ្ចុះត្រង់ទីកន្លែងណា ពីព្រោះថាខ្លួនយើងនេះ មានមនុស្សព្យាបាទស្អប់ ច្រើនណាស់ ក្រែងពួកលួចគាស់កាយយកសពនោះទៅចោលអសារ ឥតការ, ចូចូផ្តាំផ្ញើសព្វគ្រប់ហើយក៏ចេះតែដកដង្ហើមធំយំអណ្តើតអណ្តក ទឹកភ្នែកក៏ហូរមកជោករសើបពាន់មុខមាត់ បាត់ស្មារតីដួលចុះ អស់ជីវិត សង្ខារ, កាលចូចូធ្វើកាលកិរិយានោះ កុងខៃមានអាយុ ៦៦ ឆ្នាំ; ព្រះចៅហៀនតេ ចៅគង់នៅក្រុង ហ៊ូតោបាន ២៥ ឆ្នាំ ( ពុទ្ធសករាជ ៧៦៣ ) ។

អស់បណ្ដានាម៉ឺនសព្វមុខមន្ត្រីធំថា ចូចូក្ស័យជីវិតហើយ ក៏នាំគ្នាថ្ងូញសោកាល័យ ហើយប្រើបម្រើឲ្យទៅអញ្ជើញបុត្រចូចូ ដែលទៅឈរខេត្តទាំង ៤ នាក់, ចូគីនៅខេត្រនៀបកុន, ចូវៀននៅខេត្តអៀនឡេន, ចូស៊ុតនៅខេត្តលិមឈី, ចូហ៊ឹមនៅខេត្តសៀវហ្វូយ ឲ្យចូលមកឯស្រុកឡូកអៀន, នាម៉ឺនទាំងពួង ក៏នាំគ្នារៀបតែងការសពជាធំពន្ធឹក តាមរបៀបព្រះមហាក្សត្រ ហើយឲ្យរៀបគ្រឿងហែ សែនអញ្ជើញសពទៅទាំងកណ្ដាលយប់កណ្ដាលថ្ងៃ តម្រង់ទៅស្រុកនៀបកុន ។

ឯចូគីធំថា បិតាអនិច្ចកម្ម ក៏យំសោកប៉ោកខ្លួនប្រាណ ហើយនាំអស់គ្នាក់ងារទាំងប៉ុន្មាន ចេញចាកខេត្តមកប្រហែល ១០០ សិន ( ៤ គី. ) ក៏ប្រទះទីក្បួនហែសពបិតា; ចូគីក៏អញ្ជើញសពត្រឡប់ហែចូលទៅកាន់ស្រុកនៀបកុន ហើយឲ្យប៉ាវតងប្រាប់អស់នាម៉ឺនមុខមន្ត្រី និងបណ្ដាពលរដ្ឋស្រុក ប្ដាណាខេត្តដែលឡើងទាំងប៉ុន្មាន ឲ្យស្លៀកពាក់ស ជួតក្បាលសំពត់ស តាមបែបម្ចាស់ផែនដីសុគត; ចូគី និងបណ្ដានាម៉ឺនមុខមន្ត្រីទាំងពួង ក៏នាំគ្នាសោកយំដំរែកទូទាំងទីក្រុង ។

ខណៈនោះ មានមនុស្សម្នាក់មកស្រែកឃាត់ថា ៖ យើងពាល់គ្នាកុំអាលយំសោកថ្វី, ឯសេចក្ដីស្លាប់នោះ មានគ្រប់រូបជាធម្មតា គ្រាន់តែគិតការរៀបចំផែនដីសិន, ពួកវាធំនោះ ក្រឡេកទៅឃើញស៊ុម៉ាហ៊្វូ ក៏ដណ្ដឹងសួរទៅវិញថា ហេតុអ្វីបានជាមកឃាត់ហាមដូច្នោះ ?

ស៊ូម៉ាហ្វ៊ី ឆ្លើយថា ស្រុកទេសរបស់យើង មិនមានម្ចាស់គ្រប់គ្រងរក្សា ត្រូវតែបារម្ភខ្លាចក្រែងមានសត្រូវមកប្រមាថបៀតបៀន, ហេតុនេះ គួរតែលើកបុត្រីឲ្យឡើងស្តីរាជការជាម្ចាស់ស្រុក ទើបបណ្តារាស្ត្រទាំងពួង នឹងបានសង្ឃឹមទុកចិត្ត មិនគិតញញើតខ្លាចសឹកសត្រូវ ។ ក៏មិនអាចនឹងកម្រើកចិត្តគិតប្រទូសរ៉ាយបាន ។ នាម៉ឺនទាំងអស់ឆ្លើយថា គំនិតអ្នកគិតនោះ ត្រូវណាស់ហើយ តែថាវេលានេះ ព្រះរៅហៀនតេ នៅមិនទាន់មានព្រះតម្រាស់ត្រាស់ឲ្យតាំងដូច្នេះនៅឡើយ; យើងនឹងធ្វើតាមអំពើចិត្តនោះដូចពុំគួរទេ ។

គាន់កៀវឆ្លើយថា ចំនៀមម្ចាស់ស្រុកទិវង្គតផុតទៅ ត្រូវតែឲ្យបុត្រច្បងឡើងនិយាយការជំនួស, ថាហើយក៏ចាប់យកព្រះសែងដាវលើកឡើងកាន់ ហើយកាត់ដាយអាវផ្តាច់បន្តិចទម្លាក់ទៅលើផែនដី ដើម្បីបង្ហាញឲ្យមន្ត្រីទាំងពួងមើល ហើយស្រែកថា យើងត្រូវលើកបុត្រីឲ្យឡើងជាម្ចាស់ក្នុងពេលនេះ បើនរណារឹងទទឹងនឹងកាត់ក្បាលអ្នកនោះឲ្យដាច់ចុះដូចជាកំណាត់អាវដែលកាត់នេះ ។ នាម៉ឺនទាំងអស់ឃើញដូច្នោះ ក៏ភ័យទាំងអស់គ្នា គ្មាននរណានឹងឆ្លើយតបថាអ្វី. ទទួលពេលនោះ ហ្វ៊ីហ៊ឹមជានាម៉ឺនធំ ទើបមកពីក្រុងហ៊្វូគោ ដើរចូលទៅក្នុងទីប្រជុំធំ, នាម៉ឺនទាំងពួងឃើញហើយ ក៏ឲ្យមានសេចក្តីខ្លាចណាស់ ទើបនាំគ្នាសួរដណ្តឹងថា លោកអញ្ជើញមកដោយកិច្ចរាជការអ្វី ?

ហ្ស៊ីហ៊ុមឆ្លើយថា វេលានេះ អត់ពីព្រះចៅរុយអង់ទៅហើយ យើងបានឮក្រែងមានសត្រូវទឹងកម្រើក, ហេតុនេះ ទើបយើងមក ដើម្បីទឹងជំនុំគ្នា អញ្ជើញចូគីឲ្យឡើងជាស្ដេចនិយាយរាជការផែនដីជំនួសបិតា នាម៉ឺនទាំងពួងឆ្លើយឡើងថា ឥឡូវបានប្រឹក្សាគ្នាហើយថា ត្រូវលើកចូគីឡើងជាម្ចាស់ តែនៅយល់ថាស់ ព្រោះមិនទាន់ត្រាតាំងពីព្រះចៅហៀនគេរាជទានមក ។ ហ្ស៊ីហ៊ុមឆ្លើយថា ខ្ញុំបានទទួលសុំត្រាព្រះចៅហៀនគេ ហើយទ្រង់ព្រះរាជទានមកនេះ ទាំងអស់គ្នាឮដូច្នោះ ក៏មានអំណរណាស់ នាំគ្នាស្រែកហោកញ្ជ្រៀវលោតកំព្រហ៊ឹងអឺងកង ។ ហ្ស៊ីហ៊ុមក៏យកត្រាតាំងបង្ហាញឲ្យមើលគល់គ្នា, ឯហ្ស៊ីហ៊ុមនោះ នៅធ្វើរាជការផ្ទាល់ក្នុងព្រះចៅហៀនគេ តែជាពួកម៉ាក់របស់ចូចូ ចាំស៊ើបការល្អអាក្រក់មកប្រាប់ចូចូ, លុះដឹងថាចូចូស្លាប់ហើយ ទឹងចង់ឲ្យលើកចូគីជាម្ចាស់ជំនួសឡើង បានជាសរសេរត្រាតាំងសុំឡាយព្រះហស្តកាន់នាំមក ។

ឯចូគីក៏ឲ្យប្រមូលនាម៉ឺនមុខមន្ត្រីចូលមកគាល់; មន្ត្រីទាំងពួង ក៏ក្រាបថ្វាយបង្គំ ហើយចូគីឲ្យរៀបតុលៀងអាហារដល់នាម៉ឺនមុខមន្ត្រីធំ-តូចទាំងពួង, មានចារស៊ើបការចូលទៅចូគីថា ចូជៀងជាប្អូនទ្រង់ នៅស្រុកទៀងអាន់ លើកកងទ័ពធំ មានទាហានប្រហែល ១០ ម៉ឺន ។ ចូគីឮដូច្នោះ ក៏ភ័យណាស់ ប្រឹក្សាទឹងនាម៉ឺនទាំងពួងថា អាហោខូច

នេះ កាលដែលនៅជាមួយគ្នា ក៏ជាមនុស្សរឹងរូសមោហោខ្លាំង ហើយ ព្រហើនកោងកាច មិនខ្លាចក្នុងការចម្បាំងសោះ ដែលក៏លើកទ័ពមក គ្រានេះ គឺប្រាថ្នានឹងដណ្តើមយករាជសម្បត្តិជាប្រាកដហើយ ។

គៀគុយទូលថា ទូលបង្គំនឹងសុំចេញទៅនិយាយសម្រួលនឹងចូ-ជៀងមើល ដើម្បីឲ្យដឹងថា មកនោះល្អអាក្រក់ប្រការម្តេច ។ នាម៉ុនតាំងតួងឆ្លើយព្រមគ្នាថា អ្នកនិយាយនោះត្រូវណាស់, នោះបើជាគេមកដោយកាច ក៏អាចសម្រួលបានទៅជាល្អ ដោយវោហាររបស់អ្នក ។ ចូគីញ្ញដូហ្មោះ ក៏មានអំណរណាស់ ទើបត្រាស់ប្រើគៀគុយឲ្យចេញទៅជួបនឹងចូជៀង ។

ចូជៀងក៏សួរថា បិតាយើងមរណភាពទៅហើយ; ព្រះចៅហៀន-តេ ទ្រង់តាំងអ្នកឯណានិយាយរកការជំនួសបិតានោះ ។ គៀគុយឆ្លើយថា ប្រពៃណីបុរាណ បើជាភ្នាក់ងារស្រុកមួយ ៗ បើអត់ពីអាពុកទៅ ត្រូវឲ្យកូនប្រុសច្បងដែលនៅក្នុងបន្ទុកនោះ ទទួលកាន់ការជាជំនួសអាពុក, បើជាស្តេចផែនដីវិញ ក៏ត្រូវឲ្យព្រះរាជឱរសច្បងឡើងសោយរាជ្យជំនួសព្រះវររាជបិតាដូចគ្នា, ដូចជាខ្លួនអ្នកនេះសោក គឺមិនមែនជាបុត្រច្បងទេ ឬជាមន្ត្រីធំក៏មិនមែនផង នឹងត្រូវការអ្វីក៏មកសួររឿងនេះមិនត្រូវការ ។

ចូជៀងបានឮដូច្នោះ ក៏គិតឃើញថា គៀគុយលើកយកទំលាប់

ទាំទៀមមកនិយាយថា ត្រឹមត្រូវប្រាកដ ក៏ហៅស្មៀម, ហើយនាំគៀគុយ ចូលទៅក្នុងស្រុក, លុះទៅដល់ជិតកាំងកំពែងហើយ គៀគុយក៏សួរថា អ្នកអញ្ជើញមកវេលានេះ នឹងដណ្ដើមយករាជសម្បត្តិ ឬមករៀបចំសពបិតា ? ចូដៀងថា ខ្ញុំមកនេះ នឹងបានតាំងចិត្តគិតដណ្ដើមយកបុណ្យស័ក្តិអ្វីក៏ឥតអង្គីមាន មកនេះប្រាថ្នានឹងធ្វើការសែនសពបិតា ជាទីតបគុណទេ ។ គៀគុយថា បើពិតដូច្នោះ ហេតុម្ដេចបានជាអ្នកនាំទាហានមកច្រើនម្ល៉េះ ? ចូដៀងឮដូច្នោះ ក៏យល់ឃើញថា ជាខ្លួនធ្វើខុសមែន ទើបបណ្ដេញទាហានទាំងពួងឲ្យវិលត្រឡប់ទៅវិញ ទៅតែខ្លួនមួយទៅជាមួយនឹងគៀគុយ ចូលទៅគាល់បង ។ ក៏ចេញមកទទួល ឃើញមុខគ្នាហើយ ក៏កៀកគ្នាយំសោកទាំង ២ នាក់, លុះអស់សំណោកហើយ ចូដៀងក៏គិតថា ក្រែងបងសង្ស័យក៏និយាយថា ទាហានខ្ញុំបានដែលមកវេលានេះ ខ្ញុំបាទសូមប្រគល់ជូនបងទាំងអស់ ហើយចូដៀងក៏ចូលទៅគំនាប់សពបិតា ។ ទើបចូភីប្រើចូដៀងឲ្យទៅឈររក្សាស្រុកអៀនឡេង; ចូដៀងក៏ធ្វើការគំនាប់សពបិតា ហើយក៏លាបងលើកទាហានទៅរក្សាស្រុកអៀនឡេង ។ ចូភីឲ្យតាក់តែងគ្រឿងឧបភោគបរិភោគឲ្យដូចគ្រឿងរាជបរិភោគព្រះចៅហៀនតេគ្រប់ប្រការ ។ កាលចូភីបានឡើងជាស្ដេចនោះ ព្រះចៅហៀនតេទៅគង់នៅក្រុងហ៊ូតោ បាន ២៦ ឆ្នាំ ( ពុទ្ធសាក ៧៦៤ ) ។

ជូជី ក៏តាំងហ៊ូហ៊ុមជាសេនាបតីស្តាំ. តាំងកាសៀង ជាសេនាបតីឆ្វេង, តាំងអេងឡង ជាទីប្រឹក្សាធំ, បណ្តាខាមុឺនតាំងតួង ក៏ឲ្យឡើងទីតាមគុណានុរូប ហើយឲ្យកែងទីបញ្ចុះសពបិតា ៧២ អន្លើ តាមពាក្យបណ្តាំបិតា ហើយឲ្យចារឹកអក្សរពីមុខអនុស្សាវរីយថា ទីនេះជាកន្លែងបញ្ចុះសពព្រះចៅវ៉ុយអង តាមក្បែរជញ្ជាំងនោះ ពីខាងក្រៅឡើងគូរជារឿងអ៊ុគិមទៅច្បាំងនឹងគួនអ៊ូ នៅតំបន់ស្រុកអ៊ុនសៀ, គួនអ៊ូធ្វើកលឧបាយឲ្យនាំទាហានទៅទប់ទឹកឲ្យលិចកងទ័ពអ៊ុគិម ១ បាក់ទ័ព, គួនអ៊ូចាប់អ៊ុគិមនិងបាំងតេកបាន, គួនអ៊ូអង្គុយលើទីខ្ពស់ ឲ្យអ៊ុគិមនិងបាំងតេកអង្គុយទីទាប, បាំងតេកជាជាតិទាហានមិនខ្លាចសេចក្តីស្លាប់, គួនអ៊ូឲ្យនាំទៅប្រហារជីវិត, អ៊ុគិមខ្លាចស្លាប់ ក៏ក្រាបសំពះគួនអ៊ូលន់តួទោសសុំអាយុជីវិត, ជូជីឲ្យធ្វើរឿងដូច្នេះ ប្រាថ្នានឹងផ្ចាញ់ផ្ចាលអ៊ុគិមឲ្យឃើញថា អ៊ុគិមខ្លាចស្លាប់ មិនមែនជាជាតិទាហាន មិនមានសេចក្តីអៀនខ្មាស បានជាអង្វរគេសុំអាយុជីវិត ក្រោយនោះក៏រស់រួចខ្លួនមកវិញ, ដើម្បីមិនឲ្យទាហានទាំងពួងយកយឿងយ៉ាងតាមតទៅ ទើបប្រើឲ្យអ៊ុគិមទៅឈររក្សាទីបា៉ា (អនុស្សាវរីយ) ដែលបញ្ចុះសពជូជីនោះ, ឯអ៊ុគិមកាលទៅនៅរក្សាសពជូជី ក៏បានឃើញគំនូររឿងដែលខ្លួនទៅធ្វើចម្បាំង ក៏ថា ជូជីឲ្យធ្វើផ្ចាញ់ផ្ចាលខ្លួន ក៏មានសេចក្តីអៀនខ្មាសណាស់, អំណើះតមក ក៏ផ្តួលចិត្តទៅជាឈឺស្គមក្រំក្រៀមស្លាប់ ។

ហ៊ូហ៊ឹម ក៏ទូលចូភីថា ចូដៀងជាប្អូនទ្រង់នោះ បានមកគំនាប់សពបិតា ហើយលើកយកពលទាហានថ្វាយប្រគល់អស់ តែចូស៊ុតនៅស្រុកលិមឈី ចូហ៊ឹមនៅស្រុកសៀវហ៊្វយ ប្អូនទ្រង់ទាំងពីរនាក់នេះ មិនបានមកជួយរៀបចំសពបិតាសោះ ត្រូវឲ្យទ្រង់បង្គាប់ទៅឲ្យចុះអាជ្ញា តាមទោសានុទោសទើបគួរ ៗ ចូភីយល់ឃើញត្រូវ ទើបចាត់ប្រើនាយទាហានធំឲ្យនាំកងទ័ពទៅចុះអាជ្ញាប្អូនទាំងពីរនាក់ ៗ នាយទាហានធំ ២ នាក់ក៏លើកពលចេញទៅតាមបង្គាប់ចូភី ៗ ពួកល្បាតចូហ៊ឹម ក៏នាំពត៌មានទៅប្រាប់ចូហ៊ឹមថា បងលោកខឹងនឹងលោក ពីព្រោះមិនទៅគំនាប់សពបិតា, ឥឡូវប្រើទាហានឲ្យមកចុះអាជ្ញាធ្វើទោសលោកហើយ ៗ

ចូហ៊ឹម បានឮដូច្នោះ ក៏មានសេចក្តីភ័យខ្លាំងណាស់ ព្រោះខ្លាចអាជ្ញា ក៏ចងកស្លាប់ទៅ ៗ នាយទាហានដែលទៅចុះអាជ្ញានោះដឹងថា ចូហ៊ឹមចងកស្លាប់ហើយ ក៏លើកទ័ពត្រឡប់ទៅទូលចូភី ៗ ក៏បង្គាប់ឲ្យភ្នាក់ងារទៅរៀបចំសពចូហ៊ឹមបញ្ចុះតាមប្រពៃណី ហើយឲ្យចារឹកអក្សរទុកទៅមុខអនុស្សាវរីយ៍ថា ទីបញ្ចុះសពចៅហ្វាយស្រុកសៀវហ៊្វយ ៗ

ឯពួកល្បាតស្រុកលិមឈីដឹងថា មានបំរើចូភីទៅធ្វើទោសចូស៊ុតដូច្នោះ ក៏នាំពត៌មាននោះទៅប្រាប់ចូស៊ុត វេលានោះ ចូស៊ុតកំពុងអង្គុយផឹកស្រាជាមួយនឹងគេងង៉ី, គេងអ៊ុ, ចូស៊ិត ដឹងសេចក្តីហើយ ក៏មិនមានតក់ស្លុតភោតភាញញើតសោះ ៗ (នៅមានត)

# ឯកសារ កម្ពុជសុរិយា

(ក)

លោក ទឹក-ភាម ប្រមូលរៀបរៀង

សត្វាធេវមនុស្សធំ : ព្រះ•ចាលាវង្ស មីន-សេស ទ.ក. ១២, ទំព័រ ៨៨៣, ឆ្នាំ ១៩៥៤, (ម.៥២/២៥) ។

សត្វខ្លា (រឿង) : ទ.ក. ១, ទំព័រ ៣៩, ឆ្នាំ ១៩៣១ (ម.៥២/៤) ។

សត្វចាបចង់ជីវិតស្ដ : លោក ប៊ូ ប៊ូ ទ.ក. ៤, ទំព័រ ៣៦៨, ឆ្នាំ ១៩៥៩, (ម.៥២/៣១) ។

សត្វលោកងងឹតកាមគុណ : លោក មាស-យុគ្គ ទ.ក. ៧, ទំព័រ ៦៩៧, ឆ្នាំ ១៩៦៥, (ម.៥២/៣៧) ។

សត្រូវរបស់ខ្ញុំ : លោក ប៊ូ-ប៊ូ ទ.ក. ២, ទំព័រ ១៨២ ឆ្នាំ ១៩៦០ (ម.៥២/៣២) ។

សទ្ធម្មគាថា : ព្រះញាណវិរិយ ក៏ន-សាខុំ ទ.ក. ៥, ទំព័រ ៣៩៩, ឆ្នាំ ១៩៥៨, (ម.៥២/៣០) ។ ទ.ក. ៥, ទំព័រ ៤៥៣, ឆ្នាំ ១៩៦២, (ម.៥២/៣៤) ។

សទ្ធម្មប្បជោត : ព្រះមហា អ៊ុក-អ៊ន ទ.ក. ៧, ទំព័រ ៦០១, ឆ្នាំ ១៩៥៨, (ម.៥២/៣០) ។

សន្តិភាពតាមគតិពុទ្ធសាសនា : ព្រះភិក្ខុ ខៀវ-ជុំ ទ.ក. ៧,
ទំព័រ ៦០៣, ឆ្នាំ ១៩៥៦, (ម.៥២/២៨) ។

សន្តោសកថា : ឃុនបណ្ណាទុក្រេ ប៊ូ-ប៉ូ ទ.ក. ៨ ទំព័រ
៧០៣ ឆ្នាំ ១៩៥៦ (ម.៥២/២៨) ។

សន្និបាតប្រគល់មុខការ ព្រះសង្ឃជាយកាវត្តឧណ្ណា
លោម : សមុហ៍ពោធិញ្ញាណ ជួន-ឌៀន ទ.ក. ៣, ទំព័រ
២២៥, ឆ្នាំ ១៩៤៨ (ម.៥២/៣០) ។

សន្និថាកនៃបណ្ឌិតវិស្សាង់អេក្លាត : លោក ក៏យ - ប៊ុក
ទ.ក. ៩, ទំព័រ ៨៦៣, ឆ្នាំ ១៩៤៧ (ម.៥២/២៩) ។

សន្និសីទនៃលោកម៉ាក្សិសឆាក់ : ក៏ះ - ប៊ុក ទ.ក.
៤, ទំព័រ ២២៩, ឆ្នាំ ១៩៥៩ (ម.៥២/៣១) ។

សន្និសីទព្រះពោធិវង្សហួត-តាត អំពីសៈមាជសកល
លើកទី ៦ នៃពុទ្ធសាសនា : ព.ប. ទ.ក. ១, ទំព័រ
៦២, ឆ្នាំ ១៩៥៣ (ម.៥២/២៥) ។

សន្និសីទ អំពីពុទ្ធសាសនានៃលោកបណ្ឌិតជាត់ជាតិ
ឥណ្ឌា : ទ.ក. ៩, ទំព័រ ១០៦៦, ឆ្នាំ ១៩៦៦ (ម.៥២/៣៤)។

សប្បុរិសកថា : ព្រះបាឡាត់ពោធិកម យូរ - ប៊ុណ្ណ ទ.ក. ៤,
ទំព័រ ២១៥, ឆ្នាំ ១៩៤៧ (ម.៥២/១៩) ។ ភិក្ខុ អ៊ុង-សុខ

ទ.ក. ៣, ទំព័រ ២២៩, ឆ្នាំ ១៩៦៤ (ម.៥២/៣៦) ។

សប្បុរិសធម៌ (កាព្យ) : លោក បាន . កេង ទ.ក. ១០-១១ - ១២ ទំព័រ ១៣៧, ឆ្នាំ ១៩៣៦ (ម.៥៦/៨) ។

សប្បុរិសធម្មកថា : ព្រះទេពសត្ថា សូរ-ហាយ ទ.ក. ៥ ទំព័រ ៣៧៤, ឆ្នាំ ១៩៥០ (ម.៥៦/៦៦) ។

សប្បុរិសកបុរិសកថា : ភិក្ខុ ពេជ្រ - ពុម្ព ទ.ក. ៧, ទំព័រ ៦៩៣, ឆ្នាំ ១៩៦៤ (ម.៥៦/៣៦) ។

ស័ព្ទបារាំងប្រែជាខ្មែរ : ហួនទិពន្ធមន្ត្រី ញ៉ុក-ថែម ទ.ក. ៥, ទំព័រ ៣៤១; ឆ្នាំ ១៩៤៩ (ម.៥២/២១) ។

សព្វសិទ្ធិ : ទ.ក. ១, ទំព័រ ៥៣, ឆ្នាំ ១៩៥៩ (ម.៥២/៣១) ។

សត្តិសមាសកថា : ព្រះធម្មបាលវង្ស សូរ-ហាយ ទ.ក. ១, ទំព័រ ១; ឆ្នាំ ១៩៥៨ (ម.៥២/៣០) ។

សមណសក្តិនៃព្រះសង្ឃ ៣ រូប : ពុ.ប ទ.ក. ៤, ទំព័រ ៣១៥, ឆ្នាំ ១៩៣៤ (ម.៥២/២៥) ។

សមត្ថភាពតិអ្វី : ព្រះមុនីកោសល សូរ-ហាយ ទ.ក. ៦, ទំព័រ ៦២១; ឆ្នាំ ១៩៦៤ (ម.៥២/៣៦) ។

សមភាពក្នុងព្រះពុទ្ធសាសនា : យុទ្ធបណ្ឌិតរក្ស ប៊ុ-ប៉ុ ទ.ក. ៨, ទំព័រ ៥៦៣ ឆ្នាំ ១៩៥៤ (ម.៥២/២៥) ។

សម័យចំរើនរបស់ក្បាច់រចនាខ្មែរ : លោក ហ. មារ្យុល
ទ.ក. ៧-៨-៩ ទំព័រ ១៦៩, ឆ្នាំ ១៩៣៦,
(ម.៥២/៨) ។

សមាជសភាគលៈលើកទី ១ នៃពុទ្ធសាសនា សុន្ទរកថាសម្តេចព្រះសង្ឃនាយក នៅប្រទេសសីឡង់ :
ទ.ក. ១, ទំព័រ ៦៩, ឆ្នាំ ១៩៥៣, សុន្ទរកថាបណ្ឌិតម៉ាឡ៉ាល៉ៈសេកេរៈ ទ.ក. ២, ទំព័រ ១៥៣, ឆ្នាំ ១៩៥៣,
(ម.៥២/២៥) ។

សម្តេចព្រះមហាសមណៈ : ភិក្ខុ ឈឹម-ស៊ុម ប្រែ ទ.ក ៤-
៥-៦ ទំព័រ ៧៥, ឆ្នាំ ១៩៣៥ (ម.៥២/៧) ។

សម្ពុលជាតក : ព្រះបាឡាត់កោធិកម យូរ-ប៉ុណ្ណ ទ.ក. ៦,
ទំព័រ ៣២១, ឆ្នាំ ១៩៤៥, (ម.៥២/១៧) ។

សម្ពោធពុទ្ធសាលាបាលីរង់នៅឃុំគគីរធំ ស្រុកកៀនស្វាយ : ទ.ក. ១០-១១-១២ ទំព័រ ៩៩ ឆ្នាំ ១៩៣៥
(ម.៥២/៧) ។

សម្មាទិដ្ឋិកថា : ព្រះអាចារ្យ អាំ-សាមុល ទ.ក. ១០, ទំព័រ
៧៣១, ឆ្នាំ ១៩៥១, (ម ៥២/២៣) ។

សម្មោធមានជាតក : ព្រះញាណកោសល ញាណ-ឈឹន
ទ.ក. ៣, ទំព័រ ៣-០, ឆ្នាំ ១៩៦២, (ម.៥២/៣៤) ។

សម្លាញ់ពីរនាក់ : ទ.ក. ១-២-៣, ឆ្នាំ ១៩៣៣ (ម.៥២|៦) ។

សម្លាញ់ពីរនាក់ចង់ពង្រីកពឹកសមុទ្រ : លោក ទៀង-កៃឈុន ទ.ក. ៦, ទំព័រ ៥៤១, ឆ្នាំ ១៩៥៨ (ម.៥២|៣០) ។

សម្លាញ់ពីរនាក់នៅក្រុងជាមួយគ្នា : ទ.ក. ៧-៨-៩, ទំព័រ ១៦៤, ឆ្នាំ ១៩៣៣, (ម.៥២|៦) ។

សរណគាថា : លោកអាចារ្យ ខន-សាមិទ្ធ ទ.ក. ៦, ទំព័រ ៤២៤, ឆ្នាំ ១៩៥១, (ម.៥២|២៣) ។

សរណគមន៍ : ព្រះមហាពជធម្ម ឌិត ពជាគណ: ទ.ក. ៣, ទំព័រ ២១, ឆ្នាំ ១៩២៧ (ម.៥២|២ ។

សរសើរព្រះរស្មី : លោកគ្រូសីលសំវរ អ៊ុក ហាក់ ទ.ក. ៧ ទំព័រ ៣៦៩ ឆ្នាំ ១៩៤៣ (ម.៥២|៥) ។

សរសបណ្ឌិតជាតក : ព្រះគ្រូសាសនវង្ស គុយ ស្បូក ទ.ក. ១១ ទំព័រ ៨៦៣ ឆ្នាំ ១៩៥០ (ម.៥២|១៥) ។

សាធុរក្ខណគាថា : ព្រះគ្រូសិរីសោភណ កឹម-តួរ ទ.ក. ១២, ទំព័រ ៨៨៦ ឆ្នាំ ១៩៥៣ (ម.៥២|២៥) ។

សភាវៈត្រូត : អ្នកឧកញ៉ាវិបុលរាជសេនា នូ កន ទ.ក. ២ ទំព័រ ៩០, ឆ្នាំ ១៩៤៧ (ម.៥២|២០) ។ ពាក្យបរិយាយដើមនៃរឿងសាមកុក:ហ្វាំងទិពនូមន្ត្រី ញ៉ុក-ថែម ទ.ក. ២, ទំព័រ ៨១, ឆ្នាំ ១៩៤៨ (ម.៥២|២០) ។

សាមគ្គីកថា : មហា ស៊ុំ-កោ ទ.ក. ៤, ទំព័រ ២៩៣, ឆ្នាំ ១៩៤៩ (ម.៥២/២១) ។ ព្រះមហាឡាត់ ពាន់-លី ទ.ក. ៦, ទំព័រ ៤០៩, ឆ្នាំ ១៩៥២ (ម.៥២/២៤) ។ ព្រះគ្រូវិសុទ្ធិញាណ សួរ-ហាយ ទ.ក.៦, ទំព័រ ៣១៧, ឆ្នាំ ១៩៤៧ (ម.៥២/១៩)។ ព្រះមហា ឈឹម-មី ទ.ក. ២១, ទំព័រ ៨០៣, ឆ្នាំ ១៩៥៤, (ម.៥២/២៥) ។

សាមគ្គីធម៌ : សម្តេចព្រះពោធិវង្ស ហួត-តាត ទ.ក. ៣, ទំព័រ ៤២៦, ឆ្នាំ ១៩៦៥ (ម.៥២/៣៧) ។

សាធឿ : បុណ្យស្រង់ព្រះពុទ្ធរូប ទ.ក. ៦, កូមិបាឋទគ្រួសារត្រកូលក្បា៉ ទ.ក. ៩, ទំព័រ ១, ធាតុចេតិយលាវនៅមឿង ទ.ក. ១០, ទំព័រ ១, ឆ្នាំ ១៩៥១ (ម.៥២/១៣) ។

សារលិខិតនៃលោកស្វាអីវិវេកានន្ទ : លោក ក៉យ-ប៊ុក ទ.ក. ៤, ទំព័រ ២៦៦, ឆ្នាំ ១៩៥១ (ម.៥២/២៣) ។

សារទេសនា : ព្រះវិសុទ្ធិវង្ស ហ.តាត ទ.ក. ១០-១១-១២, ទំព័រ ៣, ឆ្នាំ ១៩៣៧ (ម ៥២/៩) ។

សាវតារវត្តចាយន : មេឃុំ ឌួង-អ៊ុប ទ.ក. ៧, ទំព័រ ៥១៩, ឆ្នាំ ១៩៥០ (ម.៥២/ ២) ។

សាវតារវត្តវិហារឧត្តម : អ្នកឧកញ៉ា កែវ ហង្ស ទ.ក. ៥, ទំព័រ ៣៥៣, ឆ្នាំ ១៩៥០ (ម.៥២/២២) ។

សាភណីយធម្មកថា : ព្រះមហា កែ អឿន ទ.ក. ១, ទំព័រ ៣,
ឆ្នាំ ១៩៥២ (ម.៥២/២៤) ។

សាភណីយធម៌ : ព្រះមហា ប៉ាច់-សឿន ទ.ក. ៩, ទំព័រ ៦៤៣,
ឆ្នាំ ១៩៥៣ (ម.៥២/២៥) ។

សាវតារជាងហ្សួនជាតា : លោក អុំ-ហ៊ី ទ.ក. ១, ទំព័រ ៣២,
ឆ្នាំ ១៩៥៧ (ម.៥២/២៩) ។

សាវតារវត្តកោកណ្ដាល : លោក ឌ.តាម ទ.ក. ១, ទំព័រ ៧៥,
ឆ្នាំ ១៩៦៥ (ម.៥២/៣៧) ។

សាវតារវត្តអដ្ឋរស : អ្នកអង្គម្ចាស់ក្សត្រី ន.សុខាធារី ទ.ក. ៩,
ទំព័រ ៦៨៤, ឆ្នាំ ១៩៥០ (ម.៥២/២២) ។

សាវតារវត្តកោះឆតារង្សី : ព្រះមហា គុយ ហួត ទ.ក. ៤, ទំព័រ
៤៨០, ឆ្នាំ ១៩៥១ (ម.៥២/២៣) ។

សាលាបារាំងសេសនៅចុងបូព៌ាប្រទេស : ក្រមការ ជុំ-មៅ
ទ.ក. ៤, ទំព័រ ៥១, ឆ្នាំ ១៩២៧ (ម.៥២/២) ។

សាលាបង្រៀនមនុស្សខ្វាក់ នៅប្រទេសសៀម និង
ទ្វីបអឺរុប : ខេមរង្សី ទ.ក. ៣, ទំព័រ ៩, ឆ្នាំ ១៩៤០ (ម.៥២/១៦)។

សាលារៀននៅប្រទេសជប៉ុន : អ្នកស្រីសារិះយ៉ាន ទ.ក. ១៦,
ទំព័រ ៩២០, ឆ្នាំ ១៩៥៥ (ម.៥២/២២) ។

សាសនបវត្តិបរិច្ឆេទ ទី ១–២ : ព្រះមហាពិទូរក្រសេម ទ.ក. ១-៦, ទំព័រ ១៦៤, ឆ្នាំ ១៩៣៣ (ម.៥៤/៥) ។ ទី ៨ ទ.ក. ៤ ៥–៦ ទំព័រ ៤១, ឆ្នាំ ១៩២៥ (ម.៥២/៧) ។

សាសនាវតារសង្ខេប : លោកអាចារ្យ មៀវ-នន្ទ ទ.ក. ៥, ទំព័រ ២៦៥, ឆ្នាំ ១៩៤៥ (ម.៥២/១៧) ។

សាសនភក្តី (កោតក្យ) : យុទ ស្នេហា ហ៊ុម ទ.ក. ៧–៨ ៩, ទំព័រ ១៣១, ឆ្នាំ ១៩៣៦ (ម.៥២/៨) ។

សាសនាមានប្រយោជន៍យ៉ាងណា : ព្រះឧបាលិវង្ស សូរ-ហាយ ទ.ក. ១០, ទំព័រ ៣៤៣, ឆ្នាំ ១៩៥៥ (ម.៥២/២២) ។

សាសនាឥស្លាម និង សាសនាកាតូលិក : លោក ទៀង-កៃឈុន ទ.ក. ១, ទំព័រ ៦៤, ឆ្នាំ ១៩៥៧, (ម.៥៤/៦៩) ។

សាសនបវត្តិ : ព្រះមហាពិទូរក្រសេម ទ.ក. ១-២-៣, ទំព័រ ២៧, ឆ្នាំ ១៩៣៦ (ម.៥៤/៨) ។

(នៅមានត)

# ជីវប្រវត្តិរបស់ខ្ញុំ

ឈ្មោះ អៀង-សាយ

(គ)

មិនមែនតែម្ដង ពីរដងនេះទេ មានម្ដងក្រោយធ្លាយមកទៀត គេដាក់ការបានចែករថយន្តធុនធំ ១ ឲ្យមួយ ១ គ្រប់ក្រសួង ឲ្យតុបតែងលំអរ តាមចេះគិត បេះធ្វើយ៉ាងណាឲ្យបានល្អមើល ក្នុងឱកាសបុណ្យហែក្បួនយ៉ាងធំ ក្នុងយប់មួយនោះ គេនឹងឲ្យលេខឲ្យរង្វាន់ ។ កាលនោះរថយន្តដែលខ្ញុំតុបតែងលំអរ ដោយគោមក្រដាស ដាក់ភ្លើងខាងក្នុង និងលំអដោយសម្លៀកបំពាក់សិស្សប្រុស - ស្រី ប្អូន - ប្រាំនាក់ ឈរមានរបៀបនៅលើរថយន្តបានទទួលរង្វាន់លេខ ១ ។

សូមបញ្ជាក់បញ្ចប់ ១ ភាគខាងវិចិត្រសិល្បៈថា សញ្ញាបត្រពុទ្ធិកសមាគមកម្ពុជរដ្ឋ ដែលព្រះតេជព្រះគុណ, ព្រះករុណា និង លោកអ្នកជាសមាជិកមាន ១ សន្លឹក ដាក់ក្នុងក្របកញ្ចក់នោះ គឺជាសំណាដៃរបស់ខ្ញុំព្រះករុណា ខ្ញុំបាទបានគិតគូរ គម្រូវឱ្យគេគូរតាមគោលអធិការនេះ ឲ្យគេធ្វើពុម្ពតាមគំនូរនោះ ។

មួយទៀត គ្រាន់តែអក្សរ ក ខ គ ឃ ង ដែលគេចេះសរសេរគ្រប់គ្នា ក៏គេពឹងពាក់ខ្ញុំ ឲ្យសរសេរយកមកធ្វើពុម្ព ដាក់នៅដើមពាក្យតាមលំដាប់អក្សរ ក្នុងវចនានុក្រមខ្មែរទាំងពីរក្បាល ដែលមាននៅ

គ្រប់ទីកន្លែងទាំងអស់ សព្វថ្ងៃនេះ គឺអក្សរ ក ខ គ ឃ ង ធុនធំ ដែលមានស្រមោលខ្មៅនៅទំព័រដើមពាក្យ តាមលំដាប់អក្សរនោះ ៗ

ក្នុងប្រវត្តិខ្ញុំ មានរឿងមួយ ដែលខ្ញុំទុកដូចជាខ្យល់ព្យុះបោកបក់មកលើខ្លួន ដែលខ្ញុំនៅកណ្តាលសមុទ្រ គឺកាលគ្រាដែលហោចហេវក្នុងសាកល ( គ្រឹះម៉ុងឌីយ៉ាល់ ) ក្រុមការអាណាព្យាបាលនៅឥណ្ឌូចិន សម្រេចថា ត្រូវបន្ថយចំនួនអ្នកធ្វើការ ដើម្បីសំចៃប្រាក់ទុកទប់ទល់ នឹងការហោចហេវរកប្រាក់មិនបាន គេបាត់អាំងស្ប៉ិកទ័រ ឲ្យមកគិតបន្ថយចំនួនអ្នកធ្វើការ អ្នកណាមិនសូវចេះ ឬចេះដែរ តែធ្វើការមិនសូវមានប្រយោជន៍ គេបណ្តេញលុបឈ្មោះចោល ៗ គេសើរើមើលពិនិត្យគ្រប់ក្រសួង មកដល់សាលា•សិប្បកម្ម គេពិនិត្យសើរើមើលសញ្ញាប័ត្រគ្រូ ៗ មើលកិច្ចការដែលបានធ្វើ ឬបានបង្រៀន មើលការសិស្សរបស់គ្រូម្នាក់ ១ ៗ មកដល់ឈ្មោះខ្ញុំ គេឃើញខ្ញុំថា ខ្ញុំគ្មានសញ្ញាប័ត្រខាងគំនូរសិប្បការ មានតែសញ្ញា-ប័ត្រខាងគំនូររចនា តែចៅហ្វាយនាយខ្ញុំ បង្ហាញការដែលខ្ញុំគូរប្លង់ ហើយបង្ហាញការ ដែលខ្ញុំបានគូរនិងបង្រៀនគំនូរសិប្បការជាច្រើនឲ្យគេមើល គេឆ្ងល់គេសួរខ្ញុំថា : អ្នកឯងចេះដេស៊ីនអាំងឌុស្ទ្រីយែលពីណាមក? ខ្ញុំឆ្លើយថា : ខ្ញុំរៀនតាមសៀវភៅច្បាប់ក្បួនគំនូរ ៗ គេទារកសៀវភៅនោះ ខ្ញុំយកមកឲ្យគេមើល ៗ គេមើលរួច គេនិយាយ

ទីងទៅហាយខ្ញុំថា : អាចេះតូវតែធ្វើការបានល្អហើយ តែកុំឲ្យបង្រៀន ធ្វើការតាមសៀវភៅច្បាប់ក្បួនជាន់ចាស់ ដែលអារៀននោះ ត្រូវឲ្យវា ទៅមើលគេបង្រៀនធ្វើការតាមសៀវភៅច្បាប់ក្បួនថ្មី ឯអេកូលប្រាទិច-ជាំងឌុសត្រីយ៉ែល ឯព្រៃនគរវិញ ។

ក្នុងគ្រានោះ នៅស្រុកយួន ស្រុកលាវ និងស្រុកខ្មែរ ប្រហែល ជាគេបណ្ដេញលុបឈ្មោះអស់ច្រើន ដ្បិតគ្រាន់តែសាលាឧស្សាហកម្ម មានគ្រូខ្មែរពីរនាក់ និងគ្រូយួនម្នាក់ ត្រូវគេបណ្ដេញលុបឈ្មោះចោល ។

ឯខ្លួនខ្ញុំ ត្រូវគេបញ្ជូនឲ្យទៅមើល ទៅហាត់ធ្វើការ តាមច្បាប់ ក្បួនថ្មីនៅសាលាឧស្សាហកម្មឯព្រៃនគរ ខ្ញុំចម្លងច្បាប់ក្បួនគំនូរដែល គេបន្ថយការឲ្យឆាយធ្វើបានឆាប់ ឲ្យឆាយយល់ឃើញត្រង់ណាថែកពី សៀវភៅចាស់ ខ្ញុំចម្លងដោយសរសេរផង គូរផង បានមួយសៀវភៅ ។ ចាងហ្វាងសាលា ជាតិបារាំងឃើញថា ខ្ញុំចេះដឹងសព្វគ្រប់ហើយ ឲ្យខ្ញុំ ប្រឡងជាមួយពួកសិស្សយួន ដោយដាក់វិញ្ញាសាដូចគ្នាទាំងអស់ គឺ សិស្សថ្នាក់ទី ៣ ។

ខ្ញុំធ្វើបានល្អត្រឹមត្រូវដែរ តែទាស់ខ្ញុំធ្វើយឺតយូរជាងគេ បើបារាំង វាថាប្រមូលយកទៅពេលម៉ោងដែលគេហើយគ្រប់គ្នានោះ ខ្ញុំធ្វើបានតែ ៧ ភាគ ១០ តែគេបណ្ដោយឲ្យខ្ញុំហើយក្រោយគេ ខ្ញុំខ្វាសគូនសិស្ស ជាតិបួន ដោយវាដឹងថា ខ្ញុំធ្វើជាគ្រូទៅហើយ មកធ្វើការមិនរហ័ស

ដូចរាំ ៗ ដល់ខ្ញុំពិនិត្យរកហេតុ ដែលគេធ្វើរហ័សនិងខ្ញុំធ្វើយឺតយូរទៅ ឃើញថា ការគូសដីខ្មៅ ហើយដាក់ទឹកខ្មៅបង្ហើយ គេមិនបាច់គូរ, សរសេរដោយដីខ្មៅ ទាំងអស់នេះ ១ ដោយគេចាំគូរ ចាំសរសេរ ដោយទឹកខ្មៅតែម្តង ត្រង់ណាដែលឆ្ងាយនោះ ៗ មួយទៀត ការដាក់ទឹកខ្មៅគេមិនចាំស្ងួតទឹកខ្មៅទើបដាក់បន្ទាត់ ដូចជាខ្ញុំខ្លាចដាម ខ្លាចប្រឡាក់នោះទេ គេមានបន្ទាត់ពិសេស ដែលមានកំណល់ចុងដើម បង្ហើបមិនឲ្យប៉ះដល់ក្រដាស ដែលមានគំនូសទឹកខ្មៅនៅសើម ៗ

ដល់ខ្ញុំត្រឡប់មកពីព្រៃនគរវិញ ខ្ញុំចង់រើបម្រះចេញពីសាលាទស្សា-កម្មដោយពិបាកនឹងយានជំនិះទៅមក ឆ្ងាយពីផ្ទះដែលមានចម្ងាយ ៥ គីឡូម៉ែត្រ បើគុណនឹង ៤ ដែលខ្ញុំទៅមក ៤ ដង ក្នុង ១ ថ្ងៃ ឃើញជិះកង់ចម្ងាយ ២០ គីឡូម៉ែត្រ ៗ

ខ្ញុំរកឧបាយដោយសរសេរសៀវភៅច្បាប់ក្បួនបង្រៀនគំនូរ ធរណី-មាណសាស្ត្រ ( ដេសំង ហ្សេអូមេទ្រិក ) នៅខាងដើមសៀវភៅនេះ មានពាក្យផ្តើមដែលខ្ញុំរំលើកអំពីគ្មានគ្រូខ្មែរ ចេះគំនូរធរណីមាណ-សាស្ត្រ មានខ្ញុំម្នាក់ និងគ្រូបារាំងជាច្រើន ហើយបញ្ចេញគំនិតដែលខ្ញុំគិត ចង់ឲ្យខ្មែរចេះគំនូរ ដោយរបៀបណានោះ ៗ

ខ្ញុំយកសៀវភៅ ដែលខ្ញុំទើបនឹងសរសេរគួរ បានភាគខាងដើមបន្តិច យកទៅជូនលោកនាយកនៃការសិក្សា ដែលកាលនោះមាន

លោក អ៊ុំ-ឈាងស៊ុន និង លោក ទៀង-គង់ នៅទីនោះ ។ ខ្ញុំធ្វើជាសួមសួរថា សូមមេត្តាជួយឲ្យយោបល់ តើសៀវភៅបែបនេះ បើខ្ញុំសរសេរចប់ទៅ ហើយបោះពុម្ពលក់ ឬ ជូនមកជការ តើវាមានប្រយោជន៍ឬទេ ?

ពេលនោះគេទទួលសៀវភៅខ្ញុំទុក ថាចាំមានពេលនឹងពិនិត្យមើលៗ

ក្រោយពីពេលនោះមកមិនយូរប៉ុន្មាន ខ្ញុំបានគេផ្លាស់ឲ្យមកបង្រៀនគំនូរធរណីមាណសាស្ត្រទៅសាលាគរុវិជ្ជា ដោយកាលនោះ សាលាគរុ-វិជ្ជានៅជាប់នឹងវិទ្យាល័យស៊ីសុវត្ថិ ។

កាលនោះ អាយុខ្ញុំបាន ៤៥ ឆ្នាំ ខ្ញុំនៅតែជាប់គំនិតបង្រៀនសិស្សផង នាំលេងកំប្រៀង និង លេងកល់ថ្ពនភ្លេងផង តែដល់មានពិធីបែករង្វាន់ ឬ បុណ្យកឋិន ខ្ញុំតែងតែជួយលេងកំដរបរិយាកាស ឲ្យបានសប្បាយរីករាយ ហើយដល់ពេលវិស្សមកាល នាំអ្នកហាត់លេងកំប្រៀង រួចចេញទៅលេងខេត្តក្រៅ កាលឆ្នាំណានោះ លោក កេង-វ៉ាន់-សាក់ និង លោក ហង់ ធុនហាក់ កាលនៅជាសិស្សវិទ្យាល័យនៅឡើយ បានទៅលេងជាមួយនឹងខ្ញុំ នាំគ្នាចូលទៅលេងកងពេងកុន ឬ ពេងល្ងោន នៅខេត្តកំពង់ចាម យកប្រាក់មកជួយជាតិ ។

ឯសិស្សសាលាគរុវិជ្ជានិងខ្ញុំ បាននាំគ្នាហាត់លេងញីកញយ ដោយខ្ញុំសរសេរឲ្យលេងរឿងគតកថ្លៃដ៏ខ្ញុំ ។ និងហាត់កំប្រៀងគម្រូវិធីបែករង្វាន់ ឬ

បុណ្យផ្កា បុណ្យកឋិន ហើយមានបាននាំគ្នាទៅលេង ឲ្យគេមើលនៅខេត្តក្រៅ យកប្រាក់មកជួយសិស្សដែលទីទាល់ក្រ ឲ្យទៅបន្តវិជ្ជាឯប្រ-ទេសបារាំង ។

បើសរសេរពីការដែលបានជួយសរសេរអត្ថបទ បានជួយគូររូបដាក់ក្នុងសារពត៌មាន ខ្ញុំត្រូវត្រឡប់ទៅសរសេរពីខាងដើមមកវិញថា : កាលអាក្បត់ជាតិម្នាក់ ក៏នៅជាមនុស្សល្អនៅឡើយ ក៏បបួលបានគ្នាដប់នាក់ គឺខ្លួនក៏ ១ ឯ. ។. ស. រ. កាលនៅជាមេធាវី ១, លោក ប៊ិ-ហ៊ី-១, លោក ស៊ិ-រ-១, មហា ក-ស-១, មហា ថ-១, លោកអាចារ្យ ស-១, លោក ជ-ម-១, និងខ្ញុំនេះ ១ បាននាំគ្នាចេញសារពត៌មានមួយឲ្យឈ្មោះថា ខេមរវត្ត គេចែកមុខការឲ្យខ្ញុំសរសេរអត្ថបទខាងសិល្បៈ មានវេទនា និងរបាំជាដើម ខ្ញុំជួយធ្វើតាំងពីកាសែតនេះកើតរហូតដល់ស្លាប់ ដោយខ្ញុំមិនដឹងចិត្តគំនិតអាមេក្បត់នេះ ខ្ញុំស្មានថាក៏ធ្វើការជាប្រយោជន៍ដល់ជាតិ ខ្ញុំចេះតែជួយរហូតបាត់ខ្លួនក៏ម្តងទៅ ដល់ក៏ត្រឡប់មកវិញ នាំធ្វើកាសែតមួយទៀតឲ្យឈ្មោះថា ខ្មែរក្រោក ខ្ញុំនៅតែស្មានថា ក៏ជាមនុស្សល្អ ដោយពួកអ្នកដែលខ្ញុំរាប់ឈ្មោះបួនដប់នាក់មុននេះ ក៏បានចូលជួយដែរ ថែមទាំងមានលោកអ្នកថ្មីជួយទៀតមានលោក ម.យ និង ជ-ជ ជាដើម ទាំងលោក រ.គ. និង ហ. ធ. ហ. ក៏ចូលជួយធ្វើការកាសែតខ្មែរក្រោកនេះដែរ ។

ខ្ញុំស្តាយហៅសែនស្តាយ ដោយរៀនកាត់ពេលថ្ងៃសៅរ៍ ដែលយកអត្ថបទទៅជួបជុំគ្នានោះ មានប៉ូលិសចាំយាមទ្វារកកាតខ្ញុំមើលហើយកត់ឈ្មោះគ្រប់គ្នា លោកអ្នកដែលចូលនោះ ។

លុះដល់តាមេកាសែតនេះ ក៏ទៅជាមេក្បត់ជាតិចូលព្រៃបាត់ ទើបចាំងអស់គ្នាភ្ញាក់ខ្លួនភ័យជាក្រោយ ដោយមានឈ្មោះក្នុងបញ្ជីទៅថាជាពួកក៏មានទោសប្រកាន់ចង់បណ្តេញខ្ញុំឲ្យលែងធ្វើការ ចង់បន្ទយថ្នាក់ស័ក្តិយសខ្ញុំ តែខ្ញុំសូមទោសគេថា ខ្ញុំមិនមែនជាអ្នកនយោបាយ ខ្ញុំជាកវីនិពន្ធជាវិចិត្រសិល្បករ ដោយខ្ញុំមានចំណេះនេះ គេហៅឲ្យជួយសរសេរ ជួយគួរ មិនមែនឲ្យជួយក្បត់ជាតិទេ ពួកក្បត់តែម្នាក់ៗ ខ្ញុំគ្មានបានទៅរួមគំនិតក្បត់ទេ ខ្ញុំសរសេរបំភ្លឺ សរសេរអប់រំគេទេតើ ។

គេលែងទោសប្រកាន់ទោសខ្ញុំ តែឈ្មោះខ្ញុំប្រឡាក់លាងមិនជ្រះ ខ្ញុំចង់ឲ្យជ្រះ ខ្ញុំចេញពីគណៈបក្សប្រជាធិបតេយ្យ មកសុំចូលក្នុង ចលនាសង្គមរាស្ត្រនិយម ។

ខ្ញុំចង់ឲ្យមានឈ្មោះជាអ្នកបកប្រែភាសាបារាំងមកជាភាសាខ្មែរ ខ្ញុំឃើញអក្សរបារាំងក្នុងសៀវភៅ ឬនៅកាសែត ដែលជាពាក្យមួយឃ្លាពិបាកយល់សេចក្តី ពិបាកបកប្រែ ខ្ញុំយកមកបកប្រែគិតតាមសេចក្តីពន្យល់នៅក្នុង ទិកស៊ីយ៉ូនែរ មួយម៉ាត់ម្តង លុះតែយល់ល្អមបកប្រែជាខ្មែរបានសេចក្តីល្អ ។ ដោយពីដើមមិនទាន់មានគណៈកម្មការវប្បធម៌

គ្មានសៀវភៅបកប្រែពាក្យបារាំងមកជាពាក្យខ្មែរនៅឡើយ ខ្ញុំលេងតែម្នាក់ឯង ដល់លេងណាស់ទៅ ចេះតែយល់ឃើញភ្លាម ៗ សរសេរជាខ្មែរតាមសេចក្ដីនោះ ធ្វើជាសួរគេអ្នកមានសញ្ញាប័ត្រធំ ៗ ថាបើប្រែជាខ្មែរយ៉ាងនេះត្រូវឬទេ ? ជួនកាលយកឃ្លាណាដែលដឹងថា ពិបាកបកប្រែជាខ្មែរទៅសួរគេអ្នកចេះ ឲ្យគេជួយបកប្រែ តែគេមិនធ្លាប់បកប្រែ គេគ្រាន់តែយល់សេចក្ដី មិនអាចនឹងសរសេរបកប្រែឲ្យខ្ញុំហើយត្រូវតាមពាក្យនោះ ដល់ខ្ញុំធ្វើជាសរសេរបកប្រែហើយ សួរថា បើប្រែយ៉ាងនេះត្រូវឬទេ គេឃើញថា ខ្ញុំពូកែដល់មា ការបកប្រែ គេហៅឲ្យជួយ ៗ ញយ ៗ ទៅល្បីឮឈ្មោះថាខ្ញុំចេះបកប្រែភាសាបារាំងមកជាភាសាខ្មែរល្អណាស់ ។

ខ្ញុំមានរឿងមួយទៀត ដោយគេបញ្ជូនសៀវភៅបោះពុម្ពអក្សរបារាំង ១ ក្បាល និងសៀវភៅសរសេរដោយដៃ ១ ក្បាល ជាអក្សរខ្មែរព្រមទាំងសំបុត្រមួយមកហៅហ្វាយខ្ញុំ ៗ ឲ្យគេហៅខ្ញុំមកជួបលោក ឃើញមុខខ្ញុំលោកសើចញឹម ៗ ហើយហុចសៀវភៅទាំងពីរនិងសំបុត្រមួយឲ្យខ្ញុំ ៗ មើលឃើញសេចក្ដីក្នុងសំបុត្រនោះ សូមលោកអាណិតឲ្យឈ្មោះ អៀង - សាយ មើលពិនិត្យកែឲ្យបានត្រឹមត្រូវ សៀវភៅដែលគេបកប្រែពីបារាំងមកជាខ្មែរដែលផ្ញើមកនេះ ។

(នៅមានត)

# សិរី នៃកបិលមហាព្រហ្ម

សហជីវិន ឆល-ទិត នៅពុទ្ធសាសនបណ្ឌិត្យ

(១៧-៤-៦៧)

រាល់តែពេលចូលឆ្នាំថ្មី រឿងកបិលមហាព្រហ្មដែលចោទបញ្ហាអំពីសិរីចំពោះធម្មបាលមាណព តែងលើកឡើងមកសំដែងជាសាធារណៈ អស់កាលយូរលង់មកហើយ, តើយើងបានចាប់ភ្ញាក់គិតនាដល់ន័យដ៏មានខ្លឹមសាររបស់ពាក្យថា សិរី នេះឬទេ ? បើបានគិតនាដែរ, តើអ្វីទៅដែលហៅថា សិរី ?

តាមប្រភពរឿងព្រេងកបិលមហាព្រហ្មនេះ បានឲ្យដំណឹងដល់យើងថា សម័យកាលនោះ ពិភពមនុស្សលោក ឋិតនៅក្រោមទេវបញ្ជារបស់ព្រហ្មដែលនៅឯព្រហ្មលោក ។ ព្រះព្រហ្មបានចាត់ឲ្យកបិលមហាព្រហ្មមកគ្រប់គ្រង ដឹកនាំមនុស្សលោកឲ្យប្រតិបត្តិតាមនូវអ្វីៗគ្រប់យ៉ាងតាមទេវបញ្ជា ដោយហេតុគេយល់ថា មនុស្សលោក ជាកូនបង្កើតរបស់ព្រះព្រហ្ម គឺព្រះព្រហ្មហ្នឹងឯង ជាអ្នកបង្កើតពិភពលោកតាំងមូល ព្រមទាំងមនុស្សសត្វ និងសារពើធម្មជាតិទូទៅ ។

ប៉ុន្តែ ពិភពមនុស្សលោកនេះ ត្រូវបានផ្លាស់ប្តូរបរិនាយកថ្មីដែលមានជាតិជាមនុស្សដូចគ្នាវិញ ចាប់តាំងពីខណៈដែលមាណពម្នាក់មានសញ្ជាតជាមនុស្សឈ្មោះ ធម្មបាល បានជោគជ័យលើកបិល

មហាព្រហ្មក្នុងការដោះស្រាយបញ្ហា ហើយកបិលមហាព្រហ្មប្រគល់កិច្ចការដឹកនាំមនុស្សលោកឲ្យដល់ជាតិមនុស្ស រួចលោកកាត់ព្រះសិរៈក្ស័យព្រះជន្មនោះមក ។

សេចក្តីនេះ សឲ្យដឹងថា ប្រហែលជាពេលពីមុនមក ពុំទាន់មានជាតិមនុស្សណាម្នាក់ដែលមានសតិបញ្ញា អាចនឹងដឹកនាំពិភពលោកយើងនេះបានឡើយ ទើបការកិច្ចដឹកនាំនេះ ឋិតនៅក្នុងកណ្តាប់ព្រះហស្តរបស់ព្រះព្រហ្ម ។ លុះក្រោយមក ជាតិមនុស្ស កាន់តែចំរើនការចេះដឹងឡើងជាលំដាប់ រហូតដល់អាចគ្រប់គ្រងពិភពលោកដោយខ្លួនឯងបាន ទើបព្រះព្រហ្ម ទ្រង់ផ្ទេរក្រសួងគ្រប់គ្រងដឹកនាំពិភពលោកនេះ មកឲ្យមនុស្សលោកកាន់កាប់ផ្ទាល់ដោយខ្លួនឯងវិញ ។

ការកាត់ផ្តាច់នូវព្រះសិរៈរបស់ព្រះព្រហ្ម គឺជានិមិត្តរូបនៃការផ្ទេរអំណាចសព្វយ៉ាង, បានសេចក្តីថា ព្រះព្រហ្ម លោកផុតអំណាចដឹកនាំពិភពមនុស្សលោក ចាប់តាំងពីគ្រានោះ មក ។

ដើម្បីជាអនុស្សាវរីយ៍ និងដើម្បីសំដែងនូវកតញ្ញូតាចំពោះព្រះកជ-ហឫទ័យដ៏សប្បុរសរបស់ព្រះព្រហ្ម ដែលបានប្រគល់អំណាច និងសិទ្ធិគ្រប់យ៉ាងក្នុងកិច្ចគ្រប់គ្រងដឹកនាំពិភពលោក មកឲ្យមនុស្សលោកដោយមេត្តាករុណានេះ ទើបបានជាមនុស្សលោក តែងតែធ្វើពិធីយ៉ាងអធិករំឭកដល់ប្រវត្តិរបស់លោក ជារៀងរាល់ពេលចូលឆ្នាំថ្មីនេះឯង ។

រីឯបញ្ហា ដែលព្រះព្រហ្មលើកមកចោទសួរជាតិមនុស្ស ដើម្បីស្ទាបស្ទង់មើលសតិបញ្ញាការចេះដឹងនោះ គឺ បញ្ហាសិរី ។

ពាក្យថា សិរី នេះ បើនិយាយឲ្យខ្លីថា អ្វីៗ ដែលជាប៉ែកខាងល្អប្រសើរ ហៅថា សិរី ទាំងអស់ ព្រោះវចនានុក្រមខ្មែរបានបញ្ជាក់ថា សិរី គឺ លំអ, លំអដែលគួរឲ្យស្រឡាញ់; សួស្តី, ស្រីសួស្តី; មង្គល; ជោគ; សេចក្តីសុខ, សេចក្តីចំរើន; បុណ្យ, ភ័ព្វបុណ្យ; ភព្វព្រេង, សំណាងល្អ, ព្រេងសំណាងល្អ; ទ្រព្យ; ការមានបាន, លាភ; ឥស្សរភាព; តេជះ, អំណាច; រាជស័ក្តិ; ទិព្វស័ក្តិ; ភគវតី; លក្ខ្មី ។ល។

ដូច្នេះ គប្បីយល់ថា បានជាព្រះព្រហ្មលើកយកសិរីមកចោទសួរមនុស្ស ព្រោះសិរីនេះ អាចចាត់ទុកបានថា ជានិមិត្តរូបនៃឥស្សរភាពរបស់មនុស្សលោកហ្នឹងឯង ។

ឥឡូវ យើងចង់ដឹងន័យខាងចំលើយ របស់ធម្មបាលមាណព ដែលលើកយកទឹកមកឲ្យឈ្មោះថាសិរីវិញ, ចំលើយនោះថា សិរី នេះ ពេលព្រឹកឋិតនៅត្រង់មុខ ព្រោះពួកមនុស្សតែងភ្ញាក់ឡើងពីដេក ហើយយកទឹកមកលុបមុខរាល់តែពេលព្រឹក, ពេលថ្ងៃត្រង់ឋិតនៅត្រង់ដើមទ្រូង ព្រោះពួកមនុស្សកាលណាតែក្តៅខ្លាំង តែងតែយកទឹកមកលាបស្រឡាបដើមទ្រូង, ពេលល្ងាចឋិតនៅត្រង់ជើង ព្រោះពួកមនុស្សតែងយកទឹក

មកលាងជើងមុនទើបចូលដំណេក ។ បានសេចក្តីថា បើទឹក ទៅទទឹក ទីងអយេរៈណា, សិរី គឺបិតនៅត្រង់អយេរៈនោះដែរ គឺទឹកហ្នឹង ឯងជាសិរី ។

តើសមឬទេ ? ចំពោះបំឡេយធម្មបាលមាណពនេះ ដែលលើក ទឹក មកឲ្យឈ្មោះថា សិរី ។

តាមយោបល់ខ្ញុំ ថាសមហើយ ព្រោះសម័យនោះ នៅប្រទេស ឥណ្ឌា មានសាស្តាច្រើនណាស់ ដែលប្រកាសលទ្ធិប្លែកៗ ពីគ្នា ។ បណ្តាលទ្ធិទាំងនោះ, មានលទ្ធិខ្លះ គោរពភ្លើង, ខ្លះ គោរពសត្វ អាស្តិរស, ខ្លះ គោរពដី, ខ្លះ គោរពខ្យល់ ។ល។ ខ្លះ គោរព ទឹក ។ ដើម្បីឲ្យបានចំណេញឥទ្ធិពលរៀងខ្លួន, សាស្តាទាំងនោះ ក៏ខំសំដែងរឿងកាត់ក្នុងលទ្ធិរបស់ខ្លួនឲ្យឃើញអស្ចារ្យផ្សេងៗ ជាប្រកព បញ្ជាក់ថា លទ្ធិរបស់ខ្លួន ពិតជាលទ្ធិត្រឹមត្រូវប្រាកដមែន ។ ដូច លទ្ធិគោរពគោញី, មេលទ្ធិខំប្រឹងអួតសរសើរ អំពីគុណសម្បត្តិគោញី ថាជាព្រះនៃមនុស្សលោក, លទ្ធិគោរពភ្លើង, ក៏ប្រឹងពណ៌នា អំពីលទ្ធិ នៃព្រះភ្លើងថា ជាព្រះនៃពិភពលោកមនុស្សយើងដែរ ។

ឯលទ្ធិគោរពទឹក ក៏ខំប្រឹងធ្វៀតបញ្ចូលព្រះទឹក ទៅក្នុងទេវប្រវត្តិ លើកតំកើងទឹកថា ជាវត្ថុពិសេសបំផុតក្នុងលោក ដូចគ្នាដែរ ។ យ៉ាង ហ្នឹងហើយ បានជាទឹកក្នុងរឿងមហាព្រហ្មនេះ លោកចាត់ទុកថាជា

សិរីរបស់ពិភពលោក គឺគេចាត់ទឹកនេះទុកជា ជាវត្ថុសក្តិសិទ្ធិបំផុត រហូតដល់មានតេជះអាចនឹងរំដោះយកឥស្សរភាពនៃមនុស្សលោក អំពីព្រះព្រហ្មដែលជាកំពូលនៃត្រៃលោកបានទៀតផង ។

ម្យ៉ាងទៀត ទឹក នេះ ជារបស់យ៉ាងចាំបាច់របស់មនុស្សសត្វ ព្រោះមនុស្សសត្វត្រូវការទឹក ដើម្បីរស់ ហើយក៏ជារបស់ចាំបាច់ ម្យ៉ាងទៀត គឺមនុស្សត្រូវការប្រើប្រាស់ទឹកសំរាប់ងូតជំរះកាយ, លាងសំអាតនូវអ្វីៗ ដែលប្រឡាក់ និងសំរាប់លាបស្រឡាបឲ្យត្រជាក់ ។ល។ ដូច្នេះ លុះតែចាត់ ទឹក ទុកជា ជាសិរី បានមែន ។

ប៉ុន្តែ បើឲ្យរិតតែសមជាងនេះទៅទៀត គឺទឹកដែលចាត់ទុកជាជាសិរីនេះ សំដៅយកទឹកចិត្តដ៏ត្រជាក់របស់មនុស្សលោក ។ មនុស្សក្នុងលោកនេះ តែងមានភាពពុំស្មើគ្នា ដូចជា ខ្លះមានកម្លាំងច្រើន, ខ្លះខ្សោយ, ខ្លះបេះ, ខ្លះល្ងង់, ខ្លះមានប្រាជ្ញា, ខ្លះអប្បប្រាជ្ញា, ខ្លះមានទ្រព្យច្រើន, ខ្លះក្រីក្រ, ខ្លះមានតេជះអំណាច, ខ្លះអាប់រស្មី ។ល។ ខ្លះជាមហាអំណាច, ខ្លះនៅទន់ខ្សោយ ។ ការខុសសភាពគ្នានេះ បើមនុស្សក្នុងលោកពុំយកទឹកចិត្តដ៏ត្រជាក់ មកប្រើសម្រាប់លាងជំរះ ដោះស្រាយបញ្ហាផ្សេងៗ រវាងគ្នាទេ ពិភពលោកនេះ ទំនងដើរទៅរករណ្តៅភ្លើងអន្តរាយយ៉ាងឆាប់រហ័ស ព្រោះតែភ្លើងចិត្តដ៏ក្តៅ ដ៏[illegible] ប្រហាញទៅ ។ ដូច្នេះ សិរី សំដៅយកទឹកចិត្តដ៏ត្រជាក់នេះ

ឃើញថា ត្រូវហើយសមៈទៀតផង ដែលពុំចាំបាច់កែប្រែទៀតឡើយ ព្រោះធីតាចិត្តដ៏ត្រជាក់ ជាសភាវៈអាចគ្រប់គ្រងពិភពលោក ឲ្យបានសេចក្ដីសុខ សេចក្ដីចំរើន ជោគ មង្គល តេជះ អំណាច ឥស្សរភាព ។ល។ រីឯក្មេងចិត្តដ៏ក្ដៅវិញ ជាសភាវៈពុំមែនជាកត្តានៃសិរី គឺពុំអាចគ្រប់គ្រងពិភពលោក ឲ្យកើតសិរីដូចបំណងព្រះព្រហ្មបរមទេវៈនោះបានឡើយ ។

ហេតុដូច្នោះហើយ បានជាធីតានេះ លោកចាត់ទុកថាជា សិរី ។

---

សួស្ដីជ័យជោគលោកពពែ
ពង្សឆ្នាំមមែពូជទេពតា
តាយកព្រះនាមកិមិត្ថា
បួលរើនរក្សាពិភពមនុស្ស

# ផ្នែកកំណត់ និង ប្រវត្តិការណ៍

## អនិច្ចធម្មនៃព្រះមហាវីរវង្សាចារ្យ

ពិន សាឌុម

ព្រះតេជព្រះគុណព្រះមហាវីរវង្សាចារ្យ ពិន - សាឌុម, រាជាគណៈ ថ្នាក់ត្រី, ជាសមាជិកក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ គង់នៅវត្តឧទ្ទមណីពម សង្កាត់លេខ ៦ ក្រុងភ្នំពេញ. បានទទួលអនិច្ចធម្ម កាលពីថ្ងៃអាទិត្យទី ២២ មករា ១៩៦៧ ដោយរោគាពាធ ក្នុងព្រះជន្ម ៦០ ឆ្នាំ នៅមន្ទីរពេទ្យព្រះកេតុមាលា ។ ពុទ្ធបរិស័ទ បានរៀបចំតំកល់ព្រះសពនេះយ៉ាងសមរម្យថ្កុំថ្កើង តាមប្រពៃណី នៅវត្តឧទ្ទមណីពម ហើយធ្វើបុណ្យទក្ខិណានុប្បទាន ឧទ្ទិសកុសលចំពោះព្រះសព រៀងរាល់ថ្ងៃ ក្រោមព្រះអធិបតីភាពនៃសម្តេចព្រះសង្ឃនាយក, ចាប់តាំងពីថ្ងៃចន្ទទី ២៣ ដកប ដល់ថ្ងៃចន្ទទី ៣០ មករា ១៩៦៧ ដែលជាថ្ងៃត្រូវបូជាព្រះសព ។

ពុទ្ធសាសនបណ្ឌិត្យ មានសេចក្តីសោកស្តាយយ៉ាងក្រៃលែង ចំពោះការបាត់បង់ព្រះមហាថេរអង្គនេះ ដែលជា ព្រឹទ្ធសមាជិកមួយអង្គ មានសមត្ថភាពដ៏ខ្ពង់ខ្ពស់ ក្នុងវិស័យព្រះពុទ្ធសាសនា គួរឲ្យសរសើរ ក្នុងចំណោមព្រឹទ្ធសមាជិកគេចបញ្ជិកទាំងឡាយ នៃក្រុមជំនុំព្រះត្រៃបិដក ។

ក្នុងថ្ងៃចន្ទទី ៣០ មករា ១៩៦៧ ពេលម៉ោង ២ កន្លះរសៀល

គណៈកម្មការចាត់ការបុណ្យ ព្រមទាំងពុទ្ធបរិស័ទទាំងឡាយ ទាំងបព្វជិត ទាំងគ្រហស្ថ បានរៀបចំពិធីដង្ហែព្រះសពជាក្បួនផ្លូវការ យ៉ាងឱឡារិក អធិកអធម ចេញពីវត្តទួនមណីកមទៅតាមវិថីបុធរាស, វិថីព្រះសុរាម្រឹត. មហាវិថីព្រះនរោត្តម ទៅចួបនឹងវិថីសុធារសវិញ បត់ចូលទៅកាន់ឈាបនដ្ឋាន ដែលសង់ទេវនាវិចិត្រជារបៀបមណ្ឌប នៅមុខព្រះវិហារវត្តទួនមណីកម ។

ពិធីបូជាព្រះសពនេះ បានធ្វើឡើងក្រោមព្រះរាជាធិបតីភាពនៃអ្នកអង្គម្ចាស់ នរោត្តម-កន្ថុល អគ្គនាយកក្រសួងនានាក្នុងបរមរាជវាំង ជាព្រះរាជតំណាងនៃសម្តេចព្រះមហាក្សត្រិយានី ជាអម្ចាស់ជីវិតលើត្បូង ដោយមានសមាជិកសភាទាំងពីរ, សមាជិកគណៈរដ្ឋមន្ត្រី មួយរបអន្ទើដោយមន្ត្រីអ្នករាជការជាច្រើន បានចូលរួមក្នុងពិធីនេះផង ។ ផ្នែកខាងព្រះសង្ឃ, មានសម្តេចព្រះសុធម្មាធិបតី ទេព-លឿង ព្រះសង្ឃនាយកគណៈធម្មយុត្តិកនិកាយ, សម្តេចព្រះពោធិវង្ស ហួត-តាត ជាព្រះរាជតំណាងនៃសម្តេចព្រះមហាសុមេធាធិបតីព្រះសង្ឃរាជគណៈមហានិកាយ ព្រមទាំងព្រះសង្ឃរាជាគណៈ ឋានានុក្រម ភិក្ខុ-សាមណេរទាំងឡាយ ។

មុននឹងបូជាព្រះសព, សហជីវិន គុយ-ពៅ អនុរដ្ឋលេខាធិការក្រសួងធម្មការ បានថ្លែងសុន្ទរកថា និងជីវប្រវត្តិនៃព្រះមហាវិរវង្សពាង្យ រ៉ឹន-សាធុម ។ បន្ទាប់មក, មានសុន្ទរកថាតំណាងសម្តេចព្រះសង្ឃនាយក ។ ឯសុន្ទរកថា ទាំងពីរ យើងសូមចុះផ្សាយដូចតទៅនេះ ៖

## សុន្ទរកថា

ព្រះសមុហ៍ពុទ្ធាចារ្យ ពុង - ប៊ុណ្ណា ជាតំណាងសម្តេច
ព្រះសុខុមាធិបតីព្រះសង្ឃនាយក ព្រះនាមគន្ធោ ទេក - លឿង

សូមទូលព្រះពុទ្ធដីការ ព្រះករុណាគ្រប់ព្រះអង្គ

សូមថ្វាយព្រះពរ សម្តេច - ទ្រង់ - ឯកឧត្តម - លោកជំទាវ

អស់លោក-អ្នកសប្បុរសទាំងឡាយ

សូមពានជ្រាប - សូមទ្រង់ជ្រាប - សូមជ្រាប ៗ

ខ្ញុំព្រះករុណា អាត្មាភាព សូមអភ័យទោសអំពីសំណាក់ព្រះតេជព្រះគុណ ព្រះករុណាគ្រប់ព្រះអង្គ – ទ្រង់ – ឯកឧត្តម លោកជំទាវ-អស់លោកអ្នកទាំងឡាយ ដ្បិតពេលនេះ ខ្ញុំព្រះករុណា អាត្មាភាព បានទទួលព្រះបញ្ជាពីសម្តេចព្រះសង្ឃនាយក ឲ្យថ្លែងសុន្ទរកថា ជំនួសព្រះអង្គ ដូចមានសេចក្តីដើមទាំងស្រុងតទៅ :

## សុន្ទរកថា

– សូមពិតព្រះថេរានុថេរៈ គ្រប់ព្រះអង្គ មានសម្តេចព្រះពោធិវង្ស ជាដើម ៗ

– សូមថ្វាយព្រះពរ អ្នកអង្គម្ចាស់ព្រះរាជតំណាងនៃសម្ដេចព្រះមហាក្សត្រិយានី ជាម្ចាស់ជីវិត ព្រះអគ្គពុទ្ធសាសនូបត្ថម្ភក៍

– សូមថ្វាយព្រះពរ សម្ដេចព្រះរាជកនិដ្ឋារស្មីសោភ័ណ និងព្រះរាជវង្សានុវង្ស

– សូមចំរើនពរ ឯកឧត្ដម លោកជំទាវ និងអស់លោក-អ្នក ពុទ្ធបរិស័ទទាំងឡាយ

សូមទ្រង់ជ្រាប - សូមជ្រាប ។

ក្នុងនាមនៃសម្ដេចព្រះសង្ឃនាយក ក្នុងនាមនៃគណៈកម្មការវត្ត និងក្នុងនាមនៃសិស្សានុសិស្ស ក្រុមគ្រួសារញាតិមិត្តនៃសព ជាបឋមខ្ញុំព្រះករុណា អាត្មាភាព សូមថ្លែងអំណរព្រះមហាករុណាធិគុណ យ៉ាងជ្រាលជ្រៅបំផុតចំពោះសម្ដេចព្រះមហាក្សត្រិយានីជាអម្ចាស់ជីវិត ដែលព្រះអង្គសព្វព្រះរាជហឫទ័យ ចាត់ព្រះរាជតំណាង យាងមកជាព្រះរាជាធិបតីក្នុងឱកាសនេះ ព្រមទាំងព្រះគុណដែលព្រះអង្គទ្រង់បានចំណាយព្រះរាជទ្រព្យយ៉ាងច្រើនលើសលុប ក្នុងការព្យាបាលពេតព្រះមហាវិរវង្សាចារ្យ ក៉ង់-សាឌុម តាំងពីលោកមានអាពាធ រហូតដល់ថ្ងៃនិច្ចកម្ម ករម្សៀតែពិធីបូជាសពព្រះមហាវិរវង្សាចារ្យ ក៉ង់ - សាឌុម ដែលបានប្រព្រឹត្តទៅ យ៉ាងឧឡារិក ក្នុងឱកាសនេះ ក៏សុទ្ធតែឋិតនៅក្រោមព្រះរាជូបត្ថម្ភ នៃសម្ដេចជាអម្ចាស់ជីវិតទាំងអស់ ។

— ចំពោះព្រះករុណាធិគុណដ៏មហិមានេះ ធ្វើឲ្យអាត្មាភាពនិងពុទ្ធបរិស័ទ សិស្សានុសិស្ស ក្រុមគ្រួសារញាតិមិត្តទាំងអស់ មានសេចក្តីរំភើបចិត្តរកទីបំផុតគ្មាន ហើយសូមកំណត់ចាំទុកក្នុងចិត្តឥតភ្លេចដរាបអស់មួយជីវិត ។

បពិត្រព្រះករុណាថ្លៃវិសេស អាត្មាភាពសូមព្រះរាជានុញ្ញាត ព្រះបរមរាជឱកាស ថ្វាយអំណរព្រះមហាករុណាធិគុណចំពោះសម្តេចជាអម្ចាស់ ព្រមទាំងទ្រង់ ឯកឧត្តម លោកជំទាវ លោកស្រី និងអស់លោក—អ្នកទាំងឡាយ ដែលបានចំណាយព្រះរាជទ្រព្យ ព្រមទាំងកម្លាំងកាយ, កម្លាំងចិត្ត ក្នុងការព្យាបាលរោគ ព្រះមហាវីរវង្សាចារ្យ ហ៊ង់ - សាឌុម ក្តី ក្នុងការចាត់ចែងបូជាសពក្តី និងសូមថ្លែងអំណរគុណ ចំពោះព្រះរាជរដ្ឋាភិបាល មានក្រសួងធម្មការ និង ពុទ្ធសាស.នបណ្ឌិត្យ; រាជការក្រុង និងក្រុមព្រះបរមរាជវាំងជាដើម ដែលមានចិត្តជ្រះថ្លា ជួយរៀបចំក្នុងពិធីបុណ្យសពនេះយ៉ាងក្រៃលែង ។

ព្រះមហាវីរវង្សាចារ្យ ! ពិតមែនតែលោកបានអនិច្ចធម្មលះលោកនេះ ទៅកាន់បរលោកហើយក៏ដោយ តែគុណសម្បត្តិ និងបរិយាសម្បត្តិរបស់លោកទាំងអស់ ទ្រង់ព្រះករុណាថ្លៃវិសេសក្តី ពួកពុទ្ធបរិស័ទទាំងឡាយក្តី នៅនឹករលឹកឃើញជានិច្ច ឥតភ្លេចឡើយ ។

ចំពោះពាក្យពេចន៍ ដ៏ប្រកបដោយគតិបណ្ឌិតទាំងប៉ុន្មានរបស់

លោក គ្រូសិស្សានុសិស្ស និងញាតិមិត្តនៅចាំជាប់ក្នុងចិត្ត ហើយនិង ប្រតិបត្តិតាមតទៅ ។

នៅទីអវសាននេះ ខ្ញុំព្រះករុណា អាត្មាភាព សូមលើកបុញ្ញរាសី ដែលកើតមានឡើងអំពីកិច្ចខ្វល់ខ្វាយគ្រប់យ៉ាង ក្នុងពិធីបុណ្យបូជាសពនេះ ថ្វាយជាព្រះរាជកុសល ចំពោះសម្តេចព្រះមហាក្សត្រិយានីជាអម្ចាស់ជីវិត និងសម្តេចព្រះប្រមុខរដ្ឋ សូមព្រះអង្គមានព្រះសុខភាពបរិបូណ៌ មាន ព្រះជន្មយឺនយូរ ប្រកបដោយតេជៈបារមី ឈ្នះអស់មារសត្រូវគ្រប់ ទិសទី ដើម្បីបានជាម្លប់ដ៏ត្រជាក់ នៃពុទ្ធសាសនិក និង ប្រជាពលករ ក្នុងកម្ពុជរដ្ឋទាំងមូលរៀងទៅ ។

មួយចំណែកទៀត សូមថ្វាយព្រះរាជកុសលចំពោះសម្តេចព្រះរាជកនិដ្ឋា រស្មីសោភ័ណ ទ្រង់ ឯកឧត្តម លោកជំទាវ លោកស្រី អស់លោក-អ្នកពុទ្ធបរិស័ទទាំងឡាយ សូមទ្រង់បានប្រកប និងបានប្រកបដោយ ពុទ្ធពរ ៤ ប្រការ គឺ: អាយុ, វណ្ណ, សុខ, ពល កុំបីអាក់ ខានឡើយ ។

សូមថ្វាយព្រះពរ សូមចំរើនពរ

# សុន្ទរកថា

សហជីវិន គុយ-ពៅ អនុរដ្ឋលេខាធិការ
ក្រសួងធម្មការ និង សាសនសិក្សាធិការ

សូមព្រះរាជទានក្រាបបង្គំទូល អ្នកអង្គម្ចាស់ព្រះរាជតំណាង នៃ សម្តេចព្រះមហាក្សត្រិយានី ជាអម្ចាស់ជីវិតលើត្បូង ជាព្រះអគ្គពុទ្ធសាសនូបត្ថម្ភក៍

សូមទ្រង់ជ្រាប ។

ក្នុងនាមរាជរដ្ឋាភិបាល និង ក្នុងនាមក្រសួងធម្មការ និង សាសនសិក្សាធិការ ព្រមទាំងក្នុងនាមពុទ្ធបរិស័ទទាំងអស់ ដែលបានមកជួបជុំក្នុងពិធីបូជាសព ព្រះតេជព្រះគុណព្រះមហាវីរវង្សាចារ្យ ហ៊ិង-សាខុម រាជាគណៈថ្នាក់ទី ៣ នេះ, ទូលព្រះបង្គំជាខ្ញុំ សូមថ្វាយនូវសេចក្តីគោរពស្វាមីភក្តិយ៉ាងជ្រាលជ្រៅបំផុត ចំពោះព្រះអង្គ ព្រះរាជតំណាង ដែលស្តេចយាងមក ជាព្រះរាជាធិបតីខ្ពង់ខ្ពស់ក្នុងពិធីនេះ ។

ព្រះរាជវត្តមាននៃព្រះអង្គ ព្រះរាជតំណាង „ សម្តេចព្រះមហាក្សត្រិយានី ជាអម្ចាស់ជីវិតលើត្បូង " នៅពេលនេះ, មិនត្រឹមតែញុំាងពិធីបុណ្យឲ្យថ្កើងរុងរឿងយ៉ាងគ្រប់គ្រាន់ប៉ុណ្ណោះទេ, ថែមទាំងជាសក្ខីភាពមួយប្រសើរបំផុត ចំពោះព្រះពុទ្ធសាសនា ដែលបង្ហាប់តែបានទទួលសេចក្តីឧបត្ថម្ភយ៉ាងសកម្ម និងយ៉ាងមេត្តាប្រោសប្រណីបំផុត អំពីសំ-

ណាក់ព្រះរាជបល្ល័ង្ក តាំងពីបុរាណកាលមក ។

សូមទ្រង់ព្រះមេត្តាប្រោស

ព្រះសពព្រះមហាវីរវង្សាចារ្យ ហ៊ិង-សា ឌុម នេះ ធ្លាប់បានទទួលឧបត្ថម្ភពិសេស ពីសម្ដេចព្រះមហាក្សត្រិយានី ជាអម្ចាស់ជីវិតលើត្បូង តាំងតែកាលគង់ព្រះជន្មនៅ រហូតដល់អនិច្ចធម្ម ចាកលោកនេះទៅ, លុះដល់វេលារំលាយព្រះសពទៀត សម្ដេចជាអម្ចាស់ទ្រង់សព្វព្រះរាជហឫទ·ទ័យ ចាត់ព្រះអង្គព្រះរាជតំណាង ស្ដេចយាងមកជាព្រះរាជាធិបតីទៀត ។

សូមទ្រង់ព្រះមេត្តាប្រោស

ទូលព្រះបង្គំជាខ្ញុំ សូមព្រះរាជានុញ្ញាត ដើម្បីថ្លែងក្នុងពេលនេះនូវអំណរព្រះគុណ-អំណរគុណចំពោះសម្ដេច ទ្រង់ ឯកឧត្តម និង សហជីវិន-សហជីវិនីទាំងអស់ ដែលទ្រង់ស្ដេចយាងនិងអញ្ជើញមករួមក្នុងពិធីបុណ្យ ដែលជាការគោរព ជាចុងក្រោយបំផុតចំពោះព្រះសពនេះ និងជាការបានអនុមោទនា យកកុសលមគ្គផលផង ជាការហែហមព្រះរាជដំណើរ និងញ៉ាំងពិធីបុណ្យនេះ ឲ្យបានរុងរឿងផង ។

ឱកាសនេះ ទូលព្រះបង្គំជាខ្ញុំ ខ្ញុំបាទ សូមព្រះរាជានុញ្ញាត សូមអនុញ្ញាតថ្លែងរៀបរាប់អំពីព្រះជីវប្រវត្តិ និង អំពីកិត្តិគុណនៃព្រះសពដែលលោកបានបំពេញមកតាំងពីមានព្រះជន្មនៅឡើយ ។

ព្រះតេជព្រះគុណព្រះមហាវីរវង្សាចារ្យតិរស្សមេ ហ៊ិង·សា ឌុម

ប្រសូតពីថ្ងៃ ច័ន្ទ ៨ កើត ខែអាសាធ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៤៤៧ គ.ស. ១៩០៤ នៅសង្កាត់កំពង់ហាស់ ស្រុកឧត្តុង្គ ខេត្តកំពង់ស្ពឺ ។ បិតានាម សៀង មាតានាម អ៊ុច ជាអ្នកតំណពូជពង្ស អំពីឧកញ៉ា ភជមន្ត្រីនាម ស៊ុំ និងឧកញ៉ាសុមេធាសិរីនាម សួស្តិ៍ ជាមន្ត្រីជាន់ខ្ពស់សម័យរាជកំពង់ឧត្តុង្គមានជ័យ ។ កាលពីអាយុ ៧ ឆ្នាំ កុមារ ហ៊ង់-សាឌុម បានចូលទៅរៀនអក្សរខ្មែរ ក្នុងសំណាក់ព្រះវិនយរក្ខិត ប៉ាត ចៅអធិការវត្តព្រះសុគន្ធមានបុណ្យ (ឧត្តុង្គ) ។ លុះដល់ជន្មាយុបាន ១៤ ឆ្នាំ បានចូលបួសជាសាមណេរ ដោយមានព្រះវិមលធម្មព្រះនាម ម៉ា ជាឧបជ្ឈាយ៍ ហើយនៅសិក្សាធម្មវិន័យ ក្នុងទីនោះអស់ពេល ២ ឆ្នាំ រួចហើយសាមណេរ ហ៊ង់-សាឌុម ក៏លាលោកគ្រូឧបជ្ឈាយ៍ មកបន្តការសិក្សាអក្ខរាបាលី នៅក្នុងសំណាក់ព្រះញាណ វិរិយៈ ព្រះនាម ឡុង ចៅអធិការវត្តឧណ្ណាលោម ក្រុងភ្នំពេញ ។ លុះព្រះជន្មគម្រប់ ២១ ឆ្នាំ ក៏បានបំពេញឧបសម្បទ ជាភិក្ខុ ដោយមានព្រះញាណវិរិយៈ ឡុង ជាឧបជ្ឈាយ៍ មានព្រះគន្ធរេ ជាន់ ជាឧបសម្បទាចារ្យ ។ ព្រះជន្ម ២៥ ឆ្នាំ លោកបានប្រឡងប្រជែងជាប់ចូលរៀននៅសាលាបាលីជាន់ខ្ពស់អស់រយៈ ៤ ឆ្នាំ ក៏ប្រឡងជាប់សញ្ញាប័ត្រចេញពីសាលានេះ ។

ចំពោះកិច្ចការ ដែលព្រះសពបានបំពេញមក គឺ :

- បានធ្វើជាអាចារ្យបង្រៀនសាលាបាលីរង នៅវត្តទួខមណីកម តាំងពីមានព្រះជន្ម ១៨ ឆ្នាំ ។

- បានធ្វើជាសមាជិកក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ ក្រសួងធម្មការ តាំងពី គ.ស ១៩៣៧ រហូតមកដល់ពេលសុគត ។

- បានធ្វើអធិការគ្រូសាលាបាលីរងក្នុងនាទីខេត្រកំពតនិងតាកែវ ពី គ.ស. ១៩៤៣ ។

- បានធ្វើជាសមាជិកគណៈមេប្រយោគ ប្រឡងសញ្ញាប័ត្រជ្រើសរើស ក្នុងពុទ្ធិកសិក្សាតាំងពី គ.ស. ១៩៤២ ។

- បានចូលជាសមាជិកគណៈកម្មការវប្បធម៌ សម្រាប់ប្រែពាក្យបារាំងមកជាខ្មែរ និងបង្កើតពាក្យថ្មី តាំងពី គ.ស. ១៩៤៦ ។

- បានរួមជាសមាជិកគណៈប្រតិភូខ្មែរ ទៅប្រជុំធ្វើឆដ្ឋសង្គាយនា នៅប្រទេសភូមា កាល គ.ស. ១៩៥៦ ។

- ជាសមាជិកក្រុមជំនុំតែងសៀវភៅធម្មវិន័យពី គ.ស.១៩៤៨ ។

- ជាសមាជិកគណៈកម្មការរៀបចំកម្មវិធីសិក្សា សាលាបាលីជាន់ខ្ពស់ ពី គ.ស. ១៩៥១ ។

- ជាអនុប្រធានគណៈប្រតិភូខ្មែរ រួមប្រជុំសន្និសីទលើកទី ៦ នៃពុទ្ធិកសមាគមពិភពលោក ដែលធ្វើនៅក្រុងភ្នំពេញពី គ.ស.១៩៦១ ។

- ជាសមាជិកទីប្រឹក្សា នៃមន្ទីរសង្ឃពេទ្យព្រះកុសុមៈ ។

— ជាសមាជិកទីប្រឹក្សាផ្នែកសាសនា នៃចលនាកាយឫទ្ធិ សម្ដេចព្រះមហាក្សត្រិយានី ពី គ.ស. ១៩៥៧ ។

និងជាសមាជិកនៃសមាគមខាងពុទ្ធសាសនា បុគ្គល កម្មការផ្សេងៗ ក្នុងការបកប្រែភាសាបាលី បោះពុម្ពផ្សាយធម៌អាថ៌ និងការកសាងនានា ជាច្រើនទៀត ។

បំណែកគុណសម្បត្តិពិសេសរបស់ព្រះសពអង្គនេះគឺ លោកមានសរិយាបថសុភាពរាបសា ជាទីរាប់អាននៃមនុស្សទូទៅគ្រប់មុខ ជាទីគោរពរាប់អាននៃសិស្សគណ ព្រមទាំងឧបាសក-ឧបាសិកាទាំងអស់ ដែលធ្លាប់បានមកប្រស្រ័យជាមួយលោក ។ មិនតែប៉ុណ្ណោះសោត លោកមានប្រាជ្ញាក្នុងការរៀនសូត្រចាប់ចេះចាំ ហើយប៉ុនប៉ងបង្ហាត់បង្រៀនដល់អ្នកដទៃថែមទៀត ។ ព្រះសពបានទទួលគ្រឿងឥស្សរិយយសទី អស្សបុទ្ធិមុនីសោភណ៍ ជាសក្ខីភាពផង ។ សន្តានចិត្តលោកតែងជាប់ជំពាក់ក្នុងការកសាងសប្បុរិសធម៌គ្រប់បែបយ៉ាង ព្រមទាំងឧបត្ថម្ភព្រះពុទ្ធសាសនា គ្មានពេលក្ដេចក្ដាំងថ្ងៃណា ។ រីឯបច្ច័យទាំងឡាយ ដែលកដការបានបរិណាចំពោះព្រះអង្គលោក, លោកតែងយកទៅបំណាយក្នុងកិច្ចការសង្គ្រោះ និង ឧបត្ថម្ភដល់មនុស្សជាតិជានិច្ច មានផ្នែកវប្បធម៌ និងសង្គមកិច្ចជាដើម ឧទាហរណ៍គឺ លោកបានចែងមុនអនិច្ចធម្ម ធ្វើជាបណ្ដាំជាលាយលក្ខណ៍អក្សរ បែងចែកនូវបច្ច័យដែលមានទាំងអស់

៣៧.៤១២៛០០ ឲ្យទៅជាការឧបត្ថម្ភកងការស្ថាបនាផ្សេង ៗ ក្នុងពុទ្ធសីមា និងអគ្គការសង្គ្រោះដទៃទៀត ដូចតទៅនេះគឺ :

១ ឧបត្ថម្ភសាលាពុទ្ធិកបឋមសិក្សាវត្តសាលាគូ (ខេត្ត) ២៧.៥០០៛០០

២– ជីកស្រះខាងត្បូងវត្តសុគន្ធមានបុណ្យ (ខេត្ត) ២៧.៥០០៛០០

៣– ឧបត្ថម្ភបណ្ណាល័យវត្តខ្ទមណីកម . . . . . ៤១.២៥០៛០០

៤– ជួយដល់ក្រុមកាកបាទក្រហមខ្មែរ . . . . ១៣.៧៥០៛០០

៥– ជំនួយចំពោះបរិយត្តិ ក្នុងពុទ្ធសាសនា . . . ២០.០០០៛ ០

៦– ជួយគិលានសង្គ្រោះ-កុមារសង្គ្រោះ . . . . ២០.០០០៛០០

៧– កសាងឈាបនដ្ឋានអនាម័យ . . . . . . ២០.០០០៛០០

៨– ជួយកងការកសាងវិហារថ្មី វត្តខ្ទពណីកម ..២០.០០០៛០០

៩– ជួយសាលាពុទ្ធិកបឋមសិក្សា វត្តខ្ទមណីកម ១៤៧.៨៨៩៛០០

១០– សម្រាប់ធ្វើទក្ខិណានុប្បទាន . . . . ៣៦.៥២៣៛០០

សូមទ្រង់ព្រះមេត្តាប្រោស

តាំងអស់នេះ ជាព្រះសកម្មភាពយ៉ាងចម្លែក ដែលគួរកត់សំគាល់ និង ពុំអាចបំភ្លេចបាន របស់ព្រះសព ។

គតិនេះ ទូលព្រះបង្គំជាខ្ញុំ ខ្ញុំបាទសូមព្រះរាជឱកាស សូមឱកាស ថ្លែងជាអវសាន ចំពោះទៅកាន់ព្រះសពជាទីអាល័យដូចតទៅនេះ :

បពិត្រព្រះសពជាទីគោរព

ព្រះរូបកាយនៃព្រះតេជព្រះគុណ បានបាត់បង់ទៅតាមអនត្តាធម៌ ជាដី ទឹក ភ្លើង ខ្យល់ ទៅហើយ ប៉ុន្តែព្រះនាមគង់នៅជាប់ជានិច្ច ក្នុងសន្តានចិត្តយើងខ្ញុំព្រះករុណា ជាពុទ្ធបរិស័ទគ្រប់ ៗ កាល ៗ យើងខ្ញុំព្រះករុណាពុំភ្លេចទេ នូវកិត្តិគុណពិសេស របស់ព្រះតេជព្រះគុណ កាលគង់ជន្មានៅឡើយ, ព្រះតេជព្រះគុណជាព្រះថេរមួយអង្គ ដែលមានគុណសម្បទ សមត្ថភាព និង វិរិយធម៌ គួរកោតសរសើរពន់ពេក ៗ សូម្បីតែមានរោគាមកញាំញីព្រះកាយហើយក្តី ព្រះតេជព្រះគុណតែងមានថេរដីការឿយ ៗ ថា : « មច្ចុរាជ តើអ្នកមកធ្វើបាបកងកាយយើងដល់ណាទៀត ! ខន្ធ ៥ គឺរូប វេទនា សញ្ញា សង្ខារ និង វិញ្ញាណធ្វើទុក្ខយើងណាស់តើ យើងពុំសុខនឹងអ្នកទេ ! » មិនតែប៉ុណ្ណោះ ពេលណាព្រះរាជគណៈ ក្រុមញាតិ ឬឧបាសក ឧបាសិកាណាមួយ ទៅសាកសួរ ព្រះតេជព្រះគុណតែងតែសម្តែងធម៌ជាប្រៀនប្រដៅ រំលឹកឲ្យស្គាល់នូវអនិច្ចតាធម៌របស់ជីវិតសត្វលោក ជាដរាប ៗ ហេតុនេះហើយបានជានៅពេលដែលព្រះតេជព្រះគុណទទួលអនិច្ចធម្ម គឺទទួលប្រកបដោយភាពស្ងប់ស្ងាត់ជាទីបំផុត នារាត្រីរំលងអធ្រាត្រនៃថ្ងៃ ១៣ កើត ខែមាឃ ត្រូវនឹងថ្ងៃចន្ទ ទី ២៣ មករា ១៩៦៧ ក្រោមព្រះរាជូបត្ថម្ភសម្តេចព្រះមហាក្សត្រិយានីជាអម្ចាស់ជីវិតលើត្បូង ដែលព្រះ

អង្គទ្រង់សព្វព្រះរាជហឫទ័យប្រោសព្រះរាជទាន ព្រះរាជទ្រព្យជាច្រើន ដើម្បីព្យាបាលរោគាពាធនេះ ។ ក្នុងខណៈនេះ យើងខ្ញុំព្រះករុណា សូមឧទ្ទិសកុសលចំពោះវិញ្ញាណក្ខន្ធនៃព្រះសព សូមបានសុគតក្នុងភពថ្មី ប្រកបដោយសុខៈក្សេមក្សាន្តជាតិយោភាព ហើយព្រះកិត្តិនាមព្រះអង្គនៅ តែចារឹកយ៉ាងច្បាស់ក្រឡែត ពុំអាចរលុបបានក្នុងលោកនេះ ដូចពុទ្ធ ភាសិតថា ៖

«រូបំ ជីរតិ មច្ចានំ នាមគោត្តំ ន ជីរតិ» ។

សូមទ្រង់ព្រះករុណាប្រោស

នៅទីបំផុតនេះ ទូលព្រះបង្គំជាខ្ញុំ សូមថ្លែងកតញ្ញុតាជាថ្មីម្តងទៀត ថ្វាយចំពោះព្រះអង្គព្រះរាជតំណាង សូមទ្រង់មេត្តាក្រាបបង្គំទូលថ្វាយ សម្តេចព្រះមហាក្សត្រិយានីជាម្ចាស់ជីវិតលើត្បូង ដែលទ្រង់សព្វព្រះ រាជហឫទ័យ ចាត់ព្រះអង្គមកជាព្រះរាជតំណាង ក្នុងឱកាសបុណ្យឈាប-នកិច្ចដ៏ធំធេងនេះ ហើយទូលព្រះបង្គំជាខ្ញុំទាំងឡាយ សូមលំអុតលំឱន កាយបួងសួងចំពោះគុណានុភាពនៃព្រះរតនត្រ័យ និងវត្ថុស័ក្តិសិទ្ធិទាំង អស់ក្នុងលោក សូមជួយគាំពារអភិបាល រក្សាព្រះសុខភាពព្រះអង្គឱ្យ ក្សាន្តភិរម្យជាអង្វែង ដើម្បីបានជាម្លប់យ៉ាងត្រជាក់ នៃប្រជាជាតិខ្មែរ ទូទៅ ។ មួយបំណែកទៀត សូមឱ្យតេជានុភាព និងផលានិសង្ស ដែលកើតឡើងទាំងប៉ុន្មានក្នុងការកុសលនេះ ផ្សាយថ្វាយចំពោះសម្តេច

ព្រះប្រមុខរដ្ឋ ព្រះអគ្គពុទ្ធសាសនូបត្ថម្ភក៍ ដែលសព្វថ្ងៃ ព្រះអង្គគង់នៅព្យាបាលព្រះរោគ នា ប្រទេសបារាំង សូមព្រះអង្គបានរសះស្បើយយ៉ាងឆាប់រហ័ស ហើយសូមឲ្យមានព្រះកាយពលបរិបូណ៌ ដើម្បីបានជាម្លប់យ៉ាងសុខចំរើនរបស់ជាតិខ្មែរ ជាអង្វែងតទៅ ។

---

# សេចក្ដីរាយការណ៍អំពីសកម្មភាព នៃពុទ្ធសាសនបណ្ឌិត្យ

ពីថ្ងៃទី ១ ដល់ ៣១ មីនា ឆ្នាំ ១៩៦៧

១– ផ្នែករដ្ឋបាល:

## ក– អំពីច្បាប់របស់បុគ្គលិក:

ក្នុងត្រីមាសទី ១ នេះ គិតពីថ្ងៃទី ១ មករា មកដល់ថ្ងៃទី៣១មីនា បុគ្គលិកក្នុងក្របខ័ណ្ឌ និងជាប់កិច្ចសន្យា ទាំងព្រះសង្ឃនិងគ្រហស្ថ បានអនុញ្ញាតឲ្យឈប់សម្រាកប្រចាំឆ្នាំ តាមពាក្យសុំច្បាប់ដោយលាយលក្ខណ៍អក្សររបស់សាមីខ្លួនព្រោះមានធុរៈ ។

## ខ– លិខិតឆ្លើយឆ្លង :

ក្នុងខែមីនានេះ វិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ បានទាក់ទងនិងទទួលលិខិតផ្សេង ៗ ពីគ្រប់អង្គការនានា :

- លិខិតចូលចំនួន ១៤១ ច្បាប់ : ពីលេខបញ្ជី ១៦០ដល់ ៣០១
- លិខិតចេញចំនួន ១៤៤ ច្បាប់: ពីលេខបញ្ជី ១៦០ ដល់ ៤៨.

## គ– ផ្នែកទស្សនាវដ្ដីកម្ពុជសុរិយា :

តាមសេចក្ដីសម្រេចនៃការប្រជុំការងាររបស់ក្រសួងពីថ្ងៃទី ២៧ មីនា ១៩៦៧ អ្នកទទួលខុសត្រូវខាងការផ្សាយនៃទស្សនាវដ្ដី កម្ពុជសុរិយា ត្រូវប្រគល់ទៅសហ. លី ឆាមគេង ៗ ដោយត្រូវប្រគេនព្រះមុនីកោសល

ស្ទួរ-ហាយ ជួយខាងផ្នែកលម្អិតថា និងជូនសហាជីវិនទីពេជ សល់ ជួយខាង ចំនៀមទម្លាប់ តាមដីកាពាក់លេខ ៤៨១ ចុះថ្ងៃ ៣១-៣-៦៧ ។

២- ផ្នែកខាងសម្ភារៈ :

ដោយអ្នកអានខ្លះនិងអ្នកស្រាវជ្រាវបេះកែធ្វើឱ្យបាត់ ឬប្រឡាក់ខ្ទង់ នៃស្នាដៃឈ្មោះអ្នកនិពន្ធ ឈ្មោះសៀវភៅនានានៅក្នុង របៀបទុកឯក-សារនៃបណ្ណាល័យ នាយកដ្ឋានបានឱ្យនាយការិយាល័យគណនេយ្យ និងនាយបណ្ណារក្សរៀបចំធ្វើដែកចំពុះភ្ជាប់ស្លាកទាំងឡាយក្នុងទូ កុំឱ្យ អ្នកអានទាញចេញមកក្រៅបាន ។ កិច្ចការនេះធ្វើសព្វគ្រប់បានចំនួន ទូ ៦ ហើយ ។

ក្រៅពីនេះ សៀវភៅដែលចាស់ ៗ ឬរហែកក្របនោះ នាយក-ដ្ឋានអនុញ្ញាតឱ្យបណ្ណាល័យចងក្របឡើងវិញ បានចប់សព្វគ្រប់ចំនួន ១៩០ ក្បាល តាំងខាតតូច-ធំរួមគ្នា ។

៣- ផ្នែកបោះពុម្ពផ្សាយ :

សៀវភៅដែលបានអនុញ្ញាតបោះពុម្ពផ្សាយពីខែកុម្ភៈ ចំនួន ១២ មុខ ស្ទើរបោះពុម្ពស្រេចបាច់ហើយ បកមកប្រគល់ជូនឃ្លាំងចំនួន ៨ មុខហើយ គឺ គិហិបដិបត្តិ រឿងទុំទាវ កិច្ចប្រជុំអាក្ខបាលី រឿងមួយពាន់មួយ យប់ភាគ ១៦ ១៧-១៨-១៩ និង សត្តុបត្តិខាងសបត្តិ ។

៤- ផ្នែកចំណូលចំណាយ :

## ក- ផ្នែកចំណូល :

ពីថ្ងៃទី ១ ដល់ ៣១ មីនានេះ ចំណូលពីការលក់សៀវភៅផ្សេងៗ ឡើងដល់ ២២០.៦៧ រៀល បើគិតសរុបពីដើមខែមករាមក ចំណូលមានដល់ ៥២៨.២៥២រៀល ហើយ ។ គិតទៅគ្រាន់តែក្នុងខែមីនានេះ ចំណូលលើសពីខែ កុម្ភៈចំនួន ២៧.៣២៨រៀល ។

## ខ- ផ្នែកចំណាយ :

ចំណាយខាងគ្រឿងទី គិតទាំងការបោះពុម្ពទៅក្រសួងឧបត្ថម្ភការផង ក្នុងខែមីនាចំនួន ៨៨៣,១០០ ។

បើធៀបទៅនឹងចំណាយខែកុម្ភៈ ខែមីនានេះចាយលើសច្រើនជាង ៩៩ រៀល ។

សរុបចំណាយខាងគ្រឿង ១ ត្រីមាសនេះ គឺពីថ្ងៃ ១ មករា ដល់ ៣១ មីនា អស់ចំនួន ២៦៧៩ រៀលហើយ ។ នៅពុំទាន់ឃើញថ្ងៃចំណាយខាងទឹក ដែលត្រូវសងគេសម្រាប់ ១ ត្រីមាសនេះនៅឡើយទេ ។

## ២- ផ្នែកការងារក្នុងការិយាល័យនានា :

### ក- បណ្ណាល័យ

- ចំនួនអ្នកចូលមកអាន ក្នុងខែមីនា មាន ៣០៧ នាក់ ។
- ចំនួនអ្នកខ្ចីសៀវភៅផ្សេងៗ យកទៅស្រាវជ្រាវតាមនៅផ្ទះ ក្នុងខែមីនា ១៤៧ នាក់ ។

សូមបញ្ជាក់ថា ក្នុងខែនេះ មានអ្នកប្រាជ្ញ អ្នកស្រាវជ្រាវ និងអ្នក

សិក្ខាបរទេសជាច្រើនរូបបានមកពិនិត្យរៀបចំឯកសារ ជាស្នាដៃនិពន្ធរបស់ខ្លួននៅបណ្ណាល័យ គឺមាននិស្សិតឧត្តមសិក្សា ៦ រូប សាស្ត្រាចារ្យស្ត្រី ៣ រូប អ្នកបច្ចេកទេសនៃសាលាបច្ចេកទេស ១ រូប និងចិត្រករ ១ រូប ។ ទាំងអស់គ្នានេះជាជាតិសូវៀត ។

ក្នុង ១ ត្រីមាសនេះ បណ្ណាល័យបានទទួលឯកសារជាទស្សនាវដ្តី សារពត៌មានអំពីស្ថានទូតនិងអង្គការនានាបានចំនួន ៦៣ ក្បាល ។

ដើម្បីរក្សាទុកជាឯកសារ ក្រសួងបានអនុញ្ញាតឲ្យការិយាល័យគណនេយ្យជាវសារពត៌មានភាសាជាតិក្នុងប្រទេស ដើម្បីយកបកចងទុក ដូចជាខ្មែរឯករាជ្យ មាតុភូមិ សុជីវធម៌ សុវណ្ណភូមិ សុរិយា បន្ថែមទៅលើអ្នកជាតិនិយម ឡឺសង្គម កម្ពុជា ឡាឌូវែលដេប៉ែស្ស៊ី និងកំពែងប្រែសឺ ព្រឹត្តិប័ត្រសារពត៌មានខ្មែរ និងរាជកិច្ចបាលតាំងខ្មែរ តាំងបារាំង ។

## ១_ ការិយាល័យទំនៀមទម្លាប់ :

ក្នុងត្រីមាសនេះការិយាល័យបានទទួលឯកសារសម្រាប់បញ្ចូលផ្នែកទំនៀមទម្លាប់ចំនួន ៩ រឿង ។ រួមឯកសារបានទទួលក្នុង ១ ត្រីមាសនេះមាន ៤៥ ឯកសារ ។

## គ_ សកម្មភាពទូទៅ:

ទី ១ - ក្នុងត្រីមាសនេះ ក្រសួងបាន [illegible] ប្រូបរ៉ូក

ផ្សាយវប្បធម៌ [illegible]

- សៀវភៅល្បែងប្រជាប្រិយ ចំនួន ៣៥ ក្បាលទៅទីចាត់ការគរុកោសល្យនៃក្រសួងអប់រំជាតិ ដើម្បីផ្សាយដល់គ្រូបង្រៀនអប់រំសិល្បៈ និងទំនៀមទម្លាប់ខ្មែរ

- ទស្សនាវដ្តីកម្ពុជសុរិយា តាំងពីឆ្នាំចាស់ៗ (មិនគ្រប់តាមលេខរៀងទេ) ចំនួន ២១៧ ក្បាល សម្រាប់អគ្គស្នងការដ្ឋាននៃយុវជនរាជសង្គមនិយមខ្មែរ ។

- សៀវភៅធម៌អាថ៌ជូនចំពោះសហជីវិនអនុរដ្ឋលេខាធិការក្រសួងធម្មការចំនួន ៨១៥ ក្បាល (ពីថ្ងៃ ៤ កុម្ភៈ ៤៦៥ ក្បាល និងថ្ងៃ ២៣ មីនា ៣៥០ ក្បាល) សម្រាប់ផ្សាយដល់វត្តនានា ។

ទី ២ - ក្នុងខែមីនានេះ បានប្រជុំការងារចំនួន ២ លើក „ គឺថ្ងៃទី ១ មីនា មួយ និងថ្ងៃទី ២៧ មីនាមួយ „

ទី ៣ - បានបញ្ជូនសំណុំរឿងបណ្តឹងចោទប្រកាន់អ្នកនិពន្ធ និងបណ្ណាគារ ដែលលួចបោះពុម្ពឯកសារសៀវភៅជាទ្រព្យសម្បត្តិរាជការចំនួន ១៥ មុខ „លិខិតលេខ ៤៧៩ ចុះថ្ងៃ ២៩ ៣-៦៧ និងលេខ ៤៨៥ ចុះថ្ងៃ ១ ៤ ៦៧„ ។

ភ្នំពេញ ថ្ងៃទី ៦ មីនា ១៩៦៧

នាយករដ្ឋបាល

# ពរសព្ទសាធុការ

ព្រះរាជាណាចក្រកម្ពុជា
លេខ ៨៩

វត្តឧណ្ណាលោម ក្រុងភ្នំពេញ

## ក្រសួងសម្តេចព្រះសង្ឃនាយកគណៈធម្មយុត្តិកនិកាយ

ថ្ងៃ ៥ ៤ ៦ ឆ្នាំមមីអដ្ឋស័ក ព.ស ២៥០៩

គឺថ្ងៃទី ១៣ ខែមេសា គ.ស. ១៩៦៧

សូមចំរើនពរមកលោកនាយក វិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ

សូមជ្រាប ។

អាត្មាភាព បានទទួលកាលពីថ្ងៃ ព្រហស្បតិ៍ ទី ១៣ មេសា ១៩៦៧ នូវលិខិតប្រគេនពររបស់លោក លេខ ៥០៤ ព.ប. ដែលលោកព្រមទាំងសហការីរបស់លោក បានប្រសិទ្ធិពរប្រគេនអាត្មាភាព ក្នុងឱកាសចូលឆ្នាំថ្មីនេះ ។

ចំពោះពរសព្ទសាធុការ ដែលលោកប្រសិទ្ធិប្រគេនអាត្មានេះបញ្ជាក់ឲ្យឃើញនូវសមានចិត្តដ៏ស្មោះសររបស់លោកចំពោះរូបអាត្មាភាព ។

ក្នុងនាមនៃព្រះសង្ឃ ខាងគណៈធម្មយុត្តទាំងមូល និងក្នុងនាមផ្ទាល់នៃអាត្មាភាព សូមប្រសិទ្ធិពរជ័យសិរីមង្គលវិបុលសុខ គ្រប់ប្រការជូនលោកនិងសហការីរបស់លោក ព្រមទាំងគ្រួសារ និងសូមបួងសួងដល់

គុណព្រះរតនត្រ័យនិងវត្ថុសក្តិសិទ្ធិក្នុងលោក ព្រមទាំងទេវតាដែលមានមហិទ្ធិឫទ្ធិ មានទេវតាឆ្នាំថ្មីនេះជាដើម សូមជួយទ្រទ្រង់លោក និងសហការីរបស់លោក ឲ្យបានប្រកបដោយជោគជ័យ ជាទីបំផុតក្នុងការបំរើជាតិតទៅ ។

សូមលោកទទួលនូវសេចក្តីរាប់អានដ៏ស្មោះអំពីអាត្មាភាព ។

សម្តេចព្រះសុធម្មាធិបតីសង្ឃនាយក

ព្រះហស្តលេខា លៀង

ទីស្តីការក្រសួងធម្មការ

អគ្គាធិការដ្ឋាន

នៃ

ពុទ្ធិកសិក្សា

ព្រះរាជអាណាចក្រកម្ពុជា

ភ្នំពេញ ថ្ងៃទី ៨ មេសា ១៩៦៧

លេខ ៤៩ អ.ព.ស.

ចំរើនពរមកលោកនាយករដ្ឋបាលពុទ្ធសាសនបណ្ឌិត្យ

ភ្នំពេញ ។

អាត្មាបានទទួលលិខិតលោក លេខ ៥០៨–ប.ព. ចុះថ្ងៃទី ៧ មេសា ១៩៦៧ ហើយ ។ ក្នុងលិខិតនោះ លោកបានប្រគេនពរជ័យសិរីសួស្តីចំពោះអាត្មា ក្នុងឱកាសចូលឆ្នាំថ្មីនេះ គឺឆ្នាំ មមែនព្វស័ក ព.ស ២៥១០ នេះ ដើម្បីសូមឲ្យអាត្មា មានសុខភាពបរិបូណ៌គ្រប់កាល ។ អាត្មាសូមទទួលពរជ័យ របស់លោកដោយសេចក្តីរីករាយជាទីបំផុត ។

អាត្មាសូមទៀតក្នុងឱកាសដ៏ប្រសើរនេះ ប្រសិទ្ធពុទ្ធពរទាំង ៤ ប្រការ ជូនចំពោះលោក ព្រមទាំងបុគ្គលិកទាំងអស់ ទាំងបព្វជិត-គ្រហស្ថ នៃរដ្ឋបាលនេះ សូមប្រកបដោយសុខសួស្តីជ័យមង្គលគ្រប់ប្រការ កុំបីឃ្លៀតឃ្លាត ហើយសូមឲ្យរដ្ឋបាលនៃពុទ្ធសាសនបណ្ឌិត្យ ក្រោមការគ្រប់គ្រងនៃលោក មានសិរីភាពបវរកាលតរៀងទៅ ។

ព្រះហស្តលេខា: ហួត តាត